ប្រជុំទ្រឹស្តីទស្សនវិជ្ជា និងការល្បងអត្ថាធិប្បាយ

# ប្រតិទិនទស្សនៈ

# ៣៦៥ថ្ងៃ

## ការអាន

មិនអាចធ្វើឲ្យយើងទាំងអស់គ្នា ក្លាយទៅជាអ្នកដឹកនាំបានទេ
តែវាអាចប្រាប់យើងឲ្យដឹងថា តើមនុស្សប្រភេទណាដែលយើងគួរដើរតាមៗ

មនុស្សណាដែលប្រឹងអានច្រើនបំផុត តែបែរជាប្រើប្រាស់ខួរក្បាលគិតតិចតួចបំផុត
ក៏នឹងធ្លាក់ចូលទៅក្នុងទម្លាប់នៃការខ្ជិលគិតៗ

រៀបរៀង និងចងក្រង
ឡាំ លីម

សៀវភៅអេឡិចត្រូនិច

# អារម្ភកថា

សៀវភៅ *"ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ"* ដែលមានទម្រង់ជាលក្ខណៈអេឡិចត្រូនិចនេះ (eBook) គឺជាសៀវភៅបែបទស្សនៈដែលប្រមូលផ្តុំទៅដោយគំនិតរបស់អ្នកប្រាជ្ញជាច្រើនបូកថែមនឹងការពន្យល់ខ្លះចេញពីការយល់ឃើញផ្ទាល់របស់ខ្ញុំផងដែរ។ ក្នុងរយៈពេលកន្លងមក ខ្ញុំបានព្យាយាមអានសៀវភៅជាច្រើនទាំងភាសាខ្មែរនិងភាសាបរទេស ហើយក៏បានឆ្លៀតសរសេរចែករំលែកគំនិតតាមបណ្តាញសង្គមហ្វេសប៊ុកតាំងពីឆ្នាំ២០១៥ ដើម្បីជូនជាគតិពិចារណាដល់យុវជនខ្មែរតាមលទ្ធភាពដែលអាចធ្វើទៅបាន។

ការធ្វើបែបនេះគឺអាចផ្តល់ផលប្រយោជន៍ទាំងខ្ញុំផង និងទាំងកល្យាណមិត្តរបស់ខ្ញុំក្នុងបណ្តាញសង្គមហ្វេសប៊ុកផង។ ថ្វីត្បិតតែយើងមិនស្គាល់គ្នានៅខាងក្រៅក៏ពិតមែន តែខ្ញុំយល់ថាយើងជាបងប្អូនរួមឈាមជ័រសង្គមជាមួយគ្នា ចាប់តាំងពីយើងបានចាប់កំណើតលើទឹកដីខ្មែររបស់យើងមកម្ល៉េះ។

សៀវភៅនេះមិនត្រូវបានដាក់លក់មែន តែមិនមែនមានន័យថាគ្មានតម្លៃ ឬមានតម្លៃទេ ហើយតម្លៃរបស់វាក៏មិនត្រូវបានគិតជាលុយកាក់នោះដែរ។ ប៉ុន្តែតម្លៃរបស់វាគឺស្ថិតនៅលើអ្នកអានជាអ្នកផ្តល់តម្លៃឲ្យដោយខ្លួនឯង។ ដូច្នេះហើយ ទើបខ្ញុំដាក់ឲ្យទាញយកដោយសេរី។ គោលបំណងធំបំផុតរបស់ខ្ញុំ គឺចង់ឲ្យប្រិយមិត្តអ្នកអាន ជាពិសេសយុវជនគួរតែមានឱកាសបានអានទាំងអស់គ្នា មិនថាជាអ្នកមានលុយទិញ ឬអ្នកគ្មានលុយទិញទេ។ សៀភៅនេះមានទម្រង់អេឡិចត្រូនិចដែលជាហេតុនាំឲ្យពិបាកអានបន្តិចក៏ពិតមែន ប៉ុន្តែនៅលើលោកនេះ ពុំមានអ្វីដែលបានមកដោយងាយស្រួលទទេៗនោះឡើយ។

ដោយសារសៀវភៅនេះគឺជាសៀវភៅបែបទស្សនៈ និងការយល់ឃើញ។ ជាទូទៅ ពាក្យថា *"ទស្សនៈនិងការយល់ឃើញ"* គឺតែងស្ថិតនៅចន្លោះកណ្តាលរវាងការពិត និងក្លែងក្លាយ ឬស្ថិតនៅចន្លោះរវាងភាពត្រឹមត្រូវ និងភាពមិនត្រឹមត្រូវ។ ខ្ញុំជឿជាក់ថាសៀវភៅនេះអាចនឹងមានកំហុសឆ្គងតិច ឬច្រើនដោយចេតនា ឬអចេតនា មិនថាជាកំហុសឆ្គងអក្ខរាវិរុទ្ធ

កំហុសទស្សនៈ ឬការបកស្រាយពន្យល់របស់ខ្ញុំផ្ទាល់ទេ។ ប៉ុន្តែបើមានកំហុសឆ្គង ខ្ញុំសូមខន្តីអភ័យទោស ហើយខ្ញុំពេញចិត្តទទួលនូវការរិះគន់បែបស្ថាបនា ឬមិនស្ថាបនាក្តី។

ជាអវសានកថា ខ្ញុំសង្ឃឹមថា ប្រិយមិត្តអ្នកអាននឹងទទួលបានប្រយោជន៍ដើម្បីអាចពង្រីកគំនិតថែមទៀត បន្ទាប់ពីបានអានសៀវភៅនេះ។ ខ្ញុំសូមគោរពជូនពរប្រិយមិត្តអ្នកអានទាំងអស់ មានសុខភាពល្អ និងទទួលបាននូវភាពជោគជ័យ ក្នុងជីវិតតាមលទ្ធភាពនៃការប្រឹងប្រែង។ ខ្ញុំសូមឧទ្ទិសសៀវភៅនេះជូនចំពោះអ្នកនិពន្ធ និងអ្នកប្រាជ្ញខ្មែរគ្រប់រូបព្រមទាំង ឧទ្ទិសចំពោះអ្នកប្រាជ្ញទាំងអស់ ទូទាំងសកលលោកគ្រប់ជំនាន់៕

សៀមរាប, ថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៧

ឡាំ លីម

# របៀបនៃការអានសៀវភៅនេះ

សៀវភៅនេះ គឺជាសៀវភៅបែបទស្សនៈសម្រាប់តែគិតពិចារណាប៉ុណ្ណោះ។ រាល់គំនិតបកស្រាយដែលខ្ញុំបានព្យាយាមពន្យល់ គឺអាចត្រឹមត្រូវ ឬត្រឹមត្រូវខ្លះ និងអាចខុស ឬខុសខ្លះ ឬអាចខុសទាំងស្រុងតែម្តង។ ប៉ុន្តែខ្ញុំសង្ឃឹមថា ខុស ឬត្រូវ នឹងពុំមែនក្លាយទៅជាឧបសគ្គរាំងនូវត្រិះរិះពិចារណា ក្រេបយកចំណេះដឹងរបស់ប្រិយមិត្តអ្នកអានទេ។ ប្រិយមិត្តអ្នកអានអាចប្រើវិធីបន្សុទ្ធចំណេះដឹង តាមរយៈការចាប់យកតែចំណេះដឹងត្រឹមត្រូវ និងចំណេះដឹងល្អ ដែលត្រូវកាលៈទេសៈ ឬត្រូវស្ថានភាពជាក់ស្តែងរបស់ខ្លួន។

ជាទស្សនៈ ខ្ញុំយល់ថាត្រូវ និងខុស ឬល្អនិងអាក្រក់ តែងនៅលាយឡំជាមួយគ្នា តែសំខាន់គឺសមត្ថភាពនៃការមើលឃើញចំណុចល្អ ហើយចាប់យកចំណុចល្អមកប្រើធ្វើជាប្រយោជន៍។ រឿងដែលខ្ញុំបារម្ភជាងគេ

គឺរឿងនយោបាយ និងសាសនា ពីព្រោះ រឿងទាំងពីរនេះតែងក្លាយជានាំងញែកមនុស្សឲ្យមានការស្អប់ស្រទ្បាញ់ ទំនាស់គ្នា និងរើសអើងមនុស្សដូចគ្នា។

បើលោកអ្នកជាសាសនិកជនក្នុងសាសនាណាមួយ ឬមានជំនឿលើនិកាយសាសនាណាមួយ នៅពេលដែលអានសៀវភៅនេះ ប៉ះចំចំណុចដែលប្រឆាំងនឹងគោលជំនឿសាសនារបស់លោកអ្នក គឺសូមមេត្តាកុំយកចិត្តទុកដាក់ ឬកុំប្រតិកម្មអារម្មណ៍ ពីព្រោះជៀសវាងការធ្វើឲ្យអារម្មណ៍លោកអ្នកមិនល្អ ឬល្អក់កករ ប៉ុន្តែសូមត្រឹមតែអានបន្ត ឬរំលងទៅទំព័រផ្សេងទៀត។ បើលោកអ្នកមាននិន្នាការនយោបាយលើបក្សណាមួយ នៅពេលដែលអានប៉ះចំគំនិតដែលប្រឆាំងនឹងនិន្នាការនយោបាយផ្ទាល់របស់លោកអ្នក គឺសូមមេត្តាកុំយកចិត្តទុកដាក់ ឬកុំប្រតិកម្មអារម្មណ៍ ពីព្រោះជៀសវាងការធ្វើឲ្យអារម្មណ៍លោកអ្នកមិនល្អ ឬល្អក់កករ ប៉ុន្តែសូមត្រឹមតែអានបន្ត ឬរំលងទៅទំព័រផ្សេងទៀត។

ក្នុងពេលអានអត្ថបទ ឬអានការបកស្រាយពន្យល់របស់ខ្ញុំ អាចធ្វើឲ្យលោកអ្នកអាចអានយល់ខ្លះ ឬពុំយល់សោះ តែយ៉ាងណាក៏ដោយគួរតែរកឃ្លា ឬប្រយោគដែលខ្លួនអាចយល់បាន ដោយមិនថាមួយឃ្លា ឬពីរឃ្លាទេ ពីព្រោះបើធ្វើបែបនេះ គឺដើម្បីជៀសវាងការអានរំលងទំព័រណាមួយដោយពុំយល់អត្ថន័យអ្វីសោះពីសៀវភៅ។

តាមបទពិសោធន៍ខ្ញុំផ្ទាល់ សៀវភៅខ្លះខ្ញុំចំណាយពេលអានមួយឆ្នាំទើបអាចយល់បាន ពីព្រោះពេលខ្លះខ្ញុំយល់ថា ចំណេះដឹងរបស់ខ្ញុំនៅមានកម្រិតដែលជាបុព្វហេតុមួយ អាចឲ្យខ្ញុំពិបាកយល់នូវអ្វីដែលខ្ញុំមិនធ្លាប់បានយល់ពីមុន។ ប៉ុន្តែឲ្យតែមានការព្យាយាមតាំងចិត្ត មិនថាអត្ថន័យ ឬឃ្លាប្រយោគពិបាកប៉ុនណាទេ គឺគ្រប់យ៉ាងសុទ្ធតែអាចស្វែងយល់បានជានិច្ច។

បើលោកអ្នកយល់ថាមានទស្សនៈខ្លះល្អ ឬគំនិតខ្លះគួរពិចារណា និងមានប្រយោជន៍ លោកអ្នកនាងគួរតែប្រឹងអានម្តងហើយម្តងទៀតដើម្បីជាការចងចាំ និងអាចពង្រីកគំនិតនេះ ឬគំនិតនោះទៅតាមរបៀប

មួយផ្សេងទៀត។ ហើយម្យ៉ាង បើប្រិយមិត្តអ្នកអានអាចយល់គំនិតណាបាន តែចាំមិនបាន គឺយើងចេះតែម្នាក់ឯងទេ តែបើយើងអាចយល់បានហើយចាំបានទៀត ក៏ល្អសម្រាប់ឲ្យយើងអាចយកទៅចែករំលែកគំនិតនេះដល់អ្នកដទៃបានផងដែរ។ ចុងក្រោយ បើប្រិយមិត្តអ្នកអានមិនយល់ស្របនឹងទស្សនៈ ឬការបកស្រាយណាមួយរបស់ខ្ញុំ គឺថាខ្ញុំពេញចិត្តនឹងទទួលការរិះគន់បែបស្ថាបនា រិះគន់ក្នុងបំណងល្អ រិះគន់ក្នុងនាមជាខ្មែរដូចគ្នា។ ប្រិយមិត្តអ្នកអានអាចសរសេរសាអេឡិចត្រូនិចផ្ញើតាមរយៈអ៊ីមែលផ្ទាល់របស់ខ្ញុំ៖ lamlem01@gmail.com ខ្ញុំរីករាយនិងស្វាគម៍ដោយក្តីរាប់អានជានិច្ច៕

សូមអរគុណ និងអរព្រះគុណ!

# មូលវិចារ

ខ្ញុំបានស្គាល់ប្អូន ឡាំ លីម តាមរយៈការចែករំលែកគំនិតទស្សនៈល្អៗក្នុងបណ្តាញសង្គមហ្វេសប៊ុក (Facebook )និងបានជួបជជែកផ្ទាល់មុខពីរដង។ ខ្ញុំមានទឹកចិត្តកោតសរសើរចំពោះ លីម ដែលបានចំណាយពេលយុវវ័យរបស់ខ្លួនអានសៀវភៅ ដែលស្តីអំពីទស្សនវិជ្ជាការអភិវឌ្ឍន៍ខ្លួន និងភាពជាអ្នកដឹកនាំដែលមានសារៈប្រយោជន៍ខ្លាំងសម្រាប់ការលូតលាស់ផ្នែកស្មារតី ការដឹកនាំជីវិតដ៏ត្រឹមត្រូវ និងការបំពេញការងារដោយជោគជ័យ។ បន្ថែមពីនេះ លីម បានដកស្រង់គំនិតល្អៗចេញពីការអានរបស់ខ្លួន ដោយមានការបកស្រាយបន្ថែម លើខ្លឹមសារនៃគតិបណ្ឌិតសំខាន់ៗទាំងនោះ ដើម្បីចែករំលែកដល់យុវជនដទៃបានដឹង និងយល់។ កិច្ចប្រឹងប្រែង ចងក្រងសៀវភៅ *"ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ"* ជាស្នាដៃមួយដ៏ល្អប្រសើរ ក្នុងការរួមចំណែកចែករំលែកគតិល្អៗរបស់អ្នកប្រាជ្ញ ទស្សនវិទូ អ្នកត្រាស់ដឹង

ក្នុងលោក ដើម្បីឲ្យកូនខ្មែរបានក្រេបជញ្ជក់យកគោលគំនិតល្អៗទាំងនេះ ជាមាគ៌ាសម្រាប់ដឹកនាំជីវិតឲ្យមានអត្ថន័យ រីករាយ និងជោគជ័យ។ លក្ខណៈពិសេសនៃសៀវភៅ "ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ" គឺការស្រង់យកគតិបណ្ឌិតវិសេសវិសាលទាំងឡាយ បូកផ្សំនឹងការបកស្រាយខ្លឹមសារបែបសាមញ្ញៗដើម្បីឲ្យអ្នកអានងាយយល់ អំពីអត្ថន័យនៃគោលគំនិតនីមួយៗ។

ខ្ញុំបានអានសៀវភៅ *"ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ"* ជាមួយអារម្មណ៍រីករាយនិងជំរុញចិត្ត ពីព្រោះវាបានផ្តល់ចំណេះដឹងបែបទស្សនៈគំនិតច្រើនបន្ថែមទៀតចំពោះខ្ញុំ។ គតិបណ្ឌិតខ្លះៗ ជាការរំលឹកឡើងវិញ ហើយគតិមួយចំនួនទៀតជាចំណេះដឹងថ្មីសម្រាប់ខ្ញុំ។ ខ្ញុំលើកទឹកចិត្តប្រិយមិត្តអ្នកអាន ជាពិសេសយុវជនចំណាយពេលអានសៀវភៅ *"ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ"* ដើម្បីពង្រឹងថាមពលផ្លូវចិត្ត និងស្វែងរកមាគ៌ាជីវិតដ៏ល្អប្រពៃ៕

បណ្ឌិត សាម អ៉ីន

អ្នកជំនាញពីភាពជាអ្នកដឹកនាំ

ការអភិវឌ្ឍន៍ធនធានមនុស្សដែលជាកម្លាំងស្នូលនៃផលិតភាព សម្រាប់ទ្រទ្រង់ស្ថាប័ននានាដែលជាសរីរាង្គនៃសង្គម ហើយការសិក្សា និងការអភិវឌ្ឍន៍ធនធានបញ្ញា ជាកត្តាចម្បងបំផុតដែលត្រូវយកចិត្តទុកដាក់។ ការសិក្សាគឺជាការវិនិយោគរយៈពេលវែង ទាមទារការខិតខំប្រឹងប្រែងតស៊ូទាំងកម្លាំងកាយ កម្លាំងចិត្តនិងការជំរុញគាំទ្រជានិច្ច ហើយការសិក្សាគ្មានដែនកំណត់នោះឡើយ។ តាមរយៈការរៀននៅតាមសាលាបណ្ណាល័យ ការអានសៀវភៅ ព័ត៌មាននានា ឬការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធើណេតសុទ្ធសឹងតែជាប្រភពធនធាននៃចំណេះដឹង នឹងត្រូវបម្រើដល់កិច្ចការ និងការទទួលខុសរបស់បុគ្គលម្នាក់ៗតាមរយៈកិច្ចការខុសៗគ្នានៅតាមស្ថាប័ននីមួយក្នុងសង្គម។

សង្គមប្រៀបដូចជាដើមឈើមួយដើម ដែលទាមទារនូវការថែទាំស្រោចទឹកដាក់ជី កំចាត់សត្វល្អិត ឬការបំផ្លិចបំផ្លាញណាមួយ។ យ៉ាងណាមិញសង្គមក៏ត្រូវការ ការរួមចំណែកកសាងទ្រទ្រង់តាមរយៈបុគ្គលម្នាក់ៗដែលអាចធានាបានថា ផលិតភាពនៃចំណេះដឹងទាំង

នោះ ត្រូវបានត្រូវបានយកមកបម្រើ ដល់ចលនាអភិវឌ្ឍវិជ្ជមានដល់សង្គម ឲ្យមានសុខសន្តិភាពនិងស្ថេរភាពសម្រាប់ភាពសុខដុមរនារបស់មនុស្ស។

ម្យ៉ាងវិញទៀត មនុស្សម្នាក់ៗគឺជាសមាជិកនៃសង្គម ឯស្ថានប័ននីមួយៗគឺជាសរីរាង្គនៃសង្គម ហើយដើម្បីឲ្យស្ថាប័នទាំងនោះដំណើរការរីកចំរើនទៅបាន លុះត្រាតែមានធនធានមនុស្សជាអ្នកកាច់ចង្កូត ផ្សាភ្ជាប់ជាមួយនឹងការកសាងធនធានមនុស្សត្រូវទាមទារឲ្យមានការសិក្សា ការស្រាវជ្រាវតាមរយៈការអានឲ្យបានច្រើន ជាពិសេសខំខិតបំពេញកែលំអចំណុចខ្វះខាត និងពង្រឹងចំណេះដឹងថ្មីៗបន្ថែមជានិច្ច។ ដូច្នេះហើយបុគ្គលរូបគួរយកចិត្តទុកដាក់ ខិតខំដុសខាត់អភិវឌ្ឍធនធានបញ្ញារបស់ខ្លួនជានិច្ច តាមរយៈការអាន ការស្តាប់ឲ្យបានច្រើន៕

មី ខេមរា

គ្រូបង្រៀន

សៀវភៅ "ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ" ជាសៀវភៅប្រជុំទៅដោយទស្សនៈគតិល្អៗដែលមានអត្ថន័យគួរជាទីទាក់ចិត្ត។ សៀវភៅនេះរៀបរាប់និងអធិប្បាយទស្សនៈវិជ្ជាខ្លីៗ តែខ្លឹមសារល្អ មានន័យជ្រៅ និងងាយយល់ បូករួមនឹងការអធិប្បាយ សមនឹងសាច់រឿងនៃទស្សនៈរបស់អ្នកប្រាជ្ញទាំងឡាយ។

ខ្ញុំសូមណែនាំសៀវភៅនេះ ដល់មិត្តអ្នកអានទាំងអស់ដែលប្រាថ្នាចង់ក្រេបជញ្ជក់នូវចំណេះដឹងផ្នែកទស្សនវិជ្ជា និងចង់បានទស្សនៈនិងគតិបណ្ឌិតល្អៗសម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការគិតបែបទស្សនវិជ្ជា ទាំងក្នុងជីវិតរស់នៅប្រចាំថ្ងៃ និងសម្រាប់ចែករំលែកដល់អ្នកដទៃផង៕

ហង្ស វិទូ

ប្រធានក្រុមអ្នកវិភាគវ័យក្មេង

ខ្ញុំសូមសម្តែងនូវការគោរព កោតសរសើរចំពោះឆន្ទៈ និងការខិតខំប្រឹងប្រែងរបស់លោក ឡាំ លីម ក្នុងការស្រាវជ្រាវ និងសរសេរសៀវភៅ "ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ" នេះឡើង។ ខ្ញុំកោតសរសើរ ពីព្រោះគាត់មានគំនិត និងការខិតខំស្រាវជ្រាវចងក្រងសៀវភៅដ៏មានតម្លៃនេះឡើង។ ខ្ញុំកោតសរសើរ ពីព្រោះគាត់បានសម្រេចចិត្តដាក់ចែកចាយដល់ប្រិយមិត្តអ្នកអានដោយសេរី និងឥតគិតថ្លៃ។

ខ្ញុំប្រាកដយ៉ាងច្បាស់ក្នុងចិត្តថា ទម្រាំបង្កើតបានសៀវភៅដែលមានកម្រាស់រាប់សិបទំព័រនេះឡើង មិនមែនជាការងាយស្រួលឡើយ។ គាត់បានចំណាយពេលវេលាយ៉ាងច្រើនទាំងក្នុងការស្រាវជ្រាវ ពិសេសបានអានសៀវភៅរាប់សិបក្បាល។ គាត់លះបង់ច្រើនក្នុងការបង្កើតវាឡើង និងបានចែកជូនជនរួមជាតិទាំងអស់ដោយឥតគិតថ្លៃ។ ដូចនេះ ដើម្បីឆ្លើយតបនឹងតម្លៃនេះ លោកអ្នកដែលរួមទាំងខ្ញុំមួយដែរ ត្រូវតែអាននិងស្វែងយល់ទៅបានហើយ។

ការណ៍ដែលមានឱកាស ក្នុងការបង្ហាញពីចំណាប់អារម្មណ៍របស់ខ្ញុំចំពោះសៀវភៅមួយក្បាលនេះ ពិតជាកិត្តិយសណាស់។ ប៉ុន្តែការចងក្រងចេញជារូបរាងសៀវភៅអេឡិចត្រូនិក សម្រាប់ប្រិយមិត្តអ្នកអាន រឹតតែជាកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត។ ចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរម្តងទៀត ចំពោះប្អូនប្រុស ឡាំ លីម ហើយក៏សូមសំណូមពរឲ្យប្រិយមិត្តអ្នកអាន បន្តចែករំលែកចំណេះដឹងរបស់ខ្លួន ទោះបីជាតាមវិធីសាស្ត្រណាក៏ដោយ៕

ឈុំ សីហា

សហស្ថាបនិក ក្រុមបោះពុម្ពផ្សាយហាតប៊ុក

សៀវភៅ "ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ" បង្ហាញយ៉ាងស៊ីជម្រៅទៅលើទស្សនៈគតិផ្សេងៗរបស់អ្នកល្បីៗ រាប់ចាប់តាំងពីសកលវិទូរហូតដល់ទស្សនវិទូ នយោបាយវិទូរហូតដល់អ្នកដឹកនាំ និងរាប់ពីសាសនវិទូរហូតដល់គ្រូបង្រៀន។ ក្រៅពីនោះ មានការវិភាគស៊ីជម្រៅប្រកបដោយហេតុ និងផល ផលនិងហេតុ ចេញពីអំពីពិសោធជីវិតរបស់អ្នកនិពន្ធ។

លោក ឡាំ លីម បានបង្ហាញយ៉ាងឥតខ្ចោះទៅលើជីវិតជាក់ស្តែងដែលរូបគាត់បានជួប ហើយលើកទ្រឹស្តីទស្សនៈអ្នកល្បីមកបញ្ជាក់ គួបផ្សំនឹងការគិតយ៉ាងប្រពៃ ទៅលើសីលធម៌ និង សុជីវធម៌ ទាំងការសរសេរ និងនិយាយ ដែលយកមកប្រើបានទាំងជីវិត និងការទំនាក់ទំនង៕

អេង រតនៈ

បរិញ្ញាជំនួញ និងទំនាក់ទំនង

ការសរសេរសៀវភៅ គឺជាកិច្ចការងារដ៏លំបាកមួយសម្រាប់មនុស្សគ្រប់រូប ជាពិសេសសម្រាប់បុគ្គលដែលមិនចូលចិត្តអានសៀវភៅ។ វាគឺជាកិច្ចការងារមួយដ៏សំខាន់ សម្រាប់បុគ្គលដែលមានឆន្ទៈក្នុងការចែករំលែក អភិវឌ្ឍន៍ និងបង្កើនការយកចិត្តទុកដាក់លើអ្វីដែលខ្លួន ក៏ដូចជាមនុស្សផងទាំងពួងមិនធ្លាប់បានគិតអំពី។

សម្រាប់ខ្ញុំ ការសរសេរសៀវភៅបានផ្តល់នូវមូលដ្ឋានគ្រឹះដំបូងដល់កិច្ចការ ការសិក្សារៀនសូត្រ និងអាចធ្វើការវិនិច្ឆ័យដល់ចំណេះដឹងរបស់ខ្លួនចំពោះអ្វីដែលធ្លាប់រៀន ចំពោះកិច្ចការដែលធ្លាប់ធ្វើ និងចំពោះសង្គមដែលកំពុងរស់នៅ ដើម្បីឈានដល់ការអភិវឌ្ឍន៍ប្រាជ្ញាស្មារតីរបស់ខ្លួនបន្ត។ វាក៏ជាការដើម្បីបង្ហាញនូវអ្វីដែលជារបស់ខ្លួនយើង ដើម្បីឆ្លុះបញ្ចាំងដល់ការគិត និងពន្យល់ពីហេតុនិងផលសម្រាប់ជាពុទ្ធិក្នុងការជួយខ្លួនឯងផង និងអ្នកដទៃជុំវិញខ្លួនយើងផងដោយខានពុំបាន។

ដូច្នេះហើយ សៀវភៅ "ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ" របស់លោក ឡាំ លីម ពិតជាមានសារសំខាន់ណាស់ដល់រូបខ្ញុំផ្ទាល់ផង ក៏ដូចជាប្រិយមិត្តអ្នកអានផ្សេងទៀត ក្នុងការទទួលបាននូវគំនិតនិងទស្សនៈសម្រាប់បង្កើនការយល់ដឹងបន្ថែមទៀត។

វាគឺជាលទ្ធផលចេញពីការខិតខំប្រឹងប្រែងទាំងយប់ទាំងថ្ងៃ ដោយគតិបញ្ញាយ៉ាងទូលំទូលាយ របស់អ្នករៀបរៀងចងក្រងជាមួយនឹងថ្ងៃនីមួយៗរបស់ខ្លួនពេញមួយឆ្នាំដែលកម្រនឹងមានបុគ្គលធម្មតាទូទៅអាចធ្វើបានណាស់។ មិនត្រឹមតែប៉ុណ្ណោះ លទ្ធផលមួយនេះក៏ជាការចូលរួមដ៏ធំសម្រាប់ការអភិវឌ្ឍន៍ ការអប់រំធនធានមនុស្សក្នុងប្រទេសកម្ពុជាយើងផងដែរ។

ក្នុងនាមខ្ញុំជាអ្នកអានមួយរូប សូមកោតសរសើរដោយក្តីគោរពចំពោះកិច្ចខិតខំប្រឹងប្រែងនេះ ហើយសូមធ្វើការលើកទឹកចិត្តដល់លោក ឡាំ លីម ក៏ដូចជាបញ្ញវន្តដទៃទៀត ប្រឹងប្រែងធ្វើការចងក្រង និពន្ធ

និងរៀបរៀងជាសៀវភៅផ្សេងៗ តាមលទ្ធភាពនិងចំណេះដឹងដែលខ្លួនមាន ដើម្បីជាប្រយោជន៍ដល់ការបង្កើនសមត្ថភាពខ្លួនឯងផង និងចូលរួមលើកម្ពស់សមត្ថភាពធនធានមនុស្សរបស់ប្រទេសយើងទាំងមូលផងដែរ ៕

រីន សីហា

សហស្ថាបនិក ក្រុមបោះពុម្ពផ្សាយហាតប៊ុក

សៀវភៅ "ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ" ដែលនិពន្ធចងក្រង រៀបរៀងដោយ លោក ឡាំ លីម គឺផលិតឡើងយ៉ាងល្អិតល្អន់ ហើយប្រមូលផ្តុំនូវគំនិត ទស្សនៈ ដោយលើកហេតុផល និងការពន្យល់យ៉ាងល្អក្បោះក្បាយ រៀបរាប់រ៉ាយរ៉ាប់អំពីសំដី និងទស្សនៈរបស់បុគ្គលល្បីៗដែលបានជោគជ័យក្នុងលោកមកបរិយាយ រួមបញ្ចូលទៅក្នុងសៀវភៅនេះតែមួយ ដើម្បីងាយក្នុងការរៀនសូត្របន្ថែម ងាយរកអាន ងាយរកឯកសារ ងាយយល់ ងាយដកពិសោធន៍ បានគ្រប់គ្រាន់។

សៀវភៅ "ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ" នេះដែរ ក៏ជាសៀវភៅល្អ ហើយសំខាន់ណាស់ដែរ ក្នុងការចូលរួមបំផុសលើកទឹកចិត្តយុវជនខ្មែរយើង និងមិត្តអ្នកអានគ្រប់ជាន់ថ្នាក់ឱ្យមានការតស៊ូ ហ៊ានតស៊ូបោះជំហានពុះពារគ្រប់ឧបសគ្គ បុកទម្លុះ ចុះរូងជាផ្លូវ ធ្វើជាស្ពាន ដើម្បីជម្នះឆ្លងកាត់គ្រប់បញ្ហាដែលរារាំងយើងពីខាងមុខ។ សៀវភៅដ៏សំខាន់មានសារៈប្រយោជន៍ដែលមិត្តអ្នកអានកំពុងកាន់នឹងដៃមួយនេះ អាចនិយាយបាន

ថាជាដុំពេជ្រដ៏មានតម្លៃ មានពន្លឺចែងចាំងបំភ្លឺសតិបញ្ញាយ៉ាងប្រពៃដល់ហែសាធុជនទាំងឡាយ ឱ្យរលាស់ខ្លួនរួចផុតអំពីភាពងងឹតអវិជ្ជាបាន ដោយឱ្យយើងចេះគិត ចេះពិចារណា ចេះច្នៃខ្លួនពីដុំដីទៅជាដុំពេជ្រដ៏ថ្លៃថ្លាអស្ចារ្យបាន។

ខ្ញុំសូមអរគុណនូវសណ្តានចិត្តដ៏ប្រសើរប្រកបដោយឆន្ទះខ្ពស់ ក្នុងការចំណាយពេលយ៉ាងយូរ វែងអន្លាយច្រើនខែ ច្រើនឆ្នាំ ដើម្បីធ្វើសៀវភៅនេះឡើង ក្នុងន័យចូលរួមជួយ និងយិតយោងសង្គមខ្មែរដ៏កម្សត់កម្រមួយនេះឱ្យរួចចាកផុតពីអវិជ្ជាទាំងពួង។ សូមជូនពរលោក ឡាំ លីម មានសុខភាពល្អ កម្លាំងខ្លាំងក្លា មានសេចក្តីស្ងប់ល្អ ប្រាជ្ញាវាងវៃថ្កុំថ្កើង សំណាងល្អ ក្នុងជីវិតគ្រប់ពេលវេលា រួមនឹងប្រសិទ្ធិពរសាទរពីព្រះគ្រប់ព្រះអង្គ ដល់លោក ឡាំ លីម ថែមទៀតផង...៕

ជា វ៉ាន់សាន្ត

សៀវភៅ "ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ" ថ្វីត្បិតតែមិនបានបោះពុម្ពផ្សាយសារចរណ៍លើទីផ្សារ តែពុំមែនមានន័យថាជាសៀវភៅឥតគុណភាពទេ ព្រោះខ្ញុំបានអានគ្រប់ទស្សនៈនីមួយៗ មានអត្ថន័យខ្លឹមសារអប់រំល្អសម្រាប់ជាការត្រិះរិះ យកប្រើប្រាស់ក្នុងសង្គម និងនយោបាយជាដើម។ ម្យ៉ាងវិញទៀត សៀវភៅនេះមានបណ្តាទស្សនៈបុគ្គលល្បីៗជាច្រើនរូប មិនថាក្នុងឆាកនយោបាយ ឬអ្នកដឹកនាំនានាជាច្រើនទៀត ដែលមិនគួរនឹងរំលងឡើយ។

ប៉ុន្តែ រាល់កិច្ចការងារ មិនថាតែជាការតែងនិពន្ធ ឬការងារអ្វីផ្សេងទៀតទេ គឺតែមានតែមានកង្វះខាតតិចតួចចៀសមិនផុត។ ដូច្នេះ ក្នុងសៀវភៅនេះក៏មានខ្លះដែរ។ សង្ឃឹមថាអ្នកនិពន្ធ និងអ្នករៀបរៀងក្តី មេត្តាជួយពិនិត្យឡើងវិញ ចៀសវាងធ្វើឱ្យអ្នកអានយល់ច្រឡំ និងដាក់ទោសាដល់យើងជាអ្នកនិពន្ធ។ ការកែតម្រូវកំហុសឆ្គង មិនមែនជារឿងគួរឱ្យអៀនខ្មាសទេ តែគឺជារឿងគួរឱ្យមោទកភាពវិញ ព្រោះយើងអាចដឹង និងរៀងពីចំណុចខ្វះខាតរបស់ខ្លួនឯងបន្ថែម ។

ជាចុងក្រោយនេះ ខ្ញុំបាទសូមថ្លែងនូវអរគុណដល់អ្នកនិពន្ធសៀវភៅ "ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ" លោក ឡាំ លីម ដែលខិតខំចងក្រង និងស្រាវជ្រាវជាសៀវភៅមួយក្បាលដ៏មានតម្លៃសម្រាប់សង្គមជាតិគួរសិក្សារៀនសូត្រ។ សង្ឃឹមថាសៀវភៅមួយក្បាលនេះ ជាបច្ច័យបន្ថែមក្នុងកិច្ចជំរុញដល់ការលើកកម្ពស់ការអានសៀវភៅនៅកម្ពុជាយើងបន្ថែមទៀត៕

មនោ វិជ្ជា

អ្នកនិពន្ធ និងស្រាវជ្រាវ

សៀវភៅកម្រាស់រាប់រយទំព័រនេះ មិនមែនកើតឡើងដោយការស្រមើស្រមៃ ដោយការគ្រាន់តែគិត ដោយការគ្រាន់តែនឹកចង់ធ្វើ... ប៉ុន្តែដំបូងបំផុត វាកើតឡើងដោយទឹកចិត្តដ៏ល្អត្រជាក់ ទឹកចិត្តនៃសេចក្តីស្នេហាដ៏ជ្រាលជ្រៅសម្រាប់មនុស្សនៅក្នុងដែនដីសុវណ្ណភូមិ និងនៅក្នុងទីកន្លែងផ្សេងទៀតនៃពិភពលោកនេះ។ ទឹកចិត្តគាត់ពិតជាល្អប្រសើរណាស់! ព្រោះបើមិនអ៊ីចឹងទេ គាត់នឹងមិនប្រឹងប្រែងអាន ប្រឹងប្រែងគិតរហូតអាចយល់ ហើយក៏ប្រឹងប្រែងដើម្បីសរសេរចេញមកដើម្បីចែករំលែកដោយឥតគិតថ្លៃ។

ជាង៦០០ទំព័រនៃសៀវភៅ យើងមិនអាចអានចប់ក្នុងរយៈពេលមួយថ្ងៃនោះទេ ហើយរឹតតែមិនអាចសរសេរបានក្នុងពេលមួយថ្ងៃ...។ អ្វីដែលកាន់តែមិនអាច គឺខួរក្បាលរបស់យើងមិនអាចបញ្ចេញគំនិតមកច្រើនម្លឹងក្នុងពេលតែមួយថ្ងៃនោះក៏ទេដែរ ជាពិសេសគឺការស្រាវជ្រាវជាច្រើន បើមិនអត់ធ្មត់បើមិនស្រលាញ់យើងមិនអាចធ្វើបានដោយងាយឡើយ។

វាជាការណ៍មួយលំបាក! ហើយខ្ញុំពិតជាយល់ចំពោះទឹកចិត្តនៃការលះបង់នេះ។ ទម្រាំតែសៀវភៅមួយក្បាលនេះប្រសូតជារូបរាងឡើង វាទាមទារឲ្យយើងលះបង់ទឹកចិត្ត កម្លាំងចិត្ត កម្លាំងកាយ និងការតស៊ូ ការអត់ធ្មត់ អត់ងងុយ ញ៉ាំមិនទៀងទាត់...។ មានតែសេចក្ដីស្រលាញ់ប៉ុណ្ណោះ ដែលធ្វើឲ្យមនុស្សចេះលះបង់។ គាត់មានសេចក្ដីស្រលាញ់ចំពោះខ្លួនឯង ចំពោះគ្រួសារ មនុស្សក្បែរខ្លួន សហគមន៍ និងជនរួមឈាមខ្មែរគ្រប់រូប។

ដោយហេតុនេះ ទើបស្នាដៃសៀវភៅអេឡិចត្រូនិច (eBook) មួយក្បាលដែលមានកម្រាស់ដ៏ក្រាស់នេះ អាចលេចចេញជារូបរាងឡើងនៅក្នុងដៃអ្នកអានគ្រប់គ្នា។ សូមអានសៀវភៅនេះដោយក្ដីស្រលាញ់ ហើយទទួលក្រេបយករាល់ចំណេះទាំងឡាយដោយចិត្តរីករាយ ឲ្យដូចកាលដែលគាត់បានចែករំលែកនូវក្ដីស្រលាញ់ និងការលះបង់ចំណែកតូចមួយសម្រាប់មាតុភូមិទាំងមូល៕

សែត ហត្ថា(កូន ចាបមាស)

# សេចក្ដីថ្លែងអំណរគុណ

សៀវភៅ "ប្រតិទិនទស្សនន ៣៦៥ថ្ងៃ" នេះអាចលេចចេញជារូបរាងឡើងមក គឺដោយមានការចូលរួមជួយជ្រោមជ្រែញពីមនុស្សជាច្រើន។ រាល់ការជួយជ្រោមជ្រែងទាំងឡាយ គឺមិនអាចកាត់ថ្លៃបាន ហើយក៏ពុំមែនជាតម្លៃគិតជាលុយកាក់ទេ តែជាតម្លៃរបស់មនុស្សដែលគួរឲ្យគោរពកោតសរសើរជាខ្លាំង។

កញ្ញា សែត ហត្ថា (កូន ចាបមាស)

*ម្ចាស់ស្នាដៃសៀវភៅ "វិញ្ញាសាជីវិត" ដែលបានចំណាយពេលវេលាជួយក្នុងការរចនាសៀវភៅនេះឡើង ព្រមទាំងបានជួយ ពិនិត្យអក្ខរាវិរុទ្ធ និងផ្ដល់មូលវិចារ។*

លោក ជុំ សំណាង

*ដែលបានជួយពិនិត្យអក្ខរាវិរុទ្ធ និងជួយកែពាក្យខុសនៅក្នុងសៀវភៅ។*

លោក មី ខេមរា

*ដែលបានផ្ដល់កិត្តិយសក្នុងការផ្ដល់មូលវិចារ*

លោក ហង្ស វិទូ

*ដែលបានផ្ដល់កិត្តិយសក្នុងការផ្ដល់មូលវិចារ*

លោក ឈុំ សីហា

*ដែលបានផ្ដល់កិត្តិយសក្នុងការផ្ដល់មូលវិចារ*

លោក រឺន សីហា

*ដែលបានផ្ដល់កិត្តិយសក្នុងការផ្ដល់មូលវិចារ*

លោក បណ្ឌិត សាម អ៊ីន

*ដែលផ្ដល់កិត្តិយសក្នុងការផ្ដល់មូលវិចារ។*

លោក មនោ វិជ្ជា

*ដែលបានផ្ដល់កិត្តិយសក្នុងការផ្ដល់មូលវិចារ*

លោក ជា វ៉ាន់សាន្ត

*ដែលបានផ្ដល់កិត្តិយសក្នុងការផ្ដល់មូលវិចារ និងជួយពិនិត្យអក្ខរាវិរុទ្ធ*

លោក អេង រតនៈ

*ដែលបានផ្ដល់កិត្តិយសក្នុងការផ្ដល់មូលវិចារ*

សូមគោរពជូនពរដល់អ្នកដែលមានទឹកចិត្តល្អ ចូលរួមយ៉ាងអស់កម្លាំងកាយចិត្ត លើកិច្ចការងាររៀបរៀង និងពិនិត្យរាល់កំហុសឆ្គង ព្រមទាំងបានជួយកែលំអ បានជួបប្រទះតែសេចក្ដីសុខ មានសុខភាពល្អ និងសម្រេចបានជោគជ័យលើកិច្ចការងារគ្រប់ប្រការ ៕

សូមអរគុណ!

ពីខ្ញុំ ឡាំ លីម

# មាតិកា

១. ទស្សនៈប្រចាំខែមករា........................................១
២. ទស្សនៈប្រចាំខែកុម្ភៈ........................................៥៣
៣. ទស្សនៈប្រចាំខែមីនា........................................៩៦
៤. ទស្សនៈប្រចាំខែមេសា........................................១៤២
៥. ទស្សនៈប្រចាំខែឧសភា........................................១៩២
៦. ទស្សនៈប្រចាំខែមិថុនា........................................២៣៨
៧. ទស្សនៈប្រចាំខែកក្កដា........................................២៨២
៨. ទស្សនៈប្រចាំខែសីហា........................................៣៣០
៩. ទស្សនៈប្រចាំខែកញ្ញា........................................៣៨៦
១០. ទស្សនៈប្រចាំខែតុលា........................................៤៣២
១១. ទស្សនៈប្រចាំខែវិច្ឆិកា........................................៤៩២
១២. ទស្សនៈប្រចាំខែធ្នូ........................................៥៨៣

# ទស្សនៈសម្រាប់ខែ

# មករា

# ថ្ងៃទី០១ ខែមករា

សូរិន កៀកឺហ្គាដ [ Soren Kierkegaard ] ពោលថា៖ "*ផ្នែកម្ខាងនៃសច្ចធម៌ គឺសច្ចធម៌*" មនុស្សគិតរាក់ៗតែងតែឆាប់ជឿលើពាក្យ សម្ដីរាក់ៗ និងសកម្មភាពរាក់ៗរបស់មនុស្សជុំវិញខ្លួន។

មនុស្សខ្លះបង្កើតរូបភាពនៃគំនិតជាច្រើនដើម្បីវិនិច្ឆ័យ និងវាយតម្លៃខ្លួនឯង ព្រមទាំងអ្នកដទៃ បើទោះបីជាខ្លួនឥតស្គាល់ខ្លួនឯងច្បាស់ និងអ្នកដទៃច្បាស់ក៏ដោយ។ មនុស្សដែលមិនយល់ តែងប្រើការវាយតម្លៃសន្មតកំណត់យក ហើយមនុស្សដែលឆាប់កំណត់យកអ្វីមួយត្រូវ ឬអ្វីមួយខុសដោយងាយពេក គឺជាប្រភេទមនុស្សមិនយល់។ ការបង្កើតអកុសល និងវេទនាដល់ខ្លួនឯង។ សច្ចធម៌ ឬសេចក្ដីពិតរបស់ធម្មជាតិមានតែមួយទេ តែសច្ចធម៌របស់មនុស្សលោកមានច្រើនរាប់មិនអស់៕

# ថ្ងៃទី០២ ខែមករា

មហាត្មៈ គន្ធី [ Mahatma Gandhi ] ពោលថា *"យើងមិនត្រូវបោះបង់ចោលសទ្ធា ឬជំនឿលើសេចក្តីមេត្តាករុណាឡើយ ពីព្រោះសេចក្តីមេត្តាករុណាប្រៀបបីដូចជាសមុទ្រដែលតែងត្រូវការនូវដំណក់ទឹក។ ដំណក់ទឹកដែលហូរចូលក្នុងទឹកសមុទ្រអាចកខ្វក់ខ្លះ តែមិនអាចធ្វើឲ្យសមុទ្រទាំងមូលកខ្វក់បានឡើយ"*។

ព្រះយេស៊ូគ្រិស្ទ [ Jesus Christ ] បានរកឃើញច្បាប់ចក្រវាលមួយដែលគេហៅថា *"ច្បាប់នៃសេចក្តីស្រឡាញ់ ឬ The Law of Love"*។ ច្បាប់នេះមាននៅក្នុងទាំងមនុស្ស និងធម្មជាតិ។ មនុស្សនាំគ្នាប្រឡូកប្រឡាក់បង្ហូរគ្រឿងពុល ទឹកស្អុយ ឬសំរាមនានាចូលក្នុងទន្លេ។ បន្ទាប់មកទន្លេក៏ហូរនាំចាក់ចូលទៅក្នុងទឹកសមុទ្រ ហើយទឹកសមុទ្រមានជាតិប្រៃអាចសម្លាប់មេរោគដែលបំពុលទាំងប៉ុន្មាន។

 

សូមរៀនធ្វើជាមនុស្សដែលមានទឹកចិត្តប្រៀបដូចជាមហា-សមុទ្រ តែកុំមានទឹកចិត្តដូចជាបឹងទន្លេដែលចង្អៀតបង្កជម្លោះនឹងគ្នា ៕

*"You must not lose faith in humanity. Humanity is like an ocean; if a few drops of the ocean are dirty, the ocean does not become dirty."*

- Mohandas Gandhi

# ថ្ងៃទី០៣ ខែមករា

អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] បានពោលថា *"មានវត្ថុពីរយ៉ាងដែលគ្មានព្រំដែននោះគឺចក្រវាល និងភាពល្ងង់ខ្លៅរបស់មនុស្ស"*។

ភាពខុសគ្នារវាងអ្នកល្ងង់ខ្លៅ និងអច្ឆរិយបុគ្គលស្ថិតនៅត្រង់ថាចំណេះដឹងរបស់អច្ឆរិយបុគ្គលមានព្រំដែន ចំណែកឯភាពល្ងង់ខ្លៅរបស់មនុស្សល្ងង់ គ្មានដែនកំណត់ទេ។ នៅពេលដែលយើង ព្រមទទួលស្គាល់នូវព្រំដែនរបស់យើងនោះ គឺបានន័យថាយើងបានឆ្លងផុតវាបាត់ទៅហើយ។

មនុស្សខ្លៅចូលចិត្តបង្ករឿងឈ្លោះជាមួយអ្នកចេះ ហើយមនុស្សដែលបង្កជម្លោះជាមួយអ្នកចេះ ត្រូវបានគេដាក់ងារឲ្យមួយទៀតថាជា "បុគ្គលពាល"។បុគ្គលពាលនឹងតែងតែឈ្លោះជាមួយគេឯងគ្រប់គ្នា ព្រោះបុគ្គលពាលឥតចេះស្តាប់ហេតុផលទេ តែអ្នកចេះដឹង គឺអាចចេះស្តាប់ហេតុផលនៃបុគ្គលពាលខ្លះប្រកបដោយសីលធម៌៕

*"Only two things are infinite, the universe and human stupidity, and I'm not sure about the former."*

- Albert Einstein

# ថ្ងៃទី០៤ ខែមករា

ហ្វេដេរីកូ ម៉ៃយ៉ឺរ [ Federico Mayor ]បានពោលថា និយមន័យពីរបែប ស្តីពីមនុស្សដែលទស្សនវិទូអារីស្តូតបានផ្តល់ឲ្យយើងដឹងថា *"មនុស្សជាសត្វចេះធ្វើនយោបាយ"*។ មនុស្សជាភាវៈដែលមានសម្បទារពីកំណើតខាងការនិយាយស្តី និងបានផ្តល់ឲ្យយើងនូវតថភាពមួយដូចគ្នាគឺ៖ ជីវិតក្នុងសង្គមអាចប្រព្រឹត្តទៅបាន លុះត្រាតែការងាររួមត្រូវបានលើកយកមកជជែកវែកញែក និងដោះស្រាយដោយសារការចរចា និងការស្រុះស្រួលគ្នា តែមិនមែនដោយសារមធ្យោបាយប្រើកម្លាំងបាយនោះឡើយ។

វិធីល្អបំផុតនៅក្នុងលទ្ធិប្រជាធិបតេយ្យ គឺជាវិធីប្រើគំនិតដើម្បីពិភាក្សាគ្នា ហើយមានតែការពិភាក្សាគ្នានេះទេ ទើបធ្វើឲ្យយើងដឹងច្បាស់ពីចំណុចព្រមព្រៀងគ្នា និងចំណុចមិនព្រមព្រៀងគ្នា ឬចំណុចអាចវាស់វែងបាននូវការខិតជិតគ្នា និងការឃ្លាតឆ្ងាយពីគ្នា៕

# ថ្ងៃទី០៥ ខែមករា

សូក្រាត [ Socrates ] និយាយថា"*ពេលយើងមិនទទួលបានអ្វីដែលយើងចង់បាន គឺយើងកើតទុក្ខ ហើយពេលយើងទទួលបានអ្វីដែលយើងមិនចង់បានគឺយើងក៏កើតទុក្ខ*"។

មានជីវិតរស់នៅគង់ស្លាប់ ទទួលរងការឈឺចាប់គង់រសាត់ ភាពក្រៀមក្រំគង់តែរលាយបាត់ ក្តីសប្បាយរីករាយគង់ប្រែប្រួលមិនខាន ប៉ុន្តែមានតែការប្រែប្រួលប៉ុណ្ណោះដែលតែងស្ថិតស្ថេរជាអមតៈ និងមិនប្រែប្រួលទៅណា។

ជីវិតអាប់អួរថ្ងៃនេះ ចូរកុំចងចាំទុកដល់ស្អែក តែបើជីវិតរីករាយថ្ងៃនេះ សូមកុំបំភ្លេចចោលឲ្យសោះ។ តើយើងនៅចាំបានទេ? ខុងជឺ [ Confucius ] និយាយថា "*ជីវិតគឺធម្មតាទេដូច្នេះចូរកុំធ្វើឲ្យវាស្មុគស្មាញ*"។

*"If you don't get what you want, you suffer; if you get what you don't want, you suffer."* - Socrates

# ថ្ងៃទី០៦ខែមករា

លី ក្វាន់យូ [ Lee Kuan Yew ] ពោលថា *"យុវជនយើងក្នុងថ្ងៃនេះ គឺជាអ្នកដឹកនាំរបស់ពលរដ្ឋយើងនៅថ្ងៃស្អែក"។*

អតីតមេដឹកនាំសិង្ហបុរីរូបនេះជឿជាក់យ៉ាងមុតមាំថា ការអប់រំគឺជាគន្លឹះសំខាន់បំផុត ក្នុងការអភិវឌ្ឍន៍សង្គមជាតិទាំងមូល។ ទស្សនៈវិស័យអប់រំរបស់ លី ក្វាន់យូ គឺគិតដល់ការអភិវឌ្ឍសមត្ថភាពកុមារ និងយុវជនឲ្យមានសក្តានុពលខ្លាំងដោយឈរលើគោលការណ៍ *"វិន័យល្អ អាកប្បកិរិយាល្អ និងតម្លៃនៃឥរិយាបថនិយម"។*

ការអប់រំ គឺជាមធ្យាបាយនាំទៅរកសេរីភាព។ សេរីភាពនឹងអាចធ្វើឲ្យមនុស្សគេចផុតពីភាពក្រីក្រ។ សេរីភាពនឹងមិនឲ្យមានអយុត្តិធម៌សង្គម ព្រមទាំងសេរីភាពលើចំណេះដឹង។

ទ្រឹស្តីដ៏ល្បីល្បាញបំផុតសម្រាប់ លីក្វាន់ យូ *"វប្បធម៌សង្គមមួយបែបណាវានឹងកំណត់ជោគវាសនានៃប្រទេសជាតិមួយបែបនោះដែរ ឬ Culture is destiny"*។

*"វប្បធម៌"* គឺមានន័យថាជាការសាប ការដាំ ការបណ្តុះដែលសំដៅដល់ដាំមនុស្សមិនល្អនឹងប្រមូលផលសង្គមចលាចល និងប្រមូលផលទង្វើអសីលធម៌សង្គម។ ប៉ុន្តែបើសាបព្រោះល្អ ក៏នឹងប្រមូលផលល្អ។ ការសាបព្រោះចំណេះដឹងខុសលើមនុស្សខុស គឺប្រៀបដូចជាការសាបព្រោះគ្រោះកាចមួយយ៉ាងធំដល់សង្គមទាំងមូល។

*"In our youth of today are the leaders and citizens of tomorrow."*-Lee Kuan Yew

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី០៧ខែមករា

រ៉េ ប្រាឌប៊ឺរី [ Ray Bradbury ] ពោលថា *"អ្នកមិនចាំបាច់ដុតកម្ទេចសៀវភៅចោលឲ្យអស់ ដើម្បីបំផ្លាញវប្បធម៌នៃសង្គមមួយនោះទេ ប៉ុន្តែគ្រាន់តែធ្វើឲ្យមនុស្សក្នុងសង្គមនោះលែងចង់អានសៀវភៅ គឺវាគ្រប់គ្រាន់ហើយ ដើម្បីបំផ្លាញប្រទេសនោះ"* ។

ការអានមិនអាចធ្វើឲ្យយើងទាំងអស់គ្នាក្លាយទៅជាអ្នកដឹកនាំបានទេ ប៉ុន្តែវាអាចប្រាប់យើងថា តើមនុស្សប្រភេទណាដែលយើងគួរដើរតាម។

រយៈពេល១០ឆ្នាំរហូតមកទល់ថ្ងៃនេះ ខ្ញុំធ្លាប់បានអានសៀវភៅក្រោមម្លប់ដើមក្រសាំង ឬនៅក្រោមម្លប់ដើមស្វាយម្នាក់ឯង។ ខ្ញុំឥតមានសម្លៀកបំពាក់ស្អាតស្លៀកពាក់ ហើយខ្ញុំក៏ឥតមានអាហារអ្វីឆ្ងាញ់ៗដើម្បីហូបដែរ ប៉ុន្តែខ្ញុំសម្បូរសៀវភៅល្អៗដើម្បីអាន។

តាមពិតមនុស្សខ្លះ រស់នៅបានសុខ គឺដោយសារតែការប្រឹងប្រែងសង្វាតសិក្សា និងការប្រឹងអានសៀវភៅនានា។ មនុស្សខ្លះដែលពុំសូវបានអាន គឺពួកគេស្លាប់ស្មើររាល់ថ្ងៃ ពីព្រោះគេជួបបញ្ហាជីវិតរាល់ថ្ងៃ ហើយគេត្អូញត្អែររាល់ថ្ងៃ។ ចំណេះដឹងច្រើន នឹងនាំឲ្យមានបញ្ហានៃជីវិតនឹងកាន់តែតិច ហើយចំណេះដឹងតិច គឺនឹងធ្វើឲ្យបញ្ហានៃជីវិតនឹងកាន់តែច្រើន៕

# ថ្ងៃទី០៨ ខែមករា

## ខ្លាចដឹង និងខ្លាចមិនដឹង

តើរដ្ឋាភិបាលខ្លាចប្រជាជន ឬប្រជាជនជាអ្នកដែលភ័យខ្លាចរដ្ឋាភិបាល? អ្នកក្តោបក្តាប់អំណាចតែងខ្លាចប្រជាជនដែលស្ថិតនៅក្រោមអំណាចខ្លួន ផ្តួលរំលំទម្លាក់ខ្លួន ទើបជ្រើសរើសធ្វើទុក្ខបុកម្នេញប្រជាជនមុន។

តថភាពជាក់ស្តែង ប្រជាជននិងរដ្ឋាភិបាលខ្លាចគ្នាទៅវិញទៅមក ប៉ុន្តែប្រជាជនគ្រាន់តែមិនដឹងថា អ្នកក្តាប់អំណាចខ្លាចខ្លួនប៉ុណ្ណោះ។ គ្មានអ្វីដែលគួរឲ្យខ្លាចជាងកម្លាំងរបស់យុវជន និងគ្មានអ្វីដែលគួរឲ្យខ្លាចជាង អ្នកសាបព្រោះមនោគមវិជ្ជាមិនល្អដាក់យុវជនទេ។មនោមវិជ្ជាតែងមានល្អនិងអាក្រក់ ហើយបើសាបព្រោះល្អ ក៏នឹងប្រមូលផលល្អ ប៉ុន្តែបើសាបព្រោះអាក្រក់ គឺនឹងប្រមូលផលក៏អាក្រក់ដែរ។

អ៊ុងសាន ស៊ូជី ផ្លាស់ប្តូរសង្គមដោយធម៌អហិង្សា មិនដែរ។ មហាត្មៈ គន្ធី ផ្លាស់ប្តូរសង្គមដោយធម៌អហិង្សា មិនដែរ។ លោក ម៉ាទីន លូធើឃីញ ជូនៀផ្លាស់ប្តូរសង្គមដោយធម៌អហិង្សា មិនដែរ។ ណែលសុន មិនដេឡា ផ្លាស់ប្តូរសង្គមដោយធម៌អហិង្សា មិនដែរ...។ល។

គេថា *"មនុស្សមានគោលដៅដូចគ្នាគង់តែអាចជួបគ្នានៅថ្ងៃណាមួយ"*។ ប៉ុន្តែខ្ញុំថា *"មនុស្សមានគោលដៅដូចគ្នាគ្មានថ្ងៃជួបគ្នាទេ បើប្រើវិធីសាស្ត្រខុសគ្នា គឺមួយប្រើវិធីសាស្ត្រទន់ត្រជាក់ ហើយមួយទៀតប្រើវិធីសាស្ត្ររឹងក្តៅនោះមិនចាំបាច់ជួបគ្នាឡើយ"*។

គោលគំនិតល្អ តែវិធីសាស្ត្រអាក្រក់។ វិធីសាស្ត្រប្រែប្រួលជានិច្ច គឺត្រូវតែប្រែប្រួលឈរលើគោលការណ៍សីលធម៌ តែគោលការណ៍មិនប្រែប្រួលទេ៕

# ថ្ងៃទី០៩ ខែមករា

ហូ ជីមិញ [ HO Chi Minh ] ពោលថា *"ទាហានយើងស្លាប់១០នាក់ ហើយទាហានអ្នកស្លាប់ម្នាក់ក៏ពិតមែនតែ ចុងបញ្ចប់ មុននិងក្រោយ ទាហានអ្នកនឹងហេវហត់អស់កម្លាំង"*។ គាត់បានបន្ថែមទៀតថា *"យើងមានអាវុធសម្ងាត់មួយ នោះគឺទឹកចិត្តជាតិនិយមរបស់ប្រជាជនយើង។ ទឹកចិត្តជាតិនិយមនេះហើយ គឺជាអាវុធមហាអស្ចារ្យបំផុតក្នុងលោកយើងនេះ"*

ក្នុងសង្គ្រាមវៀតណាម ទាហាន និងប្រជាជនវៀតណាមកុម្មុយនិស្តបានលះបង់ជីវិតប្តូរស្លាប់រស់ដើម្បីការពារពីការឈ្លានពានរបស់បរទេស ពីព្រោះពួកគេយល់ថាវាជា *"តម្លៃដែលត្រូវបង់"*។

បុរាណខ្មែរបានពោលទុកមកថា *"លះបង់មនុស្សម្នាក់ដើម្បីគ្រួសារមួយ, លះបង់គ្រួសារមួយ ដើម្បីភូមិស្រុកមួយ, លះបង់ភូមិស្រុកមួយ ដើម្បីសង្គមមួយ, លះបង់សង្គមមួយ ដើម្បីប្រទេសជាតិទាំងមូល"*។

បន្ទាប់ពីសង្គ្រាមត្រជាក់ត្រូវបានបញ្ចប់ ពិភពលោកក៏បានបន្តដំណើរផ្លាស់ប្តូរមកសម័យកាលថ្មីមួយទៀត ដែលអ្នកប្រវត្តិសាស្ត្របានហៅថា "បដិវត្តន៍បច្ចេកវិទ្យា"ឬ "បដិវត្តន៍ឌីជីថល [ Digital Revolution ]"។

ក្នុងការជួយសង្គម បើមិនយកការអប់រំមកដាក់ពីមុខទេ នោះរាល់មនោគមន៍វិជ្ជានយោបាយរបស់អ្នកនយោបាយ នឹងបង្កភាពគ្រោះថ្នាក់ដល់សង្គម ហើយមនោគមន៍វិជ្ជាដែលប្រាស់ចាកសីលធម៌សង្គមនឹងនាំសង្គមឲ្យវិនាស។ យើងអាចមិនមានយុវជនខ្លាំងច្រើនក្នុងថ្ងៃនេះក៏ពិតមែន តែយើងអាចរៀបចំយុវជនថ្ងៃនេះឲ្យក្លាយជាយុវជនខ្លាំងសម្រាប់ថ្ងៃអនាគតបាន៕

# ថ្ងៃទី១០ ខែមករា

អាប់ឌុល កាឡាម [ Abdul Kalam ] ពោលថា *"ការរៀនសូត្រ [ Learning ]នឹងផ្តល់ឲ្យយើងនូវការចេះច្នៃប្រតិដ្ឋ ការចេះច្នៃប្រតិដ្ឋ[ Creativity ] នឹងផ្តល់ឲ្យយើងនូវការចេះគិតពិចារណា ការចេះគិតពិចារណា [ Thinking ] នឹងផ្តល់ឲ្យយើងនូវចំណេះដឹង ហើយចំណេះដឹងនឹងធ្វើឲ្យយើងក្លាយជាមនុស្សដ៏អស្ចារ្យ [ Great ] ។"*

ការសាបព្រោះចំណេះដឹងដល់មនុស្សខ្វះសីលធម៌ ខ្វះគុណធម៌ និងខ្វះមនុស្សធម៌នៅក្នុងខ្លួន គឺប្រៀបដូចជាបានសាបព្រោះព្យុះភ្លៀងមួយយ៉ាងធំដល់សង្គមជាតិទាំងមូល ។

អាល់ប៊ឺត អាញស្តាញ[ Albert Einstein ] និយាយថា *"ចំណេះដឹងតែងតែស្ថិតនៅជាមួយរបស់ពីរយ៉ាងគឺ"៖*

*១. ស្ថិតនៅជាមួយរបស់មានជីវិត [ខួរក្បាលរបស់មនុស្ស ] ។*

*២. ស្ថិតនៅជាមួយរបស់ឥតជីវិត [ គម្ពីរ ឬសៀវភៅសិក្សា ]។*

ចំណេះដឹងគួរមិនស្ថិតក្នុងសភាពងាប់ក្រឡា តែយើងត្រូវដុសខាត់ច្នៃប្រឌិតបន្ថែម និងត្រួតពិនិត្យវាជាប្រចាំ ព្រោះដើម្បីឲ្យវាកាន់តែប្រសើរឡើង។ មហាត្មៈ គន្ធី និយាយថា *"ចំណេះដឹងដែលគ្មានជ្រាបចូលជាចរិត[ Knowledge Without Character ] គឺជាអំពើបាបសង្គមមួយក្នុងចំណោមអំពើបាបទាំង៧ [ 7 Deadly Sins ] ក្នុងសង្គម"*។

ការណ៍ដែលមនុស្សមានចំណេះដឹងខ្ពង់ខ្ពស់ ប៉ុន្តែគេបែរជាបង្ហាញចរិតខ្វះសីលធម៌ជាមនុស្ស ដោយមិនយកចំណេះដឹងបញ្ជ្រាបឲ្យកើតជាចរិតលក្ខណៈល្អ នោះចំណេះដឹងគ្មានតម្លៃដាច់ខាត ឬបានត្រឹមតែប្រើចំណេះដឹងសាបព្រោះព្យុះភ្លៀងដល់សង្គមប៉ុណ្ណោះ។ ប្លាតុង [ Plato ] និយាយថា *"ចំណេះដឹងនឹងក្លាយទៅជាឥតប្រយោជន៍ប្រសិនបើគោលបំណងនៃចំណេះដឹងខុសគោលការណ៍សីលធម៌"* ៕

# ថ្ងៃទី១១ ខែមករា

*មហាត្មៈ គន្ធី [ Mahatma Gandhi ] និយាយថា "សីល សមាធិ បញ្ញា"* មនុស្សដែលឆ្លាតតែងស្គាល់ខ្លួនឯង ប៉ុន្តែក៏ស្គាល់មិនច្បាស់ដូច អច្ឆរិយបុគ្គលស្គាល់ខ្លួនឯងដែរ ។ មនុស្សដែលស្គាល់ខ្លួនឯងដល់ថ្នាក់ស៊ីជម្រៅ និងមនុស្សដែលមានសន្តិភាពក្នុងខ្លួនគង់ មិនងាយខឹងច្រឡោតផ្តេសផ្តាសឡើយ ប៉ុន្តែគេអាចសម្តែងជាខឹងបានខ្លះបើកំហឹងនោះមានប្រយោជន៍ច្រើន។

ពេលចិត្តស្ងប់មែនទែន យើងនឹងលែងខឹង លែងស្អប់ លែងស្រឡាញ់ គឺពេលនោះហើយដែលបញ្ញាអាចកើតឡើងពិតប្រាកដ។ ដើម្បីកើតបញ្ញា មនុស្សត្រូវតាំងចិត្តឲ្យស្ងប់ ហើយចិត្តស្ងប់គឺជាចិត្តដែលមានសមាធិ ឬមានសតិដឹង។ ដើម្បីមានសមាធិទៅបាន លុះត្រាតែមានសីល ហើយសីលគឺការប្រព្រឹត្តល្អជាប្រក្រតី។ មនុស្សប្រព្រឹត្តអាក្រក់តែងតែប្រឆាំងនឹងខ្លួនឯងដោយមិនថាបុគ្គលនោះជាសាសនាណានោះទេ៕

# ថ្ងៃទី១២ ខែមករា

*អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] និយាយថា "មនុស្សណាដែលប្រឹងអានច្រើនបំផុត តែបែរជាប្រើប្រាស់ខួរក្បាលគិតតិចតួចបំផុតគឺនឹងធ្លាក់ចូលទៅក្នុងទម្លាប់ខ្ជិលគិត"។*

*ធម្មជាតិបង្កើតមនុស្សឲ្យមានដៃពីរជើងពីរគឺឲ្យយើងប្រឹង។ ឲ្យមានភ្នែកពីរ គឺឲ្យយើងសម្លឹងមើលទៅមុខ មើលគ្រប់យ៉ាង។ ឲ្យមានត្រចៀកពីរ គឺស្តាប់ឲ្យច្រើន។ ឲ្យមានមាត់មួយ គឺនិយាយឲ្យតិច ឬច្រើន ត្រូវមើលកាលៈទេសៈ។*

យើងមានដៃជើង មានភ្នែក មានត្រចៀក មានមាត់ តែបើត្រឹមតែរៀនដោយទទួលយកព័ត៌មាន និងទិន្នន័យដោយឥតប្រើខួរក្បាលគិត ឬបន្សុទ្ធចំណេះដឹងទេ នោះរាល់ចំណេះដឹងទាំងឡាយ គឺឥតន័យ ហើយក៏ឥតប្រយោជន៍ដែរ។ ការសាបព្រោះចំណេះដឹងខុស គឺប្រៀបដូចជាសាបព្រោះគ្រោះកាចដល់សង្គមទាំងមូល។

*ខួរក្បាលទម្ងន់ ១.៣ ទៅ១.៥គីឡូ តែវាអាចដឹកនាំ និងគ្រប់គ្រងខ្លួនប្រាណទាំងមូលរបស់មនុស្សរាប់សិបគីឡូបាន ៕*

*"Any man who reads too much and uses his own brain too little falls into lazy habits of thinking."*

*-Albert Einstein*

# ថ្ងៃទី១៣ ខែមករា

*"យើងគ្រប់គ្នាត្រូវការបំភ្លឺឲ្យគ្នាទៅវិញទៅមក ពីព្រោះពន្លឺតែងសាងភាពយល់យោគឲ្យគ្នា។ ការចេះយល់យោគគ្នាតែងសាងសេចក្តីស្រឡាញ់ឲ្យគ្នា។ ការចេះស្រឡាញ់គ្នាតែងសាងភាពអត់ធ្មត់ចំពោះគ្នា។ ការចេះអត់ធ្មត់ចំពោះគ្នាតែងសាងសាគ្គីភាពគ្នាតែមួយ"*។ ពេលដែលក្តីស្រឡាញ់អាចគ្រប់គ្រងមនុស្សមានកំហឹងបាន នោះកំហឹងនឹងក្លាយជាស្នាមញញឹមនៃការចេះសាមគ្គីតែមួយ។ចូរមើលលើចំណុចស្របគ្នា ប៉ុន្តែសូមកុំមើលលើចំណុចឈ្លោះគ្នា។

ជាទូទៅ មុននឹងបំបែកសង្គម គេត្រូវបំបែកមនុស្សក្នុងសង្គមឲ្យបែកគ្នាជាមុនសិន។ បន្ទាប់មក គឺគេបំបែកសង្គមតាមរយៈនិន្នាការសាសនា និងនយោបាយ។ ជនជាតិខ្មែរយើងជាពិសេសយុវជនទាំងឡាយ ត្រូវមានសតិដឹងជានិច្ចថាគ្រប់សាសនាទាំងអស់ក្នុងលោក តែងបង្រៀនមនុស្សឲ្យធ្វើសេចក្តីល្អ ហើយសាសនាគ្មានអ្វីគួរឲ្យខ្លាចទេ តែយើងត្រូវប្រយ័ត្នចំពោះសាសនិក។ ស្រដៀងគ្នាដែរ តាមពិតនយោបាយគឺជាផ្ទាំងបាយរបស់ប្រជាជន

ហើយនយោបាយមិនមែនអាក្រក់ថោកទាបទេ តែដាច់ខាតត្រូវចេះប្រុងប្រយ័ត្នចំពោះអ្នកនយោបាយ។ នៅក្នុងសង្គមប្រជាធិបតេយ្យ អ្នកនយោបាយ គឺជាទូក ហើយប្រជាជនគឺជាទឹក។ទឹកអាចបណ្តែតទូកបានក៏គង់នឹងអាចពន្លិចទូកបានដែរ៕ "We need more light about each other. Light creates understanding, understanding creates love, love creates patience, and patience creates unity." - Malcolm X

# ថ្ងៃទី១៤ខែមករា

ណាប៉ូលេឡុង ប៉ូណាប៉ាត [ Napoleon Bonaparte ] មានបន្ទូលថា
*"សូមអ្នកកុំរំខានសត្រូវរបស់អ្នកឡើយ ក្នុងខណៈពេលគេកំពុងតែសាងកំហុស"*។ ទ្រឹស្តីខាងលើនេះ គឺជាទ្រឹស្តីបែបយុទ្ធសាស្ត្រ ហើយយុទ្ធសាស្ត្រឥតនិយាយពីការស្អប់ ឬការស្រឡាញ់ មិត្ត ឬសត្រូវ និងគុណធម៌ ឬថោកទាបទេ តែសំខាន់គឺឈ្នះ ពីព្រោះអ្នកឈ្នះជាស្តេចដែលត្រូវដឹកនាំគ្រប់គ្រងផែនដី រីឯអ្នកចាញ់ជាចោរ។

បើយើងគិតត្រឡប់មកវិញគឺ នៅពេលយើងកំពុងតែសាងកំហុស ហើយបែរជាគ្មាននរណាម្នាក់ជួយណែនាំយើងទេ នោះគឺមានន័យថាគេបានចាត់ទុកយើងជាសត្រូវរបស់គេរួចហើយ ពីព្រោះមិត្តភក្តិ ឬអ្នកស្រឡាញ់រាប់អានយើងពិតប្រាកដ គេនឹងមិនបណ្តោយឲ្យយើងដើរខុសផ្លូវទេ។

ក្នុងសិល្បៈសង្គ្រាមក៏បានបង្រៀនថា "នៅពេលដែលមានសត្រូវចូលមកអុកឡុក អ្នកត្រូវដើរចេញឲ្យឆ្ងាយ ជៀសវាងមានបញ្ហាធំ។ ហេតុអ្វី? ពីព្រោះថាការបង្កឲ្យមានបញ្ហាធំតម្រូវឲ្យយើងប្រើកម្លាំងច្រើន។ បើយើងឈ្លោះប្រកែកជាមួយជនកំបិុកកំប៉ុកតូចតាច យើងក៏ជាជនកំបិុកកំប៉ុកតូចតាចដែរ"។ ប៉ុន្តែត្រូវចាំថា ពន្លឺរបស់ព្រះអាទិត្យទៅដល់គ្រប់ទីកន្លែងនៃផែនដីដោយមិនទីកន្លែងកខ្វក់ណាទេ ប៉ុន្តែយើងកម្របានឃើញពន្លឺរបស់ព្រះអាទិត្យកខ្វក់ណាស់៕

"Never interrupt your enemy when he is making a mistake."- Napoleon Bonaparte

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី១៥ ខែមករា

អាប្រាហាម លីនខុលន៍ [ Abraham Lincoln ] និយាយថា *" បុគ្គលណាដែលតាំងចិត្តស្វែងរកសេចក្ដីអាក្រក់នៅក្នុងខ្លួនអ្នកដទៃ គឺគេនឹងអាចរកឃើញសេចក្ដីអាក្រក់ពីជនដទៃដោយពិតប្រាកដ"។* គ្រូឧបាសកបង្ហាត់វិបស្សនាកម្មដ្ឋាន លោក ស.ន ហ្គោឥនកា បានបង្រៀនថា *"ហេតុអ្វីយើងត្រូវប្រកែកគ្នា? ចូរយើងទុកទស្សនៈផ្សេងៗគ្នាមួយអន្លើសិន។ ប៉ុន្តែ ចូរផ្ដោតតែទៅលើអ្វីដែលយើងអាចយល់ស្របគ្នា និងអាចឲ្យយើងយកទៅអនុវត្តន៍បាន"។*

*កាលបើមនុស្សមិនហ៊ានទទួលស្គាល់ថាខ្លួនឯងពិតជាសត្វមនុស្សទេ នោះគេនឹងនៅតែតាំងខ្លួនជាព្រះ ឬជាមនុស្សចិត្តព្រះ ឬជាមនុស្សបរិសុទ្ធ។* ក្នុងភាពល្អតែងមានអាក្រក់ខ្លះ ហើយក្នុងអាក្រក់ក៏តែងមានល្អខ្លះ ។មនុស្សពេញលេញមិនគិតថាខ្លួនឯងល្អឥតខ្ចោះទេ ហើយមនុស្សដែលតាំងខ្លួនឯងល្អឥតខ្ចោះ ឬត្រូវឥតខ្ចោះមិនដែលខុសសោះ គឺមិនពេញលេញទេ៕

# ថ្ងៃទី១៦ ខែមករា

ប្លែរ ប៉ាស្កាល់ [ Blaise Pascal ] ពោលថា *"សូមអធ្យាស្រ័យ ខ្ញុំនិពន្ធអត្ថបទវែងជាងធម្មតា ពីព្រោះខ្ញុំគ្មានពេលវេលានិពន្ធឲ្យខ្លី"។ អ្វីគ្រប់យ៉ាងដែលយើងត្រូវធ្វើគួរតែប្រឹងធ្វើឲ្យបានល្អជាស្រេចចប់សព្វគ្រប់ ដោយមិនចាំបាច់ចំណាយពេលវេលាមកកែសម្រួលសាជាថ្មីម្តងទៀត។ ការណ៍នេះតែងនាំឲ្យតែខាតពេលវេលាច្រើន។ បុរាណខ្មែរអប់រំប្រដៅថា "ធ្វើអ្វីធ្វើឲ្យហើយ កុំឡើយបន្សល់កេរ្តិ៍"។*

ថ្ងៃស្អែក និងសេចក្តីស្លាប់ តើយើងអាចដឹងទេថា មួយណានឹងមកដល់មុន? ចូររស់នៅឲ្យដូចជាយើងត្រូវស្លាប់ទៅវិញនៅថ្ងៃស្អែក ហើយចូរប្រឹងប្រែងរៀន ប្រឹងប្រែងសន្សំទ្រព្យ និងកេរ្តិ៍ឈ្មោះល្អឲ្យដូចជាយើងត្រូវរស់នៅជាអមតៈអ៊ីចឹង៕

"I'm sorry I wrote you such a long letter; I didn't have time to write a short one."- Blaise Pascal

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី១៧ ខែមករា

លោក ជីមី ហែនឌ្រិក [ Jimi Hendrix ] និយាយថា *"ពេលដែលអំណាចនៃសេចក្តីស្រឡាញ់ [ Power Of Love ] អាចប្រើដើម្បីបន្ទន់ចិត្តមនុស្សដែលស្រឡាញ់អំណាចបាន [ Love Of Power ] នោះពិភពលោកទាំងមូលនឹងស្គាល់សន្តិភាពពិតប្រាកដ"។*

ពេលខ្លះ មនុស្សដែលចង់បានអំណាចអាចថាមានគោលបំណងដើម្បីធ្វើបាបគាបសង្កត់មនុស្ស ពីព្រោះបើគ្រាន់តែចង់ជួយសង្គ្រោះមនុស្ស មានត្រឹមតែសេចក្តីស្រឡាញ់ និងក្តីអាណិតអាសូរ គឺអាចគ្រប់គ្រាន់ហើយ។ ដើម្បីផ្លាស់ប្តូរពិភពលោកឲ្យមានសន្តិភាពពិតប្រាកដទៅបាន លុះត្រាតែយើងជាអ្នកនយោបាយ ព្រមទាំងមនុស្សទាំងឡាយនៅក្នុងសង្គម ចាំបាច់ត្រូវរកវិធីស្រុះស្រួលមូលគំនិតគ្នាជាធ្លុងមួយ [ put your head together first ]។

ចំពោះអ្នកដឹកនាំសង្គម ដែលមិនសុខចិត្តចុះចាញ់ឈាមជាតិឯង តែខ្លួនឯងក៏នៅតែមិនឈ្នះ រីឯអ្នកឈ្នះគឺប្រទេសជិតខាងទៅវិញ។ យើងឈ្លោះគ្នា យើងពឹងគេ យើងបាត់បង់ទឹកដី។ យើងឈ្លោះគ្នា គេធ្វើឲ្យយើងហែកគ្នាស៊ីជាចម្រៀក គេបំបែកសាមគ្គីជាតិយើង។ គេចាំទទួលផល យើងជាអ្នកចាញ់ទាំងស្រុង។ វប្បធម៌ឱនលំទោនជ្រុលដាក់គេ តែជាន់ពន្លិចឈាមជាតិឯង និងគំរាមឈាមជាតិឯង គឺជាវប្បធម៌នយោបាយជាតិយើង។គ្មាននរណាម្នាក់ដឹងថាជនបរទេសបិទវាំងននប្រមាថជនជាតិខ្មែរទេ។

ជនជាតិយើងកើតក្នុងទឹកដីនេះ មិនមែនកំហុសយើងទេ ព្រោះយើងមិនអាចជ្រើសកន្លែងកើតបាន តែបើថ្ងៃណាមួយយើងស្លាប់ទៅវិញ ដោយបន្សល់ទុកនូវសេចក្តីវេទនាដល់អនុជនជំនាន់ក្រោយដែលត្រូវជាកូន ជាចៅ ជាសាច់ញាតិ ឬជាបងប្អូនរួមលោហិត នោះទើបជាកំហុសយើង។ ប្រវត្តិសាស្ត្រនឹងជេរស្តីយើងទាំងអស់គ្នាថា *"អសមត្ថភាពបំផ្លាញធនធាន គ្មានបន្សល់កេរ្តិ៍"*៕

# ថ្ងៃទី១៨ ខែមករា

*" ដរាបណាឲ្យតែយើងមានការជឿជាក់ថាខ្លួនអាចធ្វើបាន គឺមានន័យថាយើងសម្រេចលទ្ធផលបាន ៥០ភាគរយរួចទៅហើយ"។*

ចូរឧស្សាហ៍ប្រាប់ខ្លួនឯងថា យើងគឺជាមនស្សអស្ចារ្យខ្លាំងណាស់ ហើយពេលនោះយើងក៏ក្លាយជាមនុស្សអស្ចារ្យ។ បើយើងចង់ធ្វើជាមនុស្សអស្ចារ្យ គឺយើងត្រូវខំប្រឹងធ្វើកិច្ចការងារអស្ចារ្យ។ មនុស្សអស្ចារ្យ គឺជាមនុស្សធម្មតាម្នាក់ដែលប្រឹងធ្វើការងារអស្ចារ្យ ហើយមនុស្សធម្មតា គឺប្រហែលជាមនុស្សអស្ចារ្យម្នាក់ ដែលត្រឹមតែប្រឹងធ្វើការងារសាមញ្ញៗប៉ុណ្ណោះ។

គ្មាននរណាម្នាក់ខ្វល់ថាយើងជាមនុស្សបែបណា មកពីណា ឬចេះដឹងប៉ុនណានោះទេ តែសំខាន់ការងារដែលយើងធ្វើ និងលទ្ធផលដែលយើងទទួលបាន ពីព្រោះលទ្ធផលល្អ ឬអាក្រក់ គឺជាភស្តុតាងបញ្ជាក់ថា យើងជានរណាពិតប្រាកដ

ព្រះយេស៊ូវគ្រីស្ទ [ Jesu Christ ] បានមានបន្ទូលថា *"ជំនឿអាចរំកិលភ្នំបាន"*។ ចូរជឿជាក់ចំពោះខ្លួនឯង ផ្តល់កម្លាំងចិត្តដល់ខ្លួនឯង និងត្រូវគិតថាយើងអាច គឺយើងពិតជាអាច។ សូមយើងកុំខ្លាចអ្វីទាំងអស់ឲ្យសោះ តែត្រូវមានសេចក្តីក្លាហានដើរទៅមុខដោយភាពជឿជាក់ជានិច្ច៕

"Believe you can and you're halfway there."

- Theodore Roosevelt,

# ថ្ងៃទី១៩ ខែមករា

អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] និយាយថា " *ការសិក្សាមិនមែនជាការរៀនសូត្រលើមូលដ្ឋាននៃការពិតនោះទេ តែជាការហ្វឹកហាត់ពីវិធីនៃការគិត*"។ ប្រព័ន្ធសិក្សាអប់រំប្រទេសមួយចំនួនផ្តោតទៅលើជំនាញនៃការគិតជាជាងចំណេះដឹង ឬព័ត៌មាន ឬការពិត។ ក្នុងសំណួរប្រឡងតែងសួរថា ដើម្បីបានចម្លើយ ១៥ តើមានប៉ុន្មានវិធីសាស្ត្រហើយតាមវិធីសាស្ត្រណាល្អជាងគេ និងលឿនជាងគេ។ ជាជាងការសួរ ៣ x ៥ ស្មើនឹងប៉ុន្មាន ?

ចម្លើយគឺមានតែមួយគត់ ប៉ុន្តែវិធីសាស្ត្រដើម្បីទទួលបានចម្លើយតែងមានច្រើនរបៀប។ចំណេះដឹងដែលមានសភាពងាប់ក្រឡាគឺគ្មានភាពរីកចម្រើនទេ តែអ្វីដែលអាចផ្តល់ការអភិវឌ្ឍន៍បានគឺជំនាញនៃការគិត និងការស្រមើស្រមៃ។ អាញស្តាញលើកឡើងថា "*ចំណេះដឹងមានព្រំដែន ប៉ុន្តែមនោគតិឬការគិតស្រមើស្រមៃគ្មានដែនកំណត់ទេ ពីព្រោះចំណេះដឹងអាចត្រឹមតែនាំយើងឲ្យឆ្លងពីកន្លែង(ក) ទៅ*

*កន្លែង (ខ) ចំណែកមនោគតិ ឬការគិតស្រមៃអាចនាំយើងទៅដល់គ្រប់ទីកន្លែងទាំងអស់"។*

មានរឿងនិទានថា...គ្រាមួយ លោក អាល់ប៊ឺត អាញស្តាញ ត្រូវបានគេសួរសំណួរមួយថា"តើ១ម៉ាយមានប៉ុន្មានហ្វីត"? អាញស្តាញឆ្លើយថា"ខ្ញុំមិនដឹងទេ។ហេតុអ្វីខ្ញុំត្រូវចាំទិន្នន័យទាំងអស់នេះនាំឲ្យរំខានខួរក្បាលខ្ញុំ ក្នុងខណៈដែលខ្ញុំអាចស្វែងរកចម្លើយបានក្នុងពេលពីរនាទីពីសៀវភៅយោងនោះ"?

អាញស្តាញ បានបង្រៀនយើងឲ្យដឹងថា "សមត្ថភាពដែលកើតចេញពីការគិត មានតម្លៃច្រើនជាងសមត្ថភាពដែលត្រឹមតែអាចចាំទិន្នន័យ និងតួលេខបានច្រើន"។ មនុស្សឆ្លាតពិតប្រាកដ មិនមែនជាបុគ្គលដែលពូកែឆ្លើយសំណួរ [ Answering ] នោះទេ ប៉ុន្តែគឺជាបុគ្គលដែលពូកែសួរនូវសំណួរ [ Questioning ]៕

# ថ្ងៃទី២០ ខែមករា

ណាប៉ូឡេអុង ប៉ូណាប៉ាត [ Napoleon Bonaparte ] ពោលថា" ប្រសិនបើយើងចង់ឲ្យការងារណាមួយទទួលបានលទ្ធផលល្អបំផុត ចូរធ្វើវាដោយខ្លួនឯង"។ពេលគ្មាននរណាលាងកាណុងកាំភ្លើង លោកលាងដោយខ្លួនឯង។ ពេលគ្មាននរណាធ្វើគ្រាប់រំសេវ លោកធ្វើដោយខ្លួនឯង។ ពេលគ្មាននរណាធ្វើទីតាំងកាំភ្លើងធំ លោកធ្វើដោយខ្លួនឯង ហើយពេលដែលគ្មាននរណាចាក់ពុម្ពកាំភ្លើងលោកក៏ចាក់ដោយខ្លួនឯង។

លោកបន្ថែមទៀតថា "មិនអាចទៅរួច ឬ Impossible" គឺជាពាក្យដែលមានតែនៅក្នុងវចនានុក្រមនៃមនុស្សល្ងង់និងមនុស្សឥតមានក្តីព្យាយាមតែប៉ុណ្ណោះ។គ្រប់យ៉ាងគឺសុទ្ធតែអាចទៅរួច ប៉ុន្តែវាត្រូវការឲ្យមានតម្លៃដោះដូរខ្លះ។ នយោបាយវិទូអ៊ីតាលីពោលថា "គ្មានជោគជ័យណាដែលបានមកដោយគ្មានឧបសគ្គនោះទេ"។

*"If you want a thing done well, do it yourself."*

- Napoleon Bonaparte

# ថ្ងៃទី២១ ខែមករា

មហាត្មៈ គន្ធី [ Mahatma Gandhi ] ពោលថា *"បើយកភ្នែកទៅសងភ្នែកនឹងបង្កើតមនុស្សពិការភ្នែកមួយផែនដី"* ។ សម្តេចសង្ឃដាឡៃ ឡាម៉ា [ 14th Dalai Lama ] មានសង្ឃដីកាថា*"សង្គមមិនត្រូវស្អប់អ្នកដែលធ្លាប់ធ្វើខុស និងអ្នកដែលជាឧក្រិដ្ឋជនឡើយ ពីព្រោះពួកគេក៏គឺជាមនុស្សម្នាក់ដែលជាសមាជិកមួយរបស់សង្គមដូចយើងដែរ។ តាមពិត ពួកគេក៏អាចផ្លាស់ប្តូរបានដូចយើងដែរ ប៉ុន្តែរឿងសំខាន់ យើងត្រូវនាំក្តីសង្ឃឹម និងការប្រឹងប្រែងមកឲ្យពួកគេអាចកសាងជីវិតថ្មីរបស់ខ្លួនបាន"*។

តាមពិតទៅ យើងគួរតែដកចិត្តស្អប់ស្រឡាញ់ចេញសិន ហើយបន្ទាប់មកព្យាយាមសិក្សាពីប្រភពនៃបញ្ហាវិញម្តងថា តើហេតុអ្វីបញ្ហានេះកើតឡើងដោយបែបនេះ។ លើលោកយើងនេះ វាតែងមានឫសគល់ដើម ឬហេតុខាងដើមនៃបញ្ហា។ ពេលដែលយើងបានយល់ច្បាស់ពីហេតុនៃបញ្ហា ឬឫសគល់បញ្ហា គឺថាយើងនឹងលែងមានភាពស្អប់ស្រឡាញ់ទៀតហើយ៕

# ថ្ងៃទី២២ ខែមករា

*"ចុងបញ្ចប់នៃជីវិត មិនមែនជាចំនួនឆ្នាំដែលយើងរស់នៅក្នុងជីវិតនោះទេ ប៉ុន្តែជាគុណភាពនៃជីវិតដែលយើងរស់នៅ"។*

អ្នកប្រាជ្ញបារាំង ម៉ុង តេស្គីយ័រ [ Baron de Montesquieu ] បានពោលថា "តម្លៃពិតរបស់ជីវិត វាពុំមែនស្ថិតលើចំនួនថ្ងៃដែលយើងរស់នៅឡើយ ប៉ុន្តែគឺវាស្ថិតនៅលើការដែលយើងចេះប្រើប្រាស់ថ្ងៃទាំងនោះឲ្យមានតម្លៃ"។

មនុស្សអាក្រក់ខ្លះអាចរស់នៅបានយូរយារ ប៉ុន្តែជីវិតរបស់គេមានតម្លៃតិចតួចណាស់។ បើយកជីវិតទៅដោះដូរយកតម្លៃជីវិត យើងនឹងបានតម្លៃពិតនៃជីវិត។ បើយើងយកជីវិតទៅដោះដូរនឹងការសិក្សា យើងនឹងទទួលបាននូវការចេះដឹង ហើយបើយកចំណេះដឹងទៅធ្វើសេចក្តីល្អ យើងនឹងគេងលក់ស្រួលនៅពេលយប់ជាងមនុស្សអាក្រក់៕

"In the end, it's not the years in your life that count. It's the life in your years." - Abraham Lincoln

# ថ្ងៃទី២៣ ខែមករា

ហេតុអ្វីបានជាព្រះពុទ្ធ [ Buddha ] សម្តែងថា *"អវិជ្ជា គឺជាប្រភពនៃអកុសលទាំងឡាយ"?* មនុស្សល្ងង់ជឿលង់លើសាសនា អាចនឹងបង្កើតឲ្យមានភេរវកម្ម។ មនុស្សល្ងង់កាន់អំណាចក្នុងដៃ អាចនឹងសង្កត់សង្កិនផ្តាច់ការ។ មនុស្សល្ងង់ប្រើប្រាស់សិទ្ធិសេរីភាព អាចនឹងបង្កើតភាពវឹកវរ និងភាពអនាធិបតេយ្យ។ មនុស្សល្ងង់មានលុយ អាចបង្កើតភាពមិនស្កប់ស្កល់ លោភលន់ និងពុករលួយ ហើយមនុស្សល្ងង់រស់ក្នុងភាពក្រីក្រ គឺអាចនឹងប្រព្រឹត្តឧក្រិដ្ឋកម្មនានា។

គោលដៅនៃជីវិតគឺសុភមង្គល ហើយមនុស្សខុសគ្នា តែងខំស្វែងរកនិយមន័យនៃភាពជោគជ័យខុសគ្នា។ តើសេចក្តីសុខនៅឯណា? ឬសុភមង្គលនៅទីណា? ព្រះពុទ្ធទ្រង់បានសម្តែងថា "គ្មាន (ផ្លូវ)ដើរទៅរកសុភមង្គលទេ ប៉ុន្តែមាន (សុមង្គល)"។ សុភមង្គលមិននៅទីឯណាឆ្ងាយទេ គឺវានៅតែក្នុងខ្លួនយើងគ្រប់ៗគ្នានេះឯង។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

យើងគ្រាន់តែដកពាក្យ "ផ្លូវ" ចេញ គឺយើងនឹងបានជួប ពាក្យថា"សុភមង្គល"  ពីព្រោះសុភមង្គលគឺនៅក្នុងខ្លួនមនុស្សគ្រប់រូប ហើយសូមកុំខំប្រឹងដើរទៅរកកន្លែងណាផ្សេង ៕

# ថ្ងៃទី២៤ ខែមករា

ទស្សនវិទូក្រិច សូក្រាត [ Socrates ] ពោលថា *"ជីវិតដែលគ្មានការសោកល្បង ឬការដកពិសោធន៍ចំពោះការរស់នៅគឺមិនសមនឹងរស់នៅមានជីវិតទេ"*។

ពេលខ្លះ យើងខ្លាចការបង្កើតកំហុសរហូតដល់យើងគ្មានការបរាជ័យដើម្បីយកមករៀនសូត្រ។ បើមើលពីទីជិត ជីវិតគឺជាសោកនាដកម្ម តែបើសិនជាយើងក្រលឡេកមើលពីទីឆ្ងាយវិញ ជីវិតគឺជាសុខនាដកម្ម។

សូមកុំខ្លាច កុំខ្លាច តែត្រូវហ៊ាន ត្រូវហ៊ាន និងក្លាហានជានិច្ច។ មនុស្សធម្មតារៀនពីកំហុសផ្ទុងខ្លួនឯងពីអតីតកាល។ មនុស្សឆ្លាតយកមេរៀននៃកំហុសឆ្គងរបស់អ្នកដទៃមកសិក្សារៀនសូត្រ ពីព្រោះមនុស្សឆ្លាតយល់ថាខ្លួនគ្មានពេលវេលាច្រើនដើម្បីបង្កើតកំហុសទេ។ ទោះបីជាយ៉ាងណាក៏ដោយ ខុសក៏ខុសចុះ តែកុំភ្លេចកែកំហុសផង ពីព្រោះថាការខុសមួយថ្ងៃគឺមិនមែនមានន័យថាខុសមួយជីវិតឯណា។

ការបង្កើតកំហុសឆ្គង ទោះជាដោយចេតនា ឬអចេតនាក្តី គឺជាបរាជ័យមួយតូច តែការមិនព្រមរៀនសូត្រពីកំហុស និងការមិនព្រមកែកំហុស គឺជាបរាជ័យមួយធំ៕

*"The unexamined life is not worth living."*

- Socrates

# ថ្ងៃទី២៥ ខែមករា

*"តាមពិតទៅ លក្ខខណ្ឌ និងស្ថានភាពខាងក្រៅរបស់យើង មិនមែនជាអ្នកកំណត់វាសនាជីវិតរបស់យើងឡើយតែគឺជាការសម្រេចចិត្តចេញពីខាងក្នុងរបស់យើងទៅវិញទេ"។*

ជីវិតគឺជាជម្រើស ប៉ុន្តែយើងក៏ត្រូវតែឆ្លាតក្នុងការជ្រើសរើស ។ លទ្ធផលនៃស្ថានភាពជីវិតយើង គឺបានមកពីលទ្ធផលនៃការគិតពីខាងក្នុង ហើយបន្ទាប់មកបង្កើតបានការសម្រេចចិត្ត។ មនុស្សមិនអាក្រក់ទេ តែគំនិតក្នុងខ្លួនមនុស្សទេតើដែលមិនល្អ។

មនុស្សមិនបរាជ័យឡើយ ប៉ុន្តែគឺចិត្តគំនិតក្នុងខ្លួនមនុស្សឯណោះទេដែលបរាជ័យ។ គំនិត គឺជាកំណើត តែបើគំនិតមិនកើត កំណើតក៏មិនល្អ។ បើចង់ឲ្យជីវិតជោគជ័យ សូមទៅជួបអ្នកមានទ្រព្យ និងអ្នកមានគំនិតវិជ្ជមាន តែបើចង់ឲ្យជីវិតមានន័យ ចូរទៅជួយអ្នកក្រ និងជួយអ្នកមានគំនិតអវិជ្ជមាន ៕

"It is your decisions, and not your conditions, that determine your destiny." - AnthonyRobbins

# ថ្ងៃទី២៦ ខែមករា

នីកូឡូ ម៉ាឆិវីលី [ Niccolo Machiavelli ] ពោលថា *"ប្រសិនបើត្រូវជ្រើសរើស ខ្ញុំសុខចិត្តឲ្យគេកោតខ្លាចប្រសើរជាងឲ្យគេគោរពស្រឡាញ់"*។ ជាក់ស្ដែងនិយម [ Realism ] និងប្រាកដនិយម [ Pragmatism ] គឺមានន័យថាត្រូវយកលទ្ធផលជាការណ៍ធំ [ Result ] តែមិនមែនយកហេតុផល [ Reason ] ទេ ។

ចំពោះ Machiavelli អ្នកដឹកនាំត្រូវយល់ស្ថានការណ៍ និងកាលៈទេសៈពេលណាសម្ដែងធ្វើជាសត្វតោ ឬនៅពេលណាសម្ដែងធ្វើសត្វកញ្ជ្រោង ឬពេលណាគួរឲ្យគេស្រឡាញ់ និងពេលណាឲ្យគេស្អប់។ គោលការណ៍ប្រើកម្លាំងដូចជាសត្វតោ និងគោលការណ៍ប្រើល្បិចកលដូចសត្វកញ្ជ្រោង គឺមានគោលដៅដើម្បីបានអំណាច។ បន្ទាប់មក ប្រើអំណាចដើម្បីរក្សាសន្តិភាព ហើយអំណាចនោះទៀតសោត មិនឲ្យដើម្បីតែបក្សខ្លួន និងក្រុមខ្លួនទេ ៕ "It is better to be feared than loved, if you cannot be both."

- Niccolo Machiavelli

# ថ្ងៃទី២៧ ខែមករា

*"តាមពិតទៅ ភាពជាអ្នកឈ្នះ ឬអ្នកចាញ់មិនមែនកើតមកជាមួយកំណើតមនុស្សទេ តែវាកើតចេញពីការគិតរបស់មនុស្ស"។*

ការឈឺចាប់កើតឡើងពីគំនិត ហើយវាក៏រលត់ទៅវិញតាមពេលវេលា។ ពេលវេលា និងការឈឺចាប់ធ្វើឲ្យមនុស្សផ្លាស់ប្តូរ ប៉ុន្តែចំពោះការផ្លាស់ប្តូរ វាឥតដែលមានការផ្លាស់ប្តូរទេ។ គំនិតជាអ្នកដែលបង្កើតមនុស្ស។ បើយើងដឹងថាខ្លួនឯងកំពុងគិតខុស សូមផ្លាស់ប្តូរការគិតមកត្រូវវិញ តែបើមិនចេះប្តូរការគិតទេ សូមគ្រាន់តែឈប់គិតវិជ្ជមាន។ ប៉ុន្តែបើមិនអាចបញ្ឈប់ការគិតអវិជ្ជមានបានទេ ក៏សូមចេះត្រឹមតែទទួលយកក៏បាន។ ទឹកល្អក់ ត្រូវការពេលវេលាដើម្បីឲ្យវាថ្លាវិញ ហើយមេរោគក្នុងគំនិតខ្លះ ត្រូវការវេលាប្រឹងប្រែងរៀនសូត្រដើម្បីឲ្យថ្លាបរិសុទ្ធវិញដែរ៕

"Winners and losers aren't born; they are the products of how they think" - Lou Holtz

# ថ្ងៃទី២៨ ខែមករា

"បើយើងយកការដកដង្ហើមធំ និងសេចក្ដីខ្វល់ខ្វាយតានតឹងទាំងឡាយមកដាក់លើសៀវភៅ នោះវាប្រសើរជាងការទៅត្អូញត្អែរដាក់លើអ្នកដទៃ"។

យើងតែងមានអារម្មណ៍ថាខ្លួនឯងគួរឲ្យអាណិត ព្រោះតែដៃទាំងពីររបស់យើងពោរពេញទៅដោយស្នាមរបួសនៃការតស៊ូ រហូតដល់ថ្ងៃណាមួយ យើងក៏បានជួបមនុស្សដែលគ្មានសូម្បីតែដៃ ប៉ុន្តែគេនៅតែមានការតស៊ូ។ យើងតែងតែមានអារម្មណ៍អាណិតខ្លួនឯង ព្រោះយើងពាក់ស្បែកជើងដាច់ដាចរហែករហូត ដល់ថ្ងៃមួយដែលយើងបានជួបនឹងមនុស្សដែលគ្មានសូម្បីតែជើង ប៉ុន្តែគេនៅតែអាចដើរទៅមុខបាន។

ខ្ញុំជាមនុស្សខ្សោយមែន គឺខ្សោយព្រោះតែខ្ញុំជាមនុស្សដែលគ្មានសញ្ញាបត្របរិញ្ញា គ្មានសញ្ញាបត្រថ្នាក់អនុបណ្ឌិត គ្មានសញ្ញាបត្រថ្នាក់បណ្ឌិត និងគ្មានកិត្តិយសនៅក្នុងសង្គមតែខ្ញុំ តែខ្ញុំមិនមែនជាជនរងគ្រោះទេ។
ឡាំ លីម

## ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

ខ្ញុំតែងតែស្តាប់ការត្អូញត្អែរពីមនុស្សដែលមានការអប់រំខ្ពស់ ទាំងឡាយនិយាយពីបញ្ហាជីវិតគេប្រាប់ខ្ញុំជារឿយៗថា *"ជីវិតគេលំបាក និងកំសត់ណាស់..."* ។ ប៉ុន្តែចំពោះខ្ញុំវិញ ខ្ញុំឥតត្រូវការឲ្យនរណាម្នាក់អាណិតខ្ញុំទេ ហើយខ្ញុំក៏មិនចង់ ទទួលងារជា *"ជនរងគ្រោះ ឬជាជនគួរឲ្យអាណិតដែរ"*។

សូមចងចាំថា *"ការបានកើតមកជាមនុស្សលោកម្នាក់នឹង គេ [ Human Beings ] គឺសំណាងជាងសត្វលោកទាំងពួង [ Beings ] ពីព្រោះមនុស្ស គឺជាសត្វចម្រើននិយម ឬ វឌ្ឍនិយម ឬ Being of Progressivism"* ។ ដូច្នេះ ចូរខិតខំ ប្រឹងប្រែងប្រព្រឹត្តទង្វើជាមនុស្ស [ Human Doing ] ដែល តែងតែដើរទៅមុខរកភាពចម្រើនរុងរឿង ៕

# ថ្ងៃទី២៩ ខែមករា

*"ចូរប្រើពេលវេលាសន្តិភាពឲ្យមានប្រសិទ្ធិភាព។ គ្រប់សមរភូមិសង្គ្រាមសង្គមទាំងឡាយ តែងតែបញ្ចប់ទៅវិញដោយសន្តិភាព គ្រាន់តែមុន ឬក្រោយប៉ុណ្ណោះ"*។ ពេលវេលាសន្តិភាពតិចតួចយ៉ាងណាក្តី ក៏ត្រូវទាញយកប្រយោជន៍ដោយខិតខំស្តារស្ថានភាពនៃជីវិតដោយត្រូវសិក្សាឡើងវិញពីអតីតកាល ធ្វើសកម្មភាពបច្ចុប្បន្ន រៀបចំអនាគត និងកុំចំណាយពេលសប្បាយដាច់បង្ហៀរភ្លេចខ្លួន និងភ្លេចការឈឺចាប់អតីតកាលឲ្យសោះ។

ពេលក្រកុំអស់សង្ឃឹម ពេលមានកុំភ្លើតភ្លើន។ ការរៀនពីប្រវត្តិសាស្ត្រ មិនថាជាប្រវត្តិសាស្ត្រមនុស្ស ឬក៏ប្រទេសគឺមិនមែនរៀនដើម្បីស្អប់ ឬការស្រឡាញ់ទេ តែរៀនដើម្បីកុំឲ្យជាន់ដានចាស់។ បើភ្លេចប្រវត្តិសាស្ត្រគឺប្រវត្តិសាស្ត្រនឹងកើតម្តងទៀតជាន់ដានចាស់។កុំភ្លេចការឈឺចាប់សង្គមបើមិនអ៊ីចឹងទេ សេចក្តីឈឺចាប់សង្គមនឹងអាចនិមិត្តខ្លួនឡើងម្តងទៀតដល់យើងឬដល់អនុជនជំនាន់ក្រោយរបស់យើង។

ឡាំ លីម

ឬដល់អនុជនជំនាន់ក្រោយរបស់យើង។ បុរាណខ្មែរបាន ពោលថា *"កុកអាចភ្លេចជង់ តែជង់ពុំដែលភ្លេចកុកទេ"*។ "The time to repair the roof is when the sun is shining."- John F Kennedy

# ថ្ងៃទី៣០ ខែមករា

បណ្ឌិត សាមញ៉ូអែល ចនសាន់ [ Dr. Samuel Johnson ] ពោលថា *"កិច្ចការងារអស្ចារ្យ [ Great work ] មិនមែនបានមកដោយសារភាពខ្លាំងអស្ចារ្យ [ Great strength ] របស់យើងនោះទេ តែបានមកដោយសារការតស៊ូននៀលយ៉ាងអស្ចារ្យ [ Great perseverance ] របស់យើង"*។

យើងអាចឈ្នះដោយសារ *"ភាពខ្លាំង"* ហើយយើងក៏អាចចាញ់ដោយសារ "ការបោះបង់" បានដែរ។ ខ្លាំងគឺល្អ តែតែមិនងាយបោះបង់ចោល គឺល្អជាង ហើយបើខ្លាំងបូកនឹងមិនងាយបោះបង់ គឺអស្ចារ្យខ្លាំង។ មនុស្សខ្លាំងពិតប្រាកដគឺជាមនុស្សពូកែតស៊ូដល់ដំណាក់ឈាមចុងក្រោយ ហើយការតស៊ូអត់ធ្មត់ គឺជារូបមន្តចុងក្រោយនៃភាពជោគជ័យ។ ពេលខ្លះ យើងដើរទៅមុខទាំងឈឺ។ ពេលខ្លះ យើងដើរទៅមុខទាំងទឹកភ្នែក។ ពេលខ្លះយើងត្រូវដើរទៅមុខទាំងស្រក់ឈាមតែការតស៊ូគង់បានសម្រេច ពីព្រោះឲ្យតែយើងចេះតស៊ូនឹងការលំបាកក្នុងជីវិត នោះជីវិតនឹងងាយស្រួល។

មានតែអ្នកធ្លាប់ញ៉ាំអំបិល និងស្ករទេ ដែលដឹងជាតិប្រៃ និងផ្អែម តែអ្នកក្រៅពីនោះ សូមស្តាប់ និងរៀនពីទ្រឹស្តីសិនចុះ ។សូម្បីតែខ្ញុំខ្លួនឯងជាអ្នកសរសេរ ក៏មិនមែនអង្គុយស្រមៃសរសេរ ឬបានគេងយល់សប្តិពីយប់ ហើយបន្ទាប់សរសេរចេញនោះទេតែដោយសារបទពិសោធន៍ជាក់ស្តែង៕

# ទស្សនៈសម្រាប់ខែ

# កុម្ភៈ

# ថ្ងៃទី០១ ខែកុម្ភៈ

*"ការចេះផ្ដល់តម្លៃដល់ខ្លួនឯង គឺមានន័យថា យើងកំពុងតែប្រយុទ្ធតស៊ូដើម្បីសុភមង្គលក្នុងជីវិតយើង"*។ យើងអាចលះបង់ដើម្បីនរណាម្នាក់ តែមនុស្សដែលធ្វើខ្លួនមិនសាកសមនឹងការលះបង់របស់យើង នោះយើងត្រូវដកគេចេញពីជីវិតយើង។ ពេលខ្លះ ការដកនរណាម្នាក់ចេញពីជីវិតយើង មិនមែនមានន័យថាយើងស្អប់គេនោះទេតែគ្រាន់តែចង់បញ្ជាក់ថាយើងចេះស្រឡាញ់ខ្លួនឯងប៉ុណ្ណោះ។

រឿងខ្លះ វាពុំមែនជារឿងមេឃរលំភ្នំរលាយអ្វីទេ ហើយក៏គ្មានអ្វីដែលមិនអាចដូរថ្មីបានដែរ។ ធ្វើចិត្តឲ្យដាច់ស្រេច កុំស្ទាក់ស្ទើរបើស្ថិតក្នុងកាលៈទេសៈដែលត្រូវធ្វើបែបនោះ។ ខ្មែរយើងតែងនិយាយតគ្នាថា *"ចិត្តមិនដាច់ ធ្វើស្ដេចមិនកើត"*។ នយោបាយវិទូ អ៊ីតាលី ពោលថា "នៅតាមមាគ៌ាទៅរកភាពជោគជ័យរបស់យើងម្នាក់ៗ គឺវាមិនប្រាកដថាគ្មានអ្នករងគ្រោះដោយសារតែយើងនោះទេ វាគ្រាន់តែមានតិច ឬមានច្រើនប៉ុណ្ណោះ"។

"Learn to value yourself, which means: fight for your happiness."- Ayn Rand

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី០២ ខែកុម្ភៈ

សូក្រាត [ Socrates ] ពោលថា *"ខ្ញុំដឹងថា អ្នកទាំងអស់គ្នានឹងមិនជឿខ្ញុំទេ។ តាមពិតទៅ ការពូកែដាក់សំណួរសួរខ្លួនឯង និងសួរអ្នកដទៃ គឺជាទម្រង់ខ្ពង់ខ្ពស់បំផុតនៃឧត្តមភាពចំណេះដឹងរបស់មនុស្សជាតិ"*។

មាននិទានមួយថា៖ គ្រាមួយលោកអាល់ប៊ឺត អាញស្តាញ [ Albert Einstein ] ជាអ្នកវិទ្យាសាស្ត្រដ៏មានឥទ្ធិពលម្នាក់ត្រូវបានគេសួរសំណួរមួយថា *"តើមួយម៉ែយ៍មានប៉ុន្មានហ្វីត"?* អាញស្តាញឆ្លើយថា *"ខ្ញុំមិនដឹងទេហើយហេតុអ្វីខ្ញុំត្រូវចាំទិន្នន័យទាំងអស់នេះដែលនាំឲ្យរំខានខួរក្បាលរបស់ខ្ញុំ ក្នុងខណៈដែលខ្ញុំអាចស្វែងរកចម្លើយបាន ក្នុងពេល ២នាទី ពីសៀវភៅយោងជាច្រើននោះ"*។

សូក្រាត[Socrates]និងអាញស្តាញបង្រៀនយើងឲ្យដឹងថា *"សមត្ថភាពដែលប្រើការគិត ពិតជាមានតម្លៃច្រើនជាងសមត្ថភាពត្រឹមតែចាំនិន្នន័យ និងតួលេខច្រើន"*។

ចម្លល់ គឺជាប្រភពនៃគតិបណ្ឌិត។ មនុស្សដែលចាំត្រឹមតែនិន្ន័យ និងតួលេខបានច្រើន គឺមិនហៅថាមនុស្សឆ្លាតទេ តែអ្នកឆ្លាតពិតប្រាកដ គឺអ្នកពូកែសួរ និងអ្នកពូកែគិតអ្វីឲ្យផ្សេងពីអ្នកដទៃ។ ពិភពលោករីកចម្រើន ក៏មានចំណែកក្រុមមនុស្សគិតបែកធ្វេងដែរ។ គំនិតបែកធ្វេង តែងកើតចេញពីសំណួរបែកធ្វេង៕

# ថ្ងៃទី០៣ ខែកុម្ភៈ

អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] យល់ថា "*ការរៀនពីប្រវត្តិសាស្ត្រ គួរតែរៀនដោយអព្យាក្រិត ដោយមិនលំអៀងសិក្សាពីប្រភពដាក់លាក់ជៀសវាងការសិក្សាខុស ឬកាឡៃបំភ្លៃប្រវត្តិសាស្ត្រ*"។ មេដឹកនាំរុស្ស៊ី លោក ប្លាឌីមៀរ ពូទីន [ Vladimir Putin ] និយាយថា "*ខ្ញុំមិនអានសៀវភៅទាំងឡាយណា ដែលសរសេរដោយជនក្បត់ជាតិនោះទេ*"។

ជនក្បត់ជាតិ គឺមានន័យដល់អ្នកនិពន្ធទាំងឡាយណា ដែលសរសេរប្រវត្តិសាស្ត្រ ដោយមាននិន្នាការនយោបាយ ឬសរសេរដោយអគិតទាំងបួន។ សូមប្រយ័ត្នចំពោះមនុស្ស ដែលអានសៀវភៅប្រវត្តិសាស្ត្រតែមួយក្បាល។ វាល្អមើល តែមិនល្អស៊ី...។ ស្អាតកាយ តែចិត្តពឹសពុល...។ រូបកាយនៅរស់ ប៉ុន្តែចិត្តគំនិត និងឧត្តមគតិស្លាប់។ ធ្វើជាចិត្តល្អ តែរំពឹងផលប្រយោជន៍តបស្នង...។ មានគំនិតដែរ តែឲ្យគេគ្រប់គ្រង...។ ចេះដឹកនាំ តែគ្មានអ្នកដើរតាម ប្រៀបដូចដើរលេង...។

រស់បាន តែឆាប់ស្លាប់...។ មានឆន្ទៈល្អ ប៉ុន្តែបែរជាសុខចិត្តរស់ក្រោមឆន្ទៈមនុស្សអាក្រក់ទៅវិញ។ ស្រមៃចង់មានការផ្លាស់ប្តូរ ប៉ុន្តែបែរជាមានចិត្តកំសាកខ្លាចស្លាប់ទៅវិញ...៕

# ថ្ងៃទី០៤ ខែកុម្ភៈ

ប្លាតូ [ Plato ] ពោលថា *"យើងត្រូវប្រើជីវិតរស់នៅឲ្យដូចជាការកម្សាន្តសប្បាយ"*។ សមីការជីវិតរបស់ អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] គឺ *"បើ A ជាបុគ្គលជោគជ័យក្នុងជីវិត នោះ A ស្មើឲ្យ x បូក y បូក z ។ តាង x គឺការងារ ។ តាង y គឺជាការលេងកម្សាន្ត និងតាង z គឺជាការមិននិយាយច្រើនឥតប្រយោជន៍"*។

ការក្លាយជាបុគ្គលជោគជ័យម្នាក់ គឺត្រូវមានកត្តាបីខាងលើ។ មានការប្រកបការងារផង [ x ] មានការលេងកម្សាន្តផង [ y ] នោះវាជារឿងធម្មតានៃជីវិតមនុស្សពីធម្មជាតិ។ យើងមិនមែនជាមនុស្សម៉ាស៊ីនដែលត្រូវតែគិតពីការងារគ្រប់វេលានោះទេ។ ចំណែកឯការនិយាយស្តី [ z ] គឺជាការប្រសើរត្រូវនិយាយឲ្យតិច ធ្វើឲ្យច្រើន ហើយធ្វើល្អប្រសើរជាងការគ្រាន់តែនិយាយល្អ។

បុគ្គលដែលកាន់តែជោគជ័យ គេដឹងកាន់តែច្បាស់ថា ការនិយាយឲ្យកាន់តែតិច និងធ្វើឲ្យច្រើនជារឿងប្រពៃ និងមានប្រយោជន៍ជាង។ ត្រូវចងចាំថា ពេលរៀន គឺរៀន, ពេលធ្វើការ គឺធ្វើការ ហើយពេលលេង គឺលេង តែសូមកុំច្របល់គ្នាក្នុងពេលតែមួយឲ្យសោះ៕

*"Life must be lived as play."* - Plato

# ថ្ងៃទី០៥ ខែកុម្ភៈ

មហាត្មៈ គន្ធី [ Mahatma Gandhi ] ពោលថា *"យើងត្រូវតែហ៊ានស្លាប់ ដើម្បីគ្រួសាររស់ ហើយគ្រួសារត្រូវតែហ៊ានស្លាប់ ដើម្បីជាតិរស់"*។ បុរាណខ្មែរក៏បានបន្សល់ពុំនោលមួយថា *"លះបង់មនុស្សម្នាក់ ដើម្បីគ្រួសារមួយ។ លះបង់គ្រួសារមួយ ដើម្បីភូមិស្រុក ហើយលះបង់ភូមិស្រុក ដើម្បីស្រុកទេស"*។

ករណីកិច្ចមនុស្សរស់នៅក្នុងសង្គមមាន ៣យ៉ាង៖
ទី១. ករណីកិច្ចចំពោះខ្លួនឯង គឺត្រូវធ្វើយ៉ាងណាឲ្យខ្លួនឯងមានចំណេះដឹង រីកចម្រើន។

ទី២. ករណីកិច្ចចំពោះគ្រួសារ គឺបន្ទាប់ពីជួយខ្លួនឯងបានហើយ ត្រូវជួយបងប្អូន ឬគ្រួសារឲ្យរីកចម្រើនដែរ។

ទី៣. ករណីកិច្ចចំពោះសង្គមជាតិ គឺបន្ទាប់ពីចប់ករណីកិច្ចចំពោះគ្រួសារហើយ ត្រូវធ្វើយ៉ាងណាគិតដល់សង្គមជាតិ។

ប៉ុន្តែក្នុងករណីចាំបាច់ មនុស្សត្រូវហ៊ានលះបង់ខ្លួនឯងម្នាក់ដើម្បីគ្រួសារ ហើយក៏ត្រូវហ៊ានលះបង់គ្រួសារមួយ ដើម្បីសង្គមជាតិផងដែរ ដោយសារបើគ្មានជាតិ ក៏គ្មានមនុស្សនិងក្រុមគ្រួសារដែរ។

ក្នុងសង្គមខ្មែរ ឲ្យតែយុវជនកុំឈឺដោយជំងឺសម្ភារនិយម កុំឈឺដោយជំងឺស្នេហា កុំឈឺដោយជំងឺខ្ជិលរៀន និងកុំឈឺដោយជំងឺវង្វេងប្រវត្តិសាស្ត្រ គឺគ្រប់គ្នានឹងក្លាយទៅជាធនធានមានតម្លៃរបស់សង្គមក្នុងរយៈពេល ១០ ឬ២០ ឬ៣០ ឆ្នាំខាងមុខ។ យើងមិនអាចក្លាយទៅជាយុវជនដែលមានសមត្ថភាពខ្លាំងក្នុងពេលបច្ចុប្បន្ននេះ តែយើងអាចរៀបចំខ្លួនយើងក្នុងពេលបច្ចុប្បន្ននេះ ឲ្យខ្លាំងសម្រាប់ពេលអនាគតខាងមុខបាន។

យើងមិនអាចមានយុវជនខ្លាំងក្នុងថ្ងៃនេះ តែយើងអាចរៀបចំយុវជនថ្ងៃនេះឲ្យខ្លាំង សម្រាប់ថ្ងៃអនាគតបាន។ យុវជនខ្មែរគួរតែត្រូវមានទាំងចំណេះដឹង និងឧត្តមគតិ ពីព្រោះបើមានតែចំណេះដឹង តែខ្វះឧត្តមគិត គឺចំណេះដឹងនឹងប្រើដើម្បីតែយកឋានៈបុណ្យសក្តិអំណាចខ្លួនឯង ហើយប្រសិនបើមានឧត្តមគតិ ប៉ុន្តែខ្វះចំណេះដឹងវិញ គឺនឹងត្រូវពួកអ្នក

នយោបាយ អាក្រក់បោកប្រាស់ប្រើជាក់ជាពុំខាន។ ធ្វើជាមនុស្សធម្មតា មានទេពកុសល្យ និងឧត្តមគតិ ប្រសើរជាងធ្វើជាមនុស្សអស្ចារ្យ មានទេពកុសល្យ តែលក់ឧត្តមគតិ ឬគ្មានឧត្តមគតិ៕

*"Duties to self, to the family, to the country. In the final analysis we must die that the family may live, the family must die that the country may live."*

- Mahatma Gandhi.

# ថ្ងៃទី០៦ ខែកុម្ភៈ

"លទ្ធិប្រជាធិបតេយ្យ គឺជាដីកាស្តីបន្ទោសទៅដល់ក្រុមអ្នកដឹកនាំដែលប្រជាជនសម្រេចចិត្តជ្រើសរើសយកមកបម្រើខ្លួន" ។

អ្នកនយោបាយដែលអសមត្ថភាពក្នុងការអភិវឌ្ឍន៍សង្គមជាតិ តែងបង្ហាញសារថ្លែងអំណរគុណដល់ប្រជាពលរដ្ឋដែលបោះឆ្នោតឲ្យខ្លួន ពីព្រោះខ្លួនគ្មានលទ្ធភាពធ្វើឲ្យប្រជាជនអរគុណខ្លួនវិញ។ តែអ្នកនយោបាយតួឯកនិយមជ្រុល តែងចោទប្រកាន់ និងស្តីបន្ទោសប្រជាជនដែលមិនបោះឆ្នោតឲ្យខ្លួនថា ប្រជាពលរដ្ឋល្ងង់ខ្លៅ គឺល្ងង់ដោយសារមិនទម្លាក់សន្លឹកឆ្នោតឲ្យខ្លួន។

ពេលខ្លះ អ្នកដឹកនាំដែលអរគុណប្រជាពលរដ្ឋ អាចជាមនុស្សបោកប្រាស់ ហើយអ្នកដែលប្រជាពលរដ្ឋអរគុណ ប្រហែលដោយសារអ្នកដឹកនាំនោះមានស្នាដៃ និងភាពស្មោះត្រង់ពិតប្រាកដ។ ក្នុងប្រទេសដែលមានប្រជាជនខ្វះការអប់រំ គឺពិតជាត្រូវការខ្លាំងបំផុតនូវមេដឹកនាំដែលភាពស្មោះត្រង់៕

"Democracy is the process by which people choose the man who'll get the blame."- Bertrand Russel

# ថ្ងៃទី០៧ ខែកុម្ភៈ

*"បណ្ឌិតជនគង់នឹងឥតរំភើបចំពោះពាក្យសរសើរ ឬញាប់ញ័រអន់ចិត្តនឹងពាក្យរិះគន់ ប្រៀបដូចជាភ្នំថ្មដ៏រឹងមាំដែលមិនងាយញាប់ញ័រ ដោយសារខ្យល់ធំ"។*

ពេលខ្លះ មនុស្សដែលតែងតែពេញចិត្តនឹងការសរសើរជ្រុលពេក គង់នឹងមានអំណួតខ្លួន ហើយមនុស្សដែលខឹងសម្បារនឹងការរិះគន់ គង់នឹងក្តួតឈាមស្លាប់។ មានតែជីវិតដែលស្គាល់ពីខ្លួនឯងច្បាស់ទេ ទើបជាជីវិតដែលរស់នៅមានសេចក្តីសុខពិត។ បុគ្គលដែលអាចគ្រប់គ្រងការសសើរ និងការរិះគន់របស់អ្នកដទៃបាន គឺជាមនុស្សដែលអាចរៀនសូត្របានច្រើនបំផុត ហើយឥតភ្លេចខ្លួនទេ៕

"As a solid rock is not shaken by the wind, even so the wise are not ruffled by praise or blame."

-Buddha.

# ថ្ងៃទី០៨ ខែកុម្ភៈ

*"គេថាមនុស្សយើង សូមកុំទៅក្បែរមនុស្សអាក្រក់ ពីព្រោះនឹងនាំទុក្ខទោសដល់ខ្លួន តែការពិតទៅ ខ្ញុំថាព្រះអាទិត្យទៅដល់គ្រប់កន្លែងល្អ និងកន្លែងស្មោគគ្រោកទាំងអស់នៃផែនដី ប៉ុន្តែយើងគ្មានឃើញពន្លឺព្រះអាទិត្យខូចគុណភាព ឬស្មោគគ្រោកផង"។*

គ្រូពេទ្យតែងនៅជាមួយអ្នកជំងឺ ប៉ុន្តែយើងកម្រឃើញគ្រូពេទ្យក្លាយទៅជាឈឺណាស់។ គ្រូបង្រៀនតែងនៅជាមួយនឹងមនុស្សអវិជ្ជា តែយើងកម្រឃើញគ្រូបង្រៀនក្លាយទៅជាអវិជ្ជាណាស់។ តថភាពសង្គម គឺមានន័យថា បើចង់ជួយអ្នកក្រត្រូវប្រឹងខ្លួនឯងមានសិន ។បើចង់ជួយអ្នកទន់ខ្សោយត្រូវពង្រឹងខ្លួនឯងឲ្យរឹងមាំសិន តែបើមិនដូចនោះទេ យើងនឹងត្រូវរងសេចក្តីឈឺចាប់ដោយមជ្ឈដ្ឋានខាងក្រៅមិនខាន បើយើងមិនទាន់មានប្រៀបលើអ្វីមួយទេនោះ៕

# ថ្ងៃទី០៩ ខែកុម្ភៈ

*"ទេពកុសល្យ ឬអច្ឆរិយភាពគឺមួយភាគរយ (១%) កើតឡើងពីកម្លាំងជម្រុញចិត្ត ចំណែកឯកៅសិបប្រាំបួនភាគរយ (៩៩%) ទៀតគឺ កើតចេញពីញើសឈាមនៃការតាំងចិត្តព្យាយាមធ្វើ"។*

ជោគជ័យរបស់មនុស្ស គឺមួយភាគរយបានមកដោយសារភាពឆ្លាត តែកៅសិបប្រាំបួនទៀត បានមកដោយសារការប្រឹងប្រែង។ ទីណាមានការព្យាយាម ទីនោះតែងមានភាពជោគជ័យ។ ទីណាមានជោគជ័យ ទីនោះតែងមានដានជើងមនុស្សធ្លាប់បរាជ័យ។

នៅលើលោកនេះ ពុំមាននរណាម្នាក់ត្រូវស្លាប់ដោយសារតែការប្រឹងប្រែងរៀន ឬប្រឹងប្រែងធ្វើការងារដើម្បីជីវិតទេ មានតែមនុស្សដែលមនុស្សដែលឈប់ប្រឹងប្រែង ឬមិនប្រឹងប្រែងប៉ុណ្ណោះ ដែលរស់នៅយ៉ាងលំបាកវេទនាជាងការខំប្រឹងប្រែងតស៊ូ៕

ឡាំ លីម

"Genius is one percent inspiration and ninety-nine percent perspiration." - Thomas A. Edison

# ថ្ងៃទី១០ ខែកុម្ភៈ

ទស្សនវិទូ សូរិន កៀកឺហ្គាដ [ Soren Kierkegaard ] ពោលថា *"ផ្នែកម្ខាងនៃសច្ចធម៌ គឺសច្ចធម៌"* នៅផ្នែកម្ខាងនៃកាក់ គឺជាកាក់។ *"ខុស ឬត្រូវ"* គឺអាស្រ័យលើស្ថានភាព ឬទីតាំងជាក់ស្ដែង។ យើងថា *"ត្រូវ"* តែបើស្ថិតក្នុងស្ថានភាព ឬទីតាំងខុសនោះគឺខុស។ យើងថា *"ត្រូវ"* តែបើស្ថិតក្នុងស្ថានភាព ឬទីតាំងត្រូវ នោះគឺត្រូវ។

យើងថា *"ខុស"* តែបើស្ថិតក្នុងស្ថានភាព ឬទីតាំងត្រូវ នោះគឺត្រូវ។ យើងថា *"ខុស"* តែបើស្ថិតក្នុងស្ថានភាព ឬទីតាំងខុសនោះគឺខុស។ ដូច្នេះ ត្រូវ ឬខុស គឺអាស្រ័យលើស្ថានភាពជាក់ស្ដែង ឬទីតាំងជាក់ស្ដែង៕

# ថ្ងៃទី១១ ខែកុម្ភៈ

*"មានជំនឿ ឬគ្មានជំនឿគឺជាបញ្ហារបស់សាសនា ប៉ុន្តែកាលណាមនុស្សម្នាក់កាន់តែជឿលើអ្វីមួយខ្លាំងប៉ុនណា នោះការគិតក៏កាន់តែបិទជិតប៉ុណ្ណោះដែរ"។*

មនុស្សដែលឆាប់ជឿ គឺឆាប់កំណត់បញ្ហាលឿន ឆាប់វិនិច្ឆ័យបញ្ហាលឿន ហើយក៏ឆាប់ទោរទន់ទៅរកទំនាស់ទាំងក្នុងខ្លួន និងក្រៅខ្លួនលឿនដែរ។ មនុស្សដែលយល់ដឹងពីវិធីនៃការគិតពិតប្រាកដ គឺមិនងាយជឿស្លុងដោយខ្វះការពិចារណានោះទេ។ មុននឹងជឿគឺត្រូវគិតគូរល្អិតល្អន់បំផុត គិតលើ គិតក្រោម គិតឆ្វេង គិតស្តាំ និងគិតគ្រប់ទិសទាំងអស់។

ការពិត ឬសច្ចភាព មិនជាប់ទាក់ទងនឹងអ្វីទាំងអស់ តែជាប់ទាក់ទងនឹងពេលវេលា និងស្ថានភាពជាក់ស្តែងប៉ុណ្ណោះ។ *"ខុស ឬត្រូវ"* គឺអាស្រ័យលើស្ថានភាព ឬទីតាំងជាក់ស្តែងណាមួយ។ យើងថា *"ត្រូវ"* តែបើស្ថិតក្នុងស្ថានភាព ឬទីតាំងខុស នោះគឺខុស ហើយយើងថា *"ខុស"* តែបើស្ថិតនៅក្នុងស្ថានភាព ឬទីតាំងត្រូវ នោះគឺត្រូវ៕

ឡាំ លីម

# ថ្ងៃទី១២ ខែកុម្ភៈ

ទស្សនវិទូក្រិច អារីស្តូត [ Aristotle ] ពោលថា *"ភាពក្រីក្រ គឺជាកត្តាបង្កបង្កើតឲ្យមានបដិវត្តន៍ និងឧក្រិដ្ឋកម្ម"*។ មានតែមនុស្សដែលស្លាប់ក្នុងសង្គ្រាមប៉ុណ្ណោះ ទើបអាចមើលឃើញសង្គ្រាមសង្គមបានបញ្ចប់។

ក្នុងសង្គ្រាម គ្មានឧក្រិដ្ឋកម្មទេ តែក្នុងឧក្រិដ្ឋកម្មប្រៀបដូចនឹងសង្គ្រាម។ ប្រទេសដែលគ្មានសង្គ្រាម តែមានអំពើលួចឆក់ប្លន់ ការកាប់សម្លាប់ អំពើពុករលួយ លាបពណ៌ជេរប្រទេចគ្នា អសីលធម៌សង្គម ក្មេងឥតគោរពចាស់ទុំ ចាស់ទុំឥតបង្ហាញគំរូដល់ក្មេង គឺសង្គមនោះប្រៀបបាននឹងសង្គ្រាម។ នយោបាយ គឺជាសង្គ្រាមដែលគ្មានការបង្ហូរឈាម តែសង្គ្រាម គឺជានយោបាយដែលមានការបង្ហូរឈាម៕

*"Poverty is the parent of revolution and crimes."*

- Aristotle

# ថ្ងៃទី១៣ ខែកុម្ភៈ

*"ក្នុងជីវិតរស់នៅ ១០០ភាគរយ តែងមាន១០ភាគរយគឺជាបញ្ហាដែលកើតឡើងចំពោះយើង ហើយ ៩០ភាគរយទៀតគឺដំណោះស្រាយដែលយើងត្រូវឆ្លើយតបចំពោះបញ្ហាវិញ"*

។ ក្នុងច្បាប់ធម្មជាតិ អ្នកខ្លាំងតែងឈ្នះអ្នកខ្សោយ, ខ្លាំងគឺរស់ ខ្សោយគឺស្លាប់, ខ្លាំងគឺឈ្នះ ខ្សោយគឺចាញ់ ហើយខ្លាំងគឺស្តេច ខ្សោយគឺចោរ។

ចូរធ្វើជាចំណែកនៃដំណោះស្រាយ ប៉ុន្តែកុំធ្វើជាចំណែកនៃបញ្ហា។ គួរខំប្រឹងរៀនធ្វើជាអ្នកខ្លាំងតែកុំធ្វើជាអ្នកខ្សោយ។ ចូរធ្វើជាអ្នកជួយសង្គ្រោះ តែកុំធ្វើជាជនរងគ្រោះ។ ដើម្បីឈ្នះយើងត្រូវធ្វើខ្លួនឲ្យធំជាងបញ្ហាជានិច្ច។ បើបញ្ហាជាលេខ១០ នោះយើងត្រូវតែជាលេខ២០។ បើបញ្ហាជាដុំដី យើងត្រូវតែជាដុំថ្ម។ បើបញ្ហាជាដែកគោល យើងត្រូវធ្វើជាញញួរ។ បើបញ្ហាជាស្តេច នោះយើងត្រូវធ្វើជាអាទិទេព។

ក្នុងជីវិតមិនសំខាន់ថាបញ្ហាកើតឡើងអាក្រក់បែបណានោះទេ តែសំខាន់ថា តើយើងមានចិត្តស្ងប់ឆ្លើយតបចំពោះបញ្ហាបែបណា។ គ្រប់យ៉ាងវានឹងមិនអីនោះទេ។ គ្រប់យ៉ាង គឺធម្មតាជានិច្ច ហើយគ្រប់យ៉ាងគឺល្អជានិច្ច៕

*"Life is 10 percent what happens to you and ninety percent how you respond to it."* - Lou Holtz

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី១៤ ខែកុម្ភៈ

*"ភាពជោគជ័យ គឺជាការស្រឡាញ់ចូលចិត្តចំពោះខ្លួនឯង។ សេចក្តីស្រឡាញ់ចូលចិត្តចំពោះខ្លួនឯងគឺមានន័យថាយើងស្រឡាញ់អ្វីដែលយើងធ្វើ និងធ្វើអ្វីដែលយើងស្រឡាញ់"។*

សូមកុំប្រើជីវិតឲ្យរស់នៅក្រោមឆន្ទៈនរណាម្នាក់ឲ្យសោះ តែត្រូវរស់នៅក្នុងឆន្ទៈខ្លួនឯង។ សេចក្តីសុខនៃជីវិត ត្រូវរស់នៅក្នុងជីវិតដែលខ្លួនស្រឡាញ់ និងស្រឡាញ់ពេញចិត្តក្នុងជីវិតដែលខ្លួនរស់នៅ។ សេចក្តីសុខមាននៅគ្រប់ទីកន្លែងនៃផែនដី ហើយសេចក្តីសុខមនុស្សក្នុងផែនដី គឺត្រូវចេះរស់នៅពេញចិត្តចំពោះរបស់តិចតួច៕

"Success is liking yourself, liking what you do, and liking how you do it." - Maya Angelou

## ថ្ងៃទី១៥ ខែកុម្ភៈ

*"មនុស្សម្នាក់ដែលចាយវាយលុយកាក់ច្រើន ជាងចំណូលដែលរកបានគឺហៅថាមនុស្សឆ្កួត"* ។ ចំពោះរឿងលុយកាក់ សូមយើងកុំរស់នៅដោយចាយវាយប្រៀបដូចជាត្រូវស្លាប់ទៅវិញនៅថ្ងៃស្អែក ហើយក៏សូមកុំរស់នៅ ដោយចាយត្បិតត្បៀតប្រៀបដូចជាត្រូវមានជីវិតអមតៈឲ្យសោះ។ មនុស្សដែលយល់ថា ស្អែកខ្លួនត្រូវស្លាប់នឹងប្រឹងចំណាយដោយឥតគិត ហើយមនុស្សដែលយល់ថាខ្លួនគ្មានថ្ងៃត្រូវស្លាប់នឹងប្រឹងសន្សំកិបកេងមិនហ៊ានចាយវាយទាល់តែសោះ៕

*"A person who spends more than he earns is a fool"* - Visvesvaraya

# ថ្ងៃទី១៦ ខែកុម្ភៈ

ថូម៉ាស់ អេឌីសិន [ Thomas Ava. Edison ] ពោលថា *"ខ្ញុំមិនបានបរាជ័យទេ តែខ្ញុំគ្រាន់តែបានរកឃើញវិធីដែលមិនជោគជ័យប៉ុណ្ណោះ"។*

បរាជ័យ គឺជាផ្នែកមួយនៃជីវិតមនុស្ស។ មនុស្សដែលមិនធ្លាប់ទទួលបរាជ័យ នោះក៏មិនធ្លាប់រៀនពីបរាជ័យ ហើយមនុស្សដែលមិនបានរៀនពីបរាជ័យ ក៏នឹងមិនអាចរលាស់ពីចាញ់មកឈ្នះបានឡើយ។ ធ្លាប់បានព្យាយាម ធ្លាប់បានទទួលបរាជ័យ តែទោះជាយ៉ាងណា ក៏នៅតែព្យាយាមម្តងទៀត ហើយក៏បានបរាជ័យម្តងទៀត ក៏ប៉ុន្តែគឺត្រូវបរាជ័យឲ្យល្អជាងមុន។ បរាជ័យឲ្យល្អជាងមុន គឺយើងត្រូវតែរៀនពីបទពិសោធន៍បរាជ័យឲ្យបានច្រើន ហើយបន្ទាប់មកគឺរលាស់ខ្លួនទៅរកឧត្តមភាព៕

"I have not failed. I've just found 10,000 ways that won't work." -Thomas A. Edison

# ថ្ងៃទី១៧ ខែកុម្ភៈ

ទស្សនវិទូក្រិច អារីស្តូត [ Aristotle ] យល់ថា "មនុស្សជាអ្នកបង្កើតសង្គម ហើយសង្គមក៏បង្កើតមនុស្ស វិញ"។ ជីវិតដែលឥតន័យ គឺជាជីវិតដេកស៊ី និងស៊ីដេក។ ជីវិតដែលចាញ់បោកសង្គម គឺជាជីវិតមួយដែលមនុស្សខ្លះខំ ប្រឹងរស់សម្របខ្លួនទៅនឹងសង្គម បើទោះបីសង្គមដើរខុស មាគ៌ាត្រឹមត្រូវក៏ដោយ។ ក្នុងសម័យមហានរគរ សង្គមខ្មែរ រុងរឿង។ បន្ទាប់ពីសម័យក្រោយមក ស្តេចដណ្តើមរាជ្យ ហើយរហូតដល់ដំណាក់កាលចុងក្រោយ កូនរាស្ត្រដណ្តើម អំណាចគ្នា ធ្វើសង្គ្រាមបង្ហូរឈាមគ្នា ពីរបបសង្គមរាស្ត្រ និយម មករបបសាធារណរដ្ឋ ពីសាធារណរដ្ឋ មកជារបប កម្ពុជាប្រជាធិបតេយ្យ ពីរបបកម្ពុជាធិបតេយ្យ មកជារបប ប្រជាមានិតកម្ពុជា...។ល។

មូលហេតុដែលសង្គមប្តូររបប និងប្តូរអ្នកដឹកនាំជាញឹកញាប់ គឺដោយសារប្រជាជនមិនទាន់ប្តូរការគិត និងខ្វះមូលដ្ឋាន ពិចារណាតាមបែបទស្សនវិជ្ជា។

ក្រៅពីវប្បធម៌បរទេស និងពហុវប្បធម៌ ខ្មែរឈប់ស្គាល់ជាតុពិតខ្លួនឯង ឈប់ស្គាល់បងប្អូនឯង លាបពណ៌គ្នា ឌឺដងគ្នា បញ្ចើចបញ្ចៀរគ្នា និងឈ្លោះប្រកែកគ្នាតាមគំនិតមនោគមន៍វិជ្ជារៀងខ្លួន ៕

*"This City is what it is because our citizens are what they are."* - Plato

# ថ្ងៃទី១៨ ខែកុម្ភៈ

*"អំណាចនៃភាពរឹងមាំរបស់យើង កើតចេញពីទង្វើល្អរបស់យើង ហើយទង្វើល្អរបស់យើង វានឹងជម្រុញចិត្តគំនិតអ្នកដទៃ ឲ្យធ្វើសេចក្ដីល្អតាមយើងដែរ"។*

ចូរទុកសេចក្ដីភ័យខ្លាចក្នុងខ្លួនរបស់យើងចុះ ហើយចូរចែករំលែកទាំងអស់នូវកម្លាំងចិត្តរបស់យើងដល់អ្នកដទៃផង។ មនុស្សដែលចង់ក្លាយខ្លួនជាជនអស្ចារ្យ តែងតែធ្វើឲ្យអ្នកដទៃមានអារម្មណ៍តូចទាបជាងខ្លួន ប៉ុន្តែបុគ្គលដ៏អស្ចារ្យពិតប្រាកដតែងតែធ្វើខ្លួនតូចទាបជាងអ្នកដទៃ ហើយនឹងធ្វើឲ្យអ្នកដទៃមានអារម្មណ៍ខ្លាំងអស្ចារ្យជាងខ្លួន៕

*"Good actions give strength to ourselves and inspire good actions in others."* - Plato

# ថ្ងៃទី១៩ ខែកុម្ភៈ

*"សូមកុំជឿដោយសារតែអ្នកបានអានពីសៀវភៅណា, សូមកុំជឿដោយសារតែនរណាម្នាក់និយាយ, សូមកុំជឿដោយសារតែខ្ញុំនិយាយ តែសូមជឿដោយហេតុផល និងជឿដោយសុភនិច្ឆ័យរបស់អ្នក"*។

សេចក្ដីពិត មិនជាប់ទាក់ទងនឹងសម្ដី ឬគំនិតរបស់នរណាម្នាក់ទេ។ ប៉ុន្តែសេចក្ដីពិតនៅនឹងខ្លួនមនុស្សគ្រប់គ្នា។ នៅលើលោកនេះ មានសេចក្ដីពិតតែមួយគត់ នោះគឺ *"សេចក្ដីពិតសម្រាប់តែខ្លួនយើង"*។ មនុស្សយើងនាំគ្នាបង្កើតឲ្យមានសេចក្ដីពិតផ្សេងៗគ្នាដោយខ្លួនឯង។ នៅលើលោកនេះ មានសាសនាតែមួយគត់គឺ *"សាសនានៃសេចក្ដីស្រឡាញ់"* ប៉ុន្តែមនុស្សយើងនាំគ្នាជឿលើសាសនាផ្សេងៗ ដោយការរើសអើង និងខ្វះចិត្តសប្បុរសធម៌៕

*"Believe nothing, no matter where you read it, or who said it, no matter if I have said it, unless it agrees with your own reason and your own common sense."* - Buddha

## ថ្ងៃទី២០ ខែកុម្ភៈ

*"នៅពីក្រោយមិត្តភាព មនុស្សខ្លួនឯងតែងតែមានការទាញយកប្រយោជន៍ដើម្បីខ្លួនឯង ហើយបើទំនាក់ទំនងមិនមានប្រយោជន៍ទេ នោះភាពជាមិត្តក៏មិនកើតឡើងឡើយ"។*

មិត្តប្រែថាប្រយោជន៍ ហើយប្រយោជន៍ប្រែថាមិត្ត ពីព្រោះយើងគឺជាមិត្ត និងមិត្តគឺជាយើង។ គ្រប់យ៉ាងក្នុងលោកគឺជាវត្ថុតែមួយ ឬរបស់តែមួយ ពីព្រោះវាមានសម្ព័ន្ធជាប់ស្អិតនឹងគ្នា។ ព្រះពុទ្ធ, សូក្រាត, ខុង ជឺ, ព្រះយ៉េស៊ូគ្រីស្ទ និងអ្នកប្រាជ្ញជាច្រើនបង្រៀនថា *"មិនឲ្យយើងធ្វើទង្វើណាដែលយើងមិនចង់ឲ្យអ្នកដទៃធ្វើដាក់យើង"* សច្ចភាពនៃទំនាក់ទំនង គឺដើម្បីប្រយោជន៍ បើមិនដើម្បីប្រយោជន៍ណាមួយ ក៏ដើម្បីប្រយោជន៍ណាមួយផ្សេងទៀតដែរ តែអ្វីដែលសំខាន់ គឺគ្រប់គ្នាព្រមព្រៀងគ្នាពេញចិត្តទទួលយក។

*"There is some self-interest behind every friendship. There is no friendship without self-interests. This is a bitter truth."* - Chanakya

# ថ្ងៃទី២១ ខែកុម្ភៈ

*"អ្នកម្ដាយខ្ញុំនិយាយថា បើខ្ញុំធ្វើជាទាហាន ខ្ញុំនឹងក្លាយខ្លួនទៅជាឧត្ដមសេនីយ៍ ហើយបើខ្ញុំបួសជាព្រះសង្ឃ ខ្ញុំនឹងក្លាយទៅជាសម្ដេចប៉ាប។ ប៉ុន្តែទីបំផុតខ្ញុំបានក្លាយទៅជាវិចិត្រករ ហើយក៏នឹងក្លាយជាខ្ញុំខ្លួនឯង ប៉ាប្លូ ពីកាសូ [ Pablo Picasso ]"។*

ស្រឡាញ់អ្វីដែលយើងចង់ធ្វើ ហើយធ្វើអ្វីដែលយើងខ្លួនឯងស្រឡាញ់។ កុំធ្វើការងារណាដែលយើងមិនបានស្រឡាញ់ ពីព្រោះវានឹងធ្វើឲ្យយើងស្លាប់ទាំងរស់។ ស្លាប់ទាំងរស់គឺដោយសារមនុស្សយើង រស់នៅជាមួយការងារស្ទើរពេញមួយជីវិត។ បើមួយជីវិតយើង ធ្វើការងារដែលខ្លួនមិនបានស្រឡាញ់ នោះគឺស្លាប់ទាំងរស់។

*"My mother said to me, 'If you are a soldier, you will become a general. If you are a monk, you will become the Pope.' Instead, I was a painter, and became Picasso."* - Pablo Picasso

# ថ្ងៃទី២២ ខែកុម្ភៈ

*"ជីវិត គឺជាកម្មសិទ្ធរបស់ដំណើរនៃការរស់នៅ ហើយដើម្បីឲ្យមានជីវិតរស់នៅបន្តទៅទៀតបាន លុះត្រាតែយើងបានត្រៀមខ្លួនទុកមុនក្នុងការផ្លាស់ប្តូរ"*។

គ្រប់យ៉ាងតែងផ្លាស់ប្តូរ ហើយមានតែការផ្លាស់ប្តូរប៉ុណ្ណោះដែលមិនផ្លាស់ប្តូរ។ គ្រប់យ៉ាងតែងមានទីបញ្ចប់ ហើយមានតែទីបញ្ចប់ប៉ុណ្ណោះ ដែលមិនចេះចប់។ មនុស្សដែលភ័យខ្លាចក្នុងការផ្លាស់ប្តូរ នោះគេបានបរាជ័យក្នុងការផ្លាស់ប្តូររួចទៅហើយ។ មនុស្សដែលបរាជ័យក្នុងការផ្លាស់ប្តូរ នោះគេនឹងមិនទទួលបានការផ្លាស់ប្តូរអ្វីទាំងអស់។ ចង់ប្តូរអ្វីក៏ដោយ គឺត្រូវប្តូរខ្លួនឯងជាមុនសិន គឺប្តូរពីខ្លាចមកហ៊ាន។ ប្តូរពីហិង្សាមកអហិង្សា, ប្តូរពីបែកបាក់មកសាមគ្គី។ ប្តូរពីលាបពណ៌មកយោគយល់។ ប្តូរពីស្អប់មកស្រឡាញ់ និងប្តូរពីឈ្នះម្នាក់ឯងមកឈ្នះទាំងអស់គ្នា៕

*"Life belongs to the living, and he who lives must be prepared for changes"* - Goethe

# ថ្ងៃទី២៣ ខែកុម្ភៈ

អាល់ប៊ឺត កាមុស [ Albert Camus ] ពោលថា *"ពុំមានអ្វីដែលគួរឲ្យស្អប់ខ្ពើមខ្លាំងបំផុតជាងសេចក្ដីគោរពរាប់អានគ្នា ដោយសារតែខ្លាចអំណាចគ្នានោះទេ"*។

ពេលអ្នកមានអំណាច បុណ្យសក្ដិ និងមានទ្រព្យសម្បត្តិ នោះមនុស្សគ្រប់គ្នានឹងស្គាល់អ្នក តែដល់ពេលដែលអ្នកអស់អំណាច អស់បុណ្យសក្ដិ និងអស់ទ្រព្យសម្បត្តិ នោះអ្នកនឹងស្គាល់មនុស្សគ្រប់គ្នាវិញ។

បើទោះបីជាយើងជាមនុស្សអស្ចារ្យយ៉ាងណាក៏ដោយ បើយើងសុខចិត្តធ្វើខ្លួនជាមនុស្សសាមញ្ញ នោះយើងក៏នឹងទទួលបានការគោរពរាប់អានពីមនុស្សផងគ្នាបែបសាមញ្ញ ហើយយូរអង្វែងជាង។ ក្នុងគម្ពីរសាសនាគ្រីស្ទ [ Bible ] បានលើកឡើងថា *"ចូរបេះដាក់ខ្លួនឲ្យទាប នោះនឹងទទួលបានការគោពលើកតម្កើងយ៉ាងខ្ពស់"*។

ចូរគោរពមនុស្ស និងឲ្យតម្លៃមនុស្សក្នុងឋានៈស្មើគ្នាជាមនុស្ស ដោយមិនគិតខ្វល់ថាមនុស្សនោះជាអ្នកសុំទាន ឬជានាយករដ្ឋមន្ត្រីនោះឡើយ។ អ្នកដែលមានឋានៈខ្ពស់ក្នុងសង្គម ចូរចងចាំថា គ្រប់គ្នាគោរពឋានៈសង្គមរបស់អ្នកប៉ុណ្ណោះ តែមិនមែនគោរពអ្នកទេ។ គ្រប់គ្នានឹងគោរពអ្នកលុះត្រាតែអ្នកចេះគោរពគេដែរ៕

# ថ្ងៃទី២៤ ខែកុម្ភៈ

វ៉ុលទែរ [ Voltaire ] ពោលថា "*ពេលខ្ញុំអានកាន់តែច្រើន ខ្ញុំសញ្ជឹងគិតពិចារណាកាន់តែជ្រៅខ្លាំង ហើយពេលខ្ញុំសញ្ជឹងគិតពិចារណាកាន់តែជ្រៅខ្លាំង គឺខ្ញុំក៏កាន់តែទទួលស្គាល់ខ្លួនឯងកាន់តែច្បាស់ខ្លាំងដែរថា ខ្ញុំមិនចេះអ្វីសោះ*"។

អ្នកដែលអានសៀវភៅច្រើន ដោយមិនចំណាយពេលគិតពិចារណាមានកំហុសស្មើនឹងអ្នកគិតច្រើន ដោយមិនបានអាន។ មនុស្សដែលគិតច្រើនដោយគ្មានមូលដ្ឋានគោលការណ៍ គឺតែងបង្កបញ្ហា និងមេរោគដល់ចិត្តគំនិតរបស់ខ្លួនឯងជានិច្ច។ អ្នកខ្លះអះអាងថា ស្ថានភាពប្រែប្រួល កាលៈទេសៈផ្លាស់ប្តូរ។ ដូច្នេះមនុស្សក៏ត្រូវផ្លាស់ប្តូរទៅតាមស្ថានភាព និងកាលៈទេសៈដែរ។ ប៉ុន្តែចំពោះខ្ញុំយល់ថា "មនុស្សទៅវិញទេ ដែលជាប្រធាននៃការផ្លាស់ប្តូរគ្រប់យ៉ាងទាំងឡាយក្នុងលោក"។ អវិជ្ជា គឺជាប្រភពនៃអកុសលទាំងឡាយ៕

# ថ្ងៃទី២៥ ខែកុម្ភៈ

*"បើគ្រប់យ៉ាងលើលោកយើងនេះ មិនងាយស្រួលសម្រាប់យើងធ្វើទេ សុំត្រឹមតែអ្វីដែលយើងធ្វើនោះមានតម្លៃទៅបានហើយ"។*

បញ្ហាខ្លះត្រូវយកអាយុជីវិតមកដោះស្រាយ ប៉ុន្តែនៅតែមានមនុស្សហ៊ានដោះស្រាយ បើទោះបីជាត្រូវបាត់បង់ជីវិតក៏ដោយ។ មូលហេតុគឺមិនមែនដោយសារកិច្ចការនោះវាងាយស្រួលទេ តែដោយសារកិច្ចការនោះមានតម្លៃត្រូវធ្វើ។ ការលះបង់ដ៏ធំធេងបំផុត គឺការលះបង់ជីវិត ព្រោះបើអស់ជីវិតគឺគ្រប់យ៉ាងក៏បាត់បង់ដែរ៕

*"I'm not telling you it's going to be easy - I'm telling you it's going to be worth it."*

- Arthur Williams

# ថ្ងៃទី២៦ ខែកុម្ភៈ

*"ពេលខ្លះមនុស្សប្រុសយល់ខុសស្រទ្បះពីមនុស្សស្រី ព្រោះមនុស្សស្រីរកវិធីរៀនឲ្យពូកែ និងអភិវឌ្ឍន៍សមត្ថភាពដើម្បីបានខ្ពង់ខ្ពស់ឈានដល់ការចេះគ្រប់គ្រងខ្លួន ប៉ុន្តែប្រុសខ្លួនឯងវិញ គិតតែពីរឿងស្នេហានិងស្វែងរកវិធីឲ្យបាននៅក្បែរស្រីៗប៉ុណ្ណោះ"*។ ស្រីៗខ្លួនឯងគិតថា កើតមកជាស្រីស្អាតជាសំណាងណាស់ ហើយជាព្រេងល្អខ្លាំងណាស់ តែខ្ញុំគិតថា មនុស្សខ្លះដែលកើតមកជាស្រីស្អាត គឺអភ័ព្វទៅវិញទេ ពីព្រោះថាមនុស្សស្រីខ្លះស្រឡាញ់រូបសម្បត្តិស្អាតល្អជាងសមត្ថភាពដែលមានកែវភ្នែកល្អចេះមើលបុរសល្អ។

កាលដែលគ្មានសមត្ថភាពមើលបុរសល្អ ឬគ្មានកែវភ្នែកល្អមើលបុរសល្អ គឺជាហេតុបណ្ដាលឲ្យស្រីជួបមនុស្សប្រុសដែលមានមុខគ្រប់ប្រភេទ និងសម្ដីបោកប្រាស់គ្រប់ស្នៀត។ មនុស្សស្រី ទោះជាចង់ឬមិនចង់ ប្រហែលជាត្រូវចូលក្នុងកន្ទុកព្រានសិន ទើបរកមនុស្សល្អឃើញ។

ចង់រកមនុស្សល្អពិត ត្រូវរកពេលខ្លួនជុនដាប រកពេលខ្លួនគ្មានអ្វីសោះ ទើបអាចដឹងថា អ្នកណាស្មោះ ឬអ្នកណាត្រឹមតែចង់លេងសើចជាមួយយើង៕

# ថ្ងៃទី២៧ ខែកុម្ភៈ

*"មនុស្សខ្ជិល និងមនុស្សឧស្សាហ៍ខុសគ្នាត្រង់អ្នកឧស្សាហ៍ គឺឆ្លាតខាងចេះប្រឹងប្រែង [ Courageous Intelligent ] ស្របពេលដែលអ្នកល្ងង់ ចេះតែចង់បាន តែស្រឡាញ់ភាពខ្ជិលស្អឹកប្រអូស"។*

ចង់រៀនចេះ ឲ្យប្រឹងរៀន ចង់មាន ឲ្យចេះប្រឹងរក។ អ្នកខ្ជិលចូលចិត្តរកគូស្រករកូនអ្នកមាន តែអ្នកមានគំនិត តែងរកគូស្រករណាដែលចេះបង្កើតបង្កើនទ្រព្យ និងរក្សាសម្បត្តិឲ្យគង់វង្ស។ អ្នកនិពន្ធសៀវភៅ *"ឪពុកអ្នកមានបង្រៀនកូនអ្នកក្រ"* លោក រ៉ូប៊ឺត គីយ៉ូសាគី [ Robert Kiyosaki ] និយាយថា *"មិនសំខាន់ថា តើអ្នកពូកែរកចំណូលបានច្រើនប៉ុនណានោះទេសំខាន់ត្រង់ថាអ្នកពូកែសន្សំរៀបចំទុកដាក់ចំណូលនោះយ៉ាងណា"*។

យើងអាចក្លាយជាអ្នកមាន ប្រសិនបើយើងបានរៀបការជាមួយកូនសេដ្ឋី ប៉ុន្តែយើងនឹងមិនអាចក្លាយជាបណ្ឌិតបានទេ បើទោះបីយើងបានរៀបការជាមួយបណ្ឌិត ឬកូនបណ្ឌិត

ប្រសិនបើយើងខ្ជិលរៀនសូត្រ។ "ចូររៀនចេះលាក់បាំងខ្លះនូវអារម្មណ៍នៃសេចក្តីត្រូវការរបស់ខ្លួនឯង តែចូរបង្ហាញការខិតខំប្រឹងប្រែងរបស់ខ្លួនឯងវិញ"។

*"Learn to hide your need and show your skill."*

*-Jim Rohn*

# ថ្ងៃទី២៨ ខែកុម្ភៈ

ហ្វ្រីឌ្រិច និហ្សឺ [Nietzsche] បានពោលថា *"អ្នកនយោបាយបានបែងចែកមនុស្សក្នុងសង្គមនយោបាយជាពីរប្រភេទ"* គឺ៖

១ ( ជនជាឧបករណ៍នយោបាយ [ Tools ]

២ ) ជនជាសត្រូវនយោបាយ [ Enemies ]។

បុគ្គលជាឧបករណ៍នយោបាយ ច្រើនស៊ីឈ្នួលដើរតួល្ខោនដើម្បីសម្ដែងរឿងដែលអ្នកនយោបាយរៀបចំទុក ហើយបន្ទាប់ពីបញ្ចប់បេសកម្ម ជនជាឧបករណ៍នយោបាយ នឹងបាត់ខ្លួនចេញពីសង្វៀននយោបាយ ឬអាចថាត្រូវបញ្ជូនទៅកន្លែងស្រួលតាមការកិច្ចព្រមព្រៀងសម្ដែង ឬត្រូវទទួលបានឋានៈសមរម្យមួយ។

ឱកាសដែលអ្នកនយោបាយ ផ្ដល់ឲ្យអ្នកនយោបាយដូចគ្នា គឺដើមដំបូងត្រូវតែប្រើវិធីលួងលោម [ Political lobby ] ឲ្យធ្វើជាឧបករណ៍នយោបាយសិន។ ប៉ុន្តែបើលួងលោមមិន

បានទេ គឺនឹងត្រូវក្លាយជាសត្រូវនយោបាយ ហើយបើក្លាយទៅជាសត្រូវ នោះផ្លូវមួយគត់ដែលអ្នកនយោបាយត្រូវបន្តធ្វើ គឺកម្ទេចសត្រូវចោល។

តាមសម្ដីរបស់ មហាត្មៈ គន្ធី គឺការដែលធ្វើ *"នយោបាយដោយគ្មានគោលការណ៍"* ច្បាស់លាស់ [ Politics Without Principles ] ក៏ចាត់ទុកថាជាអំពើបាបក្នុងសង្គមមួយ។ តាមរដ្ឋធម្មនុញ្ញ [ Constitutional Law ] សង្គមខ្មែរបានប្រកាសយកសាសនាព្រះពុទ្ធជាសាសនារបស់រដ្ឋដែលជឿលើបុណ្យបាប និងសាងល្អ។ អ្នកដឹកនាំក្លែងក្លាយ តែងប្ដូរគោលការណ៍ដើម្បីលាភសក្ការៈ បុណ្យសក្តិ និងអំណាច តែអ្នកដឹកនាំពិត តែងតែលះបង់លាភសក្ការៈ កិត្តិយស បុណ្យក្តិ និងអំណាចដើម្បីរក្សាគោលការណ៍ គឺគោលការណ៍ដើម្បីប្រយោជន៍ប្រជាជន។

សូមចងចាំថា *"ចេះតែម្នាក់ឯង ដើរមិនបានឆ្ងាយទេ តែបើចេះទាំងអស់គ្នា ទើបដើរបានឆ្ងាយ។ ខ្លាំងម្នាក់ឯង មិនប្រសើរដូចខ្លាំងទាំងអស់គ្នាទេ ហើយឆ្លាតម្នាក់ឯង ក៏មិនល្អដូចឆ្លាតទាំងអស់គ្នាដែរ"*។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

"A politician divides mankind into two classes: tools and enemies."- Friedrich Nietzsche

# ទស្សនៈសម្រាប់ខែ

# មីនា

# ថ្ងៃទី០១ ខែមីនា

អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] ពោលថា *"ក្រពះទទេ មិនអាចក្លាយទៅជាទីប្រឹក្សានយោបាយល្អទេ"* ។

អ្នកដឹកនាំកំសាកតែម្នាក់ គឺនឹងធ្វើឲ្យអ្នកដើរតាមធម្មតា ១០នាក់ទៀត កំសាកតាមដែរ។ យុវជនលេចធ្លោតែម្នាក់កំសាក ក៏នឹងធ្វើឲ្យយុវជនធម្មតា ១០នាក់ទៀតកំសាកតាមដែរ។ ក្រពះ គឺជាជីវិតនៃរាងកាយ តែឆន្ទៈគឺជាជីវិតនៃកិត្តិយស។ មនុស្សដែលអាចរស់បានដោយកិត្តិយស គឺជាមនុស្សដែលរស់បានដោយមិនចាំបាច់ក្រពះឆ្អែតពេក តែត្រឹមតែដើម្បីរស់បន្តឆន្ទៈទៅមុខទៀត៕

*"An empty stomach is not a good political adviser."*

- Albert Einstein

# ថ្ងៃទី០២ ខែមីនា

ម៉ាទីន លូធ័រឃីង [ Martin Luther King ] ពោលថា"*ក្នុងលោកយើងនេះ គ្មានអ្វីដែលគ្រោះថ្នាក់ជាងមនុស្សស្មោះត្រង់ដោយឥតវិជ្ជា ឬស្មោះត្រង់ដោយឥតមានប្រាជ្ញា [Sincere Ignorance] ហើយនៅតែមិនដឹងថាខ្លួនឯងល្ងង់ខ្លៅទៀត*"។

មនុស្សដែលល្ងង់ខ្លាំងបំផុត តែងប្រើត្រឹមតែអារម្មណ៍នៃមនោសញ្ចេតនាដោយខ្វះការចូលរួមពីខួរក្បាល ចំណែកមនុស្សដែលឃោរឃៅបំផុត តែងប្រើខួរក្បាលដោយខ្វះការចូលរួមពីអារម្មណ៍មនោសញ្ចេតនា។ សង្គមជាតិត្រូវការមនុស្សស្មោះត្រង់ផង និងមានបញ្ញាផង តែបើមានបញ្ញាខ្វះមនោសញ្ចេតនា គឺនឹងក្លាយទៅជាឃោរឃៅដាក់ខ្មែរគ្នាឯង ហើយបើមានមនោសញ្ចេតនាតែខ្វះបញ្ញា គឺនឹងក្លាយទៅជាឧបករណ៍នយោបាយ ដោយត្រូវអ្នកនយោបាយប្រើប្រាស់ដើម្បីកម្ទាត់ខ្មែរគ្នាឯងមិនខានឡើយ។

បញ្ហាដែលយុវជនខ្មែរត្រូវគិតគូរ គឺរឿងនយោបាយ ហើយ បញ្ហាដែលយុវជនខ្មែរត្រូវប្រុងប្រយ័ត្ន គឺអ្នកនយោបាយ។ អ្នកនយោបាយធ្វើឲ្យយុវជនខ្វែងគំនិតគ្នា ស្អប់គ្នា លាបពណ៌ដាក់គ្នា [ Label ]។ សង្គមខ្មែរដើរដល់ចំណុចនេះ គឺដោយសារកំហុសអ្នកនយោបាយ តែកំហុសធំបំផុតគឺប្រជាជនខ្មែរខ្លាចនយោបាយ។ ថ្ងៃនេះយុវជនស្អប់គ្នា វាយប្រហារគ្នា និងលាបពណ៌ដាក់គ្នា គឺដោយសារកំហុសអ្នកនយោបាយ តែកំហុសធំបំផុត គឺយើងជាយុវជនពេញចិត្តធ្វើជាឧបករណ៍នយោបាយ៕

# ថ្ងៃទី០៣ ខែមីនា

*"ភាពជាអ្នករឹងមាំ មិនមែនបានមកពីជ័យជម្នះ ដោយគ្មានឧបសគ្គនោះទេ តែវាកើតឡើងដោយសារការតស៊ូននៀលជម្នះនឹងឧបសគ្គ និងបញ្ហានានាដែលយើងបានជួបប្រទះ"*

ពេលដែលយើងបានជួបប្រទះនឹងភាពលំបាកទាំងឡាយ ប៉ុន្តែយើងបែរជាសម្រេចចិត្តមិនឲ្យភាពលំបាកនោះកំណត់វាសនាកម្មរបស់យើង នោះហើយគឺជាភាពរឹងមាំនៃជីវិត។ អ្នកឈ្នះដោយមិនធ្លាប់ជួបឧបសគ្គ ឬបញ្ហា គឺជាអ្នឈ្នះធម្មតា តែអ្នកឈ្នះអស្ចារ្យ គឺជាអ្នកដែលប្រឆាំងតវ៉ានឹងកម្មវាសនា ហើយប្រវត្តិសាស្រ្តនឹងចារឹកទុកជាគំរូសម្រាប់អ្នកជំនាន់ក្រោយ។ ចូរស្វាគមន៍ចំពោះឧបសគ្គជីវិតទាំងឡាយ ហើយកុំទាន់ថាយើងចាញ់ ឬឧបសគ្គឈ្នះយើង តែសំខាន់សាកល្បងកម្លាំងគ្នាមើលសិន តែបើយើងចាញ់បញ្ហា គឺជាមេរៀន តែបើយើងឈ្នះបញ្ហា គឺយើងអស្ចារ្យ៕

# ថ្ងៃទី០៤ ខែមីនា

ខុងជឺ[Confucius]បង្រៀនថា"*សារៈសំខាន់នៃចំណេះដឹង គឺបើយើងជាអ្នកមានចំណេះដឹង នោះយើងត្រូវយកចំណេះដឹងទាំងនោះទៅអនុវត្តន៍ជាក់ស្តែង ប៉ុន្តែប្រសិនបើយើងគ្មានចំណេះដឹងទេ គឺសុំត្រឹមតែយើងទទួលស្គាល់ថាខ្លួនឯងមិនចេះទៅបានហើយ*"។

ខ្វះចំណេះដឹង ហើយមិនចេះធ្វើ ឬធ្វើមិនបានល្អ ឬធ្វើខុសច្រើន គឺជាកំហុសមួយប៉ុណ្ណោះ តែបើដឹងថាខ្លួនឯងមិនចេះហើយ បែរជាមិនស្វះស្វែងរកចំណេះដឹង នោះគឺជាកំហុសមួយទៀត។ ពេលយើងមិនចេះក៏ដោយ ឬពេលយើងចេះក៏ដោយ តែសូមឲ្យចេះត្រឹមតែស្គាល់ពីខ្លួនឯងឲ្យច្បាស់ដោយព្រមទទួលស្គាល់ខ្លួនឯងថាខ្លួនចេះ ឬខ្លួនល្ងង់ទៅបានហើយ ពីព្រោះបើដឹងខ្លួនល្ងង់ ងាយនឹងរៀនឲ្យចេះ ហើយបើដឹងខ្លួនចេះងាយនឹងប្រឹងទប់កុំឲ្យខ្លួនមានអំណួត ។

មានមនុស្ស៤ប្រភេទដែលយើងអាចស្វែងយល់ "*ភាពជាអ្នកស្គាល់ខ្លួន ឬមិនស្គាល់ខ្លួនឯង*" គឺ៖

១. បុគ្គលដែលស្គាល់ខ្លួនឯង តែគេបែរជាមិនដឹងថាគេបានស្គាល់ខ្លួនឯង ដូច្នេះចូរដាស់គេឲ្យភ្ញាក់ឡើង ព្រោះគេកំពុងតែគេងលង់លក់ក្នុងដំណេក។

២. បុគ្គលដែលមិនស្គាល់ខ្លួនឯង ហើយគេក៏មិនដឹងថាគេមិនស្គាល់ខ្លួនឯងដែរ ដូច្នេះចូរជៀសចេញពីគេ ពីព្រោះគេជាមនុស្សឆោតល្ងង់។

៣. បុគ្គលដែលមិនស្គាល់ខ្លួនឯង ហើយគេក៏បានដឹងថាគេពិតជាមិនស្គាល់ខ្លួនឯងមែន ដូច្នេះចូរបង្ហាត់បង្ហាញផ្លូវដល់គេ ពីព្រោះគេប្រៀបដូចជាកូនក្មេង។

៤. បុគ្គលដែលស្គាល់ខ្លួនឯងហើយគេក៏បានដឹងខ្លួនឯងថាគេស្គាល់ខ្លួនឯង ដូច្នេះចូររៀនធ្វើតាមគេ ពីព្រោះគេគឺជាគ្រូបង្រៀន៕ *"The essence of knowledge is, having it, to apply it; not having it, to confess your ignorance."*-Confucius

# ថ្ងៃទី០៥ ខែមីនា

*"ជីវិតមនុស្សរស់នៅ មិនមែនជាអ្នកទោសនៃកម្មវាសនារបស់ខ្លួននោះទេ តែគឺជាអ្នកទោស និងជាទាសករនៃគំនិតរបស់ខ្លួន"។*

គំនិតបង្កើតសេចក្ដីទុក្ខ ហើយគំនិតក៏បង្កើតសេចក្ដីសុខដូចគ្នាដែរ ពីព្រោះគិតល្អគឺសុខ តែគិតអាក្រក់គឺទុក្ខ។ គំនិតគឺជាកំណើត តែបើគំនិតមិនកើត កំណើតក៏មិនល្អដែរ។ គំនិតបង្កើតជំនឿ ហើយនៅពេលដែលយើងជឿថាយើងបែបណា គឺថាយើងក៏នឹងក្លាយទៅជាបែបនោះពិតមែន៕

*"Men are not prisoners of fate, but only prisoners of their own minds."* - Franklin D. Roosevelt

# ថ្ងៃទី០៦ ខែមីនា

*"សុភមង្គលនៃជីវិតរបស់យើង គឺកើតឡើងដោយអាស្រ័យលើគំនិតខាងក្នុងរបស់យើង"*។ យើងមិនអាចរកសេចក្តីសុខឲ្យអ្នកដទៃបានទេ បើយើងមិនចេះផ្តល់សេចក្តីសុខឲ្យខ្លួនឯង។ យើងមិនអាចផ្តល់សេចក្តីសុខឲ្យសង្គមបានទេ បើយើងមិនចេះផ្តល់សេចក្តីសុខឲ្យអ្នកដទៃ។ យើងមិនអាចបង្កើតសន្តិភាពវិជ្ជមាន [ Positive Peace ] ក្នុងប្រទេសយើងបានឡើយ បើយើងមិនចេះបង្កើតសង្គមសន្តិភាពប្រកបដោយអហិង្សា។ សង្គមយើងមិនទាន់ស្លាប់និងមិនមែនស្លាប់ទេ តែគ្រាន់តែកំពុងមានជំងឺ ហើយបើចង់ព្យាបាលជំងឺសង្គម លុះត្រាតែយើងជាជនដែលរស់នៅសង្គមកុំធ្វើជាមនុស្សឈឺ។ មនុស្សឈឺ ពីព្រោះស្នេហា, មនុស្សឈឺ ពីព្រោះសម្ភារៈនិយម ហើយនឹងមនុស្សឈឺដោយជំងឺសង្គមរាតត្បាត។ ជំងឺសង្គមសាហាវ ត្រូវការឱសថទិព្វ និងគ្រូពេទ្យទិព្វ ហើយឱសថទិព្វ គឺការអប់រំរីឯគ្រូពេទ្យទិព្វ គឺជាមនុស្សមានការអប់រំប្រកបដោយសីលធម៌។"The happiness of your life depends upon the quality of your thoughts."

ឡាំ លីម

# ថ្ងៃទី០៧ ខែមីនា

*"មនុស្សខុសគ្នា តែងខិតខំស្វែងរកសុភមង្គលដោយប្រើវិធីសាស្ត្រខុសគ្នា ទៅលើនិយមន័យនៃភាពជោគជ័យខុសគ្នា"*។នៅលើលោកនេះ ពុំមាននរណាម្នាក់ដែលល្អឥតខ្ចោះ [ Perfect ] ទេ តែយើងមានលក្ខណៈពិសេសដាច់ដោយឡែកខុសពីគ្នា [ Unique ] ឬអាចនិយាយបានថា *"ម្យ៉ាងម្នាក់"*។

និយមន័យនៃភាពជោគជ័យ ក៏មិនចេញពីវចនានុក្រមដូចគ្នាដែរ ពីព្រោះគោលបំណងជីវិតមនុស្សយើងមិនដូចគ្នា។ ជោគជ័យនៃពាណិជ្ជករគឺចំណូល។ជោគជ័យនៃសាសនិកគឺសេចក្ដីសុខផ្លូវចិត្ត ហើយជោគជ័យនៃអ្នកនយោបាយគឺអំណាចដើម្បីបម្រើសង្គម។

កុំភ្លេចថា "យើងជាមនុស្សឆ្លាត តែបើយើងប្រមូលគ្នាផ្ដុំទាំងអស់ គឺឆ្លាតជាង។ យើងជោគជ័យតាមផ្នែករបស់យើង តែ

បើយើងប្រមូលជោគជ័យបញ្ចូលគ្នា នោះនឹងបង្កើតសាមគ្គី និងការផ្លាស់ប្តូរយ៉ាងធំ។ ជោគជ័យរបស់យើង គឺយើងជាអ្នកបង្កើត តែជោគជ័យរបស់សង្គម គឺយើងទាំងអស់គ្នាត្រូវចូលរួមសាមគ្គីគ្នាបង្កើតឡើង"។

"Different men seek ... happiness in different ways and by different means." - Aristotle

# ថ្ងៃទី០៨ ខែមីនា

ម៉ាទីន លូធឺឃីង ជូនៀ [ Martin Luther King Jr. ] ពោលថា*"ជីវិតយើងនឹងត្រូវបានបញ្ចប់ នៅថ្ងៃដែលយើងក្លាយទៅជាមនុស្សស្ងៀមស្ងាត់អំពីរឿងរ៉ាវអយុត្តិធម៌"*។

ការពិតទៅ នៅលើលោកយើងនេះ កន្លែងណាក៏មានទង្វើអយុត្តិធម៌ដែរ។ មានភាពយុត្តិធម៌ តែគ្មាននិយាមយុត្តិធម៌ ឬស្តង់ដាយុត្តិធម៌ទេ។ បើយើងមិនតវ៉ាទាមទារប្រឆាំងនឹងភាពអយុត្តិធម៌ទេ នោះមានន័យថា យើងបានយល់ព្រមទទួលយកភាពអយុត្តិធម៌។ ភាពយុត្តិធម៌បង្កើតដោយក្រុមមនុស្សល្អ ហើយភាពអយុត្តិធម៌ក៏កើតឡើងដោយចំណែករបស់មនុស្សល្អដែរ។

រឿងអយុត្តិធម៌ក្នុងសង្គមខ្លះ កុំថាឡើយដប់ឆ្នាំ សូម្បីតែដល់ម្ភៃឆ្នាំក្រោយក៏នៅតែគ្មានអ្នកណារកយុត្តិធម៌ឲ្យផង។ អ្នកស្លាប់ គឺបានស្លាប់ដោយអយុត្តិធម៌ អ៊ីចឹងតួនាទីអ្នក

រស់ គឺត្រូវរកយុត្តិធម៌។ ការនៅស្ងៀម និងមិនតបតអ្វីសោះចំពោះឃាតករ ឬសត្រូវ គឺកាន់តែធ្វើឲ្យពួកឃាតករកាន់តែបានចិត្ត ផ្គើនឡើងថែមទៀត។ ដោយទីបំផុតទៅស្មើពាក្យថា *"គាំទ្រអំពើបាបដោយសម្ងាត់"* ហើយបើយើងគាំទ្រអំពើបាប តើយើងនៅមានឈ្មោះថា ជាមនុស្សល្អទៀតទេ?

# ថ្ងៃទី០៩ ខែមីនា

អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] ពោលថា"*ពិភពលោកនេះ គឺមិនត្រូវបានបំផ្លាញផ្តាច់មុខ ដោយពួកមនុស្សអាក្រក់តែឯកឯងនោះទេ តែត្រូវបានបំផ្លាញដោយពួកមនុស្សល្អដែលនៅឈរឱបដៃមើលទៅវិញទេ*" ។

ការពិតក្នុងលោក គឺក្នុងលោកយើងនេះ កន្លែងណាក៏មានទង្វើអយុត្តិធម៌ដែរ។ មានភាពយុត្តិធម៌ ប៉ុន្តែគ្មាននិយាមយុត្តិធម៌ ឬស្តង់ដាយុត្តិធម៌ទេ។ បើយើងមិនត៉វាទាមទារប្រឆាំងនឹងភាពអយុត្តិធម៌ទេ នោះមានន័យថាយើងបានយល់ព្រមទទួលយកភាពអយុត្តិធម៌។

ភាពយុត្តិធម៌បង្កើតឡើងដោយមនុស្សល្អ ហើយភាពអយុត្តិធម៌ក៏បង្កើតឡើងដោយចំណែករបស់មនុស្សល្អដែរ។ រឿងអយុត្តិធម៌ក្នុងសង្គមខ្លះ កុំថាឡើយដប់ឆ្នាំសូម្បីដល់ម្ភៃឆ្នាំក្រោយក៏នៅតែគ្មានអ្នកណារកយុត្តិធម៌ឲ្យផង។

 

អ្នកស្លាប់ គឺបានស្លាប់ដោយអយុត្តិធម៌ អ៊ីចឹងតួនាទីអ្នករស់ គឺត្រូវរកយុត្តិធម៌។ ការនៅស្ងៀម និងមិនតបតអ្វីសោះ ចំពោះឃាតករ ឬសត្រូវ គឺកាន់តែធ្វើឲ្យពួកឃាតករកាន់តែបានចិត្ត ផ្គើនឡើងថែមទៀត។ ដោយទីបំផុតទៅស្មើពាក្យថា *"គាំទ្រអំពើបាបដោយសម្ងាត់"* ហើយបើយើងគាំទ្រអំពើបាប តើយើងនៅមានឈ្មោះថា ជាមនុស្សល្អទៀតទេ?

# ថ្ងៃទី១០ ខែមីនា

មហាត្មៈ គន្ធី [ Mahatma Gandhi ] ពោលថា "*ការមិនសហការជាមួយនឹងភាពអយុត្តិធម៌ គឺជាវិធីបញ្ឈប់ភាពអយុត្តិធម៌ដោយអហិង្សា*"។

ការពិតក្នុងលោក គឺក្នុងលោកយើងនេះ កន្លែងណាក៏មានទង្វើអយុត្តិធម៌ដែរ។ មានភាពយុត្តិធម៌ ប៉ុន្តែគ្មាននិយាមយុត្តិធម៌ ឬស្តង់ដាយុត្តិធម៌ទេ។ បើយើងមិនតវ៉ាទាមទារប្រឆាំងនឹងភាពអយុត្តិធម៌ទេ នោះមានន័យថាយើងបានយល់ព្រមទទួលយកភាពអយុត្តិធម៌។

ភាពយុត្តិធម៌បង្កើតដោយមនុស្សល្អ ហើយភាពអយុត្តិធម៌ក៏បង្កើតឡើង ដោយចំណែករបស់មនុស្សល្អដែរ។ រឿងអយុត្តិធម៌ក្នុងសង្គមខ្លះ កុំថាឡើយដប់ឆ្នាំ សូម្បីដល់ម្ភៃឆ្នាំក្រោយ ក៏នៅតែគ្មានអ្នកណារកយុត្តិធម៌ឲ្យផង។

អ្នកស្លាប់ គឺបានស្លាប់ដោយអយុត្តិធម៌ អ៊ីចឹងតួនាទីអ្នករស់ គឺត្រូវរកយុត្តិធម៌។ការនៅស្ងៀមនិងមិនតបតអ្វីសោះចំពោះ ឃាតករ ឬសត្រូវ គឺកាន់តែធ្វើឲ្យពួកឃាតករកាន់តែបាន ចិត្ត ផ្អើនឡើងថែមទៀត។ ដោយទីបំផុតទៅស្មើពាក្យថា *"គាំទ្រអំពើបាបដោយសម្ងាត់"* ហើយបើយើងគាំទ្រអំពើ បាប តើយើងនៅមានឈ្មោះថា ជាមនុស្សល្អទៀតទេ ?

# ថ្ងៃទី១១ ខែមីនា

សុភាសិតចិនលើកឡើងអំពីមនុស្សកំសាកថា "*មនុស្សកំសាក មើលឃើញរឿងត្រឹមត្រូវតែគេបែរជាជ្រើសយកការប្រព្រឹត្តកំហុសឆ្គងទៅវិញ*"។

វីល្លៀម ស្ពែកស្ពៀរ បានលើកឡើងថា "*មនុស្សកំសាកនឹងត្រូវស្លាប់ជាច្រើនដង មុននឹងត្រូវគេសម្លាប់ឲ្យអស់ជីវិតមែនទែន*"។

សុភាសិតអាល្លឺម៉ង់លើកឡើងថា "*អ្នកដឹកនាំកំសាកម្នាក់នឹងបង្កបង្កើតមនុស្សកំសាក១០នាក់ថែមទៀត*"។

# ថ្ងៃទី១២ ខែមីនា

*"ការពិតក្នុងលោក គឺក្នុងលោកយើងនេះ កន្លែងណាក៏មានទង្វើអយុត្តិធម៌ដែរ។ ក្នុងលោកយើងនេះ មានភាពយុត្តិធម៌ តែគ្មាននិយមយុត្តិធម៌ ឬស្តង់ដារយុត្តិធម៌ទេ។"*

បើយើងមិនតវ៉ាទាមទារប្រឆាំងភាពយុត្តិធម៌ទេ នោះមានន័យថាយើងបានយល់ព្រមយកភាពអយុត្តិធម៌។ នៅក្នុងលោកយើងនេះ យុត្តិធម៌បង្កើតដោយមនុស្សល្អ ចំណែកឯអយុត្តិធម៌ក៏បង្កើតឡើងដោយ ចំណែកនៃការចូលរួមរបស់មនុស្សល្អដែរ។ មហាត្មៈ គន្ធី ពោលថា *"ការមិនសហការជាមួយនឹងភាពអយុត្តិធម៌ គឺជាវិធីបញ្ឈប់ភាពអយុត្តិធម៌ដោយអហិង្សា"*។

អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] ពោលថា *"ពិភពលោកនេះ គឺមិនត្រូវបានបំផ្លាញផ្តាច់មុខដោយពួកមនុស្សអាក្រក់តែឯកឯងនោះទេ តែត្រូវបានបំផ្លាញដោយពួកមនុស្សល្អ ដែលនៅឈរឱបដៃមើលទៅវិញទេ"* ។

ម៉ាទីន លូធឺឃីញ ជូនៀ [ Martin Luther King Jr. ] ពោលថា *"ជីវិតយើង នឹងត្រូវបានបញ្ចប់នៅថ្ងៃដែលយើងក្លាយទៅជាមនុស្សស្ងៀមស្ងាត់អំពីរឿងរ៉ាវអយុត្តិធម៌"* ។

ថូម៉ាស់ ហ្វូល័រ [ Thomas Fuller ] ពោលថា *"វាជាអំពើឆ្កួតលីលារបស់សត្វចៀម ដែលទៅជជែកគ្នាពីសន្តិភាពជាមួយសត្វចចក"* សុភាសិតចិនពោលថា *"សុភាពបុរសចង់សងសឹក បើទោះបីជារង់ចាំដប់ឆ្នាំទៀត ក៏មិនយឺតពេលនោះដែរ"* ។

រឿងអយុត្តិធម៌ក្នុងសង្គមខ្លះ កុំថាឡើយដប់ឆ្នាំ សូម្បីតែដល់ម្ភៃឆ្នាំក្រោយ ក៏នៅតែគ្មានអ្នកណារកយុត្តិធម៌ឲ្យផង។

អ្នកស្លាប់ គឺបានស្លាប់ដោយអយុត្តិធម៌ អ៊ីចឹងតួនាទីអ្នករស់ គឺត្រូវរកយុត្តិធម៌។ ការនៅស្ងៀម និងមិនតបតអ្វីសោះចំពោះឃាតករ ឬសត្រូវ គឺកាន់តែធ្វើឲ្យពួកឃាតករកាន់តែបានចិត្ត ផ្ដើនឡើងថែមទៀត។ ដោយទីបំផុតទៅស្មើពាក្យថា *"គាំទ្រអំពើបាបដោយសម្ងាត់"* ហើយបើយើងគាំទ្រអំពើបាប តើយើងនៅមានឈ្មោះថា ជាមនុស្សល្អទៀតទេ?

# ថ្ងៃទី១៣ ខែមីនា

*"ការអប់រំចំពោះតែគំនិតរបស់មនុស្ស ដោយមិនបានអប់រំសីលធម៌មនុស្ស គឺប្រៀបដូចនឹងសាបព្រោះគ្រោះភ័យដល់សង្គមជាតិទាំងមូល"*។

ទឹកហូរធ្លាក់ពីលើចុះមកក្រោម។ អ្នកតូចរៀនពីអ្នកធំ។ អ្នកល្ងង់រៀនពីអ្នកចេះ ហើយកូនប្រុសស្រីរៀនពីឪពុកម្តាយ។ បើគ្រូខ្វះភាពជាគំរូ បើអ្នកដឹកនាំខ្វះភាពជាអ្នកដឹកនាំ ហើយបើឪពុកម្តាយខ្វះភាពជាឪពុកម្តាយល្អ នោះសីលធម៌សង្គមនឹងធ្លាក់ចុះខ្លាំង។ ទ្រឹស្តីមិនឈ្នះសកម្មភាពយជាក់ស្តែង។ បង្រៀនទ្រឹស្តីឲ្យមនុស្សរៀនគិត តែបង្ហាញភាពជាគំរូឲ្យមនុស្សរៀនធ្វើតាម។ មានវិធី ៣យ៉ាងដើម្បីអប់រំមនុស្សឲ្យមានសីលធម៌ ឬខ្វះសីលធម៌គឺ៖ ១. គំរូ, ២. គំរូ, ៣. គំរូ.....៕ *"To educate a person in the mind but not in morals is to educate a menace to society."*

- Theodore Roosevelt,

# ថ្ងៃទី១៤ ខែមីនា

*"បើចង់ដឹងថា តើខ្លួនយើងជានរណាពិតប្រាកដ ចូរចាប់ផ្ដើមធ្វើសកម្មភាពដោយខ្លួនឯងផ្ទាល់ ហើយសូមកុំទៅសួរពីនរណាម្នាក់ឲ្យសោះ ពីព្រោះសកម្មភាពដែលយើងប្រព្រឹត្តិនឹងកំណត់ថា យើងជានរណា ហើយនឹងបង្ហាញទៀតថា យើងនឹងក្លាយទៅជាអ្វី"។*

មនុស្សពូកែនិយាយ អាចបានត្រឹមតែលើកទឹកចិត្តដល់អ្នកដទៃ តែមនុស្សពូកែធ្វើនឹងបង្ហាញទង្វើជាគំរូដល់អ្នកដទៃ។ អ្នកពូកែរកស៊ី ប្រឹងរហូតក្លាយជាសេដ្ឋី តែមនុស្សពូកែទ្រឹស្ដី ប្រឹងចែករំលែកគំនិត។ មនុស្សខ្លាំងធម្មតា ចេះត្រឹមតែពូកែទ្រឹស្ដី តែមនុស្សខ្លាំងអស្ចារ្យ ចេះទាំងធ្វើសកម្មភាពបង្ហាញគំរូថែមទៀត។ មនុស្សខ្លាំងធម្មតា និយាយសម្ដីផ្អែមល្ហែម តែមនុស្សខ្លាំងអស្ចារ្យប្រព្រឹត្តទង្វើផ្អែមល្ហែម។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

នេះជាសម័យស.វទី២១ហើយ គឺថាមនុស្សគេតែងយក សកម្មភាពដែលយើងអនុវត្តជាក់ស្តែង ច្រើនជាងសម្តី៕

*"Do you want to know who you are? Don't ask. Act! Action will delineate and define you."*

- Thomas Jefferson

# ថ្ងៃទី១៥ ខែមីនា

*"ជីវិត គឺដំណើរនៃការផ្លាស់ប្តូរ ហើយការផ្លាស់ប្តូរទៅកាន់ភាពជោគជ័យ ជាជម្រើស តែសូមជ្រើសរើសដោយភាពឈ្លាសវៃ"*។

បើយើងស្រឡាញ់សង្គម គឺត្រូវផ្លាស់ប្តូរខ្លួនឯងជាមុន ហើយបើស្រឡាញ់ខ្លួនឯង គឺត្រូវផ្លាស់ប្តូរសង្គមតាមក្រោយ ។ តាមទ្រឹស្តីច្បាប់សកល ឬច្បាប់ធម្មជាតិបានឲ្យយើងដឹងថា *"គ្រប់យ៉ាង គឺជារបស់តែមួយ ឬជារបស់ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងគ្នាបំផុត"*។

# ថ្ងៃទី១៦ ខែមីនា

ប្លាឌីមៀរ លេនីន [ Vladimir Lenin ] និយាយ "*ទាហានតែ១នាក់ដែលប្រដាប់ដោយកាំភ្លើង មានអំណាចអាចគ្រប់គ្រងលើមនុស្ស ១០០នាក់ដែលគ្មានអាវុធ*"។

ជាការពិត ក្នុងរបបខ្មែរក្រហម មនុស្ស១០០នាក់ សុខចិត្តឲ្យទាហានមានប្រដាប់ដោយកាំភ្លើងម្នាក់សម្លាប់ចោល ឲ្យស្លាប់ទាំងអស់គ្នា។ ក្នុងសង្គមខ្មែរតាំងតែពីអតីតកាលមកដល់បច្ចុប្បន្ន ស្ថានភាពនយោបាយ និងរបបនយោបាយខ្មែរត្រូវបានមនុស្សក្រុមតូចដូរតម្រូវ ឬអាចនិយាយបានថា "*កាត់ក្បាលតម្រូវមួក*" តែមិនមែនកាត់មួកឲ្យត្រូវក្បាលទេ។ ប្រវត្តិសាស្ត្របានបង្ហាញផងដែរថា "*ខ្មែរមិនដែលធ្លាប់បោះបង់វប្បធម៌ ពេលទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រីម្តង*"។

"One man with a gun can control 100 without one."- Vladimir Lenin

# ថ្ងៃទី១៧ ខែមីនា

*"មនុស្សប្រកាន់ខ្ជាប់នូវទុទ្ធិដ្ឋិនិយម មើលឃើញបញ្ហានៅគ្រប់ឱកាស តែមនុស្សដែលប្រកាន់ខ្ជាប់នូវសុទិដ្ឋិនិយម មើលមើលឃើញឱកាសនៅគ្រប់ក្នុងបញ្ហា"*។

គ្រប់កាលៈទេសៈសង្គម បើយើងជាអ្នកជីករកមាស នោះត្រូវចងចាំថាក្នុងដំណើរការនៃការជីករកមាស ប្រាកដជាមានដី ឬរបស់មិនមែនជាមាសនៅលាយឡំគ្នា។ ប៉ុន្តែអ្វីដែលសំខាន់ គឺស្ថិតនៅក្នុងវិធីនៃការមើលរបស់គ្រប់យ៉ាងក្នុងក្រសែភ្នែករបស់យើង។

ចំពោះទំនាក់ទំនងសង្គម ចូរចងចាំថា ក្នុងភាពល្អទាំងអស់ តែងមានអាក្រក់ខ្លះ ហើយក្នុងភាពអាក្រក់ទាំងអស់ តែងមានល្អខ្លះ។ អ្នករៀនសូត្របានច្រើន, មនុស្សអានសៀវភៅច្រើន និងមនុស្សអាយុច្រើន គង់មានចំណុចខ្សោយ ឬគង់មានចំណុចខ្លះមិនចេះដូចគ្នា។

## ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

មនុស្សពេញលេញ គឺស្ថិតលើតម្លៃ [ Value ] តែមិនមែនស្ថិតលើតម្លៃលុយ [ Cost ] នោះទេ។ មនុស្សពេញលេញចាត់ទុកលុយជាអ្នកបម្រើ ប៉ុន្តែមនុស្សដែលមិនពេញលេញយកអ្នកបម្រើធ្វើជាម្ចាស់ខ្លួនឯង៕

*"The pessimist sees difficulties in every opportunity; an optimist sees opportunities in every difficulty. "*- Winston Churchill

# ថ្ងៃទី១៨ ខែមីនា

*"ធ្លាប់បានព្យាយាម ធ្លាប់បានទទួលបរាជ័យ តែទោះជាយ៉ាងណា ក៏នៅតែព្យាយាមម្តងទៀត ហើយក៏បានបរាជ័យម្តងទៀត ក៏ប៉ុន្តែគឺត្រូវបរាជ័យឲ្យល្អជាងមុន"។*

ថ្ងៃដែលយើងព្យាយាម គឺជាថ្ងៃដែលយើងហាត់។ ថ្ងៃដែលយើងបរាជ័យ គឺជាថ្ងៃដែលយើងយំ។ ថ្ងៃដែលយើងតាំងចិត្តសាកល្បងម្តងទៀត គឺជាថ្ងៃដែលយើងមានសង្ឃឹមឡើងវិញ។ ថ្ងៃដែលបរាជ័យស្ថិតនៅជាមួយយើងទៀត គឺជាថ្ងៃដែលយើងទទួលមេរៀននិងភាពរឹងមាំ។ ថ្ងៃបន្ទាប់យើងបរាជ័យល្អជាងមុន ហើយចុងក្រោយស្នាមញញឹមក៏មានលើផ្ទៃមុខពោរពេញដោយមោទកភាព។

*"Ever tried. Ever failed. No matter. Try again. Fail again. Fail better. "* - Samuel Beckett

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី១៩ ខែមីនា

*"ទឹកភ្លៀងធ្លាក់ពីលើមេឃ គឺប្រហែលជាដោយសារមេឃមិនអាចទប់ទម្ងន់ទឹកបាន។ ចំណែកទឹកភ្នែកស្រក់ចេញពីមនុស្សឈឺចាប់ ក៏ប្រហែលជាមនុស្សមិនអាចទប់នឹងទម្ងន់នៃសេចក្តីឈឺចាប់បាន"។*

ពេលដែលខ្ញុំព្យាយាមអានកាន់តែច្រើន នោះទើបខ្ញុំកាន់តែដឹងច្បាស់ថា តាមពិតបេះដូងឆ្លាត និងមានបញ្ញាល្អជាងខួរក្បាលឆ្ងាយណាស់ ពីព្រោះមនុស្សខ្លះមានចំណេះដឹងច្រើន មានបញ្ញាល្អ និងមានការសិក្សាអប់រំខ្ពង់ខ្ពស់ តែជាតុពិតគេទាំងនោះមិនអាចយល់ពីភាសាបេះដូងបានទេ។

ពេលខ្លះ មនុស្សដែលអាចយំចេញ [ Tears Outside ] គឺមិនសូវវេទនាប៉ុន្មានទេ តែមនុស្សដែលយំមិនចេញ គឺវេទនាក្រៃលែង [ Tears Inside ]។ គ្រប់យ៉ាងដែលស្អាតបំផុត គឺស្ថិតនៅខាងក្នុង ហើយគ្រប់យ៉ាងដែលឈឺចាប់បំផុត ក៏ស្ថិតនៅខាងក្នុងដូចគ្នាដែរ៕

# ថ្ងៃទី២០ ខែមីនា

*"ជីវិតមនុស្ស មិនសំដៅឲ្យរស់នៅដោយភាពល្អឥតខ្ចោះទេ តែបើនរណាម្នាក់ល្អឥតខ្ចោះ គឺនឹងត្រូវក្លាយទៅជាកម្មសិទ្ធ របស់សារមន្ទីរជាមិនខាន"។*

ពេលខ្លះ ជម្រើសច្រើនពេក ក៏អាចនាំឲ្យមនុស្សបរាជ័យ។ ពេលខ្លះស្អាតពេកក៏អាចនាំឲ្យមនុស្សអភ័ព្វ ហើយពេលខ្លះ បើរស់នៅដោយភាពល្អឥតខ្ចោះពេក នឹងនាំមកនូវភាពឯកាដែរ ៕

"Life did not intend to make us perfect. Whoever is perfect belongs in a museum."

- Erich Maria Remarque

# ថ្ងៃទី២១ ខែមីនា

*"បើយើងគិតថាគ្រប់យ៉ាងមិនអាចធ្វើទៅរួច នោះសូមកុំរំខានអ្នកដែលកំពុងប្រឹងធ្វើគ្រប់យ៉ាងឲ្យអាចទៅរួចឲ្យសោះ"* ។

ដើរតាមខ្ញុំ បើខ្ញុំអាចដឹកនាំអ្នក។ ដឹកនាំខ្ញុំ បើខ្ញុំមិនអាចដឹកនាំអ្នក តែសូមចេញពីផ្លូវរបស់ខ្ញុំ បើមិនព្រមដើរតាមខ្ញុំ ឬមិនព្រមដឹកនាំខ្ញុំ។ ចូកមិនចូក ចែវមិនចែវ កុំយកជើងរាទឹក។ បើមិនបានជួយចូកគ្នា បើមិនបានជួយចែវគ្នា សូមកុំជិះទូកជាមួយគ្នា៕

*"People who say it cannot be done should not interrupt those who are doing it."*

- George Bernard Shaw

# ថ្ងៃទី២២ ខែមីនា

*"កុមារដែលគ្មានការអប់រំ គឺជាកុមារដែលទទួលបានការអប់រំត្រឹមតែនៅក្នុងសាលារៀនមួយកន្លែងគត់"* ។ ពេលវេលាណា ក៏ជាម៉ោងរៀនសម្រាប់គ្រប់គ្នាដែលចង់រៀន ។ ទីណាក៏ជាសាលារៀនសម្រាប់គ្រប់គ្នាដែលចង់រៀនសូត្រ ហើយនរណា ក៏ជាគ្រូបង្រៀនសម្រាប់គ្រប់គ្នាដែលចង់រៀន ។ មនុស្សរស់ គឺមនុស្សរៀន តែមនុស្សមិនរៀន គឺជាមនុស្សស្លាប់ ពីព្រោះជីវិតគឺត្រូវតែរៀនសូត្ររហូតពេញមួយជីវិតនៃការរស់នៅ។

ការសិក្សាអប់រំ មានរសជាតិល្វីងជូរជត់ ប៉ុន្តែវានឹងផ្តល់ផ្លែផ្កាផ្អែមល្ហែម។ អ្នករៀនត្រូវហ៊ានឈឺចាប់ តែបើអ្នកមិនហ៊ានឈឺចាប់ទេ ក៏គ្មានឱកាសបានរៀនសូត្រដែរ។ រៀនមិនបានស៊ី តែបើប្រឹងរៀនតែពីរបីឆ្នាំយកជំនាញគឺ មនុស្សអាចរកស៊ីចិញ្ចឹមជីវិតពេញមួយជីវិត។

រៀបការជាមួយអ្នកមាន អាចឲ្យយើងក្លាយជាអ្នកមាន តែរៀបការជាមួយអ្នកចេះ មិនអាចឲ្យអ្នកចេះដឹងបានទេ បើមិនប្រឹងរៀនដោយខ្លួនឯង៕

*"A child educated only at school is an uneducated child."* - George Santayana

## ថ្ងៃទី២៣ ខែមីនា

*"បុគ្គលដែលរិះគន់គេឯង គឺជាមនុស្សដែលប្រឡងធ្លាក់លើមុខវិជ្ជាសិល្បៈសាស្ត្រ និងមុខវិជ្ជាអក្សរសាស្ត្រ"។*

មនុស្សដែលមានសិល្បៈក្នុងកាទិតៀនកំហុសអ្នកដទៃនឹងធ្វើឲ្យគ្រប់គ្នាយល់ថាការរិះគន់នោះ មិនមែនត្រឹមតែជាការសរសើរលើកទឹកចិត្តប៉ុណ្ណោះទេ តែថែមទាំងផ្តល់ជាសេចក្តីស្រឡាញ់ទៀតផង។

ការរិះគន់ប្រកបដោយសិល្បៈ តែងតែមានផលល្អជាងការរិះគន់ខ្វះសិល្បៈ។ សម្តីជាឯក លេខជាទោ និងអក្សរជាត្រី។ វោហារសាស្ត្រ បូកនឹងសិល្បៈទ្រឹស្តីនៃការលួងលោមដើម្បីរិះគន់ នឹងមានប្រសិទ្ធភាពជាងគ្រប់យ៉ាងទាំងអស់៕

*"Critics are the men who have failed in literature and art."* - Benjamin Disraeli

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី២៤ ខែមីនា

*"គំនិតល្អ និងទង្វើត្រឹមត្រូវនឹងមិនដែលផ្តល់លទ្ធផលអាក្រក់នោះទេ។ ចំណែកគំនិតអាក្រក់ និងសកម្មភាពខុស ក៏នឹងមិនអាចផលិតលទ្ធផលល្អបានដែរ"។*

ខួរក្បាល គឺជារោងចក្រផលិតគំនិត។ គំនិតបង្កើតសកម្មភាព គឺបានន័យថា គំនិតវិជ្ជមាន បង្កើតទង្វើល្អ។ គំនិតអវិជ្ជមានបង្កើតទង្វើអាក្រក់។ យើងជាប្រធាននៃគំនិតខ្លួនឯង ព្រោះថារាងកាយយើងទាំងមូល ត្រូវគ្រប់គ្រងដោយខួរក្បាល និងគំនិតទាំងអស់។ មនុស្សមានរូបឆោមល្អ តែគំនិតអាក្រក់ ធ្វើអាក្រក់ គេតែងហៅថា *"មនុស្សអាក្រក់"*។ ចំណែកមនុស្សរូបអាក្រក់ តែគិតល្អធ្វើល្អ នោះគេតែងហៅថា *"មនុស្សល្អ"*។

*"Good thoughts and actions can never produce bad results; bad thoughts and bad actions can never produce good results."*

ឡាំ លីម

# ថ្ងៃទី២៥ ខែមីនា

*" យើងត្រូវរកបុគ្គលល្អម្នាក់ដើម្បីលើកទឹកចិត្តឲ្យយើងដើរទៅមុខ មើលទៅមុខ និងឈានទៅមុខប្រសើរជាងគិតថយក្រោយ"។*

ចិត្តសាស្ត្រវាយប្រហារស្មារតី គឺបំផ្លាញស្មារតី កម្ទេចគំនិតវិជ្ជមាន។ យុទ្ធសាស្ត្រនេះ ស្ថិតក្នុងមនុស្សពីរប្រភេទ៖ ១.មនុស្សឆ្លាតខាងកម្ទេសគេឯងដើម្បីប្រយោជន៍ខ្លួនឯង ២. មនុស្សដែលមើលអ្វីៗត្រឹមតែក្រសែភ្នែកខ្លួនឯង នោះមានន័យថា គាត់មានបំណងល្អ តែខ្វះព័ត៌មាន នោះក៏នឹងបណ្តាលឲ្យមានការទិតៀនយើងខុស។

មនុស្សដែលចូលចិត្តទិតៀន និងរិះគន់គេឯង តែងចំណាយពេលកែប្រែគេ ប៉ុន្តែខ្វះពេលវេលាស្វែងរកចំណុចអាក្រក់របស់ខ្លួនឯង។ ជាជាងលើកទឹកចិត្ត បង្ហាញផ្លូវត្រូវដល់គេ តែបែរជាជ្រើសរើសយកការវាយប្រហារគេវិញ។

ពេលយើងធ្វើខុស គេថាយើងល្ងង់។ ពេលយើងចេះ គេថាយើងបានតែទ្រឹស្តី ប៉ុន្តែខ្វះការអនុវត្តន៍។ ពេលយើងធ្វើច្រើន គេថាយើងចង់បានមុខមាត់។ ពេលយើងធ្វើតិច គេថាយើងជិះជាន់កម្លាំងគេ ហើយពេលយើងមិនធ្វើ គេថាយើងខ្ជិល៕

# ថ្ងៃទី២៦ ខែមីនា

*"ការដឹងខ្លួនឯងល្ងង់ មិនគួរឲ្យខ្មាសអៀនទេ តែការគ្មានឆន្ទៈរៀន នោះទើបអាម៉ាស់បំផុត"។*

ការដឹងខ្លួនឯងមិនឆ្លាត ជារឿងប្រសើរ តែបើប្រទាំ្យថាខ្លួនឯងចេះ គឺជារឿងល្ងង់ខ្លៅ។ ការដឹងថាខ្លួនល្ងង់គឺរឿងល្អ តែបើមិនប្រឹងរៀនឲ្យចេះ នោះគឺជាភាពខ្ជិលច្រអូស។ ភាពពូកែ ឬជោគជ័យ បានមកពីភាពឆ្លាតមួយភាគរយ តែបានមកពីការខិតខំតស៊ូប្រឹងប្រែង កៅសិបប្រាំបួនភាគរយ (៩៩%)៕

*"Being ignorant is not so much a shame, as being unwilling to learn."* - Benjamin Franklin

# ថ្ងៃទី២៧ ខែមីនា

*"មានតែមនុស្សស្លាប់ក្នុងសមរភូមិសង្គ្រាមប៉ុណ្ណោះ ទើបអាចមើលឃើញការបញ្ចប់នៃសង្គ្រាមបង្ហូរឈាម"* ។ ការនិយាយច្រើន ប្រសើរជាងសង្គ្រាមវែងអន្លាយ ហើយការយកឈ្នះតាមវប្បធម៌សន្ទនា ឬវិធីការទូត គឺជ័យជម្នះសន្តិភាព។ សង្គ្រាម គឺជានយោបាយដែលមានការបង្ហូរឈាម ប៉ុន្តែនយោបាយ គឺជាសង្គ្រាមដែលគ្មានការបង្ហូរឈាម។

អ្នកនយោបាយម្នាក់ អាចមានជីវិតរាប់ពាន់ក្នុងសង្គ្រាមនយោបាយ តែមនុស្សម្នាក់មានជីវិតតែមួយក្នុងសង្គ្រាមជាក់ស្តែង។ ទឹកល្អក់ ក៏អាចពន្លត់ភ្លើងបាន ហើយពេលខ្លះការបង្កចលាចល ក៏អាចបង្កើតឲ្យមានការផ្លាស់ប្តូរបានដែរ ៕

*"It is only the dead who have seen the end of war"- Plato*

# ថ្ងៃទី២៨ ខែមីនា

*"បុគ្គលដែលភ័យខ្លាចចំពោះការឈឺចាប់ គឺមានន័យថាគេបានឈឺចាប់ដោយសារភាពភ័យខ្លាចនោះរួចទៅហើយ"។*

ក្នុងសង្គមជាក់ស្តែង ប្រជាជនខ្លាចការគាបសង្កត់ដាក់ទារុណកម្មរបស់រដ្ឋាភិបាល ហើយចំណែករដ្ឋាភិបាល ក៏ភ័យខ្លាចចំពោះការរើបម្រាស់តស៊ូវណ្ណៈរបស់ប្រជាជនដូចគ្នាដែរ។

ក្នុងលទ្ធិសាសនា បុគ្គលណាដែលកំពុងមានកំហឹង គឺមានវេទនា និងសេចក្តីឈឺចាប់ស្ថិតក្នុងខ្លួនឯងជាមុន។ បន្ទាប់មកទើបជះកំហឹង និងសេចក្តីឈឺចាប់ទៅអ្នកដទៃតាមក្រោយ៕

*"A man who fears suffering is already suffering from what he fears."* - Michel de Montaigne

# ថ្ងៃទី២៩ ខែមីនា

*"ប្រសិនបើយើងមានពេលវេលាប្រាំបីម៉ោង ដើម្បីកាប់រំលំដើមឈើមួយដើម នោះសូមចំណាយពេលវេលាប្រាំមួយម៉ោងដើម្បីសំលៀងពូថៅ"*។

ការត្រៀមខ្លួនទុកជាមុន ស្មើនឹងជោគជ័យ ៥០ភាគរយ។ ចំណែក ៥០ភាគរយទៀតរង់ចាំតែការអនុវត្តន៍ជាក់ស្តែងប៉ុណ្ណោះ។ មនុស្សមានសមត្ថភាព ធ្វើការងារលឿន តែមនុស្សអសមត្ថភាព ធ្វើការងារយូរ។

មនុស្សឆ្លាតត្រៀមលក្ខណៈរួចហើយ ទើបធ្វើ តែមនុស្សឆោតធ្វើខុសហើយ ទើបត្រៀមលក្ខណៈ។ មនុស្សឆ្លាតគិតមុនគូរ តែមនុស្សឆោត គូរខុសហើយ ទើបចាប់ផ្តើមគិត។ មនុស្សឆ្លាត រៀនពីបទពិសោធន៍អ្នកដទៃ ជៀសវាងបង្កើតកំហុសខ្លួនឯង ប៉ុន្តែមនុស្សដែលឆោត បង្កើតកំហុសនិងបរាជ័យរាប់រយ រួចរៀនពីកំហុសខ្លួនឯង។

មនុស្សឆ្លាតដោះស្រាយបញ្ហា តែមនុស្សមហាឆ្លាត ការពារកុំឲ្យបញ្ហាកើតឡើង ៕

*"If I had eight hours to chop down a tree, I'd spend six hours sharpening my axe."* - Abraham Lincoln

# ថ្ងៃទី៣០ ខែមីនា

*"ជ្រៅទឹកជ្រៅដី មិនជាជ្រៅអ្វី គង់អាចទៅដល់ ឯគំនិតជ្រៅ ជ្រៅឆ្ងាយសែនសល់ ជ្រៅទៅមិនដល់ គ្មានទីបំផុត"។*

សៀវភៅមិនមែនជាសៀវភៅ ឬគ្រាន់តែជាក្រដាសមួយដុំប៉ុណ្ណោះ បើយើងមិនយកវាមកអាន។ ស្នេហាមិនមែនជាស្នេហាទេ បើយើងត្រឹមតែលាក់ទុកក្នុងបេះដូងខ្លួនឯងដោយមិនបង្ហាញសេចក្តីស្រឡាញ់ចេញមក ឲ្យដល់មនុស្សដែលយើងស្រឡាញ់។

ចំណេះដឹងនឹងក្លាយត្រឹមតែជាព័ត៌មាននៅក្នុងខួរក្បាល បើយើងមិនបានចែករំលែកការចេះដឹងនោះដល់អ្នកដទៃ ឬមិនយកមកអនុវត្តជាក់ស្តែង។ សូមប្រឹងប្រែង គឺប្រឹងដោយចាំពាក្យមួយប្រយោគថា *"ឲ្យតែមានសន្តិភាព នោះនឹងលទ្ធភាព ដូច្នេះ ចូរប្រើសន្តិភាពឲ្យមានប្រសិទ្ធិភាព។*

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

ពេលក្រកុំអស់សង្ឃឹម ហើយពេលមានកុំភ្លើតភ្លើន"។

*"Deep water, deep earth, is never so deep that the bottom is unreachable; the deep idea, is deep beyond measure, it has depth that cannot be reached, having no end."*

## ទស្សនៈសម្រាប់ខែ

# មេសា

# ថ្ងៃទី០១ ខែ មេសា

*"តើមានអ្វីខុសគ្នារវាងអ្នកមិនចេះអានអក្សរ និងអ្នកចេះអានអក្សរ តែមិនព្រមអាន"?*

ចំណេះដឹងមិនមែនជាអំណាចទេ តែវាគ្រាន់តែជាព័ត៌មានតែប៉ុណ្ណោះ។ ចំណេះដឹងនឹងក្លាយទៅអំណាចទៅបានលុះត្រាតែយើងយកមកអនុវត្តជាសកម្មភាពជាក់ស្តែង នៅក្នុងជីវិតរស់នៅ។ការរៀនសូត្រ គឺដូចគ្នាទៅនឹងការបរិភោគអាហារ មិនថាយើងបរិភោគច្រើនប៉ុនណាទេ តែសំខាន់ត្រង់ថា តើយើងបានរំលាយអាហារនោះប៉ុន្មាន?

# ថ្ងៃទី០២ ខែ មេសា

អារីស្តូត [ Aristotle ] និយាយអំពីសន្តិភាព និងសង្គ្រាមថា *"ការឈ្នះសង្គ្រាមតែមួយមុខ គឺនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ ប៉ុន្តែអ្វីដែលសំខាន់ជាងទៅទៀតនោះ គឺការចេះរៀបចំសន្តិភាព"*។

អ្នកដឹកនាំណាដែលនិយាយគំរាម ប្រជាពលរដ្ឋខ្លួនឯងពីរឿងសង្គ្រាម តែងចង់បង្ហាញសារទៅបណ្តាប្រជាជន និងបញ្ញាវ័ន្តនូវ ២អត្ថន័យ៖

s

១. បើមានសង្គ្រាមមែន អ្នកដឹកនាំនោះចង់បង្ហាញថាខ្លួនគឺជាវីរបុរសសង្គ្រាម។វីរបុសនៃសង្គ្រាម គឺចង់បញ្ជាក់ថារាល់ជ័យជម្នះ រហូតបានក្លាយជាអ្នកដឹកនាំកន្លងមករបស់ខ្លួនគឺដោយសារតែចេះគំរាម ចេះសំឡុត ហើយរាល់ជ័យជម្នះរបស់អ្នកដឹកនាំប្រភេទនេះ គឺជាកង់ប្រវត្តិសាស្ត្រនៃសង្គ្រាមបង្ហូរឈាម។

២. បើគ្មានសង្គ្រាមទេ អ្នកដឹកនាំនោះចង់បង្ហាញថា ខ្លួនគឺជាវីរបុរសប្រជាពិថុតិ ឬកុហកបោកប្រាស់។ ចំណែក កវីរបុរសប្រជាពិថុតិ គឺចង់បង្ហាញថា រាល់ជ័យជម្នះកន្លង មក គឺកើតមកដោយសារនយោបាយបោកប្រាស់រាស្ត្រ និងបែបប្រជាពិថុតិ។

ដល់ពេលត្រូវផ្លាស់ប្ដូរ បែរជានៅទ្រឹងមិនធ្វើដំណើរ ហើយ បើមិនធ្វើដំណើរ គឺស្មើនឹងមិនស្គាល់ពិភពលោក។ សេចក្ដីសុខក្នុងខ្លួនមាននៅក្នុងខ្លួនមនុស្សរៀងខ្លួន។ សន្តិភាព ក្នុងសង្គមមាននៅក្នុងសង្គមមនុស្សរស់នៅ ហើយបើយើង ជាជននៃសង្គម នោះត្រូវទទួលស្គាល់ថា ផ្លាស់ប្ដូរខ្លួនឯង ឲ្យល្អប្រសើរជាងមុន គឺជារឿងពិបាកបំផុតមួយ តែមាន រឿងពិបាកជាងនេះទៀត នោះគឺផ្លាស់ប្ដូរសង្គមឲ្យល្អ ប្រសើរជាងមុន។

ផ្លាស់ប្តូរខ្លួនឯង គឺជារឿងពិបាកមួយសម្រាប់ខ្លួនឯង តែផ្លាស់ប្តូរសង្គម គឺជារឿងសុខទុក្ខរបស់កូនចៅជំនាន់ក្រោយ ៕

*"It is not enough to win a war; it is more importantto organize the peace."* - Aristotle

# ថ្ងៃទី០៣ ខែ មេសា

សូក្រាត [ Socrates ពោលថា *"ទ្រព្យសម្បត្តិមិនអាចធ្វើឲ្យមនុស្សមានគុណធម៌បានទេ តែគុណធម៌នឹងធ្វើឲ្យមនុស្សមានទាំងទ្រព្យសម្បត្តិ ព្រមទាំងមានគ្រប់យ៉ាង"*។

នៅពេលដែលទ្រព្យសម្បត្តិរបស់មនុស្ស បានធ្វើឲ្យមនុស្សមានអំណាច គឺថាគុណធម៌ជាមនុស្ស នឹងធ្វើឲ្យមនុស្សថោកទាប។ បើមានជាតិ គឺត្រូវមានមនុស្សលះបង់ដើម្បីជាតិ។ បើមានអំពើអាក្រក់ ត្រូវមានមនុស្សល្អបង្ក្រាប ហើយគ្រប់យ៉ាងនឹងប្រព្រឹត្តទៅតាមដំណើរនៃធម្មជាតិ។

ធម្មជាតិបានបង្ហាញថា មនុស្សកាន់តែចាស់នឹងស្លាប់។ អ្នកណាធ្វើអាក្រក់ នឹងមិនសូវទទួលផលល្អឡើយ ហើយគ្រប់យ៉ាងដែលឡើងខ្ពស់ គង់តែនឹងធ្លាក់ចុះវិញ។ សូមកុំបោះបង់សេចក្ដីល្អ បើទោះបីយើងត្រូវបានក្រុមភាគច្រើនថា យើងជាមនុស្សល្ងង់ក៏ដោយ តែភាពល្ងង់របស់យើងជា

សេចក្តីពិត ៕

*"Virtue does not come from wealth, but. . . wealth, and every other good thing which men have.. comes from virtue."*- Socrates

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

## ថ្ងៃទី០៤ ខែ មេសា

អារីស្តូត [ Aristotle ] ពោលថា *"មនុស្សណាដែលយល់ដឹង ត្រូវធ្វើសកម្មភាពឲ្យគេឯងមើលជាគំរូ ហើយមនុស្សណាដែលចេះដឹង ត្រូវជួយបង្រៀនដល់គេឯងផង"*។

បើរៀនដើម្បីតែដឹង គឺមិនទាន់គ្រប់គ្រាន់ទេ តែត្រូវរៀនដើម្បីធ្វើ និងអនុវត្តផង។ កុំរៀនដើម្បីចេះតែម្នាក់ឯង តែត្រូវរៀនដើម្បីបង្រៀនគេឯងផង និងកុំរៀនឲ្យយល់តែម្នាក់ឯង តែត្រូវរៀនដើម្បីជួយពន្យល់គេឯងឯងផង៕

*"Those who know, do. Those that understand, teach."*- Aristotle

# ថ្ងៃទី០៥ ខែ មេសា

អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] និយាយថា *"ចូរយើងផ្លាស់ប្តូរកែកុនហេតុការណ៍ពិតភ្លាម ប្រសិនបើហេតុការណ៍ពិតនោះមិនស៊ីមេទ្រីជាមួយនឹងទ្រឹស្តី"*។ អ្វីដែលអកុសលខ្លាំងបំផុតគឺអវិជ្ជា។ អ្វីដែលជាសោកនាដកម្មខ្លាំងបំផុត គឺចេះទ្រឹស្តី តែមិនព្រមអនុវត្ត ហើយអ្វីដែលកាន់តែឈឺចាប់ថែមទៀតនោះ គឺអនុវត្តសកម្មភាពខុសពីទ្រឹស្តីត្រឹមត្រូវ។ទ្រឹស្តីល្អ គឺជាអក្សរ ឬគំនិត តែមនុស្សជាអ្នកអនុវត្ត។ លទ្ធផលល្អ ពីព្រោះបានអនុវត្តទ្រឹស្តីល្អ ហើយលទ្ធផលអាក្រក់ ពីព្រោះអនុវត្តខុសឆ្ងាយពីទ្រឹស្តីល្អ។ ចូរប្រឹងអនុវត្តសកម្មភាពឲ្យល្អដូចទ្រឹស្តី តែបើមិនទាន់អនុវត្តសកម្មភាពល្អនៅឡើយទេ ចូរកាច់ពត់បត់បែនការអនុវត្តន៍ឲ្យស្របនឹងទ្រឹស្តីល្អ៕ *"If the facts don't fit the theory, change the facts."* - Albert Einstein

# ថ្ងៃទី០៦ ខែ មេសា

*"ចូរយើងរៀនលាក់នូវតម្រូវការរបស់ខ្លួន តែត្រូវចេះបង្ហាញនូវជំនាញការរបស់ខ្លួនវិញ"។*

បើគ្មានសំណួរក៏គ្មានចម្លើយ។បើមិនសុំនឹងគ្មានអ្នកណាឲ្យ ហើយបើចង់បាន ចង់ចេះ ត្រូវចេះរៀនតស៊ូយកដោយញើសឈាមខ្លួនឯង។ កុំដេកដើរឈរអង្គុយបន់ស្រន់ព្រះ ឬរង់ចាំឲ្យគ្រប់យ៉ាងកើតឡើងដោយខ្លួនឯងឲ្យសោះ។

មនុស្សជាអ្នកបង្កើតគ្រប់យ៉ាង មិនមែនគ្រប់យ៉ាងជាអ្នកបង្កើតមនុស្សទេ។ មនុស្សជាម្ចាស់វាសនាលើខ្លួនឯង មិនមែនវាសនាជាម្ចាស់លើជីវិតមនុស្សនោះទេ។ ប៉ុន្តែ បើសិនជាយើងជឿលើព្រហ្មលិខិត នោះក៏ត្រូវចេះតវ៉ាទាមទារចំពោះព្រហ្មលិខិតអាក្រក់ដែរ។ ការតវ៉ាទាមទារ គឺមានន័យថាប្រឆាំងវាសនាអាក្រក់ ស្របវាសនាល្អ ហើយការតវ៉ា

ទាមទារ ក៏ត្រូវធ្វើដូចជាការបរិភោគអាហារប្រចាំថ្ងៃដែរ។ បើយើងញ៉ាំរាល់ថ្ងៃដើម្បីរស់រាន នោះត្រូវប្រឹងរាល់ថ្ងៃដើម្បីមានជីវិតល្អស្រស់ដែរ៕

*"Learn to hide your need and show your skill."*

- Jim Rohn

# ថ្ងៃទី០៧ ខែ មេសា

*"សមត្ថភាពខ្លាំង ប្រហែលជានឹងធ្វើឲ្យយើងអាចឡើងដល់ចំណុចខ្ពស់ តែចរិតលក្ខណៈល្អ នឹងរក្សាយើងមិនឲ្យធ្លាក់មកខាងក្រោមវិញ"។*

ចេះដាក់ខ្លួនចំពោះអ្នកតូច ប្រសើរជាងយកខ្លួនទៅអែបអបចំពោះអ្នកធំ។ អ្នកចូលចិត្តអែបអបអ្នកធំ ក៏ប្រហែលជាប្រសើរជាងពុករលួយ។ អ្នកចេះពិត តែងធ្វើការងារពិត តែអ្នកចេះក្លែងក្លាយចូលចិត្តអែបអប។ អ្នកយល់ការណ៍ធ្វើការងារដោយស្ងប់ស្ងាត់ តែអ្នកគ្មានបានការណ៍ ធ្វើការងារយកតែឈ្មោះ។ អ្នកធ្វើការងារពិត តែងប្រឹងធ្វើដប់ រួចបង្ហាញមួយ តែអ្នកធ្វើការងារយកឈ្មោះ សុខចិត្តធ្វើមួយរួចប្រឹងបង្ហាញឲ្យបានដប់៕

"Ability may get you to the top, but it takes character to keep you there." - John Wooden

# ថ្ងៃទី០៨ ខែ មេសា

*"អាថ៌កំបាំងនៃភាពជោគជ័យក្នុងជីវិត គឺការចេះយកភាពរីករាយ ជំនួសទៅលើសេចក្ដីឈឺចាប់ ហើយយកក្ដីឈឺចាប់មកធ្វើជាក្ដីសប្បាយ។ បើអាចធ្វើបាន យើងជាម្ចាស់នៃជីវិតយើង តែបើធ្វើមិនបាន ជីវិតនឹងជាម្ចាស់នៃយើងវិញ"។*

បញ្ហាធំបំផុតរបស់យុវជន គឺស្នេហា។ បញ្ហាធំរបស់ជាតិ គឺបណ្ឌិតមិនចេញមុខ ហើយបញ្ហាធំរបស់រាស្ត្រក្រ គឺភាពក្រីក្រ។ ដើម្បីដោះស្រាយបញ្ហារាស្ត្រក្រ គឺយុវជនកុំមានជំងឺ ហើយដើម្បីឲ្យបណ្ឌិតចេញមុខ លុះត្រាតែចេះឈឺចាប់ចំពោះជាតិ៕

# ថ្ងៃទី០៩ ខែ មេសា

*"ព្រឹត្តិការណ៍ខ្លោចផ្សា ឬសោកនាដកម្មក្នុងពិភពលោក គឺនៅពេលពលរដ្ឋមិនដឹងថាខ្លួនឯងជាប្រជាពលរដ្ឋនៃពិភពលោក"។ បើមានសន្តិភាពក្នុងខ្លួននឹងបង្កើតឲ្យមានសន្តិភាពក្នុងគ្រួសារ។*

បើមានសន្តិភាពក្នុងគ្រួសារនឹងបង្កើតឲ្យមានសន្តិភាពក្នុងភូមិស្រុក។ បើមានសន្តិភាពក្នុងភូមិស្រុក នឹងបង្កើតឲ្យមានសន្តិភាពក្នុងខេត្តក្រុង។ បើមានសន្តិភាពក្នុងខេត្តក្រុងនឹងបង្កើតឲ្យមានសន្តិភាពក្នុងសង្គម ក្នុងប្រទេស និងទូទាំងសកលលោក។

បើគ្មានសេចក្តីស្រឡាញ់ គឺគ្មានកូនមនុស្ស។ បើគ្មានការកសាងសន្តិភាព ពិភពលោកនឹងរលាយ ហើយបើពិភពលោករលាយ កូនមនុស្សនឹងរលាយ។ ពេលយើងស្គាល់ខ្លួន

ឯងជានរណា យើងនឹងស្គាល់តួនាទីរបស់យើងថាត្រូវធ្វើយ៉ាងណាចំពោះសង្គមដែលខ្លួនរស់នៅ។ សង្គមឈឺ ត្រូវការមនុស្សជាមកព្យាបាល ហើយសង្គមអយុត្តិធម៌ ត្រូវការមនុស្សយុត្តិធម៌ជួយរកខុសត្រូវ។

ទីណាមានការគាបសង្កត់ នោះទីនោះមានការរើបម្រាស់ ហើយទីណាមានការរើបម្រាស់ ទីនោះមានសេរីភាពល្អប្រសើរ។ ភាពអយុត្តិនៅកន្លែងមួយ គឺជាការគំរាមគំហែងដល់ភាពអយុត្តិធម៌នៅគ្រប់ទីកន្លែងទាំងអស់៕

*"We are citizens of the world. The tragedy of our times is that we do not know this."*

- Woodrow Wilson

# ថ្ងៃទី១០ ខែ មេសា

ណាប៉ូឡេអុង ហ៊ីល [ Napoleon Hill ] អះអាងថា *"គ្រប់បញ្ហា តែងមានឱកាសក្នុងនោះយ៉ាងតិចមួយ"*។

មនុស្សវិជ្ជមាន តែងសម្លឹងស្វែងរកមើលដួងតារា បើកាលណាមេឃងងឹត ហើយសម្លឹងមើលឥន្ទធនូយ៉ាងរំភើយ បើកាលណាមេឃមានភ្លៀងផ្គរ ឬមានខ្យល់បក់បោកខ្លាំង។ ក្នុងផែនដីនេះ គ្មានអ្នកណាម្នាក់ អាចរស់នៅដោយរីករាយឥតខ្ចោះ ឬទុក្ខសោកឥតស្រាកស្រាននោះទេ តែជីវិតគឺមានឡើងមានចុះ មានសប្បាយមានទុក្ខ មានជួបមានបែក ធម្មតា និងមិនធម្មតា។
ប៉ុន្តែពេលខ្លះ បើយើងជឿលើព្រហ្មលិខិត ហើយមានរឿងអយុត្តិធម៌បានកើតឡើងយ៉ាងច្រើនលើយើង នោះសូមរៀនប្រឆាំងតវ៉ានឹងព្រហ្មលិខិត ឬអ្នកណាក៏ដោយឲ្យតែលិខិតជីវិតយើងដោយអយុត្តិធម៌ពេក៕

# ថ្ងៃទី១១ ខែ មេសា

*"មនុស្សឆ្លាតបំផុត នឹងមិននិយាយអ្វីទាំងអស់ក្នុងកាលៈទេសៈគ្រោះថ្នាក់បំផុត"*។

ក្នុងពេលជួបបញ្ហា មនុស្សខ្លះសួរថា តើមានបញ្ហាអ្វី? អ្នកខ្លះសួរថា នរណាជាអ្នកបង្កើតបញ្ហាឡើង? អ្នកខ្លះឈរមើល...។ អ្នកខ្លះដោះសា...។ អ្នកខ្លះបន្ទោសមេឃដី...។ អ្នកខ្លះស្រែកនិយាយពីទ្រឹស្តី ប៉ុន្តែមនុស្សឆ្លាតប្រឹងដោះស្រាយបញ្ហា។ មនុស្សឆ្លាតធ្វើជាចំណែកនៃដំណោះស្រាយ តែមនុស្សឆោតគ្រាន់តែជាចំណែកនៃបញ្ហាប៉ុណ្ណោះ៕

*"Wise men say nothing in dangerous times."* - Aesop

# ថ្ងៃទី១២ ខែ មេសា

ច្បាប់នៃការស្រូបទាញ [ The Law of Attraction ] អះអាងថា *"ល្អ ទាញល្អចូលរកគ្នា។ គិតពីបញ្ហាកាន់តែខ្លាំង គឺបញ្ហាកាន់តែចូលមកជិត ហើយគិតវិជ្ជមាន គឺរឿងវិជ្ជមាននឹងចូលមករកយើង"*។

ទ្រឹស្តីចិត្តវិទ្យាក៏បានអះអាងថា *"ការសរសើរលើកទឹកចិត្តដល់នរណាម្នាក់ម្តង នោះបានត្រឹមតែ ផ្តល់កម្លាំងចិត្តដល់គេម្តង តែបើសរសើរលើកទឹកចិត្តម្តងហើយម្តងទៀត នោះអ្នកដែលយើងសរសើរលើកទឹកចិត្ត នឹងក្លាយជាអ្វីដែលយើងតែងតែសរសើរលើកទឹកចិត្ត"*។

អ្នកនិពន្ធប្រលោមលោក និងកវីជនជាតិស្កុតឡង់ លោក រ៉ូបឺត ល្វី ស្ទីវិនសាន់ [ Robert Louis Stevenson ] បានអះអាងថា "ចូរទុកសេចក្តីភ័យខ្លាចក្នុងខ្លួនរបស់យើង

*ចុះ ហើយចូរចែករំលែកនូវកម្លាំងចិត្តរបស់យើងដល់អ្នកដទៃផង"។* ចំណែកកវីសញ្ជាតិអង់គ្លេស លោក ជីខេ ឆេស្ទ័រតុន [ G.K Chesterton ] ក៏បាននិយាយថា *"មនុស្សដែលមានបំណងចង់ក្លាយខ្លួនទៅជាជនអស្ចារ្យតែងតែធ្វើឲ្យអ្នកដទៃមានអារម្មណ៍តូចទាបជាងខ្លួន តែបុគ្គលអស្ចារ្យពិតប្រាកដ គឺជាជនដែលតែងតែធ្វើឲ្យអ្នកដទៃតែងមានអារម្មណ៍ខ្លាំងអស្ចារ្យជាងខ្លួន"។*

ក្នុងសង្គមខ្មែរពីដើមគឺល្អ តែមនុស្ស ឬអ្នកដឹកនាំសង្គមទេដែលធ្វើព្យុះធ្វើភ្លៀងនាំសង្គមទៅជាអាក្រក់។ យុវជនក្នុង ស.វទី២១ មានទុក្ខលំបាកច្រើន ចូលចិត្តត្អូញត្អែរច្រើន យូរទៅបញ្ហានៃការត្អូញត្អែរក៏នឹងក្លាយទៅជាវប្បធម៌ ហើយបើកម្មអវិជ្ជមាន នោះផលខាងមុខក៏មិនល្អដូចគ្នាដែរ [ the Law of Cause and Effect ]។ មេដឹកនាំសង្ហបុរីលោក លី ក្វាន់យូ [ Lee Kuan Yew ] និយាយថា " វប្បធម៌គឺជាជោគវាសនា ឬ Culture is Destiny"មិនទាន់ធំដឹងក្ដីពិតប្រាកដ តែចេះបង្កើតក្ដីស្នេហាប្រុសស្រី ហើយខ្លួនក្មេងតែមេម៉ាយចិត្ត ឬក្រមុំកាយ មេម៉ាយចិត្ត ងងឹតគំនិតព្រោះ

ស្នេហា។ បុរាណពោលទុកថា "បើស្រឡាញ់ខ្លួនត្រូវស្ងួន ចំណី ស្រឡាញ់ស្រីត្រូវថ្នមចិត្ត ហើយបើចង់បានគំនិត នោះត្រូវប្រឹងរៀនសូត្រ"៕

# ថ្ងៃទី១៣ ខែ មេសា

ខុង ជឺ [ Confucius ] ពោលទុកថា *"ជោគជ័យធំបំផុតក្នុងជីវិតមនុស្ស មិនមែនស្ថិតនៅលើការមិនចេះបរាជ័យនោះទេ ប៉ុន្តែគឺស្ថិតនៅលើការចេះក្រោកឈរឡើងវិញរាល់ពេលដួល"*។

មនុស្សខ្លាំងមិនចាំបាច់មានអាវុធអស្ចារ្យ។ មនុស្សខ្លាំងមិនចាំបាច់មានមាឌធំ។ មនុស្សខ្លាំងសុខចិត្តស្រក់ឈាមតែមិនស្រក់ទឹកភ្នែក និងសុខចិត្តហត់នឿយកាយ តែមិនហត់នឿយចិត្ត។ មនុស្សខ្លាំង គឺនឹងរស់នៅក្នុងសភាពខ្លាំងខាងក្នុងចិត្ត មានឆន្ទៈខ្លាំង និងមិនងាយចុះចាញ់ ទោះមេឃរលំភ្នំរលាយចំពោះមុខ ក៏នៅតែមិនព្រឺព្រួចឡើយ។

ជោគជ័យគ្មានអ្វីគួរឲ្យរីករាយ បើមិនបានជួបឧបសគ្គខ្លះ។ បរាជ័យក៏គ្មានអ្វីគួរឲ្យខ្លាច បើយើងនៅតែអាចក្រោកឈរបាន។

ឡាំ លីម

ឧបសគ្គតូច ឬធំ ការប្រឹងប្រែងតិច ឬច្រើន បើទោះបីគ្មាននរណាម្នាក់ឃើញតម្លៃ នោះក៏កុំអាក់អន់ស្រពន់ចិត្តឡើយ ពីព្រោះមនុស្សខ្លាំងប្រៀបដូចនឹងផ្កាមួយទង បើទោះបីជាគ្មានអ្នកណានិយាយថាក្រអូប តែវាក៏នៅតែក្រអូបក្នុងសភាពធម្មជាតិរបស់ផ្កាជានិច្ច៕

# ថ្ងៃទី១៤ ខែ មេសា

មហាត្មៈ គន្ធី [ Mohandas Gandhi ] ពោលថា *"គ្មានផ្លូវ ឬមាគ៌ាទៅកាន់សន្តិភាពទេ តែមានតែសន្តិភាព"*។

យើងមិនចាំបាច់ស្វែងរកផ្លូវទៅរកសន្តិភាពទេ ហើយសូមលុបពាក្យ *"ផ្លូវ"* ចេញ នោះយើងនឹងបានប្រទះនឹងសន្តិភាពជាក់ជាពុំខាន។ សន្តិភាពតែងតែស្ថិតនៅក្នុងខ្លួនមនុស្សរៀងខ្លួន ហើយក៏ពុំចាំបាច់ដើររកនៅកន្លែងណា ឬទៅសុំពីនរណាម្នាក់ឡើយ។ សេចក្តីទុក្ខ ពុំល្អប្រសើជាងសេចក្តីសុខ។ សេចក្តីសុខ ពុំល្អស្មើសេចក្តីស្ងប់ ឬសន្តិភាព ហើយទ្រឹស្តីពុទ្ធនិយម បង្ហាញថា *"គ្មានសេចក្តីសុខណា ស្មើសេចក្តីស្ងប់ឡើយ"*៕

*"There is no 'way to peace,' there is only 'peace."*

- Mohandas Gandhi

# ថ្ងៃទី១៥ ខែ មេសា

សម្តេចសង្ឃដាឡៃ ឡាម៉ា [ the 14th Dalai Lama ] មានសង្ឃដីកាថា *"សាសនានៃភាពសាមញ្ញ គឺមិនចាំបាច់មានព្រះវិហារ មិនចាំបាច់គិតដល់ទស្សនវិជ្ជានាំឲ្យមានភាពស្មុគស្មាញឡើយ យើងគ្រាន់តែយកខួរក្បាលរបស់យើង និងបេះដូងរបស់យើងមកធ្វើជាព្រះវិហារ ហើយទស្សនវិជ្ជារបស់យើង គឺចិត្តសប្បុរសធម៌"*។

ពិភពលោកពោរពេញដោយបុគ្គលជោគជ័យ ទើបបិតារូបវិទ្យាស.វទី២០ អាល់បឺត អាញស្តាញ [ Albert Einstein ] ពោលផ្តាំថា "ចូរធ្វើជាមនុស្សមានតម្លៃ ប្រសើរជាងខំ*ព្យាយាមធ្វើជាមនុស្សជោគជ័យ"*។

អតីតនាយករដ្ឋមន្រ្តីចិនលោក Yun Sun Ye [ ឆ្នាំ១៩៧៨ - ១៩៨៤ ] បានផ្តល់ដំបូន្មានថា *"អំណាចបុណ្យសក្តិមិនអាចស្មើកេរ្តិ៍ឈ្មោះ និងកិត្តិយសបានទេ*។

*ចូររៀនស្គាល់ពីតម្លៃនៃវត្ថុរូបិយ និងវត្ថុអរូបិយ ដោយកុំរៀនដឹងត្រឹមតែវត្ថុនោះមានតម្លៃប៉ុន្មានដុល្លារ"។*

មហាត្មៈ គន្ធី [Mahatma Gandhi] បានផ្ដាំទុកក្នុងសៀវភៅ Principle - Centered Leadership និពន្ធដោយ លោក Stephen R. Covey បានសរសេរអំពីអំពើបាបមួយក្នុងចំណោម ៧ គឺ *"សាសនាដោយគ្មានពលិកម្ម ឬ Religion Without Sacrifice"* មនុស្សចាប់ផ្ដើមរើសអើងព្រះសាសនាអញ សាសនាឯង ឬព្រះអញព្រះឯង និងជំនឿអញត្រូវជំនឿឯងខុស។

កំហុសធំរបស់សាសនាក្នុងលោក គឺបង្រៀនមនុស្សឲ្យគោរពព្រះពិតមានតែមួយ [ Mono-Divineness ] មើលងាយព្រះរបស់សាសនាផ្សេង។ ចុងក្រោយបង្កើតជម្លោះសាសនា និងសង្គ្រាមសាសនា។ ព្រះពុទ្ធបានបង្រៀនអប់រំមនុស្សយើងឲ្យពឹងផ្អែកលើ ៤យ៉ាងគឺ៖

១. ឲ្យពឹងផ្អែកលើគំនិតស្មារតី និងអត្ថន័យនៃសេចក្ដីបង្រៀន តែមិនមែនពឹងផ្អែកលើពាក្យបង្រៀននោះទេ [ តែការយកពាក្យអសុរោះ ពាក្យជេរប្រទេច ការជាន់ពន្លិចមកបង្រៀនឲ្យមនុស្សកែប្រែផ្លាស់ប្ដូរទិសដៅមករកល្អ នោះក៏មិនចាត់ទុកថាត្រឹមត្រូវដែរ ឬបានសាបព្រោះអសីលធម៌ក្នុងសង្គម ]។

២. ឲ្យពឹងផ្អែកលើសេចក្ដីបង្រៀន តែមិនមែនទៅលើបុគ្គលិកលក្ខណៈអ្នកបង្រៀននោះទេ។

៣. ឲ្យពឹងផ្អែកលើបញ្ញាពិតប្រាកដ តែមិនមែនលើការបកស្រាយយ៉ាងរាក់សើរៗនោះទេ ។

៤. ឲ្យពឹងផ្អែកទៅលើសារៈសំខាន់នៃគំនិតបញ្ញាបរិសុទ្ធរបស់យើង តែមិនមែនពឹងផ្អែកលើទស្សនៈថ្កោលទោសនោះទេ។

"This is my simple religion. There is no need for temples; no need for complicated philosophy. Our own brain, our own heart is our temple; the philosophy is kindness." - Dalai Lama

# ថ្ងៃទី១៦ ខែ មេសា

"ដំណើរជីវិតប្រៀបបីដូចជាការបើកបរថយន្ត ពេលខ្លះយើងអាចងាកមើលក្រោយម្តងម្កាល តែនៅតែត្រូវបន្តដំណើរទៅមុខ"។

ពេលខ្លះការថយក្រោយ ប្រៀបដូចជារថយន្តត្រូវការដាក់លេខថយក្រោយ ឬ Reversed Gear ដើម្បីឲ្យមានកម្លាំងខ្លាំងសម្រុកទៅមុខបាន។ ចូរកុំភ្លេចថា ធម្មជាតិបង្កើតឲ្យមនុស្សមានត្រចៀកពីរមាត់មួយ គឺឲ្យយើងស្តាប់ឲ្យច្រើននិយាយឲ្យតិច។ ឲ្យមានដៃពីរ មានជើងពីរ គឺត្រូវប្រឹងប្រែងតស៊ូឲ្យមែនទែន ហើយឲ្យមានភ្នែកនៅខាងមុខ គឺតម្រូវឲ្យមនុស្សយើងត្រូវសម្លឹងទៅមុខជានិច្ច និងដើរទៅមុខជានិច្ច។

*"Life is like driving a car. It's okay to look behind sometimes but keep looking straight because life's goes on."*

# ថ្ងៃទី១៧ ខែ មេសា

*"ការអប់រំ គឺជាមិត្តល្អរបស់មនុស្ស ហើយមនុស្សដែលមានការអប់រំ គឺទទួលបានការគោរពរាប់អានគ្រប់ទីកន្លែង។ ការអប់រំ តែងធ្វើឲ្យមនុស្សនៅតែមានសម្រស់ស្រស់ស្អាតក្មេងជានិច្ច"។*

អ្នករៀនមិនងាយចាស់ រីឯអ្នកដែលចាស់ គឺអ្នកមិនចង់រៀន ។ អ្នករៀនអាចជោគជ័យ ឬរាជ័យ និងអាចមាន ឬអាចក្រ តែយ៉ាងហោចណាស់ គេក៏នឹងអាចមានសេចក្តីសុខចំពោះរបស់បន្តិចបន្តួចក្នុងជីវិត៕

"Education is the best friend. An educated person is respected everywhere. Education beats the beauty and the youth. " Chanakya

# ថ្ងៃទី១៨ ខែ មេសា

រ៉ាហ្វ រ៉ាល់ដូ អេម័រសាន់ [ Ralph Waldo Emerson ] ពោលថា *"មនុស្សលោកយើងប្រហែលជាមិនដឹងទេថា គំនិតទស្សនៈរបស់ខ្លួនចំពោះពិលោក គឺជាការសារភាពទទួលយកចរិតលក្ខណៈរបស់ខ្លួន"។*

មនុស្សអាក្រក់មើលឃើញរឿងល្អថាគ្មានប្រយោជន៍ អ៊ីចឹងខ្លួនក៏ជ្រើសរើសយកទង្វើអាក្រក់ ហើយបោះបង់ចោលការប្រព្រឹត្តទង្វើល្អ។ មនុស្សល្អមើលឃើញរឿងអាក្រក់ថាគ្មានប្រយោជន៍ អ៊ីចឹងខ្លួនក៏ជ្រើសរើសយកទង្វើល្អ ហើយបោះបង់ចោលការប្រព្រឹត្តទង្វើអាក្រក់។ មនុស្សល្អគាំទ្រទង្វើល្អ មនុស្សអាក្រក់គាំទ្រទង្វើអាក្រក់៕

# ថ្ងៃទី១៩ ខែ មេសា

ហ្វ្រីឌ្រិច និហ្សឺ [ Nietzsche ] បាននិយាយថា *"ធ្វើជាមនុស្ស កុំចេះតែដើរតាម ស្តាប់តាម ឬធ្វើតាមខ្ញុំ តែចូរចេះយកខ្លួនឯងជាប្រធាន"។*

កុំឲ្យត្រី តែត្រូវបង្រៀនឲ្យចេះស្ទូចត្រី។ ទីណាងងឹត មាននរណាម្នាក់រកផ្លូវចេញមិនឃើញ យើងមិនត្រូវធ្វើជាអ្នកភ្លឺរួចហើយដឹកដៃអ្នកនោះចេញពីទីងងឹតទេ តែយើងត្រូវផ្តល់បញ្ញាឲ្យមនុស្សនោះភ្លឺ ហើយឲ្យគេដើរចេញដោយខ្លួនឯង។ ព្រះពុទ្ធសម្តែងថា *"ធម្មទាន ឈ្នះអស់ទានទាំងពួង"៕*

# ថ្ងៃទី២០ ខែ មេសា

*"មនុស្សដែលមិនធ្លាប់ជួបការលំបាក ឬសេចក្តីវេទនាឈឺឈឺចាប់ ពេលឃើញទុក្ខវេទនារបស់អ្នកដទៃ ឬសេចក្តីក្រៀមក្រំរបស់អ្នកដទៃ គឺគេមិនអាចពាល់ត្រូវអារម្មណ៍នៃសេចក្តីលំបាក ឈឺចាប់ទាំងនោះបានឡើយ"។*

រយៈពេលប្រាំបីឆ្នាំជាង ដៃម្ខាងជាចំណែកតូចមួយនៃការជួយសង្គម និងដៃម្ខាងទៀតជួយគ្រួសារយ៉ាងពេញទំហឹង។ ចុងក្រោយ ខ្ញុំគ្មានសល់គ្រប់យ៉ាងទាំងអស់តែសល់តែម៉្យាងនោះគឺជាភាពទទេ។ខ្ញុំតែងតែនិយាយថា *"ដុំថ្មតូចមួយដុំ ក៏អាចបង្កើតឲ្យមានទឹករលកបានដែរ"*។

# ថ្ងៃទី២១ ខែ មេសា

*"ក្នុងការលេយទូកក្ដោងតាមសមុទ្រ យើងអាចនឹងគ្មានសមត្ថភាពផ្លាស់ប្ដូរទិសខ្យល់បក់បានពិតមែន តែយើងសម្របសម្រួលក្ដោងឲ្យនៅតែអាចដល់ ទីដៅបានជានិច្ច"* ។

ក្នុងជីវិត បើមិនពេញចិត្តនឹងស្ថានភាពណាមួយ ចូរយើងធ្វើការផ្លាស់ប្ដូរស្ថានភាពនោះចេញ តែបើមិនអាចដូរស្ថានភាពនោះបានទេ គឺសូមប្ដូរជំនឿ ការគិត និងឥរិយាបថរបស់យើងវិញ។ គ្រប់យ៉ាងតែងតែផ្លាស់ប្ដូរ មានតែការផ្លាស់ប្ដូរប៉ុណ្ណោះដែលមិនផ្លាស់ប្ដូរ។ គ្រប់យ៉ាងនឹងផ្លាស់ប្ដូរទៅជាល្អទាំងអស់នៅទីបញ្ចប់ តែបើការផ្លាស់ប្ដូរនោះមិនល្អនៅឡើយទេ គឺគ្រាន់តែមានន័យថាគ្រប់យ៉ាងកំពុងដំណើរការ និងមិនទាន់ដល់ទីបញ្ចប់។

បើគ្រប់យ៉ាងមិនទាន់ចប់ យើងមិនទាន់ស្លាប់ នោះចូរប្រឹងប្រែងបន្តទៀត ហើយសូមកុំបារម្ភថា យើងនឹងត្រូវស្លាប់ដោយការប្រឹងឲ្យសោះ។ ផ្ទុយទៅវិញ ការស្លាប់កើតឡើងដោយសារយើងខ្វះធាតុប្រឹងប្រែង ៕

*"I can't change the direction of the wind, but I can adjust my sails to always reach my destination."* - Jimmy Dean.

# ថ្ងៃទី២២ ខែ មេសា

វីល្លៀម ជេម [ William James ] បានលើកឡើងថា *"ចូរកុំខ្លាចថាជីវិតនឹងគ្មានន័យ តែចូរដាក់ជំនឿថា ជីវិតគឺមានតម្លៃក្នុងការរស់នៅ ហើយជំនឿបែបនេះ នឹងជួយឲ្យគ្រប់យ៉ាងក្លាយជាការពិត"*។

ជីវិតមានន័យ គឺជាជីវិតរស់នៅដើម្បីអ្នកដទៃ។ ជីវិតរស់នៅដើម្បីអ្នកដទៃ គឺជាជីវិតរស់នៅដើម្បីខ្លួនឯង ហើយជីវិតរស់នៅដើម្បីខ្លួនឯង និងជីវិតរស់នៅដើម្បីអ្នកដទៃ គឺជារឿងតែមួយដូចគ្នា ពីព្រោះមិនមែនដើម្បីគេ ក៏មិនមែនដើម្បីយើង តែដើម្បីឲ្យជីវិតមានន័យ។

ក្នុងធម្មជាតិ គ្មានគេ ក៏គ្មានយើង។ មានគេ ក៏មានយើង។ ធ្វើដើម្បីគេ ក៏ដូចធ្វើដើម្បីខ្លួនឯង ពីព្រោះគ្រប់យ៉ាងកើតឡើងដោយច្បាប់សកល [ Universal Law ] ច្បាប់ធម្មជាតិ

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

[ Natural Law ] ច្បាប់នៃការចេះផ្តល់ឲ្យ [ Law of Giving ], ច្បាប់កម្មផល [ Law of Kama ], ច្បាប់ហេតុផល [ Law of Cause and Effect ]....... ។

ដើមឈើដែលយើងដាំពេលនេះ នឹងផ្តល់ម្លប់ដល់យើងនៅពេលក្រោយ បើទោះបីជាយើងមិនរំពឹងក៏ដោយ តែវានឹងនៅតែកើតឡើង ៕

# ថ្ងៃទី២៣ ខែ មេសា

អាប់ឌុល កាឡាម [ Abdul Kalam ] ពោលថា "*ការរៀនសូត្រ [ Learning ] នឹងនាំឲ្យយើងនូវការចេះច្នៃប្រឌិត។ ការចេះច្នៃប្រឌិត[Creativity]នឹងនាំយើងឲ្យចេះគិតពិចារណា។ ការចេះគិតពិចារណា [ Thinking ] នឹងផ្ដល់ចំណេះដឹងដល់យើង ហើយចំណេះដឹង នឹងធ្វើឲ្យយើងក្លាយជាមនុស្សអស្ចារ្យ [ Great ]*"។

ការសាបព្រោះចំណេះដឹងដល់មនុស្សខ្វះសីលធម៌, សាបព្រោះដល់មនុស្សខ្វះគុណធម៌ និងសាបព្រោះដល់មនុស្សខ្វះមនុស្សធម៌ ប្រៀបដូចបានសាបព្រោះព្យុះភ្លៀងដល់សង្គម។ វិធីសាស្ត្រដើម្បីជួយសង្គ្រោះមនុស្ស ៣យ៉ាងគឺ៖

១. ឃើញអ្នកដទៃអាក្រក់ ត្រូវជួយទាញគេឲ្យមកផ្លូវល្អត្រឹមត្រូវ។

២. បើទាញមិនតាមទេ នោះគឺត្រូវប្រើវិធីបញ្ឆោត ឬប្រើកលល្បិចឲ្យគេដើរផ្លូវត្រឹមត្រូវ។

៣. បើបញ្ឆោតគ្មានប្រសិទ្ធិភាពទេ គឺត្រូវបំផ្លាញចោលដោយដាក់សម្ពាធចិត្តសាស្ត្រ បំភាន់ស្មារតី បំបាក់ទឹកចិត្ត ដើម្បីរក្សាសន្តិភាពសង្គម។

មហាត្មៈ គន្ធី [ Mahatma Gandhi ] និយាយថា "ចំណេះដឹងដែលគ្មានជ្រាបចូលជាចរិត [ Knowledge Without Character ] នោះគឺជាអំពើបាបក្នុងចំណោមអំពើបាបទាំង៧។ ការណ៍ដែលមនុស្សមានចំណេះដឹងខ្ពង់ខ្ពស់ តែបែរជាបង្ហាញចរិតខ្វះសីលធម៌ជាមនុស្ស ដោយមិនយកចំណេះដឹងបញ្ជ្រាបឲ្យកើតជាចរិតល្អ នោះចំណេះដឹងនឹងគ្មានតម្លៃដាច់ខាត ឬបានត្រឹមតែប្រើចំណេះដឹងសាបព្រោះព្យុះភ្លៀងដល់សង្គមប៉ុណ្ណោះ។

ទស្សនវិទូក្រិច ប្លាតុង [ Plato ] និយាយថា "*ចំណេះដឹងនឹងក្លាយជាឥតប្រយោជន៍ បើគោលបំណងនៃចំណេះដឹងខុសគោលការណ៍សីលធម៌*"។

# ថ្ងៃទី២៤ ខែ មេសា

*"សង្គមដែលកំពុងមានជំងឺ មិនអាចយកយុវជនដែលឈឺមកព្យាបាលឲ្យជាសះស្បើយបានឡើយ"។*

បើចង់ជួយអ្នកក្រ យើងត្រូវប្រឹងឲ្យមាន។ បើចង់ជួយអ្នកល្ងង់ យើងត្រូវប្រឹងរៀនឲ្យចេះ។ បើចង់ឲ្យសង្គមមានសីលធម៌ យើងកុំប្រទ្បើសបើស។ បើចង់ឲ្យសង្គមសកម្ម យើងកុំខ្ជិលប្រអូស។ បើចង់បានសង្គមអភិវឌ្ឍន៍ យើងកុំនៅនឹងថ្កល់។ ហើយបើចង់បានសង្គមមានមេដឹកនាំល្អ យើងត្រូវចូលរួម និងតាមដានសកម្មភាពនយោបាយ៕

# ថ្ងៃទី២៥ ខែ មេសា

*"បើទោះបីជាយើងគិតថា ខ្លួនឯងគ្មានតម្លៃយ៉ាងណាក៏ដោយ តែយ៉ាងហោចណាស់ ក៏គង់មានមនុស្សម្នាក់ដែលតែងតែគិតថា យើងគឺជាមនុស្សល្អអស្ចារ្យសម្រាប់គេ"។*

សេចក្ដីសុខស្ថិតក្នុងខ្លួនយើង ចូរកុំទៅរកពីអ្នកដទៃ។ ឱកាស គឺយើងជាអ្នកបង្កើត ចូរកុំរង់ចាំពីអ្នកដទៃផ្ដល់ឲ្យ។ តម្លៃគឺយើងជាអ្នកសាងឡើងដោយខ្លួនឯង និងផ្ដល់ឲ្យខ្លួនឯង ចូរកុំរំពឹងពីនរណាម្នាក់។ ការពិតវានៅតែជាការពិតដដែល បើទោះបីជាមានមនុស្សអស្ចារ្យខាងផ្លូវអាក្រក់ [ Good at bad way ] អាចកាឡៃការពិតបាន តែគេមិនអាចលាក់បាំងការពិតបានជារៀងរហូតឡើយ៕

*"No matter how worthless you think you are, there's at least one person who thinks you are amazing."*

# ថ្ងៃទី២៦ ខែ មេសា

ទ្រឹស្តីពុទ្ធនិយមបង្ហាញថា ""*សេចក្តីស្រឡាញ់ គឺជាទុក្ខ ពីព្រោះស្រឡាញ់តិច ទុក្ខក៏តិចក្នុងពេលបាត់បង់។ស្រឡាញ់ខ្លាំង ទុក្ខក៏ខ្លាំងក្នុងពេលបាត់បង់ ហើយបើ អស់ក្តីស្រឡាញ់ក៏អស់ក្តីទុក្ខ ក្នុងពេលបាត់បង់*"។

មនុស្សដែលមិនយល់ពីច្បាប់ធម្មជាតិ គឺនឹងមិនអាចរស់នៅជាមួយធម្មជាតិបានទេ។ តាមពិតទៅលើលោកយើងនេះពោរពេញទៅដោយសេចក្តីទុក្ខ ពីព្រោះអ្នកដែលព្យាយាមគេចពីទុក្ខដោយមិនស្វែងយល់ពីហេតុនៃទុក្ខ ឬមាគ៌ារំលត់ទុក្ខ នោះគេនឹងជួបតែទុក្ខ ហើយអ្នកដែលស្វែងយល់ពីទុក្ខគង់នឹងមានថ្ងៃរកឃើញមាគ៌ាផុតទុក្ខ។

ស្នេហាដែលកើតចេញពីការប្រាថ្នា និងការជាប់ជំពាក់នឹងនាំមកនូវសេចក្តីទុក្ខ និងភាពអស់សង្ឃឹម។

ប៉ុន្តែ ស្នេហាដែលកើតចេញពីក្ដីមេត្តា និងករុណា នឹងនាំមកនូវសុភមង្គលពិតប្រាកដ។ សូមកុំសោកស្ដាយរបស់ដែលបានបាត់បង់ទាំងឡាយ តែគួរយើងរៀនចេះមើលថែរក្សារបស់ដែលកំពុងមាន មុននឹងគ្រប់យ៉ាងក្លាយជារបស់ដែលធ្លាប់មាន៕

# ថ្ងៃទី២៧ ខែ មេសា

*"យុវជនកម្ពុជាគួរប្រឹងប្រែងរៀនសូត្រ និងត្រូវធ្វើជាមនុស្ស ជោគជ័យ និងមនុស្សមានតម្លៃ"។*

បុរស *"ក"* លះបង់គ្រប់យ៉ាងដើម្បីមនុស្សដែលគេស្រឡាញ់ តែបុរស *"ខ"* លះបង់មនុស្សដែលគេស្រឡាញ់ចោល ដើម្បីគ្រប់យ៉ាងដែលគេស្រឡាញ់។ លទ្ធផលចុងក្រោយបុរស *"ក"*ក្លាយជាមនុស្សបរាជ័យពីព្រោះគេខ្វល់គិតតែពីអ្នកដទៃ តែជីវិតគេមានន័យ។

ផ្ទុយទៅវិញបុរស *"ខ"* ក្លាយជាបុគ្គលជោគជ័យ ហើយជីវិតគេធម្មតា។ មេដឹកនាំផ្តាច់ការ អាដុលហ៍ ហ៊ីត្លែរ [ Adolf Hilter ] និយាយថា *"បុគ្គលដែលជោគជ័យដោយគ្មានឧបសគ្គ គឺគ្រាន់តែជាជ័យជម្នះធម្មតាប៉ុណ្ណោះ តែមនុស្សដែលជោគជ័យដោយទុក្ខលំបាក នោះគឺជាប្រវត្តិសាស្ត្រ"*។

# ថ្ងៃទី២៨ ខែ មេសា

*"បើយើងផ្លាស់ប្ដូររបៀបនៃការសម្លឹងមើលរឿងគ្រប់យ៉ាង គឺថារឿងគ្រប់យ៉ាងនឹងផ្លាស់ប្ដូរតាមរបៀបនៃការមើលរបស់យើង"។*

បើយើងចង់ដាក់ទោសមនុស្សណាម្នាក់ថាខុស គឺមិនខ្វះទោសចោទទេ។ បើយើងចង់ឲ្យនរណាម្នាក់ក្លាយជាមនុស្សអាក្រក់ គឺយើងគ្រាន់តែតាំងចិត្តប្រឹងសម្លឹងរកមើលរឿងអាក្រក់ពីក្នុងខ្លួនបុគ្គលនោះ ក៏ល្មមអាចឲ្យយើងរកកំហុសបាន។ ឡៅ ជឺ បង្ហាញថា ខុស និងត្រូវ គឺជាសម្ព័ន្ធភាពក្នុងធម្មជាតិ ពីព្រោះបើមានខុស ក៏គង់នឹងមានត្រូវ តែគ្រាន់តែយើងមិនដឹងមុនថាត្រូវ ឬខុស តើមួយណានឹងកើតឡើងមុនប៉ុណ្ណោះ។ នៅចន្លោះរវាងខុស និងត្រូវ គឺមានស្ថានភាពមួយដែលអនុញ្ញាតឲ្យយើងជ្រើសយកការចេះសណ្ដោសយោគយល់គ្នា ហើយពេលដែលយើង

តាំងចិត្តដោយក្តីមេត្តា គឺថាភាពយោគយល់នឹងបង្ហាញពីហេតុផលដែលបណ្តាលឲ្យខុស ឬហេតុផលដែលបណ្តាលឲ្យត្រូវ។ ពេលដែលយើងយល់ពីបុព្វហេតុពីខាងដើមនៃទង្វើមួយ យើងក៏បានដកចិត្តស្អប់ស្រឡាញ់ចេញពីក្នុងខ្លួន។ ពេលដែលគ្មានចិត្តស្អប់ស្រឡាញ់ គតិបណ្ឌិត ក៏នឹងលេចឡើង៕

*"Change the way you look at things and the things you look at change."* - Wayne Dyer

# ថ្ងៃទី២៩ ខែ មេសា

អ្នកទាមទារសិទ្ធិមនុស្ស ម៉ាទីន លូធឺឃីង ជូនៀ [ Martin Luther King Jr. ] និយាយថា *"ខ្ញុំមានក្តីសុបិនមួយដោយរំពឹងថា ថ្ងៃណាមួយក្មេងប្រុសក្មេងស្រីស្បែកខ្មៅ និងស្បែកសអាចដើរកាន់ដៃគ្នាបានដោយគ្មានការរើសអើង"* ។

តើខ្មែរយើងមានក្តីសុបិនមួយ ដែលយើងជាប្រជាជនឈប់ឈ្លោះគ្នា ព្យាយាមស្វែងយល់ពីគ្នា និងផ្តល់ឱកាសយល់យោគគ្នានៅថ្ងៃណាមួយដែរ ឬទេ? ចម្លើយគឺថាតើចង់ ឬមិនចង់ ហើយបើចង់ គឺចង់ឲ្យសុបិនក្លាយទៅជាការពិតដែរ ឬទេ? ប្រធាធិបតីឥណ្ឌា អាឌុល កាឡាម [ Adul Kalam ] ប្រាប់ថា *"បើចង់ឲ្យសុបិនក្លាយទៅជាការពិត ដាដំបូងយើងទាំងអស់គ្នាចាំបាច់ត្រូវមានក្តីសុបិនជាមុនសិន"*។

សុបិនមិនមែនជាការពិត តែការពិតទាំងអស់តែងកើតចេញពីសុបិន។

តើត្រូវធ្វើបែបណាដើម្បីឲ្យសុបិនមួយអាចក្លាយទៅជាការពិតបាន? ផលិតករភាពយន្តជីវចលជាតិអាមេរិក វ៉ល់ ឌី ស្នីយ៍ [ Walt Disney ] ប្រាប់ថា *"បើសិនជាយើងអាចមានក្តីសុបិនពិតមែន យើងក៏អាចធ្វើឲ្យសុបិនក្លាយទៅជាការពិតបានដែរ"*។

ជីវិតរស់នៅដើម្បីខ្លួនឯង ក៏មិនមែនអាត្មានិយមដែរ តែជីវិតរស់នៅដើម្បីអ្នកដទៃគឺល្អជាងបន្តិច ហើយជីវិតដែលល្អអស្ចារ្យខ្លាំងបំផុត គឺរស់នៅដើម្បី ជាតិមាតុភូមិ។ ដើម្បីជួយអ្នកដទៃ ជាដំបូងមនុស្សត្រូវ ជួយខ្លួនឯងឲ្យបានសិន។ ដើម្បីជួយសង្គមជាតិបាន ជាដំបូងមនុស្សត្រូវចេះចេះសាមគ្គីជួយគ្នាក្នុងសង្គមសិន។

អាប្រាហាម លីនខុន [ Abraham Lincoln ] ពោលថា *"ដើម្បីជួយអ្នកក្រ គឺថាយើងត្រូវប្រឹងប្រែងអភិវឌ្ឍន៍ខ្លួនឲ្យក្លាយទៅជាអ្នកមាន ឬបើចង់ជួយអ្នកក្រ ចូរយើងកុំធ្វើខ្លួនជាអ្នកក្រ"*៕

# ថ្ងៃទី៣០ ខែ មេសា

*"ភាសា ៤នៃជីវិតក្នុងផែនដី"*

ភាសាសញ្ញាដែលមានពាក្យសម្តីជាសំគាល់ [ Symbolized Language ] ហើយមនុស្សយើងប្រើភាសានេះដើម្បីពន្យល់នូវអត្ថន័យនៃអ្វីមួយដល់នរណាម្នាក់។ ភាសានេះ គឺជាភាសាដែលមនុស្សបង្កើតឡើងសម្រាប់ទំនាក់ទំនងគ្នា។

ភាសាតក្កវិទ្យា [ Logical Language ] ជាប្រភេទភាសាដែលមនុស្សប្រើនិយាយពីភាពត្រូវ ឬខុស ឬនិយាយពីរឿងឈ្នះ ឬចាញ់ ឬហេតុផលនានា។

ភាសានៃក្តីស្រឡាញ់ [ Love Language ] គឺជាភាសាដែលមនុស្សនិយាយគ្នាតាមរយៈបេះដូង។ ពេលយើងស្ថិតក្នុងសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក គឺយើងដាច់ខាតមិនប្រើភាសាតក្កសាស្ត្រ ឬភាសាសញ្ញាដើម្បីបង្ហាញពាក្យពេជន៍ទេ តែយើងនឹងប្រើបេះដូងនៃក្តីស្រឡាញ់ដើម្បីនិយាយស្វែងយល់ពីគ្នា ហើយអ្នកប្រើភាសានេះមានតែការយល់យោគ និងការអភ័យទោសឲ្យគ្នាប៉ុណ្ណោះ។

ភាសានៃភាពស្ងៀមស្ងាត់ [ Silent Language ] គឺជាភាសារបស់ធម្មជាតិ ហើយក៏ជាភាសារបស់មនុស្ស ដែលទទួលរងនូវវិបត្តិសង្គមនានាប្រើប្រាស់ដែរ។ ភាសានេះ មនុស្សធម្មតាមើលមិនងាយយល់ទេ ដូចជាអ្នកខ្លះមុខញញឹម តែក្នុងក្រសែភ្នែកពពោរពេញទៅដោយក្តីកង្វល់ឈឺចាប់។ បើចង់ដឹងថាមូលហេតុអ្វីមនុស្សម្នាក់ស្ងប់ស្ងាត់ គឺតម្រូវឲ្យយើងមានសមត្ថភាពចេះសង្កេតលើកម្មភាព និងប្រើប្រាស់ចំណេះដឹងចិត្តវិទ្យាក្នុងការស្វែងយល់។

ភាសាទី១ និងទី២ គឺជាភាសាដែលខួរក្បាលប្រើ ឬជាភាសានិយាយពីហេតុផលត្រូវខុស ល្អអាក្រក់ តែភាសាទី៣ និង៤ គឺជាភាសាដែលគ្មានសញ្ញាសំគាល់ ឬគ្មានពាក្យពេចន៍សំគាល់ ឬជាភាសាដែលឥតនិយាយពីខុសត្រូវ ឬល្អអាក្រក់ តែជាភាសាដែលបេះដូងជាអ្នកប្រើ។ ខួរក្បាលមានហេតុផលរបស់ខួរក្បាល ហើយបេះដូងក៏មានហេតុផលរបស់បេះដូងដែរ។

គ្រប់គ្នាតែងនាំគ្នានិយាយថា "ក្តីស្រឡាញ់បង្កើតគ្រប់យ៉ាងក្នុងលោក ឬ Love is everything"។ ខ្ញុំយល់ថាប្រហែលជាការពិត ដោយសារសេចក្តីស្លាប់និងកើត គឺកើតចេញពីសេចក្តីស្រឡាញ់។ សេចក្តីវិនាសអន្តរាយ ឬរីកចម្រើនកើតឡើងតាមរយៈក្តីស្រឡាញ់។ សេចក្តីប្រចណ្ឌកើតឡើងព្រោះក្តីស្រឡាញ់ និងមានរឿងជាច្រើនទៀតដែលកើតឡើង ដោយសារតែសេចក្តីស្រឡាញ់។ ការកសាងសង្គមមួយ ដែលប្រជាជនបែកបាក់សាមគ្គីគ្នាតាមរយៈនយោបាយ និងសាសនា ក៏ត្រូវការសេចក្តីស្រឡាញ់ដូចគ្នាដែរ៕

## ទស្សនៈសម្រាប់ខែ

# ឧសភា

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី០១ ខែឧសភា

*"ជីវិតមានស្នេហាមិនប្រាថ្នាបាត់បង់ តែក៏ត្រូវហ៊ានទទួលស្គាល់ថា នឹងអាចបាត់បង់នៅថ្ងៃណាមួយដែរ"។*

សេចក្តីភ័យខ្លាចចំពោះការបាត់បង់ស្នេហា គឺជាកិរិយានៃភាពអាត្មានិយមរបស់មនុស្ស។ ពេលខ្លះអ្នកត្រូវអង្គុយចុះឱនឲ្យទាប ដើម្បីឲ្យមនុស្សដែលអ្នកស្រឡាញ់ មើលឃើញមនុស្សដែលអាចផ្តល់សុភមង្គលដល់គេបានប្រាកដ។ បើអ្នកសុខចិត្តឈឺចាប់ដើម្បីមនុស្សដែលអ្នកស្រឡាញ់ នោះក៏មិនគួរឲ្យមនុស្សដែលអ្នកស្រឡាញ់ឈឺចាប់ជាមួយអ្នកដែរ៕

*"The way to love anything is to realize that it may be lost."* - Gilbert K. Chesterton

# ថ្ងៃទី០២ ខែឧសភា

*"មានតែមនុស្សដែលស្រឡាញ់ស្មោះប៉ុណ្ណោះ ដែលអាចចងចាំគ្រប់យ៉ាងបានល្អទាំងអស់"។*

មនុស្សដែលស្មោះត្រង់ តែងតែរងសេចក្តីឈឺចាប់ ហើយមនុស្សដែលមិនចេះឈឺចាប់ គឺអ្នកដែលមានចិត្តក្បត់។ ជំងឺស្នេហាកើតឡើង មិនថាចំពោះអ្នកដោះស្រាយវិបត្តិស្នេហា ឬមនុស្សធម្មតានោះទេ។ ទឹកល្អក់ ត្រូវការពេលវេលាដើម្បីឲ្យថ្លាវិញ។ ចំណែកមនុស្សខូចចិត្តដោយសារស្នេហា ក៏ត្រូវការពេលវេលាជាដើម្បីព្យាបាលការឈឺចាប់ដូចគ្នា៕

"Only one who loves can remember so well."

- Anton Chekhov

# ថ្ងៃទី០៣ ខែឧសភា

យើងជួយមនុស្សម្នាក់ដោយរបៀបណា? ការជួយការជួយសង្គ្រោះពិតប្រាកដ គឺបង្រៀនគេឲ្យចេះស្ទូចត្រី។ ការជួយសង្គ្រោះមនុស្ស គឺជាការជួយឲ្យពួកគេចេះជួយខ្លួនឯង ហើយពេលខ្លះ ចូរយើងកុំព្យាយាមធ្វើជាមនុស្សខ្លាំងដើម្បីឲ្យពួកគេពឹងផ្អែកបានរហូតឲ្យសោះ។

អំណោយអាចឲ្យមនុស្សរស់បានមួយថ្ងៃ តែភាពមានការងារនឹងជួយឲ្យមនុស្សរស់បានមួយជីវិត។ អំណោយគឺសម្រាប់ជនពិការ និងជនរងគ្រោះ តែមិនមែនសម្រាប់មនុស្សទូទៅនោះទេ។ បុគ្គលថ្លៃថ្នូរត្រូវការការងារ មិនមែនត្រូវការអំណោយដើម្បីរស់នោះទេ៕

# ថ្ងៃទី០៤ ខែឧសភា

*"ព្រះអាទិត្យរះឡើងម្នាក់ឯង លិចវិញក៏ម្នាក់ឯង ចំណែកឯមនុស្សកើតមកទទេ ស្លាប់ទៅវិញក៏ទទេ"។* ព្រះអាទិត្យមានមនុស្សស្គាល់គ្រប់កន្លែងទូទាំងផែនដី តែបែរជាឯកោម្នាក់ឯងទៅវិញ។ ទ្រឹស្តីភាពជាអ្នកដឹកនាំបានលើកឡើងថា*"មិនសូវមានមនុស្សអស្ចារ្យណាម្នាក់ អាចឡើងដល់លើកំពូលភ្នំខ្ពស់បំផុតបានទេ តែបើមនុស្សណាម្នាក់អាចធ្វើបាន គឺបុគ្គលនោះនឹងរស់នៅយ៉ាងឯកោបំផុតម្នាក់ឯង"*។

អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] ពោលថា *"ពិតជាចម្លែកខ្លាំងណាស់ចំពោះខ្ញុំ ដែលត្រូវបានគេឯងស្គាល់ជាសកលទៅហើយ តែបែរជាឯកោទៅវិញ"*។

*"It is strange to be known so universally and yet to be so lonely."* - Albert Einstein

# ថ្ងៃទី០៥ ខែឧសភា

*"ចូរកុំនិយាយថា កូនស្រឡាញ់ម្ដាយ បើកូននៅតែប្រព្រឹត្ត ទង្វើដែលម្ដាយស្អប់ខ្ពើម និងធ្វើឲ្យម្ដាយពិបាកចិត្ត"។*

ព្រោះតែគ្មានអ្នក [ លោកឪពុក ] ធ្វើឲ្យខ្ញុំមិនហ៊ានឈឺ ខ្ញុំមិនហ៊ានហត់ ខ្ញុំមិនហ៊ានខូចចិត្ត ខ្ញុំមិនហ៊ានភ្លើតភ្លើន ខ្ញុំមិនហ៊ានអស់សង្ឃឹម ខ្ញុំមិនហ៊ានធ្វើឲ្យខូចកិត្តិយសគ្រួសារ...។ បើទោះបីជាជីវិតខ្ញុំ ស្ថិតក្នុងស្ថានភាពអាក្រក់បែបណាក៏ដោយ។

ព្រោះតែមានអ្នក [ អ្នកម្ដាយ ] ទើបធ្វើឲ្យខ្ញុំចេះព្យាបាលជំងឺផ្លូវកាយផ្លូវចិត្តតាមបែបចិត្តសាស្ត្រ ធ្វើឲ្យខ្ញុំអាចប្រមូលកម្លាំងចិត្ត ធ្វើឲ្យខ្ញុំមានសេចក្ដីសង្ឃឹម។ ធ្វើឲ្យខ្ញុំតាំងចិត្តរក្សាកិត្តិយសគ្រួសារ និងប្ដេជ្ញាចិត្តតស៊ូជម្នះចំពោះឧបសគ្គ

ជានិច្ច។ ព្រហ្មលិខិត [ អ្នកធ្វើបាបខ្ញុំ ] ខ្ញុំនឹងសងសឹកចំពោះអ្នក នូវរាល់ទង្វើអយុត្តិធម៌ទាំងឡាយដែលអ្នកបានធ្វើចំពោះរូបខ្ញុំទាំងដើមទាំងការ។

ព្រោះតែអ្នក [ ទស្សនវិទូក្រិចសូក្រាត Socrates ] តែងខ្សឹបដាក់ត្រចៀកខ្ញុំថា *"ជីវិត គឺជាការហាត់ស្លាប់"*៕

# ថ្ងៃទី០៦ខែឧសភា

*"រូបសម្រស់ខាងក្រៅ គឺជាអ្វីដែលប្រែប្រួលមិនទៀង តែសេចក្តីស្លាប់គឺទៀងណាស់។ សម្បកកាយខាងក្រៅ គឺជាអ្វីដែលគ្រប់គ្នាអាចមើលឃើញនឹងភ្នែកទទេ ប៉ុន្តែចិត្តគំនិតព្រលឹងនិងស្មារតី មិនអាចប្រើភ្នែកទាំងគូមើលឃើញបានឡើយ"។*

អ្នកស្រី ហេឡិន ឃែល័រ [ Helen Keller ] បាននិយាយថា *"គ្រប់យ៉ាងដែលល្អបំផុត និងស្រស់ស្អាតបំផុតលើលោកយើងនេះ គឺមិនអាចមើលឃើញដោយភ្នែកទទេឡើយ ឬត្រឹមប៉ះដោយដៃបានទេ ប៉ុន្តែវាជាអ្វីទាំងឡាយដែលយើងពាល់ត្រូវតាមរយៈអារម្មណ៍ និងបេះដូង"។*

ចូរផ្តល់តម្លៃដល់មនុស្សគ្រប់គ្នាឲ្យខ្ពស់ប្រហែលគ្នា បើទោះបីជាអ្នកខ្លះមិនខ្ពង់ខ្ពស់ដូចយើងក៏ដោយ ពីព្រោះតម្លៃរបស់គ្រប់គ្នាជាប់ពាក់ព័ន្ធនឹងតម្លៃរបស់យើង។

រូបវិទូស.វទី ២០ លោក អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] បានទូន្មានយើងឲ្យនិយាយទៅកាន់មនុស្សទាំងអស់ក្នុងអាកប្បកិរិយាឲ្យតម្លៃស្មើគ្នា បើទោះពួកគេជានរណាក៏ដោយ ឬមិនថាអ្នកសុំទាន ឬខ្សែរាជវង្សនោះទេ៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី០៧ខែឧសភា

*"សុភមង្គលជីវិតក្នុងជាតិនេះ កើតមានឡើងចំពោះបុគ្គលណា ដែលដឹងថាខ្លួនត្រូវធ្វើអ្វី ខ្លួនស្រឡាញ់អ្វី និងខ្លួនមានក្តីសង្ឃឹមលើអ្វី"*។ ជីវិតដែលគ្មានគោលបំណងពិតប្រាកដក្នុងការរស់នៅ គឺគ្មានក្តីស្រឡាញ់ក្នុងការរស់នៅ និងគ្មានក្តីសង្ឃឹមក្នុងការរស់នៅ គឺមិនសាកសមនឹងរស់នៅទេ។

ចូរធ្វើអ្វីដែលយើងស្រឡាញ់ ហើយនិងស្រឡាញ់អ្វីដែលយើងធ្វើ។ ចូរមានក្តីសង្ឃឹមក្នុងជីវិត ហើយមានជីវិតត្រូវមានសង្ឃឹម។ ចូរស្រឡាញ់ជីវិតដែលយើងរស់នៅ ហើយនឹងត្រូវរស់នៅក្នុងជីវិតដែលយើងស្រឡាញ់។ ជីវិតមានតម្លៃបំផុត។

ភ្លេចស្រឡាញ់អ្វីភ្លេចបាន តែកុំភ្លេចជីវិតខ្លួនឯងហើយ បរាជ័យធំបំផុតក្នុងជីវិតគឺសេចក្តីស្លាប់ ពីព្រោះបើអស់ជីវិត

តែម្យ៉ាង   នោះគ្រប់យ៉ាងនឹងរលាយសាបសូន្យទាំងអស់៕

*"Three grand essentials to happiness in this life are something to do, something to love, and something to hope for."* - Joseph Addison

# ថ្ងៃទី០៨ខែឧសភា

*"ទ្រព្យសម្បត្តិពិតប្រាកដរបស់ប្រទេសជាតិមួយ គឺមិនមែនវាស់ដោយមាសប្រាក់នោះទេ តែវាស់កំណត់ដោយការសិក្សាអប់រំរបស់ប្រជាជន គតិបណ្ឌិតរបស់ប្រជាជន និងភាពរឹងប៉ឹងមាំមួនរបស់យុវជនក្នុងប្រទេសនោះ"។*

សម្តីយុវជនទាំងឡាយដែលនិយាយថាស្រឡាញ់សង្គម ឬចង់ជួយសង្គមជាតិនឹងក្លាយទៅជាសំរាមតាមផ្លូវដែលឥតប្រយោជន៍ ឬក្លាយជាលូរបង្ហូរទឹកស្អុយ ប្រសិនបើសម្តីទាំងនោះនៅតែល្អជាងការប្រតិបត្តិជាក់ស្តែង។ យុវជនមានមូលដ្ឋានគ្រឹះរឹងមាំ មានការតាំងចិត្តសិក្សាខ្ពស់មានឧត្តមគតិស្នេហាជាតិពិត ស្នេហាទឹកដីប្រាកដ មានឆន្ទៈបម្រើប្រជាជន នោះជាតិនឹងរឹងមាំជាមិនខានឡើយ៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី០៩ខែឧសភា

"នៅពេលដែលអំពើអាក្រក់កើតឡើង ហើយមនុស្សល្អមិនអើពើ គឺអំពើអាក្រក់នឹងកាន់តែរីកដុះដាលឡើង"។ ដំបូងគេកម្ទេចចោលអ្នកស្នេហាជាតិទាំងអស់ ហើយខ្ញុំមិនបាននិយាយអ្វីទាំងអស់ ពីព្រោះខ្ញុំគ្រាន់តែជាប្រជារាស្ត្រសាមញ្ញម្នាក់ប៉ុណ្ណោះ។ បន្ទាប់មក គេបង្ក្រាបបាតុករអហិង្សាទាំងអស់ ហើយខ្ញុំមិននិយាយអ្វីទាំងអស់ ពីព្រោះខ្ញុំមិនមែនជាបាតុករ។ បន្ទាប់មកគេប្រើអំណាចរឹបអូសយកដីធ្លីអ្នកជិតខាងខ្ញុំទាំងអស់ ហើយខ្ញុំមិននិយាយអ្វីទាំងអស់ ពីព្រោះមិនមែនជាដីរបស់ខ្ញុំ។បន្ទាប់មករឿងទាំងអស់នោះបានកើតឡើងចំពោះខ្ញុំ ហើយពេលនោះគ្មានអ្នកណាម្នាក់ស្រែកឡើងត៉វ៉ាឡើយ។ វប្បធម៌ស្ងៀមស្ងាត់ក្នុងការប្រឈមមុខជាមួយភាពអយុត្តិធម៌ គឺអាក្រក់ខ្លាំងជាងការមិនអើពើទៅទៀត។ អ្នកស្នេហាជាតិពិត សុខចិត្តស្លាប់ជីវិត តែមិនស្លាប់ឧត្តមគតិស្នេហាជាតិឡើយ៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី១០ខែឧសភា

*"យើងនឹងមិនអាចមានឱកាសរស់នៅដោយស្មើភាពគ្នាក្នុងសង្គមបានទេ បើកាលណាយើងមិនទាន់អាចមានឱកាសទទួលបានការអប់រំស្មើគ្នា"។*

អ្នករៀនត្រូវហ៊ានឈឺចាប់ ហ៊ានភ្លក់រសជាតិល្វីងជូរចត់ ព្រោះការអប់រំតែងមានរសជាតិល្វែងក្នុងពេលនេះ ប៉ុន្តែវាមានរសជាតិផ្អែមនាពេលអនាគត។ រៀបការជាមួយសេដ្ឋីអាចឲ្យយើងក្លាយជាសេដ្ឋី តែរៀបការជាមួយបណ្ឌិត មិនអាចឲ្យយើងក្លាយជាបណ្ឌិតបានទេ បើយើងមិនប្រឹងប្រែងរៀនសូត្រដោយខ្លួនឯងទេនោះ៕

*"Until we get equality in education, we won't have an equal society."* - Sonia Sotomayor

# ថ្ងៃទី១១ខែឧសភា

"ជោគវាសនា មិនមែនជាបញ្ហានៃឱកាស តែជាបញ្ហានៃនៃជម្រើស ហើយគ្រប់យ៉ាង គឺជាអ្វីដែលមនុស្សត្រូវប្រឹងប្រែងសម្រេចធ្វើឲ្យបាន តែមិនមែនជាការអង្គុយរង់ចាំឲ្យគ្រប់យ៉ាងសម្រេចបាន ដោយឯកឯងនោះទេ"។

អ្នកឈ្នះគិតថាត្រូវធ្វើឲ្យបានសម្រេច តែចេះចាញ់គិតថាត្រូវអង្គុយរង់ចាំឲ្យបានសម្រេច។ អ្នកឈ្នះជឿលើការប្រឹងធ្វើឲ្យកើតការណ៍ តែអ្នកចាញ់លើវាសនាព្រេងសំណាង។ អ្នកឈ្នះថាកាន់តែប្រឹង សំណាងល្អនឹងរត់មករក តែអ្នកចាញ់ថាមិនចាំបាច់ប្រឹងទេ សំណាងល្អគង់តែមករកទេ៕

"Destiny is no matter of chance. It is a matter of choice. It is not a thing to be waited for, it is a thing to be achieved." - William Jennings Bryan

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី១២ខែឧសភា

ចច អូវែល [ George Orwell ] បានលើកឡើងថា *"មនុស្សដែលអាចគ្រប់គ្រងអតីតកាលបានល្អ គឺប្រៀបបាននឹងអាចគ្រប់គ្រងអនាគតកាលបាន ហើយអ្នកដែលអាចគ្រប់គ្រងបច្ចុប្បន្នបានល្អក៏នឹងអាចបង្កើតអតីតកាលល្អដូចគ្នាដែរ"។*

ថ្ងៃម្សិលមិញ គឺជាអតីតកាលនៃថ្ងៃនេះ។ ថ្ងៃនេះ គឺជាអតីតកាលនៃថ្ងៃស្អែក ហើយថ្ងៃស្អែក គឺជាអនាគតកាលនៃថ្ងៃនេះ។ ម្សិលមិញគឺជាថ្ងៃនេះ ថ្ងៃនេះគឺជាថ្ងៃនេះ ហើយថ្ងៃស្អែកគឺជាថ្ងៃនេះ ពីព្រោះឲ្យតែយើងគ្រប់គ្រងថ្ងៃនេះឲ្យបានល្អបំផុត នោះអតីតកាល និងអនាគតនឹងល្អជានិច្ចដូចគ្នា។ គ្រប់គ្រងថ្ងៃនេះឲ្យល្អ គឺមានន័យបានបង្កើតអតីតកាលល្អ ហើយក៏មានន័យថាកំពុងបានរៀបចំអនាគតកាលយ៉ាងល្អប្រសើរដែរ។

ច្បាប់កម្ម ឬ Law of Kama និងច្បាប់ហេតុផល ឬ Law of Cause and Effect បានលើកឡើងថា "*ធ្វើល្អនឹងទទួលបានផលល្អ សាបព្រោះល្អនឹងច្រូតកាត់ល្អ*"៕

*"Who controls the past controls the future. Who controls the present controls the past."*

- George Orwell

# ថ្ងៃទី១៣ខែឧសភា

*"មនុស្សណាដែលរង់ចាំឲ្យតែគេស្រឡាញ់មុន គឺជាអ្នកក្រ តែបុគ្គលដែលចេះផ្ដល់ក្ដីស្រឡាញ់ទៅអ្នកដទៃមុនគឺជាអ្នកមាន"។*

ការណ៍ដែលយើងទទួលបានសេចក្ដីស្រឡាញ់ពីអ្នកដទៃ គឺជារឿងល្អ តែការណ៍ដែលផ្ដល់សេចក្ដីស្រឡាញ់ដល់អ្នកដទៃ គឺជារឿងល្អជាង ហើយការណ៍ដែលស្រឡាញ់ខ្លួនឯង និងចេះផ្ដល់សេចក្ដីស្រឡាញ់ដល់អ្នកដទៃ គឺជារឿងល្អបំផុត ៕

*"Who, being loved, is poor ?"* - Oscar Wilde

# ថ្ងៃទី១៤ខែឧសភា

*"ភាពខុសគ្នារវាងបុគ្គលជោគជ័យ និងមនុស្សបរាជ័យមិនមែនស្ថិតនៅលើកង្វះភាពខ្លាំង ឬកង្វះចំណេះដឹងនោះទេ។ ប៉ុន្តែដោយសារតែខ្វះឆន្ទៈមោះមុតខ្លាំង"*។

ពាក្យថា *"បរាជ័យ"* ជាភាសាបាលី គឺប្រែថា *"ជោគជ័យនៅពេលខាងមុខ"*។ ផែនដីបង្កើតភ្នែកពីរនៅខាងមុខ គឺមានន័យថា ឲ្យមនុស្សយើងចេះសម្លឹងទៅមុខប្រកបដោយឆន្ទៈមោះមុត និងគិតដល់ពេលខាងមុខដោយក្តីសង្ឃឹម។ គ្រប់យ៉ាងនឹងល្អនៅចុងបញ្ចប់ តែបើមិនទាន់ល្អនៅឡើយ គឺគ្រាន់តែមានន័យថាមិនទាន់ដល់ទីបញ្ចប់ប៉ុណ្ណោះ៕

*"The difference between a successful person and others is not a lack of strength, not a lack of knowledge, but rather a lack in will."*

- Vince Lombardi

# ថ្ងៃទី១៥ខែឧសភា

*"មនុស្សដែលនិយាយមិនឈ្នះអ្នកដទៃនឹងយកការនិយាយបង្កាច់បង្ខូច វាយប្រហារអ្នកដទៃពីក្រោយខ្នងមកធ្វើជាឧបករណ៍យកឈ្នះអ្នកដទៃ"។*

អ្នកដែលចាញ់នឹងរកហេតុផលដោះសាការពារខ្លួន ហើយមនុស្សដែលចូលចិត្តដោះសាការពារខ្លួននឹងមិនអាចទទួលជ័យជម្នះទេ។ ពេលខ្លះ ការដោះសាជារឿងខាតពេលវេលា បើទោះជាហេតុផលនោះ ត្រឹមត្រូវតាមកាលៈទេសៈក៏ដោយពីព្រោះមនុស្សយល់ពីសច្ចៈ គេនឹងប្រើពេលវេលាធ្វើសកម្មភាពកែតម្រូវខ្លួន ប្រសើរជាងបង្ខាតពេលនិយាយហេតុផលឲ្យខ្លួនត្រូវ៕

"When the debate is lost, slander becomes the tool of the loser." - Socrates

# ថ្ងៃទី១៦ខែឧសភា

*"សន្តិភាពដែលមានក្នុងគ្រួសារ ប្រៀបបាននឹងសន្តិភាពនៅក្នុងប្រទេស ហើយសន្តិភាពនៅក្នុងប្រទេស ប្រៀបបាននឹងសន្តិភាពសម្រាប់ពិភពលោកទាំងមូល"។*

បុគ្គលម្នាក់ គឺជាកោសិកានៃគ្រួសារ។ គ្រួសារ គឺជាកោសិកានៃសង្គមជាតិ ហើយសង្គមជាតិមួយ គឺជាកោសិកានៃពិភពលោកទាំងមូល។ ដូច្នេះ ដើម្បីឲ្យគ្រួសារមានសន្តិភាព ដើម្បីឲ្យសង្គមមានសន្តិភាព និងដើម្បីឲ្យពិភពលោកមានសន្តិភាព គឺមនុស្សម្នាក់ៗត្រូវមានសន្តិភាពក្នុងខ្លួនឯងជាមុនសិន៕

*"Peace at home is peace in the country. Peace in the country is peace in the world."*

- Mustafa Kemal Ataturk

# ថ្ងៃទី១៧ខែឧសភា

*"ស្ត្រីជាម្ដាយម្នាក់ ចំណាយពេលវេលាបង្កើត និងចិញ្ចឹមកូនប្រុស អស់រយៈពេលរាប់ឆ្នាំ។ ប៉ុន្តែមាននារីវ័យក្មេងម្នាក់ចំណាយពេល ត្រឹមតែ ២០នាទី ក៏អាចធ្វើឲ្យកូនប្រុសគាត់ឆ្កួតដោយសារតែស្នេហា"។*

ម៉ែស្រក់ទឹកភ្នែកព្រោះកូន តែកូនប្រុសស្រក់ទឹកភ្នែកព្រោះស្រី។ ម៉ែលះបង់គ្រប់យ៉ាងដើម្បីកូន តែកូនប្រុសលះបង់គ្រប់យ៉ាងដើម្បីស្រី។ ម៉ែចិញ្ចឹមអប់រំកូនរាប់ឆ្នាំ តែកូនប្រុសបែរឆ្កួតនឹងស្រីត្រឹមតែ ២០នាទី។ លើលោកយើងនេះពិតជាមានយុត្តិធម៌ តែគ្មាននិយាម ឬស្តង់ដារយុត្តិធម៌ទេ។ បុរាណខ្មែរបានប្រដៅកូនចៅថា "មានកូនប្រុសប្រៀបដូចព្រាយក្បាល៨ ឯមានកូនស្រីប្រៀបដូចក្រឡប្រហុកមុខផ្ទះ"។ មនុស្សប្រុស បើម្ដាយណែនាំកុំឲ្យខ្វល់នឹងស្រីគេនឹងទៅខ្វល់នឹងដបស្រា។ ណែនាំកុំឲ្យខ្វល់នឹងដបស្រាមិនអាចរីកស្គុះស្គាយវិញបានទេ។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

ខូចនឹងប្រុសប្រាកដជាអស់ព្រហ្មចារីយ៍ តែបើបុរសខូចនឹងស្រីប្រាកដជាខ្ចីវិជ្ជា ៕

*"A mother takes twenty years to make a man of her boy, and another woman makes a fool of him in twenty minutes."* - Robert Frost

# ថ្ងៃទី១៨ខែឧសភា

*"សញ្ញានៃភាពចម្រុងចម្រើន លូតលាស់ផ្នែកគតិបណ្ឌិត និងទស្សនវិជ្ជា គឺពេលដែលយើងគ្មានការរំភើបញាប់ញ័រ ចំពោះការប្រមាថកាតទាន ឬការសសើរលើកតម្កើង"។* ពេលយើងបរាជ័យ ជីវិតយើងមិនអាក្រក់ដូចអ្វីដែលអ្នកដទៃនិយាយ ឬដូចអ្វីដែលយើងបានគិតវិនិច្ឆ័យខ្លួនឯងទេ ។ ពេលយើងជោគជ័យ យើងក៏មិនល្អដូចអ្វីដែលអ្នកដទៃបញ្ចោរយើង ឬ ដូចអ្វីដែលយើងកំពុងតែមានមោទកភាពដាច់បង្ហៀរចំពោះខ្លួនឯងដែរ។

ជាទូទៅ សេចក្តីទុក្ខធំបំផុត គឺជាការមិនចេះអត់ទ្រាំនឹងសេចក្តីលំបាក ទុក្ខព្រួយ ការប្រមាថ និងការមិនចេះទប់ខ្លួនឯង។ គ្មាននរណាម្នាក់អាចរកផ្លូវទៅឋាននរកឃើញទេ ឬឋាននរកគ្មានផ្លូវទៅទេ លុះត្រាតែបុគ្គលនោះតាំងចិត្តកាយប្រព្រឹត្តអំពើអាក្រក់៕

# ថ្ងៃទី១៩ខែឧសភា

" *ការអានមិនអាចឲ្យយើងគ្រប់គ្នាក្លាយទៅជាអ្នកដឹកនាំបានពិតមែន ក៏ប៉ុន្តែវាអាចប្រាប់យើងឲ្យដឹងថា តើបុគ្គលប្រភេទណាដែលយើងគួរដើរតាម?"*

ទ្រឹស្តីពុទ្ធនិយមបានបង្ហាញថា *"អប្បមត្តា សតីមន្តោ"* ប្រែថា *"អ្នកទាំងឡាយចូរកុំប្រមាថ"* កុំចាត់ទុកអ្នកដទៃជាមនុស្សល្ងង់តែត្រូវប្រដៅខ្លួនឯងឲ្យបានល្អ។ទេពកោសល្យគឺព្រះជាម្ចាស់ជាអ្នកប្រទានឲ្យយើង ដូច្នេះចូរយើងចេះដាក់ខ្លួន។ កិត្តិនាមល្បីល្បាញ គឺអ្នកដទៃជាអ្នកឲ្យ ដូច្នេះ ចូរយើងចេះថ្លែងអំណរគុណ។ រីឯភាពអំណួតអួតក្អេងក្អាងគឺយើងជាអ្នកបង្កើតឡើងដោយខ្លួនឯង ដូច្នេះចូរយើងចេះប្រុងប្រយ័ត្ន៕

Reading can't make us all leaders, but it can teach us which leader to follow. Talent is God-given, be humble; fame is man-given, be thankful; conceit is self-given, be careful.

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី២០ ខែឧសភា

*ចន ហ្វីដើរាល់ កេណ្ណឌី [ John F. Kenndy ] និយាយថា "ចូរយើងកុំបន់ស្រន់សុំជីវិតដែលងាយស្រួល តែត្រូវបន់ស្រន់សុំឲ្យខ្លួនឯងក្លាយទៅជាមនុស្សខ្លាំងរឹងមាំ"។*

ទស្សនវិទូចិន ខុង ជឺ [ Confucius ] បានឲ្យនិយមន័យ *"មនុស្សខ្លាំង គឺសំដៅដល់បុគ្គលដែលមានគំនិតចាស់ទុំខណៈដែលខ្លួនមានអាយុនៅក្មេងនៅឡើយ"។*

បញ្ហាជីវិតកើតឡើងលើគ្រប់មនុស្សទាំងអស់ មានមនុស្សខ្លះព្រមទទួលបញ្ហា សុខខ្លះ ទុក្ខខ្លះ ដោះស្រាយបានខ្លះ ដោះស្រាយមិនបានខ្លះ វាជាច្បាប់ធម្មជាតិ។ ដូច្នេះ គួរតែទទួលស្គាល់នូវការផ្លាស់ប្តូររាល់បាតុភូត និងរឿងរ៉ាវជីវិតក្នុងធម្មជាតិ។ មនុស្សខ្លាចស្លាប់ មិនចង់បែក មិនចង់ឈឺចាប់ មិនចង់ចាស់ អីចឹងទាល់តែលែងកើត លែងចាប់

កំណើត នោះទើបអត់មានបញ្ហាជីវិត។ នេះជាច្បាប់សកល និងច្បាប់ធម្មជាតិដែលហៅថា "សច្ចៈ"។ ធម្មជាតិបង្កើតមនុស្សផង ចិញ្ចឹមមនុស្សផង និងសម្លាប់មនុស្សផង តែសេចក្ដីវិនាសមួយចំនួនធំ ក៏កើតចេញពីស្នាដៃរបស់មនុស្សដោយខ្លួនឯងដែរ ដូចជាមនុស្សបំផ្លាញបរិស្ថានព្រៃឈើ។ល។

គ្រប់យ៉ាងនឹងទៅជាល្អទាំងអស់នៅទីចុងបញ្ចប់ តែបើមិនទាន់ល្អនៅឡើយទេ គឺគ្រាន់តែមានន័យថាមិនទាន់ដល់ទីបញ្ចប់។ សូមឲ្យការប្រឹងប្រែងស្ថិតក្នុងដួងចិត្តមនុស្សទាំងឡាយក្នុងសង្គមខ្មែរ។ដើម្បីជោគជ័យ មានវិធី១០យ៉ាងគឺ៖ ១ប្រឹង, ២ប្រឹង, ៣ប្រឹង, ៤ប្រឹង, ៥ប្រឹង, ៦ប្រឹង, ៧ប្រឹង, ៨ប្រឹង, ៩ប្រឹង, ១០ប្រឹងដោយកុំបោះបង់ចោល៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី២១ ខែឧសភា

*"មនុស្ស គឺជាសត្វដែលមានភាពឧត្ដមថ្លៃថ្លាខ្ពង់ខ្ពស់ ជាងសត្វដទៃទាំងឡាយ ប៉ុន្តែបើគ្មានច្បាប់ និងមានតែច្បាប់ តែគ្មានយុត្តិធម៌ គឺមនុស្សនឹងក្លាយជាអាក្រក់ថោកទាបជាងសត្វទៅទៀត"*។

អ្នកប្រាជ្ញម្នាក់បាននិយាយថា *"ខ្ញុំមិនដឹងថាអ្វីទៅគឺជាច្បាប់នោះទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា អវត្តមាននៃច្បាប់នឹងធ្វើឲ្យសង្គមមានភាពចលាចលគ្មានសណ្តាប់ធ្នាប់"*។ ច្បាប់គឺជាអក្សរលើក្រដាស តែមនុស្សជាអ្នកអនុវត្ត។ ក្នុងសង្គមប្រជាធិបតេយ្យ និងមាននីតិរដ្ឋ គ្មានឡើយអ្នកនៅលើច្បាប់ ឬគ្មានឡើយអ្នកនៅក្រោមច្បាប់។ *"តុល ឬតុលា"* ប្រែថា *"ជញ្ជីង ឬត្រាជូ"* ឬខ្មែរបុរាណពោលថា *"ដឹងហាបឲ្យដឹងតុល ភ្នែកឲ្យយល់ទៀងត្រាជូ"*។ លើលោកយើងនេះមានយុត្តិធម៌តែគ្មានស្តង់ដារយុត្តិធម៌ទេ៕

*"I don't know what it is the law, but the absence of the right makes the country into chaos."* - Phillipe Malaurie

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី២២ ខែឧសភា

*"សេរីភាព គឺជាអ្វីគ្រប់យ៉ាង ពីព្រោះកាលណាយើងបោះបង់ចោលសេរីភាពតែម្យ៉ាង នោះយើងក៏នឹងបាត់បង់គ្រប់យ៉ាង"។*

សេរីភាពមិនមន ជាអ្វីទាំងអស់ ក្រៅពីអ្វីដែលអាចឲ្យយើងមានឱកាសទទួលបានភាពល្អប្រសើរជាងមុន។ទីណាមានការគាបសង្កត់ ទីនោះតែងតែមានការរើបម្រាស់ ហើយទីណាមានការរើបម្រាស់ ទីនោះតែងមានសេរីភាពល្អប្រសើរជាងមុន។ ចូរកុំត្រឹមតែនិយាយពីសេរីភាព តែត្រូវគិតពីសេរីភាពផង ហើយក៏សូមកុំត្រឹមតែគិតពីសេរីភាព តែត្រូវក្លាហានទាមទារសេរីភាពផង។

អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] ពោលថា "*យើងគួរនាំគ្នាកសាងវិរជននៃសន្តិភាព តែមិនមែនកសាងវីរជននៃសង្គ្រាមទេ*"។

វីរបុរសខ្វះវិចារណញ្ញាណ ក្តីហិង្សាងងឹតងងុល អំពើជេរប្រមាថជាតិសាសន៍ឯងឆ្កួតលីលាគួរឲ្យស្អប់ខ្ពើម កើតឡើងក្រោមស្លាកថាជាអ្នកស្នេហាជាតិ៕

# ថ្ងៃទី២៣ ខែឧសភា

អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] គឺជាអច្ឆរិយបុគ្គលគ្មានជំនឿលើសាសានា ឬជាមនុស្សឥតសាសនាកម្រិតខ្ពស់មួយរូបក្នុងស.វទី២១។ បើគេសួរគាត់ថា *"តើអ្នកកាន់សាសនាអ្វី?"* នោះគាត់នឹងឆ្លើយថា *"ខ្ញុំគ្មានសាសនាទេ"*។ ក៏ប៉ុន្តែបើគេសួរគាត់ថា *"តើអ្នកចូលចិត្តសាសនាណា?"* នោះគាត់នឹងតបថា *"ខ្ញុំចូលចិត្តព្រះពុទ្ធសាសនា"*។សាសនាទាំងឡាយ គឺជាប្រភពនៃសាមគ្គីភាព តែសាសនិកទាំងឡាយជាប្រភពនៃការបែកបាក់។

ស្រដៀងគ្នានេះដែរ មហាត្មៈ គន្ធី យល់ថា *"សាសនាមានគោលដៅនាំមនុស្សទៅដល់សុភមង្គលដូចគ្នា តែគ្រាន់តែមានមាគ៌ាខុសគ្នាបន្តិចប៉ុណ្ណោះ"*។ ភាពជាមនុស្សល្អ វាមានភាពសំខាន់ខ្លាំងបំផុត ដោយមិនថាយើងមានជំនឿលើសាសនាណានោះទេ។

បើយើងជាមនុស្សល្អយើងក៏នឹងក្លាយទៅជាពុទ្ធសាសនិកល្អ ឬគ្រីស្ទសាសនិកល្អ ឬឥស្លាមសាសនិកល្អ ហិណ្ឌូសាសនិកល្អ៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី២៤ ខែឧសភា

*អ្នកប្រាជ្ញក្រិច Sophocles និយាយថា "មនុស្សដែលមានវ័យកាន់តែចាស់ នឹងក្លាយខ្លួនជាមនុស្ស មានវ័យក្មេងម្តងទៀត"។*

មនុស្សចាស់ តែងតែបានរៀនសូត្រពីជីវិតរបស់ខ្លួនតាមរយៈបទពិសោធន៍។ ពេលខ្លួនកាន់តែចាស់ កាន់តែយល់ដឹងច្រើន តែក្នុងគំនិតបុគ្គលប្រភេទចាស់ឆ្លាត គឺមិនដែលធ្លាប់យល់ថាខ្លួនចេះដឹងច្រើនទេ។ គ្រប់គ្នាតែងមានអាយុក្មេងជាងវ័យ១ឆ្នាំឲ្យតែចង់រៀន។ កាន់តែរៀន កាន់តែល្ងង់ ពេលខ្លះឆ្ងល់ច្រើនដូចក្មេង។

ទស្សនវិទូក្រិច សូក្រាត [ Socrates ] និយាយថា *"ខ្ញុំមិនដឹងគ្រប់យ៉ាងទាំងអស់ តែខ្ញុំដឹងត្រឹមតែម្យ៉ាងគត់ គឺខ្ញុំមិនចេះគ្រប់យ៉ាងទាំងអស់"*។

*មានតែបុគ្គលដែលយល់ថាខ្លួនមិនចេះប៉ុណ្ណោះ ទើបតែងតែបំពេញវិជ្ជាបន្ថែម តែមនុស្សដែលយល់ថាខ្លួនចេះ គឺនឹងមិនរៀនអ្វីបន្ថែមឡើយ"៕*

*"A man growing old becomes a child again."*

- Sophocles

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី២៥ ខែឧសភា

*"ការចេះបង្អោនប្រាណស្តាប់គំនិតល្អបែបវិជ្ជមានពីអ្នកដទៃ គឺជាមាតានៃជោគជ័យ ហើយភាពជោគជ័យ គឺជាប្រភពកំណើតបញ្ចៀសយើងឲ្យគេចផុតពីគ្រោះភ័យទាំងឡាយទាំងពួង"។*

កន្លែងណាក៏ជាទីប្រឹក្សាយោបល់របស់យើង។ នរណាក៏អាចជាទីប្រឹក្សាយោបល់របស់យើង ហើយពេលវេលាណាក៏អាចឲ្យយើងឆ្លៀតរៀនសូត្របានដែរ។ មនុស្សធម្មតា យកមនុស្សឆ្លាតជាទីប្រឹក្សា។ រីមនុស្សឆ្លាត យកបណ្ឌិតជាទីប្រឹក្សា តែបណ្ឌិត យកគ្រប់យ៉ាងជាទីសិក្សាស្វែងយល់ មិនថាជាមនុស្ស សត្វ ឬធម្មជាតិទាំងឡាយនោះទេ៕

# ថ្ងៃទី២៦ ខែឧសភា

*"ទាំងលុយ និងចំណេះដឹង បើក្លាយជាចៅហ្វាយនាយរបស់មនុស្សហើយ គឺមនុស្សនឹងក្លាយជាទាសករដ៏សាហាវបំផុត"។*

*ទ្រឹស្តីដ៏អស្ចារ្យបំផុតរបស់ទស្សនវិទូក្រិចសូក្រាតគឺ "តម្រូវឲ្យមនុស្សត្រូវស្គាល់ខ្លួនឯងឲ្យច្បាស់"។* ការបង្រៀនគ្រប់សាសនាទាំងអស់ក្នុងលោកគឺ *"តម្រូវឲ្យមនុស្សចេះគ្រប់គ្រងនូវចំណង់ និងការលោភលន់របស់ខ្លួនឲ្យបាន"។* គេតែងនាំគ្នានិយាយថា *"មានលុយច្រើនគឺពិតជាល្អមែនទែន"* ប៉ុន្តែខ្ញុំថា *"បើមិនចេះគ្រប់គ្រងខ្លួនឯង គឺលុយជាចៅហ្វាយដ៏អាក្រក់"។*

មានលុយច្រើននឹងបង្កើនសុភមង្គលផ្នែករូបកាយ តែទន្ទឹមនឹងនោះក៏កើតឡើងនូវទង្វើអសីលធម៌ និងខ្វះគុណធម៌ភ្លើតភ្លើនភ្លេចខ្លួន ឬជាច់បង្ហៀរដែរ។

នេះក៏មិនខុសពីការសន្មត់របស់អ្នកប្រាជ្ញចិន ឡៅ ជឺ ដែលថា *"បើភាពមានកើតឡើងមុន នោះភាពគ្មានក៏នឹងកើតឡើងតាមក្រោយដូចគ្នាដែរ បើភាពស្អាតកើតឡើងមុន នោះភាពអាក្រក់ ក៏នឹងលេចឡើងតាមក្រោយដូចគ្នាដែរ"*។

គេតែងនាំគ្នានិយាយទៀតថា *"មានចំណេះដឹងច្រើនគឺល្អមែនទែន"* តែខ្ញុំថា *"បើមិនចេះគ្រប់គ្រងខ្លួនឯងទេ គឺចំណេះដឹង នឹងក្លាយទៅជាចៅហ្វាយនាយដ៏អាក្រក់បំផុត ឬក្លាយទៅជាភ្លើងឆេះខ្លួនឯងទៀតផង"*។

តាមទ្រឹស្តីចិត្តសាស្ត្របានបញ្ជាក់ថា ក្មេងមិនសូវចេះកើតទុក្ខព្រួយប៉ុន្មានទេ ដោយសារក្មេងមិនសូវចេះគិត ឬក្នុងខួរក្បាលរបស់ក្មេងមិនសូវមានព័ត៌មានច្រើន។ ដូច្នេះមានពេលខ្លះ យើងជាមនុស្សធំ ក៏គួរតែចេះរៀនសូត្រតាមកូនក្មេង ដោយរៀនទទេគំនិត។ បើមនុស្សមិនរៀនធ្វើជាចៅហ្វាយនាយលើលុយទេ គឺលុយនឹងគ្រប់គ្រងមនុស្សវិញ

មិនខានឡើយ។ បើមនុស្សមិនរៀនធ្វើជាចៅហ្វាយនាយលើចំណេះដឹងទេ គឺចំណេះដឹងនឹងគ្រប់គ្រងមនុស្សវិញ។ ទាំងលុយ និងចំណេះដឹង បើក្លាយជាចៅហ្វាយនាយរបស់មនុស្សហើយ គឺមនុស្សនឹងក្លាយជាទាសករដ៏អាក្រក់បំផុត៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី២៧ ខែឧសភា

*"សកម្មភាពដោយគ្មានចំណេះដឹងគឺឥតបានការណ៍ ហើយចំណេះដឹងដោយមិនយកមកអនុវត្តន៍គឺគ្មានខ្លឹមសារ"*។

ចំណេះដឹង គឺជាអំណាច តែមានអ្នកខ្លះមានចំណេះដឹងតែបែរជាគ្មានអំណាចទៅវិញ។ នេះមកពីចំណេះដឹងទាំងនោះ មិនបានដើរចេញពីភាពអរូបីយទៅកាន់ការអនុវត្តន៍ជាក់ស្តែង។ បុរាណខ្មែរពោលថា *"ចូរគិតមុនគូរ តែកុំគូររួចចាំគិតក្រោយ"*។ មនុស្សចេះត្រឹមតែគូរ តែមិនចេះគិត គឺលទ្ធផលត្រឹមទុកជាបទពិសោធន៍ រីឯអ្នកដែលចេះត្រឹមតែគិត ប៉ុន្តែមិនព្រមគូរ គឺលទ្ធផលបានត្រឹមតែអ្នកទ្រឹស្តីនិយម៕

# ថ្ងៃទី២៨ ខែឧសភា

*"ភ្លៀងធ្លាក់គង់រាំង យប់យន់គង់ភ្លឺ ឈឺចាប់គង់រសាត់ ក្ដីសង្ឃឹមនៅតែមាន ឬបើបាត់ក្ដីសង្ឃឹមគង់រកឃើញវិញ"*។

ផ្គរលាន់មុនភ្លៀង ឬ ពេលខ្លះភ្លៀងធ្លាក់ដោយគ្មានផ្គរលាន់។ ពពកខ្មៅដេរដាស បាំងសូរិយាក្នុងគ្រាមេឃបង្អុរភ្លៀង ឬពេលខ្លះភ្លៀងបណ្ដើរ សូរិយាបញ្ចេញរស្មីចិញ្ចែងចិញ្ចាចបណ្ដើរ។ ចំពោះជីវិត ក៏អាចមានសេចក្ដីសុខបានដែរ ក្នុងកំឡុងពេលយើងជួបទុក្ខ។ ពេលខ្លះព្យុះជីវិត ប្រៀបដូចនឹងខ្យល់លំហែកាយនៅតាមមាត់សមុទ្រ ឬប្រៀបដូចឥន្ទធនូប្រាំពីរពណ៌ដែលមានតែពេលភ្លៀង ឬមេឃស្រទំប៉ុណ្ណោះ ដែលអាចឲ្យយើងមើលឃើញបាន។

បិតាកំណែទម្រង់ចិន តេង ស៊ីវពីង [ Deng Xiaoping ] និយាយថា *"ឆ្មាស ឬឆ្មាខ្មៅ សំខាន់ឲ្យតែចេះចាប់កណ្ដុរ"*។ មិនថាភាពជាមិត្ត ឬភាពជាសត្រូវ សុទ្ធតែអាចឲ្យយើង

យកជាប្រយោជន៍ ហើយមិនថាសុភមង្គល ឬក៏ជាអពមង្គល សុទ្ធតែមានប្រយោជន៍ តែអ្វីដែលសំខាន់ គឺវិធីសាស្ត្រនៃការមើលរូបភាពទាំងនោះ។ ចូរប្រឈមមុខចំពោះបញ្ហាដែលយើងគេចមិនបាន ហើយចូរប្រឈមមុខចំពោះបញ្ហាដែលមានប្រយោជន៍ចំពោះយើង៕

*"The rain will stop, the night will end, the hurt will fade. Hope is never so lost that it can't be found."*

# ថ្ងៃទី២៩ ខែឧសភា

*"សមត្ថភាពនឹងគ្មានបានការណ៍ បើកាលណាគ្មានឱកាសដើម្បីអនុវត្ត។ ចំណែកឱកាសអនុវត្តនឹងគ្មានបានផល បើខ្វះការរៀបចំខ្លួនទុកជាមុន"។*

មានឱកាស តែខ្វះសមត្ថភាព ស្មើនឹងបរាជ័យ ហើយបរាជ័យនឹងក្លាយទៅជាមេរៀន។ ចំណែកមានសមត្ថភាព តែខ្វះឱកាស ស្មើនឹងបរាជ័យ ហើយនឹងក្លាយជាបរាជ័យរៀងរហូត បើនៅតែខ្វះសមត្ថភាពនិមិត្តឱកាសឡើង ឬគ្មានក្រសែភ្នែកល្អប្រមើមើលឱកាស។ ក្នុងគ្រប់បញ្ហាវិបត្តិទាំងឡាយ តែងមានលាក់កំបាំងឱកាសមួយ ហើយឱកាសតែមួយអាចនឹងមានបង្កប់បញ្ហាវិបត្តិច្រើន៕

# ថ្ងៃទី៣០ ខែឧសភា

*"សេចក្តីស្រឡាញ់ចំពោះបងប្អូនឈាមជ័រតែមួយ ប្រជាជនយើង និងជាតិសាសន៍យើង គឺមិនត្រូវប្រកាន់លើនិន្នាការសាសនា ឬនយោបាយ និងការរើសអើងនានាឡើយ"។*

បរមគ្រូ ខុង ជឺ [ Confucius ] បានពោលថា *"សូមបំភ្លេចចោលសេចក្តីឈឺចាប់ទាំងឡាយដែលមនុស្សទាំងឡាយបានប្រព្រឹត្តលើយើង។ ប៉ុន្តែសូមកុំភ្លេចសេចក្តីល្អសប្បុរសទាំងអស់ដែលគេបានធ្វើដល់យើង"។*

មនុស្សសង្គមខ្មែរមួយចំនួនត្រឹមតែខ្លួនល្អជាងគេឯងក៏កើតក្តីអំនួត មើលស្រាលដល់គេ។ ត្រឹមតែមានភាពឆ្លាតជាងគេឯង ក៏កើតក្តីអំនួត មើលស្រាលដល់គេ។ ត្រឹមតែមានមេដឹកនាំល្អជាងគេឯង ក៏កើតក្តីអំនួត មើលស្រាលដល់គេ។ ត្រឹមតែមានសាសនាល្អជាងគេឯង ក៏កើតក្តីអំនួតមើលស្រាលដល់គេ គឺគ្រប់យ៉ាងនឹងអន្តរាយវិនាសជាតិឯងវិនាសសង្គម

ឯង ក៏ព្រោះអំនួតជាច់បង្អៀរ ឬខ្វះសេចក្តីស្រឡាញ់ដោយស្មោះ។

អច្ឆរិយៈបុគ្គលស.វទី ២០ អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] ពោលថា "ធ្វើជាមនុស្សល្អដែលស្ងប់ស្ងៀម គឺល្អប្រើសើរជាងធ្វើជាមនុស្សល្អ ដែលគិតតែត្មេះតិះដៀលអ្នកដទៃ"។ ឈើចាប់របស់ជាតិ គឺមានយុវជនដែលប្រាកបដោយសក្តានុពល តែបែរជាមានអំនួតជាច់បង្អៀរ ខ្វះនូវសេចក្តីផ្សះផ្សាគ្នា ព្រោះនិន្នាការសាសនា និងនិន្នាការនយោបាយ៕

# ទស្សនៈសម្រាប់ខែ

# មិថុនា

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី០១ ខែមិថុនា

*"មនុស្សល្អ មិនមែនមានត្រឹមតែទ្រព្យសម្បត្តិស្តុកស្តម្ភនោះទេ តែគឺជាបុគ្គលដែលមានភាពសុចរិតត្រឹមត្រូវ ព្រមទាំងអាចមានសមត្ថភាពដែលជះឥទ្ធិពលវិជ្ជមានដល់មនុស្សជុំវិញខ្លួន"*។

មានលុយច្រើនអាចប្រើខ្មោចឲ្យកិនម្សៅឲ្យក៏បានដែរ ប៉ុន្តែមានអ្នកមានលុយខ្លះមិនអាចទាំងយកលុយទៅប្រើមនុស្សឲ្យធ្វើការបានផង។ ថ្វីត្បិតតែមនុស្សកើតមកដូចគ្នា តែបើគ្មានលុយធ្វើឲ្យមនុស្សខុសគ្នា។ ចូរធ្វើជាមនុស្សដែលមានម្ចាស់ការឯករាជ្យលើខ្លួនឯង ជឿលើខ្លួនឯង និងរស់ដោយពឹងលើខ្លួនឯង៕

*"The greatness of a man is not in how much wealth he acquires, but in his integrity and his ability to affect those around him positively."*- Bob Marley.

# ថ្ងៃទី០២ ខែមិថុនា

ខុង ជឺ [ Confucius ] ពោលថា *"មនុស្សយើងត្រូវបេះលះបង់ចំណង់ ៣យ៉ាងក្នុងជីវិត"* គឺ៖

១. យុវវ័យត្រូវលះបង់ចំណង់តណ្ហាត្រេកត្រអាល ។

២. មជ្ឈិមវ័យត្រូវលះបង់អំនួតអួតក្អេងក្អាង។

៣. បច្ឆិមវ័យត្រូវលះបង់ភាពលោភលន់ទ្រព្យសម្បត្តិ។

យុវជនយុវតី ខូចនឹងប្រុសអស់ព្រហ្មចារីយ៍ ខូចនឹងស្រីខ្លីវិជ្ជា។ អំនួតអួតក្អេងក្អាងនឹងនាំឲ្យវិនាសខ្លួន។ ជីវិតដែលលំបាកដោយមានប្រាជ្ញា ប្រសើរជាងការសប្បាយដាច់បង្ហៀរដោយភាពល្ងង់ខ្លៅ។ សេចក្ដីខ្វះភាពអត់ធ្មត់ក្នុងរឿងតូចតាចក្នុងពេលបច្ចុប្បន្ន នឹងបង្កផលអវិជ្ជមានដ៏ធំក្នុងពេលអនាគត៕

# ថ្ងៃទី០៣ ខែមិថុនា

ខុងជឺ[Confucius]ពោលថា"កុំបារម្ភពីអ្នកដទៃមិនសរសើរខ្លួន តែត្រូវបារម្ភថាខ្លួនត្រូវធ្វើយ៉ាងណា ឲ្យមានប្រយោជន៍ដល់អ្នកដទៃ។ កុំបារម្ភពីអ្នកដទៃមិនយល់ពីខ្លួនតែត្រូវចេះបារម្ភពីខ្លួនដែលមិនយល់ពីអ្នកដទៃ"។

ការរិះគន់ដើម្បីស្ថាបនាគឺជាអាហារសម្រាប់បណ្ឌិត តែការរិះគន់គ្មានការពិតគឺជាគំនិតនៃជនពាល។ បើខ្លួនយើងចង់មានសេចក្ដីសុខក្នុងជីវិត ជាដំបូងត្រូវជួយអ្នកដទៃឲ្យមានសេចក្ដីសុខជាមុនសិន។ *"ឲ្យអ្នកដទៃក្លាយទៅជាអ្នកមានជាមុន"* គឺជាទស្សនៈរបស់បិតាកំណែទម្រង់នៃប្រទេសចិន តេង សៀវពីង។

ជីវិតដែលរស់នៅដើម្បីតែខ្លួនឯងគឺជាជីវិតឯកោ តែជីវិតដែលរស់នៅដើម្បីអ្នកដទៃ គឺជាជីវិតមានន័យ។

ចូរកុំរស់នៅត្រឹមធ្វើជាមនុស្សជោគជ័យ តែត្រូវរៀនរស់ជាមនុស្សមានតម្លៃផង។ មនុស្សមានតម្លៃនឹងមានគ្រប់យ៉ាងក្នុងជីវិត តែមនុស្សដែលមានគ្រប់យ៉ាងក្នុងជីវិតមិនប្រាកដថាមានតម្លៃនោះទេ៕

*"Do not concerned other not appreciating you. Be concerned about you not appreciate others."*

- Confucius.

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី០៤ ខែមិថុនា

ខុង ជឺ [ Confucius ] ពោលថា "បើបណ្តោយឲ្យជនណាម្នាក់រៀនដោយគ្មានការគិត គឺជាការខាតពេលវេលា តែបើឲ្យជននោះគិតដោយគ្មានការរៀនគឺជាការខាតបង់ធនធានមនុស្ស"។

ចំណេះវិជ្ជាងាយស្រួលរក និងងាយស្រួលឲ្យ តែបើសាបព្រោះចំណេះដឹងខុស សាបព្រោះលើមនុស្សខុស គឺជាការខាតបង់ទាំងពេលវេលា និងព្រមទាំងបំផ្លាញ ឬបានសាបព្រោះគ្រោះកាចដល់សង្គមទៀតផង។ គំនិតល្អនាំឲ្យមានអារម្មណ៍ល្អ។ អារម្មណ៍ល្អនាំឲ្យធ្វើសកម្មភាពល្អ។ បើធ្វើសកម្មភាពល្អនាំឲ្យទទួលផលល្អទាំងយើងទាំងគេ ឬក៏ថាឈ្នះ-ឈ្នះ។

មានគំនិតអស្ចារ្យ នឹងបង្កើតភាពអស្ចារ្យ រីឯគំនិតអស្ចារ្យកើតចេញពីប្រឹងប្រែងរៀនសន្សំយ៉ាងអស្ចារ្យ។ បើគ្មានការសិក្សាទ្រឹស្តី និងការពិសោធន៍ គឺមនុស្សខ្វះព័ត៌មាន។

បើកាលណាខ្វះព័ត៌មាន គឺស្មើនឹងគ្មានចំណេះដឹង។ ការចងចាំបូកនឹងយល់ គឺស្មើនឹងចេះ ប៉ុន្តែបើយល់ហើយមិនចងចាំ ស្មើនឹងមិនចេះ ឬបើចងចាំតែមិនយល់ ក៏ស្មើនឹងមិនចេះដូចគ្នាដែរ។ អ្នកប្រាជ្ញម្នាក់និយាយថា "*ការអប់រំមិនអាចឲ្យយើងគ្រប់គ្នាក្លាយជាអ្នកដឹកនាំបានមែនពិត ក៏ប៉ុន្តែវាពិតជាអាចប្រាប់យើងឲ្យដឹងថា តើបុគ្គលប្រភេទណាដែលយើងគួរដើរតាម*"។ បើយើងយល់កាពល្ងង់ខ្លៅ ឬអវិជ្ជាគ្មានតម្លៃ នោះចូរយើងប្រឹងប្រែងសំដៅទៅរកវិជ្ជាដែលជាវត្ថុមានតំលៃកាត់ថ្លៃពុំបាន៕

# ថ្ងៃទី០៥ ខែមិថុនា

វិល្លៀម ស្ហេកស្ពៀរ [ William Shakespeare ] ពោលថា *"មនុស្សល្ងង់តែងគិតថាខ្លួនឯងឆ្លាត តែមនុស្សឆ្លាត បែរជាគិតថាខ្លួនឯងនៅល្ងង់"*។
ទស្សនវិទូក្រិច សូក្រាត [ Socrates ] ពោលថា *"ខ្ញុំមិនដឹងគ្រប់យ៉ាងទាំងអស់ តែខ្ញុំដឹងត្រឹមតែម្យ៉ាងគត់ គឺខ្ញុំមិនចេះអ្វីទាំងអស់"*។មនុស្សល្ងង់រៀនពីអ្នកចេះ ចំណែកអ្នកចេះរៀនពីមនុស្សគ្រប់ប្រភេទ តែបណ្ឌិតរៀនពីអ្វីគ្រប់យ៉ាង។

ចំណីដល់មាត់មិនចេះស៊ី វិជ្ជាដល់ត្រចៀកមិនចេះទទួល។ ចង់ចេះឲ្យប្រឹងរៀន ចង់មានឲ្យប្រឹងរក។ ចង់ស្រណុកឲ្យស្រវារកវិជ្ជា ចង់វេទនាឲ្យខ្ជិលច្រអូស។ កាន់តែរៀន កាន់តែរស់ ហើយអ្នកដែលឈប់រៀន គឺមានន័យថាឈប់រស់ដែរ៕

# ថ្ងៃទី០៦ ខែមិថុនា

ម៉ៅ សេទុង [ Mao Tse Tung ] និយាយថា "អព្ភូតហេតុអស្ចារ្យអាចកើតឡើងទៅបាន លុះត្រាតែ យើងប្រឹងប្រែងដណ្ដើមយកជ័យជម្នះឲ្យខានតែបាន"។ ទីណាមានបញ្ហា ទីនោះមានមនុស្សអស្ចារ្យកើតឡើង ពីព្រោះបញ្ហាកាន់តែខ្លាំង កាន់តែធ្វើឲ្យមនុស្សយើងក្លាយជាមនុស្សអស្ចារ្យ។ ដើមឈើធំ ប៉ះខ្យល់ធំ កាហ្វេប៉ះទឹកកាន់តែក្ដៅខ្លាំង ធ្វើឲ្យវាកាន់តែមានរសជាតិឈ្ងុយឆ្ងាញ់ខ្លាំង។

ការប្រឹងប្រែងតស៊ូជាមួយបញ្ហា ប្រៀបដូចការសម្លាប់សត្រូវក្នុងសមរភូមិសង្គ្រាម បើយើងមិនកម្ចាត់បញ្ហា នោះបញ្ហានឹងកម្ចាត់យើងវិញ។ ជីវិតយើងនឹងត្រូវបញ្ចប់ បើយើងនៅធ្មឹងស្ងៀមចំពោះបញ្ហា។ រាល់សមិទ្ធិផល រាល់អព្ភូតហេតុអស្ចារ្យ គឺមនុស្សជាអ្នកបង្កើតឡើងមិនមែនទេវតាអារក្ខអ្នកតា ឬអាទិទេពណានោះទេ។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

ចូរប្រឹងប្រែងប្រាកបដោយភាពជឿជាក់លើខ្លួនឯង៕

One all struggle is grasped, miracle is possible.

# ថ្ងៃទី០៧ ខែមិថុនា

បៀល ហ្គេត [ Bill Gates ] និយាយថា *"កើតមកក្រមិនមែនជាកំហុសរបស់អ្នកទេ តែបើស្លាប់ទៅវិញក្រ នោះទើបជាកំហុស"។*

ចំពោះសង្គមខ្លះ មនុស្សខ្ជិលខ្លះ និងមនុស្សលោភលន់ខ្លះ បាននាំគ្នានិយាយថា *"កើតមកមានឪពុកម្ដាយបង្កើតជាអ្នកក្រមិនមែនជាកំហុសទេ តែបើមានឪពុកម្ដាយក្មេកជាអ្នកក្រ នោះទើបជាកំហុសពិតប្រាកដ"។*

កុំស្រឡាញ់រកតែអ្នកមាន តែត្រូវគិតដល់អ្នកមានចំណេះដឹង និងចរិតលក្ខណៈល្អខ្លះផង។ ទ្រព្យសម្បត្តិមិនអាចធ្វើឲ្យមនុស្សមានសុភមង្គលទាំងអស់នោះទេ តែសុភមង្គលនឹងធ្វើឲ្យមនុស្សទាំងអស់មានទ្រព្យសម្បត្តិ៕

# ថ្ងៃទី០៨ ខែមិថុនា

មហាត្មៈ គន្ធី [ Mahatma Gandhi ] ពោលថា *"អ្នកទន់ខ្សោយមិនចេះអភ័យទោសឲ្យអ្នកដទៃទេ ពីព្រោះការចេះអភ័យទោសឲ្យអ្នកដទៃ គឺជាគុណលក្ខណៈនៃមនុស្សខ្លាំង"* ។ មហាត្មៈ គន្ធី បានដើរតាមគោលការណ៍នៃភាពជាអ្នកដឹកនាំ ៥យ៉ាងរបស់ព្រះយេស៊ូ៖

១) ចូរស្រឡាញ់សត្រូវរបស់អ្នក។

២) ចូរកុំខឹងគុំគួននឹងសត្រូវ ឬបងប្អូនរបស់អ្នកឡើយ។

៣) ចូរកុំសងសឹកនឹងមនុស្សទុច្ចរិតឡើយ។

៤) ចូរកុំត្រេកត្រអាលនឹងកាមតណ្ហាឡើយ។

៥) ចូរកុំប្រើពាក្យស្បថសច្ចាឲ្យសោះ តែបើ *"មែន គឺមែន"* ហើយបើ *"ទេ គឺទេ"*។ គោលការណ៍ទាំង ៥ចំណុចខាងលើ មានចែងក្នុងគម្ពីរគ្រីស្ទសាសនាត្រង់ម៉ាថាយ ជំពូក៥ ចាប់ពីខ ២២ ដល់ ខ ៤។

អ្នកនយោបាយខ្មែរក្នុងបរិបទខ្មែរបានដើរតាមគោលការណ៍មនោគមវិជ្ជាផ្ទុយពីអ្នកដឹកនាំឥណ្ឌា៖

១) ស្អប់ជេរប្រទេចអ្នកណាដែលយល់មិនដូចគំនិតខ្លួន។

២) ខឹងគុំគួនជេរប្រទេចអ្នកណា ដែលយល់មិនដូចគំនិតខ្លួន។

៣) ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី។

៤) អបាយមុខ ស្រី ស្រា ល្បែង។

៥) ប្រជាភិថុតិ ស្បថស្បែឲ្យតែបានអំណាច។

អ្នកនយោបាយខ្មែរ បើបានយករាស្ត្រខ្មែរជាប្រជារាស្ត្ររបស់ខ្លួន និងចង់ជួយសង្គ្រោះជាតិខ្មែរ គួរតែបង្រៀនប្រជាជនឲ្យចេះគោរពស្រឡាញ់ខ្មែរគ្នាឯង មានសីលធម៌គ្រប់គ្នា និងកុំឈ្លោះប្រកែកគ្នា តែមិនមែនបង្រៀនឲ្យស្អប់ខ្មែរ និងយកខ្មែរជាសត្រូវ ឬប្រើពាក្យជេរប្រទេចបញ្ឆេះកំហឹងនោះទេ។ លក្ខណៈចរិតបែបសុភាពរាបសារ មហាត្មៈ គន្ធីត្រូវបានគេហៅថាជា *"សាសនិកនៃអហិង្សា ឬអ្នកសន្តិភាពនិយម ឬ Religion of Nonviolence"*។

បិតាឯករាជ្យឥណ្ឌាម្នាក់នេះ បានទទូចអង្វរឲ្យមនុស្សចេះស្រឡាញ់គ្នា ចេះសាមគ្គីគ្នា និងកុំមានគំនុំសងសឹកដល់គ្នាថា *"បើនឹងយកភ្នែកមួយទៅស៊ីសងនឹងភ្នែកមួយ គឺបានត្រឹមតែធ្វើឲ្យពិភពលោកយើងទាំងមូលនៅសល់ត្រឹមតែមនុស្សខ្វាក់ប៉ុណ្ណោះ"*។

មិនខុសពីគំនិតរបស់លោកនាយរដ្ឋមន្ត្រីអង់គ្លេស វីនស្តុនឆើឈីល [ Winston Churchill ] ដែលនិយាយថា *"មេរៀនជីវិតដ៏អស្ចារ្យពិតប្រាកដរបស់មនុស្សយើងទាំងឡាយ គឺការដែលយើងត្រូវតែដឹងខ្លួនថា ពេលខ្លះមនុស្សល្ងង់ ក៏អាចគិតត្រូវ និយាយត្រូវ និងធ្វើត្រូវម្តងម្កាលដែរ"*។

# ថ្ងៃទី០៩ ខែមិថុនា

ណាប៉ូឡេអុង ប៉ូណាប៉ាត [ Napoleon Bonaparte ] ពោលថា *"សេចក្តីក្លាហាន គឺមិនមែនមានន័យថា យើងមានកម្លាំងបន្តដំណើរទៅមុខនោះទេ ប៉ុន្តែគឺមានន័យថាយើងនៅតែបន្តដំណើរទៅមុខទាំងអស់កម្លាំង"*។

សេចក្តីស្លាប់មានន័យថា បរាជ័យចាញ់អស់ពីខ្លួន ក៏ប៉ុន្តែបើរាងកាយមិនទាន់ស្លាប់ ថ្ងៃណាមួយ ចិត្តយើងនឹងក្រោកឈរឡើងតស៊ូបន្តដំណើរទៅមុខ សាជាថ្មីម្តងទៀតយ៉ាងពិតប្រាកដ។ មនុស្សក្លាហានមិនប្រាកដថាទាល់តែមានកម្លាំងទើបអាចបន្តទៅមុខបាននោះទេ ព្រោះអ្នកក្លាហានពិតប្រាកដតែងតែហ៊ាន គឺហ៊ានបន្តដំណើរទៅមុខជាមួយទឹកចិត្តដ៏អង់អាចក្លាហានជានិច្ច បើទោះបីជាគ្មានកម្លាំងក៏ដោយ។ ក្នុងនាមជាមនុស្សក្លាហាន ញើសនិងឈាមអាចស្រក់បាន តែមិនស្រក់ទឹកភ្នែក ឬឈប់បន្តដំណើរនោះទេ៕

# ថ្ងៃទី១០ ខែមិថុនា

ប្លែស ប៉ាស្កាល់ [ Blaise Pascal ] ពោលថា "*ខ្ញុំនិពន្ធអត្ថបទវែងជាងធម្មតា ពីព្រោះខ្ញុំគ្មានពេលវេលានិពន្ធឲ្យខ្លី*"។ អ្វីគ្រប់យ៉ាងដែលលោកយើងត្រូវធ្វើ គួរតែធ្វើឲ្យបានល្អជាស្រេច ដោយមិនចាំបាច់ត្រូវចំណាយពេលវេលាមកកែប្រែសាជាថ្មីម្តងទៀតនាំឲ្យតែខាតពេលវេលាច្រើននោះទេ។

ចំពោះការអប់រំបុរាណខ្មែរពោលថា "ធ្វើអ្វី ចូរធ្វើឲ្យហើយ តែកុំឡើយបន្សល់កេរ្តិ៍" ថ្ងៃស្អែក និងសេចក្តីស្លាប់ តើយើងអាចដឹងទេថា មួយណានឹងមកដល់មុន? ចូររស់នៅឲ្យដូចជាយើងត្រូវស្លាប់ទៅវិញនៅថ្ងៃស្អែក ហើយចូរប្រឹងប្រែងរៀន ប្រឹងប្រែងសន្សំទ្រព្យ និងកេរ្តិ៍ឈ្មោះល្អឲ្យដូចជាយើងត្រូវរស់នៅជាអមតៈ៕

# ថ្ងៃទី១១ ខែមិថុនា

អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] និយាយថា " *ភាពឆ្លាតមិនមែនជាសមត្ថភាពផ្ទុកទិន្នន័យក្នុងខួរក្បាលទេ តែជាការដឹងថា ត្រូវទៅរកទិន្នន័យទាំងនោះបាននៅកន្លែងណា*"។ មានរឿងនិទានមួយថា កាលគ្រាមួយ លោកអាល់ប៊ឺត អាញស្តាញ អ្នកវិទ្យាសាស្ត្រដ៏មានឥទ្ធិពល ត្រូវបានគេសួរសំណួរមួយថា "*តើ១ម៉ាយមានប៉ុន្មានហ្វីត?*" អាញស្តាញបានឆ្លើយថា "*ខ្ញុំមិនដឹងទេ។ ហេតុអ្វីខ្ញុំត្រូវចាំទិន្នន័យទាំងអស់នេះនាំឲ្យរំខានខួរក្បាល ក្នុងខណៈដែលខ្ញុំអាចស្វែងរកចម្លើយបាន នៅក្នុងពេលពីរនាទីពីសៀវភៅយោងនោះ*"។

អាញស្តាញបង្រៀនយើងឲ្យដឹងថា "*សមត្ថភាពដែលប្រើការគិតមានតម្លៃច្រើនជាងសមត្ថភាពត្រឹមតែចាំនិន្នន័យនិងតួលេខបានច្រើន* " មនុស្សឆ្លាតពិតប្រាកដមិនជាបុគ្គលដែលពូកែឆ្លើយ [ Answering ] នោះទេ តែជាបុគ្គលដែលពូកែសួរ [ Questioning ] ៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី១២ ខែមិថុនា

អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] លើកឡើងថា *"សិស្សមិនមែនជាកុងតឺន័រ ដែលចាំតែឲ្យគ្រូដាក់និន្នន័យចូលពេញខួរក្បាលនោះទេ ប៉ុន្តែសិស្ស គឺជាចន្លុះដែលគ្រូចាំបាច់ត្រូវតែអុចបំភ្លឺឡើង"*។

ការចងចាំ បូកនឹងយល់ ស្មើនឹង *"ចេះ"* ឬបើត្រឹមតែយល់មិនចាំគឺមិនចេះ ឬបើចងចាំ តែមិនយល់ គឺស្មើនឹងមិនចេះ។ ការអុចភ្លើងចន្លុះ ប្រៀបបាននឹងការបំផុសទឹកចិត្តសិស្សឲ្យចេះស្វែងរកចំណេះដឹងដោយខ្លួនឯង ឬធ្វើយ៉ាងណាឲ្យសិស្សមានជំនាញក្នុងស្វែរកសេចក្តីចេះដឹង។ ប៉ុន្តែមិនមែនប្រឹងដាក់ទិន្នន័យចូលក្នុងខួរក្បាលសិស្សនោះទេ។

មនុស្សយើងកើតមកមានរូបរាងចិត្តគំនិតមិនដូចគ្នា ប៉ុន្តែមនុស្សមានទេពកុស្យពូកែរៀងៗខ្លួន។ ទេពកោសល្យអាច

បានមកពីអំណោយរបស់ព្រះជាម្ចាស់ ឬពីធម្មជាតិ ប៉ុន្តែចរិតលក្ខណៈល្អ ឬអាក្រក់ គឺកើតឡើង ឬបានមកពីជម្រើសនៃការជ្រើសរៀងខ្លួន៕

# ថ្ងៃទី១៣ ខែមិថុនា

ថូម៉ាស់ ចេហ្វឺសាន់ [ Thomas Jefferson ] បាននិយាយថា *"ខ្ញុំជាមនុស្សម្នាក់ដែលជឿលើសំណាងជាខ្លាំង ហើយខ្ញុំក៏បានរកឃើញថា បើខ្ញុំប្រឹងកាន់តែខ្លាំងប៉ុនណា គឺថាខ្ញុំក៏នឹងក្លាយជាមនុស្សមានសំណាងខ្លាំងប៉ុណ្ណោះដែរ"*។

បើចង់ល្ងង់ សូមកុំប្រឹងប្រែងរៀន ហើយបើចង់ក្រ សូមកុំប្រឹងរកសន្សំទុកដាក់។ បើយោងតាមវចនានុក្រមខ្មែរ យើង *"សំណាង"*មានន័យថាអំពើដែលសាង។ ប្រឹងសាងសេចក្ដីល្អ ខំសាងសេចក្ដីសកម្មព្យាយាម ជីវិតនឹងប្រមូលផលសេចក្ដីល្អ និងសមិទ្ធិផលពីការប្រឹងព្យាយាមនោះដាក់ជាពុំខាន។

ប្រឹងប្រែរៀនស្ទើរលៀនភ្នែក អត់ងងុយ មិនបានដើរលេងស្ងប់ស្ងៀម តែដល់ពេលមានការចេះដឹង ចុងក្រោយគ្រប់គ្នានិយាយថា *"សំណាង"*។

ប្រឹងប្រែងធ្វើការតាំងពីព្រះអាទិត្យមិនទាន់រះរហូតដល់ថ្ងៃលិចវិញ ញើសបើកជោគសើមពេញអាវ ចុងក្រោយគ្រប់គ្នានិយាយថា "*សំណាង*"។

# ថ្ងៃទី១៤ ខែមិថុនា

អាប្រាហាម លីនខូល [ Abraham Lincoln ] ពោលថា *"ខ្ញុំជាមនុស្សដើរយឺត ប៉ុន្តែខ្ញុំក៏មិនដែលដើរថយក្រោយដែរ"*។

មនុស្សជោគជ័យ ជាបុគ្គលដែលមិននៅស្ងៀម បើទោះបីជាដើរលឿនខ្លះ ដើរយឺតខ្លះ បរាជ័យខ្លះ ជោគជ័យខ្លះ គឺធ្វើបែបណាឲ្យដល់គោលដៅ។ ខុសពីមនុស្សមានសមត្ថភាពខ្ពស់ តែពុំមានការអត់ធ្មត់ខ្ពស់ គ្មានការស៊ូទ្រាំខ្ពស់ចំពោះការលំបាក ឬឧបសគ្គ គឺចុងក្រោយនឹងមិនដល់គោលដៅ។ គ្មានបុគ្គលជោគជ័យណាម្នាក់អាចទទួលបានជោគជ័យនោះទេ បើគេសុខចិត្តចុះចាញ់នឹងឧបសគ្គ។

ភាពជោគជ័យកើតឡើងចេញពីភាពឆ្លាតត្រឹមតែមួយភាគរយប៉ុណ្ណោះ តែកៅសិបប្រាំបួនភាគរយទៀត គឺកើតចេញ

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

ពីសេចក្តីចេះអត់ធ្មត់ ព្យាយាម ប្រឹងប្រែង និងតស៊ូចំពោះការលំបាក។បុរាណខ្មែរបានពោលថា*"ចង់ឆ្ងាញ់ឲ្យរកអន្លក់ ចង់ស្រណុកឲ្យនឿយពីក្មេង"*។

សៀវភៅ *"ឪពុកអ្នកមានបង្រៀនកូនអ្នកក្រ"* បានលើកឡើងថា *"ចូរប្រឹងប្រែងធ្វើការងារក្នុងកំឡុងពេលយើងនៅមានវ័យក្មេង ដើម្បីជាការហាត់រៀនលត់ដំខ្លួន តែសូមកុំគិតតែពីរឿងចំណូលពេក"*។ នេះចង់មានន័យថា មនុស្សដែលមានវ័យនៅក្មេង គឺមានកម្លាំងកាយមាំមួន តែបើហត់នឿយបន្តិចបន្តួច អាចសម្រាកឲ្យមានថាមពលវិញក្នុងរយៈពេលខ្លីវិញ។

*"I walk slowly, but I never walk backward."*

Abraham Lincoln

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី១៥ ខែមិថុនា

សូក្រាត [ Socrates ] និយាយថា *"ខ្ញុំមិនដឹងអ្វីគ្រប់យ៉ាងទាំងអស់តែខ្ញុំដឹងតែម្យ៉ាងប៉ុណ្ណោះគឺខ្ញុំមិនចេះអ្វីទាំងអស់"* ។

មនុស្សប្រសើរ គឺជាបុគ្គលដែលចេះ តែមិនអួតខ្លួន។ ចំណែកឯបុគ្គលកម្សោយ គឺមិនចេះ ប៉ុន្តែតែងអួតខ្លួនឯង។ អ្នកចេះគ្មានទេភាពខ្សោយ ព្រោះគិតថាខ្លួនឯងខ្សោយ ។ ការគិតថាខ្លួនឯងខ្សោយ ទើបមិនកម្សោយ។ ការយល់ថាខ្លួនឯងខ្សោយ និងភាពស្ងប់ស្ងៀម គឺជាប្រភពនៃភាពរីកចម្រើន។ បិតារូបវិទ្យាស.វទី២០ អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] ពោលថា *"មូលដ្ឋានគ្រឹះនៃក្តីរីកចម្រើនគឺការមានជីវិតរស់នៅយ៉ាងស្ងប់ស្ងៀម"*។ ស្ងប់ស្ងៀមក្នុងន័យនេះ គឺចង់សំដៅឲ្យយើងមានសន្តិភាពចំពោះខ្លួនឯង ៕

# ថ្ងៃទី១៦ ខែមិថុនា

ឡៅ ជឺ [ Lao Tzu ] ពោលថា *"អ្នកប្រាជ្ញមិនយល់ថាខ្លួនឯងអស្ចារ្យរហូតគ្រប់ពេល ទើបអាចសម្រេចកិច្ចការធំដុំបាន"* ។ អតីតនាយករដ្ឋមន្ត្រីអង់គ្លេស លោក វីស្តុន ឆើឈីល [ Winston Churchill ] ពោលថា "មេរៀនអស្ចារ្យបំផុតក្នុងជីវិតមនុស្សយើង គឺការទទួលស្គាល់ថា សូម្បីតែមនុស្សល្ងង់ក៏គង់គិតត្រូវខ្លះ និយាយត្រូវខ្លះ និងធ្វើត្រូវខ្លះ ឬម្តងម្កាលដែរ"។

គតិបណ្ឌិតពិតប្រាកដ គឺកាទទួលដឹងថាខ្លួនឯងមិនទាន់ចេះអស់ រីឯចំណេះដឹងពិតប្រាកដ គឺជាការសិក្សាឥតឈប់ឈរ។ មនុស្សឆ្លាត កាន់តែរៀន កាន់តែយល់ថាខ្លួននៅខ្សត់ខ្សោយ តែមនុស្សល្ងង់មិនចង់រៀនបន្ត តែគិតថាខ្លួនឯងឆ្លាតគ្រប់គ្រាន់ហើយ។មានតែមនុស្សដែលយល់ថាខ្លួនឯងនៅចង់បន្តការរៀនជាប់ជានិច្ចប៉ុណ្ណោះ ដែលតែងតែយល់ថា ខ្លួនឯងនៅខ្សោយ។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

បិតាទស្សនៈវិជ្ជាក្រិច សូក្រាត [ Socrates ] ពោលថា " *ខ្ញុំមិនដឹងអ្វីគ្រប់យ៉ាងទាំងអស់ ខ្ញុំដឹងតែម្យ៉ាងប៉ុណ្ណោះ គឺខ្ញុំមិនចេះអ្វីទាំងអស់*"។ សូក្រាតចង់បញ្ជាក់ថា *"មនុស្សយើងដើម្បីអាចដឹងថាខ្លួនឯងមិនសូវចេះលុះត្រាតែមាននូវចំណេះដឹងច្រើន ពីព្រោះមានចំណេះដឹងច្រើន ទើបអាចដឹងថាខ្លួនឯងមិនសូវចេះ។ ផ្ទុយទៅវិញ អ្នកមិនសូវចេះពិតប្រាកដ តែងយល់ថាខ្លួនឯងចេះ*"៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

## ថ្ងៃទី១៧ ខែមិថុនា

*"មនុស្សក្នុងសង្គមមិនសូវផ្តល់ការគោរពគ្នា តាមបែបជាមនុស្សដូចគ្នាទេ តែតែងតែផ្តល់ការគោរពគ្នា ទៅវិញទៅមក តាមរយៈឋានៈសង្គម"។*

បើស្រមៃទៅលើទិដ្ឋភាពមួយ គឺអស់លុយអស់ការគោរព អស់ឋានៈ អស់អំណាច និងមានន័យថា អស់ការគោរព ឬសូម្បីតែមិត្តភក្តិម្នាក់ក៏មិនស្គាល់ថាយើងជានរណាផង។ ពេលយើងមានបាន មិត្តភក្តិ ឬអ្នកដទៃស្គាល់យើង។ ប៉ុន្តែបើយើងធ្លាក់ខ្លួន នោះយើងនឹងស្គាល់ពីចរិតពិតរបស់អ្នកទាំងនោះវិញជាក់ជាពុំខាន។ បិតារូបវិទ្យាស.វទី ២០ លោក អាល់ប៊ឺត អាញស្តា ញ [ Albert Einstein ] ផ្តល់ដំបូន្មានថាចូរ ឲ្យយើងចេះគោរពមនុស្ស ដោយនិយាយទៅកាន់មនុស្សគ្រប់គ្នាក្នុងឋានៈជាមនុស្សស្មើគ្នាមិនថាគេជាស្តេច មន្ត្រី នាយករដ្ឋមន្ត្រី អ្នកសុំទាន ឬជានរណានោះទេ៕

# ថ្ងៃទី១៨ ខែមិថុនា

ស៊ុន ជឺ [ Sun Tzu ] និយាយថា*"បើធ្វើឲ្យសត្រូវនៅទីភ្លឺ យើងត្រូវនៅទីងងឹត បើយើងប្រមូលផ្តុំកម្លាំង ត្រូវធ្វើឲ្យសត្រូវបំបែកកម្លាំងជាដប់ ប្រៀបដូចយើងយកដប់ទៅវាយមួយ នោះកម្លាំងសត្រូវតិច កម្លាំងយើងច្រើន"*។

ជ័យជម្នះ គឺមិនមែនបានដោយសារតែភាពខ្លាំងរបស់យើងទេ តែព្រោះតែភាពខ្សោយរបស់សត្រូវ។ ដើម្បីកម្ទេចសត្រូវ ឬកម្ទេចបញ្ហាក្នុងជីវិត គឺយើងត្រូវរង់ចាំដល់ខ្លួនយើងខ្លាំងសិន ឬក៏ត្រូវរង់ចាំដល់សត្រូវធ្លាក់ខ្លួនខ្សោយសិន។ ស្គាល់សមត្ថភាពខ្លួនឯង ស្គាល់សត្រូវ មានយុទ្ធសាស្ត្រខ្លាំង មានសិល្បៈអស្ចារ្យ ច្បាំង១០០ដង ឈ្នះ១០០ដង។ ជ័យជម្នះពិតប្រាកដ គឺការឈ្នះដោយមិនចាំបាច់ច្បាំង៕

# ថ្ងៃទី១៩ ខែមិថុនា

*"យើងគ្រប់គ្នា ត្រូវតែចេះរស់នៅក្នុងជីវិតមួយ ដែលជាគំរូល្អដល់មនុស្សជាច្រើន"។*

ពេលអានសម្រង់បញ្ញាមួយឃ្លាខាងលើ ក៏ធ្វើឲ្យខ្ញុំត្រូវចោទជាសំណួរថា *"ហេតុអ្វីអ្នកដឹកនាំក្នុងសង្គមខ្មែរខ្លះ ខ្សោយភាពជាអ្នកដឹកនាំខ្លាំងម្ល៉េះ?"* ពេលជួបជុំគ្នាពិសាស្រា ក៏ត្រូវថតរូបបង្ហាញមកកាន់សង្គមដែរ ឬ?

មេទ័ពក្លាហានម្នាក់ បង្កើតបានកូនទាហានអង់អាចរាប់រយនាក់ ហើយមេទ័ពកំសាកម្នាក់ ក៏នឹងបង្កើតកូនទាហានអន់រាប់រយនាក់។ ទឹកហូរពីលើចុះមកក្រោម, អ្នកល្ងង់រៀនតាមអ្នកចេះ, ហើយអ្នកតូច រៀនតាមអ្នកធំ។ ខ្ញុំនឹកឃើញដល់ដូនតាខ្មែរផ្ដាំថា "ពុតគ្រូ កុំគ្រាប់ ច្បាប់គ្រូឲ្យយក"។ ខ្ញុំនៅមិនទាន់យល់ស្របនឹងសុភាសិតនេះ ដោយសារវានៅមាន

មនុស្សខ្លះបកស្រាយបន្ថែមឲ្យត្រូវផងដែរ។ នៅក្នុងសៀវភៅទស្សនវិជ្ជាអប់រំរបស់ លី ក្វាន់យូ ដែលមានចំណងជើងថា *"Lee Kuan Yew's Educatinal Legacy"* បានអះអាងថា *"គ្រូបង្រៀន និងអ្នកដឹកនាំត្រូវតែមានទាំងទ្រឹស្តីល្អ ព្រមទាំងការអនុវត្តន៍ល្អផងដែរ ពីព្រោះដោយហេតុថាគ្រូបង្រៀន និងអ្នកដឹកនាំ គឺជាអ្នកដែលគ្រប់គ្នាយកគំរូតាម"*។

*"Each person must live their life as a model for others. "*-Angela Merkel.

# ថ្ងៃទី២០ ខែមិថុនា

តើនរណាជាមនុស្សឆ្កួត? អាល់ប៊ឺត អាញស្តាញ បានឲ្យនិយមន័យមនុស្សឆ្កួតថា *"ធ្វើរឿងដដែលៗ តែបែរជារំពឹងចង់បានលទ្ធផលខុសប្លែកពីមុន"*។ ប៊ីរ៉ង់ ខាទី បានឲ្យនិយមន័យមនុស្សឆ្កួតថា *"មនុស្សដែលយល់ថា អ្នកដទៃជាអ្នកបង្កបញ្ហាដល់ជីវិតខ្លួន គឺជាមនុស្សវិកលចរិត"*។

មនុស្សពេញលេញ គឺជាប្រភេទមនុស្សដែលចេះទទួលខុសត្រូវចំពោះជីវិតខ្លួន [ Response-able ] ហើយមនុស្សដែលមានការទទួលខុសត្រូវពិតប្រាកដ គឺជាមនុស្សដែលមិនសូវស្តីបន្ទោសគ្រប់យ៉ាងនៅជុំវិញខ្លួន។ ចូរធ្វើជាមនុស្សពេញលេញ ពីព្រោះមនុស្សពេញលេញតែងទទួលស្គាល់ថាខុសមួយថ្ងៃ មិនមែនមានន័យថាខុសមួយជីវិតនោះទេ៕

*"If I think that someone else is causing my problem, I'm insane."* Byron Katie.

# ថ្ងៃទី២១ ខែមិថុនា

*"ជីវិត គឺប្រៀបដូចជាការអុំទូកបញ្ច្រាស្រទឹកហូរ បើមិនប្រឹងប្រែងប្ដូរទេ គឺដំណើរទៅមុខ ឬថយក្រោយ ខ្សែទឹកហូរនឹងកំណត់សម្រេចព្រេងវាសនារបស់យើង"*។

ត្រីហែលបណ្ដោយទឹក ជាត្រីងាប់ ហើយមនុស្សណាដែលសុខចិត្តបណ្ដោយតាមព្រេងវាសនា គឺជាមនុស្សស្លាប់។ លើលោកយើងនេះពិតជាមានយុត្តិធម៌ ប៉ុន្តែគ្មានស្ដង់ដារយុត្តិធម៌ទេ។ បើជីវិតរស់នៅប្រឹងប្រែងច្រើន តែបានផលតិច ឬប្រឹងប្រែងតិច តែបានផលច្រើន ឬមិនប្រឹងប្រែងតែបានផលច្រើន នោះតើយើងត្រូវទៅស្វែងរកយុត្តិធម៌នៅទីណា។ យុត្តិធម៌ គឺប្រឹងប្រែងទាមទារ។ បើទោះបីជាទាមទារមិនបាន តែវាប្រសើរជាងនៅស្ងៀម ឬបើបានទាមទារខ្លះ ក៏គង់បានផលសម្រេចខ្លះ គឺសម្រេចពីមិនបានមកបានធម្មតា ឬពីបានធម្មតាមកបានល្អ ឬពីល្អមកល្អប្រសើរ៕

# ថ្ងៃទី២២ ខែមិថុនា

*"  គ្រប់វត្ថុទាំងអស់ក្នុងលោកសុទ្ធតែមានពីរផ្នែកជាគូនឹងគ្នា ។ គ្រប់គ្នាដឹងថាភាពស្អាតជាភាពស្អាត ពីព្រោះមានភាពមិនស្អាតជាគូ ហើយសេចក្ដីល្អជាសេចក្ដីល្អ ពីព្រោះមានសេចក្ដីអាក្រក់ជាគូ" ។*

បុគ្គលឈ្លោះជាមួយបណ្ឌិត គេហៅថាជនជនពាល ។ បុគ្គលណាប្រឆាំងនឹងទង្វើល្អ គេហៅមនុស្សអាក្រក់ ។ បុគ្គលគិតប្រយោជន៍សួនតួ គេហៅមនុស្សអាត្មានិយម ។ ក្នុងលោកយើងនេះ គ្រប់យ៉ាងគ្រាន់តែជាការផ្លាស់ប្ដូរវេនគ្នាជានិច្ច គឺប្រៀបដូចជាព្រះសុរិយាចន្ទ្រា បន្ទាប់ពីយប់គឺថ្ងៃ ឬប្រៀបដូចជោគជ័យបន្ទាប់ពីបរាជ័យ ឬប្រៀបដូចកោសិការាងកាយមនុស្សកើតបន្ទាប់ពីស្លាប់ ជាដើម ៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី២៣ ខែមិថុនា

*"បរាជ័យជាផ្នែកមួយនៃជីវិត ពីព្រោះបើយើងមិនធ្លាប់ចាញ់ គឺយើងក៏មិនមានមេរៀនសម្រាប់ជីវិត ហើយបើយើងគ្មានមេរៀនធ្លាប់ចាញ់ក្នុងជីវិត គឺយើងក៏នឹងគ្មានការផ្លាស់ប្តូរឡើយ"។*

ជោគជ័យ ឬបរាជ័យមិនមែនជាគោលដៅចុងបញ្ចប់ ប៉ុន្តែគ្រប់យ៉ាងគ្រាន់តែជាដំណើរឥតឈប់គ្មានទីបញ្ចប់ប៉ុណ្ណោះ ។ បើជោគជ័យលើកទីមួយ សូមប្រឹងផ្តើមយកជ័យជាលើកទីពីរ តែបើបរាជ័យលើកទីមួយ សូមប្រឹងប្រែងសាកល្បងជាលើកទីពីរ គឺប្រឹងប្រែងរហូតដល់ញើសពណ៌សក្លាយទៅជាញើសពណ៌ក្រហម។ គ្រប់យ៉ាងនឹងទៅជាល្អទាំងអស់នៅទីបញ្ចប់ តែបើមិនទាន់ល្អនៅឡើយទេ គឺគ្រាន់តែមានន័យថាមិនទាន់ដល់ទីបញ្ចប់ប៉ុណ្ណោះ។ បើមិនទាន់ចប់ គឺគ្រាន់តែតម្រូវឲ្យយើងប្រឹងឲ្យដល់ទីបញ្ចប់៕

# ថ្ងៃទី២៤ ខែមិថុនា

*"ធាតុផ្សំនៃជោគជ័យ គឺបរាជ័យ ធាតុផ្សំនៃភាពជាអ្នកឈ្នះ គឺចាញ់ ធាតុផ្សំនៃការទទួល គឺការឲ្យ ហើយធាតុផ្សំនៃភាពជាគ្រូ គឺសិស្ស"។*

ដើម្បីជោគជ័យកាន់តែច្រើន គឺត្រូវបង្កើនភាពបរាជ័យឲ្យកាន់តែច្រើន។ ដើម្បីអាចក្លាយជាអ្នកឈ្នះ គឺទាល់តែធ្លាប់មានបទពិសោធន៍ជាអ្នកចាញ់។ ដើម្បីអាចទទួល គឺទាល់តែធ្លាប់ឲ្យ ហើយការធ្វើជាអ្នកបង្រៀន គឺប្រៀបដូចជារៀនខ្លួនឯងដែរ។ យើងអាចមានគ្រប់យ៉ាងក្នុងជីវិតទៅបានលុះត្រាតែយើងហ៊ានជួយអ្នកដទៃឲ្យមានបានជាមុនសិន។ ការរស់នៅដោយមានបានគ្រប់យ៉ាងដោយគ្មានការអបអរសាទរ ឬគ្មានមនុស្សណាម្នាក់នៅក្បែរ គឺប្រៀបដូចនឹងការបរាជ័យ។

ជីវិតដែលមានតម្លៃច្រើន គឺជាជីវិតដែលចេះបំពេញសេចក្តីត្រូវការដល់អ្នកដទៃឲ្យកាន់តែច្រើន។ ការអាចបំពេញនូវសេចក្តីត្រូវការដល់អ្នកដទៃទៅបាន លុះត្រាតែមានសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ។ សេចក្តីស្រឡាញ់ គឺជាអ្វីគ្រប់យ៉ាង៕

*"You can have everything in life that you want if you just give enough other people what they want."* - Zig Ziglar

# ថ្ងៃទី២៥ ខែមិថុនា

*"មនុស្សខ្លះឲ្យតម្លៃលើមាសប្រាក់ ដោយប្រឹងស្វែងរកទ្រព្យ ដូចជាពួកគេត្រូវយកទ្រព្យទៅជាមួយពេលស្លាប់អ៊ីចឹង"* ។

អ្នកខ្លះទៀតប្រឹងចាយវាយខ្ជីខ្ជាឥតគិត ដូចគេត្រូវស្លាប់នៅថ្ងៃស្អែកអ៊ីចឹង។ ដោយសារតែ អាល់ បឺត អាញស្តាញ់ [ Albert Einstein ] មើលឃើញថាមនុស្សកាន់តែជោគជ័យ គឺកាន់តែបំផ្លាញសង្គមដោយសមត្ថភាពរបស់ខ្លួន ទើបគាត់និយាយថា *"ចូរធ្វើជាមនុស្សមានតម្លៃ ប្រសើរជាងធ្វើជាមនុស្សជោគជ័យ"*។

ជនខ្លះធ្វើជំនួញក្រោមស្លាកសាសនា គេងចំណេញគ្រប់វេលា ឈ្មោះជាសាសនិកមានជំនឿស៊ប់ ប៉ុន្តែបែរជាគ្មានចិត្តសប្បុរសធម៌សូម្បីបន្តិច។

ដូចជាសម្តី មហាត្មៈ គន្ធី [ Mahatma Gandhi ] ពោលថា "សាសនា ដោយគ្មានពលិកម្ម ឬ Religion Without Sacrifice"។ ទាំងភាពឆ្លាត និងកិត្តិយសមនុស្ស គឺថារកកន្លែងឲ្យតម្លៃមិនឃើញ បើគ្មានមនុស្សធម៌ក្រៅពីសន្តានចិត្តសប្បុរស និងក្តីសង្គ្រោះជនទន់ខ្សោយទេ៕

# ថ្ងៃទី២៦ខែមិថុនា

*"មនុស្សអាក្រក់មើលឃើញរឿងល្អថាគ្មានប្រយោជន៍ អ៊ីចឹងខ្លួនក៏ជ្រើសរើសយកទង្វើអាក្រក់ ហើយបោះបង់ចោលការប្រព្រឹត្តទង្វើល្អ"*។

មនុស្សល្អមើលឃើញរឿងអាក្រក់ថាគ្មានប្រយោជន៍ អ៊ីចឹងខ្លួនក៏ជ្រើសរើសយកទង្វើល្អ ហើយបោះបង់ចោលការប្រព្រឹត្តទង្វើអាក្រក់។ មនុស្សល្អតែងតែគាំទ្រទង្វើល្អ មនុស្សអាក្រក់តែងតែគាំទ្រទង្វើអាក្រក់។ អ្នកនិពន្ធ រ៉ាហ្វ វ៉ាល់ដូ អេម័រសោន់ [ Ralph Waldo Emerson ] ពោលថា *"មនុស្សលោកយើងប្រហែលជាមិនដឹងទេថា គំនិតទស្សនៈរបស់ខ្លួនចំពោះពិលោក គឺជាការសារភាពទទួលយកចរិតលក្ខណៈរបស់ខ្លួន"*។ ដូច្នេះ បើយើងចង់ដឹងមនុស្សល្អឬអាក្រក់ គឺយើងគ្រាន់តែមើលលើទង្វើនៃការគាំទ្ររបស់គេលើអ្វីមួយ ក៏ល្មមអាចឲ្យយើងកំណត់សន្និដ្ឋានយកថាបុគ្គលនោះជាមនុស្សប្រភេទណា៕

# ថ្ងៃទី២៧ខែមិថុនា

រ៉ាហ្វ វ៉ាល់ដូ អេម័រសោន់ [ Ralph Waldo Emerson ] ពោលថា*"បុគ្គលឆ្នើម គឺជាអ្នកដែលបានមើលឃើញថា កម្លាំងនៃគំនិតមានអនុភាពខ្លាំងក្លា ជាងកម្លាំងនៃរាងកាយ ហើយកម្លាំងនៃគំនិត គឺជាអ្វីដែលគ្រប់គ្រងពិភពលោកទាំងមូល"*។

បើយើងចង់ផ្លាស់ប្តូរជីវិតរបស់យើង ចូរយើងចាប់ផ្តើមផ្លាស់ប្តូរការគិតរបស់យើងភ្លាមពីពេលនេះទៅ ពីឥឡូវនេះតទៅ ហើយសូមកុំនៅបង្អស់យូរឲ្យសោះ៕

William James of Harvard University said, *"If you are going to change your life, you need to start immediately and do it flamboyantly."*

# ថ្ងៃទី២៨ខែមិថុនា

*"ផ្លូវកាត់ ភាគច្រើនសុទ្ធតែនាំឲ្យមនុស្សដើរទៅដល់ភាពបរាជ័យ និងក្តីអន្តរាយមុនគេ"។*

ច្បាប់កម្មផល ឬច្បាប់នៃការសាបព្រោះ និងច្បាប់ប្រមូលផល [ The Law of Cause and Effect ] បានលើកឡើងថា *"កាលណាយើងបង្កើតគំនិតមួយ នោះយើងនឹងទទួលបានសកម្មភាពមួយ។ យើងបង្កើតសកម្មភាពមួយ នោះយើងនឹងទទួលបានទម្លាប់មួយ។ យើងបង្កើតទម្លាប់មួយ នោះយើងនឹងទទួលបានចរិតលក្ខណៈមួយ។ យើងបង្កើតចរិតលក្ខណៈមួយ នោះវានឹងកំណត់ជីវិតរបស់យើង"។*

បុរសដែលចង់សារភាពស្នេហាដល់នារីម្នាក់ ដោយភាពតក់ក្រហល់ ឬចង់បានដួចចិត្តដោយខ្វះការអត់ធ្មត់ នឹងទទួលបានត្រឹមការបដិសេធ។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

កសិករចង់ប្រមូលផលស្រូវដោយមិនបានសាបព្រោះ មិនបានដកស្ទូង គឺផ្ទុយនឹងច្បាប់ធម្មជាតិ។ ការចង់មានចង់បានដោយមិនប្រឹងប្រែងរក គឺជាគំនិតល្ងង់ ហើយការចង់ចេះចង់ដឹងដោយមិនចំណាយពេលវេលារៀនសូត្រ គឺជាគំនិតល្ងង់។ ជីវិតគឺជាជម្រើស ហើយដើម្បីជ្រើសបានល្អ គឺយើងចេះអត់ធ្មត់។

ការចេះអត់ធ្មត់ គឺផ្ទុយនឹងភាពខ្ជិលច្រអូស ពីព្រោះការចេះអត់ធ្មត់ គឺអត់ធ្មត់ដោយមានគោលដៅ និងប្រឹងប្រែងដើម្បីសម្រេចគោលដៅ។ ការចេះអត់ធ្មត់ និងពេលវេលានឹងមិនអាចឲ្យយើងបានវត្ថុល្អភ្លាម តែអាចបានវត្ថុល្អជាងពេលក្រោយ ឬមិនអាចបានវត្ថុល្អជាងភ្លាម តែអាចបានវត្ថុល្អបំផុតពេលក្រោយ៕

# ថ្ងៃទី២៩ខែមិថុនា

*"យើងត្រូវប្រើប្រពន្ធ័គ្រប់គ្រងល្អ ដើម្បីតម្រង់ទិសមនុស្ស។ ដើម្បីដឹកនាំការងារ ឬសង្គមមួយឲ្យមានប្រសិទ្ធិភាព គឺជាការចាំបាច់ដែលត្រូវការរបៀប ឬវិធីសាស្ត្រគ្រប់គ្រងល្អ"។*

បើទោះបីជាមនុស្សល្អយ៉ាងណាក៏ដោយ តែបើរបៀបគ្រប់គ្រងមិនល្អ ក៏គ្មានប្រសិទ្ធិភាពដែរ។ របៀបគ្រប់គ្រងមិនល្អអាចជំរុញមនុស្សល្អ ឲ្យក្លាយទៅជាមនុស្សមិនល្អបាន តែរបៀបគ្រប់គ្រងល្អអាចតម្រង់ និងបង្ខំមនុស្សមិនល្អឲ្យចូលគន្លងល្អបាន។ ដល់ថ្ងៃនេះទើបខ្ញុំដឹងថា "ហេតុអ្វីបានជាលោក ភីទ័រ ដ្រ័កគ័រ [ Peter F. Drucker ] អាចបង្កើតឲ្យមានការដឹកនាំដ៏អស្ចារ្យរហូតទទួលនាមថាជា *"បិតាទស្សនៈវិជ្ជាគ្រប់គ្រង"*៕

# ថ្ងៃទី៣០ ខែមិថុនា

បិនចាមិន ហ្វ្រេងឃ្លីន [ Benjamin Franklin ] ពោលថា *"ធ្វើជាមនុស្សល្ងង់ខ្លៅដោយមិនចេះធ្វើអ្វីសោះ គឺវាមិនអាម៉ាស់មុខ ដូចមនុស្សដែលគ្មានឆន្ទៈក្នុងការរៀននោះទេ"។*

ការចេះស្រេពិចស្រេពិល ចេះមិនច្បាស់លាស់ គឺមិនមែនបណ្តាលមកពីការអប់រំទេ តែវាបណ្តាលមកពីការព្រងើយកន្តើយមិនចង់រៀន។ ការទុកចិត្តខ្លួនឯងជ្រុលរបស់មនុស្សអប្បប្រាជ្ញា គឺស្តែងចេញតាមរបៀបចម្លែកខុសគេបែបល្ងង់ខ្លៅ។ភាពល្ងង់ខ្លៅរបស់មនុស្សយើងមិនមែនជាកំហុសធ្ងន់ទេ តែយើងបង្កើតភាពល្ងង់ខ្លៅជាអាជីពទើបជាកំហុសធ្ងន់៕

Being ignorant is not so much a shame as being unwilling to learn to do things the right way.

- Benjamin Franklin.

## ទស្សនៈសម្រាប់ខែ

# កក្កដា

# ថ្ងៃទី០១ ខែកក្កដា

ទ្រឹស្តីសម្ពន្ធភាពរបស់លោក អាល់ប៊ឺត អាញស្តាញ [ Albert Eistein's theory of relativity ] បានពន្យល់ប្រាប់ថា *"អំណាចនៃគំនិតចេញជាលទ្ធផលទៅបាន កាលណាគំនិតនោះវាដើរចេញពីភាពអរូបីយទៅកាន់ការអនុវត្តន៍ជាក់ស្តែង"*។

ជាទូទៅយើងតែងនាំគ្នានិយាយតៗគ្នាថា "ចំណេះដឹង គឺជាអំណាច"។ ប៉ុន្តែគំនិតនេះត្រឹមត្រូវទៅបាន លុះត្រាតែចំណេះដឹងទាំងមូល អាចដើរចេញពីភាពអរូបីយទៅជាសកម្មភាពអនុវត្តន៍ជាក់ស្តែង នោះទើបហៅថាអំណាចពិតប្រាកដ។ ម្យ៉ាងទៀត ខ្ញុំបានឃើញអ្នកចេះដឹងខ្លះ គ្មានអំណាចទាល់សោះ។ គំនិតដែលល្អប្រសើរ ត្រូវមានល្បឿនចុះចត និងស្លាប ហើយគំនិតដែលនៅ តែជាគំនិត ពុំអាចមានឥទ្ធិពលល្អប្រសើរឡើយ។ គំនិតត្រឹមត្រូវ បូកជាមួយមនុស្សត្រឹមត្រូវ នៅក្នុងបរិយាកាសត្រឹមត្រូវ កាលទេសត្រូវ

ដើម្បីបុព្វហេតុត្រឹមត្រូវ គឺស្មើនឹងលទ្ធផលត្រឹមត្រូវ។

អាល់ប៊ឺត អាញស្តាញ បាននិយាយទៀតថា *"អ្នកដែលនិយាយថាការគិតមិនលំបាក គឺអ្នកនោះពុំដែលធ្លាប់បានគិតទេ"*។ សមាជិកព្រឹទ្ធសភាអាមេរិកម្នាក់និយាយថា *"រៀនសរសេរ គឺរៀនគិត ព្រោះយើងពុំអាចដឹងអ្វីឲ្យច្បាស់លាស់នោះទេ លុះត្រាតែយើងអាចថ្លែងចេញជាការសរសេរ"*។

ក្នុងតថភាពជាក់ស្តែងនៃប្រព័ន្ធអប់រំ ចំណេះដឹងតិចតួច គឺពិតជាមានគ្រោះថ្នាក់ខ្លាំងណាស់ តែវារឹងរឹតតែគ្រោះថ្នាក់ពេលដែលមនុស្សយើងល្ងង់ ពីព្រោះភាពល្ងង់នឹងនាំឲ្យមានការវិនាសអន្តរាយដល់ខ្លួន និងសង្គម។ ចំណេះដឹងងាយស្រួលរក បើមានការប្រឹងប្រែងជាប្រក្រតី តែបើសាបព្រោះចំណេះដឹងខុសប្រក្រតីដល់មនុស្សខុស ឬសាបព្រោះចំណេះដឹងដល់មនុស្សអាក្រក់ គឺប្រៀបបាននឹងការសាបព្រោះគ្រោះភ័យដល់សង្គមទាំងមូល៕

# ថ្ងៃទី០២ ខែកក្កដា

ហឺនរី ហ្វត [ Henry Ford ] ពោលថា"ឧបសគ្គទាំងឡាយ គឺជារឿងរ៉ាវទាំងឡាយគួរឲ្យភ័យខ្លាច នៅពេលដែលយើង បានចោលក្រសែភ្នែកចេញឆ្ងាយពីគោលដៅ"។

មានគោលដៅដោយគ្មានសកម្មភាព ប្រៀបបាននឹងការ ស្រមើស្រមៃដោយគ្មានឃើញអ្វីទាំងអស់ ហើយសកម្មភាព ទាំងឡាយប្រែក្លាយសុបិនឲ្យទៅជាគោលដៅ។ ទោះបីជា យើងបរាជ័យលើគោលដៅក៏ដោយ តែមិនអាចធ្វើឲ្យយើង វង្វេងរបួសនោះទេ ឬការមិនទាន់ទៅដល់គោលដៅ មិនមែន មានន័យថាយើងសុខចិត្តចុះចាញ់ឯណា គ្រាន់តែជាសញ្ញា វិជ្ជមានមួយដែលក្រើនរំលឹកឲ្យយើង រៀបចំផែនការម្តង ទៀតលើគោលដៅតែមួយប៉ុណ្ណោះ៕

"Obstacles are those frightful things you see when you take your eyes off your goal." - Henry Ford

# ថ្ងៃទី០៣ ខែកក្កដា

ថូម៉ាស់ វូ្រ៊ូ វ៉ុលសិន [ Thomas Woodrow Wilson ] ពោលថា *"ខ្ញុំសុខចិត្តបរាជ័យក្នុងពេលនេះ ដើម្បីបុព្វហេតុមួយ ដែលនឹងធ្វើឲ្យខ្ញុំទទួលបានជោគជ័យនៅពេលក្រោយ ប្រសើរជាងជោគជ័យក្នុងពេលនេះ ដែលធ្វើឲ្យខ្ញុំបរាជ័យនៅពេលក្រោយ"*។

យើងមិនអាចជួយខ្លួនឯងដោយមិនគិតខ្វល់ខ្វាយពីអ្នកដទៃនោះទេ។ យើងមិនអាចធ្វើឲ្យជីវិតយើងល្អប្រសើរដោយទុកឲ្យអ្នកដទៃឲ្យលំបាកវេទនានោះទេ ហើយយើងក៏មិនអាចធ្វើឲ្យខ្លួនឯងចម្រុងចម្រើនបាន ដោយទុកឲ្យអ្នកដទៃក្រតោកយ៉ាកដែរ។ មនុស្សដែលចេះ "ឲ្យ" គឺរសមានកិត្តិយសជាងអ្នកដែលចេះត្រឹមតែ "ទទួល" ហើយអ្នកដែលចេះចែករំលែកដល់អ្នកដទៃ ក៏នឹងគេងលក់ស្កប់ស្រួលនៅពេលយប់៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

*"I would rather fail in a cause that will ultimately succeed than succeed in a cause that would ultimately fail. "* - Thomas Woodrow Wilson.

# ថ្ងៃទី០៤ ខែកក្កដា

ស៊ីវ ខេរ៉ា [ Shiv Kera ] ពោលថា *"ចូរចងចាំថា អ្នកចាញ់ប្រើវិធីតែមួយ ដើម្បីធ្វើរឿងជាច្រើន ប៉ុន្តែអ្នកឈ្នះវិញ គឺប្រើវិធីជាច្រើន ដើម្បីធ្វើកិច្ចការមួយឲ្យសម្រេច"*។

អ្នកឈ្នះមិនដែលបោះបង់ អ្នកបោះបង់មិនដែលឈ្នះ។ អ្នកជោគជ័យមិនប្តូរគោលដៅ អ្នកប្តូរគោលដៅនឹងមិនស្គាល់ភាពជោគជ័យ។ បិតារូបវិទ្យាស.វទី២០ អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] បានក្រាញរនៀលនឹងបញ្ហារហូតដល់ចុងបញ្ចប់ទទួលជោគជ័យ ហើយបាននិយាយថា *"យើងមិនអាចដោះស្រាយបញ្ហាជាច្រើនបានក្នុងរបៀបនៃការគិតតែមួយ ឬរបៀបនៃការគិតងាប់ក្រឡាតែម៉្យាងនោះទេ។ ខ្ញុំបានព្យាយាមធ្វើកិច្ចការលំបាកបំផុតចំនួន ៩៩លើក ហើយលើកទី១០០ ខ្ញុំក៏បានទទួលជោគជ័យ"*។

មនុស្សបរាជ័យ ធ្វើកិច្ចការងារទីមួយបរាជ័យដោយប្រើវិធីខ្ជិល ឬខ្វះសេចក្ដីអំណត់ បន្ទាប់មក គេក៏យកទម្លាប់នៃភាពខ្ជិលច្រអូស ឬខ្វះសេចក្ដីអំណត់ទៅធ្វើកិច្ចការងារទីពីរ ហើយបន្ទាប់មកទៀត ក៏យកទម្លាប់ខ្ជិលច្រអូសឬខ្វះសេចក្ដីអំណត់ទៅធ្វើការងារទីបី ៕

Remember, winners don't do different things, they do things differently. Shiv Khera

# ថ្ងៃទី០៥ ខែកក្កដា

*"កែវភ្នែករបស់យើង នឹងមិនប្រមើលមើលវត្ថុសព្វសារពើតាមរបៀបនៃការឃើញ និងរបៀបនៃការគិតរបស់អ្នកដទៃនោះទេ តែយើងមើល និងគិតពិចារណាគ្រប់យ៉ាងតាមរបៀបផ្ទាល់របស់យើង"*។

ស្ថាបនិកក្រុមក្រុមហ្វតម៉ូតូ លោកហឺនរី ហ្វត [ Henry Ford ] ពោលថា *"មិនថាយើងគិតថាខ្លួនឯងអាច ឬមិនមិនអាច ឬមិនថាយើងគិតបែបណានោះទេ ប៉ុន្តែយើងនៅតែស្ថិតក្នុងលក្ខណៈត្រឹមត្រូវទាំងអស់"*។ ក្នុងទ្រឹស្តីនៃច្បាប់នៃការស្រូបទាញ ឬ The Law of Attraction បានពន្យល់ឲ្យយើងគិតវិជ្ជមាន និងគិតដោយប្រុងប្រយ័ត្នក្នុងគំនិតខ្លួនឯង ពីព្រោះគ្រប់យ៉ាងសុទ្ធតែនឹងក្លាយទៅជាការពិតតាមរបៀបនៃស្ថានភាពខ្លួនយើង។

បុរាណខ្មែរបានផ្តាំទុកមកថា *"នៅម្នាក់ឯងឲ្យប្រយ័ត្នការគិត ហើយនៅជាមួយមិត្តឲ្យប្រយ័ត្នសម្តី"*៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី០៦ ខែកក្កដា

អ្នកនិពន្ធរឿងព្រេងនិទានក្រិច [ Aesop's Fables ] ពោលថា *"សាមគ្គីរស់ បែកបាក់សាមគ្គីស្លាប់"*។ ទ្រឹស្ដី *"ត្រីមួយត្រក បើស្អុយមួយ គឺស្អុយទាំងអស់"* គឺប្រៀបដូចជាការបញ្ឆោះកំហឹងមនុស្សល្អឲ្យចេះតស៊ូរកភាពត្រឹមត្រូវឲ្យខ្លួនឯង ពីព្រោះថាត្រីនិងមនុស្សមិនដូចគ្នាទេ។ ការឈ្លោះប្រកែកនឹងនាំបង្កើតការបែកបាក់សាមគ្គី។

ក្នុងសម័យរបបប្រល័យពូជសាសន៍ប៉ុលពត គេអប់រំសមមិត្ត [ Comrade ] ថា *"គោរពព្រះពុទ្ធ ដូចគោរពស៊ីម៉ងត៍ ហើយគោរពព្រះសង្ឃ ដូចគោរពក្បាលជង្គង់"*។ សម័យស.វទី២១ គេប្រើពាក្យចំអន់ថា *"អនុមោទនា អនុមោទនា បានលុយចែកគ្នា ព្រះវិហារនៅដដែល ឬអាចោរថង់យាម"*។ ម្ដាយឪពុកតែងនិយាយថា *"មានកូនប្រុស ប្រៀបដូចព្រាយក្បាលប្រាំបី ឯមានកូនស្រី ប្រៀបដូចក្រឡប្រហុក"*។ *"United we stand; divided we fall."*- Aesop

# ថ្ងៃទី០៧ ខែកក្កដា

ម៉ាក្ស ធ្វីន [ Mark Twain ] ពោលថា "*ភាពភ័យខ្លាចចំពោះការស្លាប់ កើតចេញពីភាពភ័យខ្លាចចំពោះការរស់រៀនមានជីវិត ហើយមនុស្សដែលរស់នៅដោយពេញលេញ គឺតែងតែត្រៀមខ្លួនរួចជាស្រេចសម្រាប់សេចក្តីស្លាប់*"។

ធម្មជាតិ បង្កើតមនុស្សផង និងសម្លាប់មនុស្សផង។ បើមិនចង់ស្លាប់ លុះត្រាតែកុំកើត តែបើកើតជាមនុស្សពេលនេះនោះអនាគតនឹងចាស់ហើយគង់នឹងស្លាប់ក្លាយទៅជាខ្មោច ។ មានតែគំនិតមនុស្សប៉ុណ្ណោះ ដែលមិនចេះស្លាប់ដូចរាងកាយមនុស្ស។ ចូរធ្វើល្អឲ្យច្រើន ជាងធ្វើអាក្រក់។ ចូរស្រឡាញ់ឲ្យច្រើនជាងស្អប់។ ចូរធ្វើឲ្យច្រើនជាងនិយាយ៕

The fear of death follows from the fear of life. A man who lives fully is prepared to die at any time.

- Mark Twin

# ថ្ងៃទី០៨ ខែកក្កដា

ស្ហូរិន កៀកឺហ្កាដ [ Soren Kierkegaard ] ពោលថា *"ក្នុងអំឡុងពេលកំណើតនៃមនុស្សជាតិ មហាគ្រោះធំបំផុតរបស់ពួកគេ គឺការមិនហ៊ានប្រថុយយកឈ្នះគ្រោះភ័យ"*។

បញ្ហា ជាអ្នកបង្កើតបញ្ញា ឧបសគ្គគឺជាអ្នកបង្កើតសមត្ថភាព សមត្ថភាព ការបរាជ័យគឺជាអ្នកបង្កើតភាពស្ទាត់ជំនាញ។ ចំណែកឯការតស៊ូ គឺជាអ្នកដែលបង្កើតឲ្យមានភាពប៉ិនប្រសព្វ ឬទេព្យកុសល្យ។ ភាពគ្រោះថ្នាក់ និងភាពគ្មានគ្រោះថ្នាក់អាចជាការសាកល្បង ចំពោះសមត្ថភាពរបស់យើងថា តើយើងហ៊ាន ឬខ្លាច? ឬ តើយើងជាមនុស្សខ្លាំងឬខ្សោយ?

យើងប្រហែលជាមិនភ្លេចទេថា ក្នុងបញ្ហាតែងមានឱកាស ឬក្នុងឱកាស ក៏គង់តែមានបញ្ហាដែរ។ គ្រប់យ៉ាងមើលមិន

ដឹងទេ តែអ្វីដែល ធ្វើឲ្យយើងអាចដឹងច្បាស់បាន គឺថាបើប្រឹងកាន់តែខ្លាំង ភាពជោគជ័យក៏មានភាគរយច្រើន តែបើមិនប្រឹងសោះ គឺសូម្បីតែមេរៀន ឬបទពិសោធន៍ល្អ អាក្រក់បែបណា ក៏យើងគ្មានឱកាសភ្លក្សរសជាតិដែរ។

ដូច្នេះ កុំខ្លាច ពីព្រោះបើខ្លាច គឺស្មើនឹងបរាជ័យរហូត។ មនុស្សដែលភ័យចំពោះខ្លាចបរាជ័យ គឺមានន័យថាគេបានបរាជ័យរួចទៅហើយ៕

"During the first period of a man's life the greatest danger is not to take the risk."- Soren Kierkegaard.

# ថ្ងៃទី០៩ ខែកក្កដា

ចាស់បុរាណខ្មែរទូន្មានថា "នឿយមុន ស្រណុកក្រោយ ឬចង់ឆ្ងាញ់ឲ្យរកអន្លក់ ចង់ស្រណុកឲ្យនឿយពីក្មេង ឬចង់ចេះឲ្យប្រឹងរៀន ចង់មានឲ្យប្រឹងរក"។ កាលពីព្រេងនាយ មានសត្វក្រួចកម្ទិលមួយក្បាល បានសុខចិត្តដោះដូររោមរបស់ខ្លួននឹងចំណីធីស្រាប់ ដោយមិនចាំបាច់បញ្ចេញកម្លាំងពលកម្ម។ជារៀងរាល់ថ្ងៃរោមរបស់សត្វក្រួចកម្ទិលត្រូវបានដកដើម្បីដូរនឹងចំណី។ លុះដល់ចុងក្រោយ វាក៏បានស្លាប់មុនកាលកំណត់ដោយសារអស់រោមពីខ្លួន។

ក្នុងព្រេងនិទានខ្មែរ គេបាននិទានពីសត្វឆ្កែ ឬសត្វសុនខដែលបានសួរទៅគោថា *"ដើម្បីបានបាយធី តើគេត្រូវធ្វើយ៉ាងដូចម្ដេច?"* សត្វគោឆ្លើយតបថា *"ដើម្បីបានអាហារធី គេត្រូវភ្ជួររាស់ស្រែ រាស់ដី។ និងបន្ទាប់មកយកទៅដាំបាយ ...។"* សត្វឆ្កែយល់ថាជាការងារដ៏លំបាកស្មុគស្មាញណាស់

អ៊ីចឹងក៏បានសម្រេចចិត្តធ្វើជា សត្វឆ្កែយាមផ្ទះធ្វើកញ្ជះរបស់មនុស្ស ដែលចាំស៊ីតែអាហារកាកសំណល់អស់មួយជីវិតឬដល់ពេលខ្លះមនុស្សមើលងាយថា"*អាឆ្កែអង្គែស៊ី*"។

# ថ្ងៃទី១០ ខែកក្កដា

ជីម រ៉ូន [ Jim Rohn ] ពោលថា *"វិបត្តិសេដ្ឋកិច្ច ឬមហន្តរាយផ្នែកសេដ្ឋកិច្ច នឹងផ្តើមកើតឡើង ចំពោះស្ថានភាពទស្សនៈគំនិតដែលគិតតែ (ចង់បានច្រើន) តែបែរជាប្រឹងប្រែងធ្វើសកម្មភាព (តិចតួច) ទៅវិញ"*។

ចាស់បុរាណខ្មែរទូន្មានថា *"នឿយមុន ស្រណុកក្រោយ ឬចង់ឆ្ងាញ់ឲ្យរកអន្លក់ ចង់ស្រណុកឲ្យនឿយពីក្មេង ឬចង់ចេះឲ្យប្រឹងរៀនចង់មានឲ្យប្រឹងរក"*។មនុស្សដែលអវិជ្ជានឹងបង្កើតបង្កើតត្រឹមតែការច្រណែន គឺមានន័យមានន័យថា ចិត្តពិតជាចង់ចេះដឹង តែបែរជាខ្ជិលរៀន។ មនុស្សអទ្រព្យធននឹងបង្កើតត្រឹមតែការច្រណែន គឺមានន័យថា ចង់មានបានដូចគេឯង តែបែរជាខ្ជិលរក។ មនុស្សយើងបើជ្រើសរើសរវាងវិជ្ជាសម្បត្តិ និងទ្រព្យសម្បត្តិ គេគួរជ្រើសរើសយកវិជ្ជាសម្បត្តិ ពីព្រោះវិជ្ជាសម្បត្តិ គឺជាប្រភពនៃគ្រប់យ៉ាងក្នុងលោក។

បើរៀបការជាមួយមហាសេដ្ឋី នោះយើងនឹងអាចក្លាយខ្លួនជាសេដ្ឋី តែបើរៀបការជាមួយបណ្ឌិត នោះនឹងមិនអាចឲ្យយើងក្លាយជាបណ្ឌិតបានទេ បើយើងមិនប្រឹងប្រែងរៀន។ និយាយដល់រឿងប្រាក់កាស អ្នកមាន និងអ្នកក្រតែងមានការរិះគន់គ្នាទៅវិញទៅមកដោយលើកឡើងថា "អ្នកមានខ្លះប្រឹងប្រែងរកប្រាក់កាស ប្រៀបដូចខ្លួនឯងនឹងត្រូវរស់នៅជាអមតៈ រីឯអ្នកក្រខ្លះខ្ជិលច្រអូសរៀបចំរកទ្រព្យទុកដាក់ ប្រៀបដូចខ្លួនឯងនឹងស្លាប់ទៅវិញនៅថ្ងៃស្អែក"។

# ថ្ងៃទី១១ ខែកក្កដា

ក្នុងទ្រឹស្តីសាសនា *"មនុស្សស្លាប់នៅពេលគេងលក់ តែរស់ឡើងវិញនៅពេលភ្ញាក់ពីគេង"*។

មានអ្នកប្រាជ្ញបុរាណសម័យម្នាក់ពោលថា *"មនុស្សយើងត្រូវចេះស្រូបយកពន្លឺពណ៌សនៃព្រះអាទិត្យរះ និងត្រូវចេះស្រូបយកពន្លឺពណ៌ក្រហមនៃព្រះអាទិត្រលិចទៅវិញ"*។

មនុស្សដែលឆ្លាត គឺជាបុគ្គលដែលចេះប្រើពេលវេលាពាក់កណ្តាលស្លាប់នៃភាពជាខ្មោច និងពាក់កណ្តាលរស់នៃភាពជាមនុស្ស ដើម្បីសម្រេចគោលបំណងនៃជីវិត។ កោសិកាមនុស្សកើតផងស្លាប់ផង កើតថ្មីធ្វើឲ្យមនុស្សខ្លាំង តែស្លាប់ធ្វើឲ្យមនុស្សខ្សោយ។ ឯខ្លាំងខ្សោយ ឬខ្សោយខ្លាំងមិនសំខាន់ តែរឿងសំខាន់គឺ *"ប្រឹងតាមដែលអាចប្រឹងបាន កុំខ្ជិល កុំត្អូញ កុំរារែក ហត់ត្រូវសម្រាក សម្រាកបាត់ហត់ត្រូវប្រឹងទៀត"*។

ឈប់បួងសួងឲ្យព្រះជួយ ឈប់បួងសួងឲ្យសាសនា ឬទេវតាណាជួយ តែត្រូវជួយខ្លួនឯង ខ្លួនឯងគឺត្រូវប្រឹង។ រីឯសេចក្ដីស្លាប់ គឺនៅមិនឆ្ងាយមិនជិត គ្រាន់តែមិនទាន់មកដល់ បើការស្លាប់មិនទាន់មកដល់ គឺនៅតែមានឱកាសប្រឹង៕

# ថ្ងៃទី១២ ខែកក្កដា

*"គ្មានអភិជនណាម្នាក់ដែលមិនគិតថាខ្លួនមានភាពខ្ពង់ខ្ពស់ជាងអ្នកដទៃនោះទេ ប៉ុន្តែភាពជាអភិជនពិតប្រាកដ គឺមានលក្ខណៈខ្ពង់ខ្ពស់ចំពោះខ្លួនឯងជាមុន"។*

លោក ឡេអុង តុលស្តុយ [ Leon Tolstoy ] ពោលថា "បង្រៀនគេ ប្រៀបដូចរៀនខ្លួនឯង ហើយឲ្យគេ ប្រៀបដូចទទួលយកខ្លួនឯង"។ គោរពអ្នកដទៃ មានន័យថាគោរពខ្លួនឯង។ អភិជនប្រព្រឹត្តចំពោះអ្នកតូចទាបបែបណាក្នុងពេលនេះ នោះក៏មានន័យថា នឹងប្រព្រឹត្តចំពោះខ្លួនឯងបែបនោះដែរក្នុងពេលអនាគត។ អភិជនល្ងង់ និងគំនិតខ្លីយល់ថាខ្លួនឯងខ្ពស់ខ្ពស់ជាងអ្នកដទៃរហូតដល់មើលងាយគេឯងហួសហេតុ និងលើកតម្កើងខ្លួនឯងហួសហេតុ នោះលទ្ធផលនឹងធ្វើឲ្យខ្លួនឯងតូចតាចទៅវិញ។ ពេលដែលភ្នែកមនុស្សបើក តែបេះដូងរបស់គេ បែរជាមិនចំហរទៅវិញ

នោះគឺមានន័យថា គេមិនទាន់បានរៀនសូត្រពីជីវិតពិតនៃមនុស្សទាំងឡាយនៅឡើយទេ។ នៅពេលដែលខួរក្បាលរបស់មនុស្សពោរពេញដោយគំនិត និងចំណេះដឹង តែបេះដូងរបស់គេបែរជាគ្មានពាល់ត្រូវអារម្មណ៍នរណាម្នាក់សោះ នោះគឺមានន័យថាការសិក្សា និងកម្រិតអប់រំរបស់គេមិនទាន់ដល់ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬថ្នាក់បណ្ឌិតនៅឡើយទេ។ ការអប់រំពិតប្រាកដ គឺត្រូវអប់រំទាំងខួរក្បាល និងលត់ដំទាំងបេះដូង៕

# ថ្ងៃទី១៣ ខែកក្កដា

*"តម្លៃរបស់មនុស្សយើង កើតចេញពីការស្គាល់ខ្លួនឯង មិនមែនបានមកពីការសុំទានពីនរណាម្នាក់នោះទេ"។*

មនុស្សឲ្យតម្លៃខ្លួនឯងទាបនឹងគិតតូច។ គិតតូច នឹងនាំឲ្យធ្វើតូច។ ធ្វើតូច នឹងនាំឲ្យបានផលតូច ហើយផលតូចនឹងកំណត់ខ្លួនយើងឲ្យក្លាយទៅជាមនុស្សតូចតាច។ ជីវិតគឺជាជាជម្រើស ហើយយើងអាចជ្រើសរើសជម្រើសពីរគឺ៖ ទីមួយធ្វើជា *"ជនរងគ្រោះ"* ឬទីពីរធ្វើជា *"អ្នកសង្គ្រោះ"*។

"ជនរងគ្រោះ" គឺជាមនុស្សដែលដើរសុំទានក្ដីអាណិតអាសូរ និងសុំតម្លៃពីគេឯង ចំណែកឯ "អ្នកសង្គ្រោះ" គឺជាអ្នកដែលជួយខ្លួនឯងបានតាមការប្រឹងប្រែង និងបង្ហាញគំរូនៃការខិតខំតស៊ូទាំងញើសឈាមដល់អ្នកដទៃ៕

# ថ្ងៃទី១៤ ខែកក្កដា

ហ្សង់ ប៉ូលហ្សាត [ Jean Paul Sartre ] ពោលថា "*ខ្ញុំមិនទទួលខុសត្រូវចំពោះអ្វីដែលអ្នកលឺនោះទេ តែខ្ញុំទទួលខុសត្រូវ តែចំពោះអ្វីដែលខ្ញុំនិយាយប៉ុណ្ណោះ*"។

ហេតុអ្វីក្មេងតែងរីករាយជាងមនុស្សធំ? មនុស្សកាន់តែចម្រើនវ័យ ក៏នឹងកាន់តែចម្រើនចំណេះដឹង ហើយបើមានចំណេះច្រើន និងដឹងកាន់តែច្រើន នោះសេចក្តីទុក្ខក៏កាន់តែច្រើនដូចគ្នាដែរ។ ទុក្ខច្រើនមកពីចំណេះដឹងច្រើន។ ចំណេះដឹងច្រើន គឺជាការល្អ តែបើគ្មានសមត្ថភាពគ្រប់គ្រងចំណេះដឹងឲ្យល្អទេ វានឹងក្លាយជាទុក្ខធំ។ ចំណេះដឹងនិងលុយនឹងក្លាយជាចៅហ្វាយនាយរបស់យើង នៅពេលយើងមិនចេះគ្រប់គ្រងពួកវា។ ពេលយើងដឹងឮអ្វីមួយពីនរណាម្នាក់ យើងក៏យកចំណេះដឹងដែលខ្លួនមានដើម្បីវិនិច្ឆ័យថារឿងនោះវាបែបនេះបែបនោះ។

ប៉ុន្តែរឿងភាគច្រើន ឬព្រឹត្តិការណ៍ខ្លះ វាមិនអាក្រក់ដូចគំនិតដែលយើងប្រមូលផ្តុំចំណោះដឹង មកបង្កើតរូបភាពអាក្រក់ក្នុងខួរក្បាលទេ ។ ក្នុងគម្ពីរគ្រិស្ទសាសនា ក៏បានបង្រៀនដែរថា *"សូមយើងកុំទុកចិត្តគំនិតខ្លួនឯងជ្រុលពេក"*។

I am only responsible for what I say; I am not responsible for what you hear. - Don Miguel Ruiz

# ថ្ងៃទី១៥ ខែកក្កដា

ទស្សនវិទូម្នាក់លើកឡើងថា *"អាចំកំបាំងដែលនាំឲ្យកើតមានសុភមង្គល គឺសេរីភាព ហើយអាថ៌កំបាំងដែលនាំឲ្យកើតមានសេរីភាព គឺភាពក្លាហានក្នុងការទាមទារសេរីភាព"*។

អំពើអយុត្តិធម៌ដែលកើតនៅកន្លែងមួយ គឺជាការគំរាមគំហែងដល់សេរីភាពនៅកន្លែងផ្សេងទៀត ហើយអំពើអយុត្តិធម៌បានកើតឡើងនៅកន្លែងខ្លះ គឺជាការគំរាមគំហែងដល់សេរីភាពនៅគ្រប់ទីកន្លែង។ គ្មាននរណាម្នាក់អាចនិយាយថា ខ្លួនមានសេរីភាពបានទេ ប្រសិនបើជាមនុស្សគ្រប់គ្នាកំពុងត្រូវបានរស់នៅក្រោមគំនាបសង្កត់។ សេរីភាពរបស់មនុស្សក្នុងសង្គម គឺត្រូវរួមបញ្ចូលទាំងសេរីភាពក្នុងការបង្កើតកំហុស៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី១៦ ខែកក្កដា

វ៉ុលទែរ [ Voltaire ] ពោលថា *"មនុស្សមានភាពស្មើគ្នា ហើយភាពស្មើគ្នាមិនមែនចាប់កំណើតមកជាមួយមនុស្ស ទេ តែការបណ្ដុះគុណធម៌ឲ្យកើតដល់ខ្លួនគ្រប់គ្នាទេ ដែលកំណត់ឲ្យមនុស្សមានភាពខុសគ្នា"។*

មនុស្សរូបរាងស្អាត ប្រព្រឹត្តទង្វើអគុណធម៌ នោះគឺនឹងក្លាយជាមនុស្សអាក្រក់ តែមនុស្សមុខមាត់អាក្រក់ ប្រព្រឹត្តទង្វើគុណធម៌ នោះគឺនឹងក្លាយជាមនុស្សល្អ។ ចំណែកមនុស្សរូបរាងស្អាត ប្រព្រឹត្តទង្វើស្អាតបាត នោះនឹងក្លាយជាមនុស្សពេញលេញ។ មនុស្សធម្មតា ធ្វើរឿងអស្ចារ្យ នោះនឹងក្លាយជាមនុស្សអស្ចារ្យ តែមនុស្សអស្ចារ្យ ធ្វើរឿងធម្មតា នោះនឹងក្លាយជាមនុស្សធម្មតា។ ចំណែក មនុស្សអស្ចារ្យ ធ្វើរឿងអស្ចារ្យ នោះនឹងក្លាយជាមនុស្សមហាអស្ចារ្យ៕

# ថ្ងៃទី១៧ ខែកក្កដា

*"មនុស្សមានគោលដៅជីវិតច្បាស់លាស់ តែគ្មានលទ្ធភាពដើម្បីសម្រេចគោលដៅ គឺមិនគួររស់នៅ ហើយមនុស្សមានលទ្ធភាពសម្រេចគោលដៅក្នុងជីវិត តែមិនមានគោលដៅជីវិតច្បាស់លាស់ នោះក៏មិនគួររស់នៅដូចគ្នាដែរ"។*

មនុស្សមានគោលដៅច្បាស់លាស់ក្នុងជីវិត ហើយបង្កលក្ខណៈឲ្យខ្លួនឯងមានលទ្ធភាពអាចសម្រេចគោលដៅបាននោះទើបសមជាមនុស្សដែលគួររស់នៅក្នុងផែនដីនេះ។ ដុល ហ៊ីត្លែ [ Adolf Hitler ] ពោលថា *"មនុស្សជោគជ័យ ឬបរាជ័យ មិនចាំបាច់ពន្យល់ហេតុផលនោះទេ"។ បើយើងជោគជ័យ ពិភពលោកនឹងកំណត់ថាយើងខ្លាំង ហើយគេនឹងរៀនសូត្រតាមយើង តែបើយើងបរាជ័យ ពិភពលោកនឹងកំណត់ថាយើងជាមនុស្សតូចតាច នោះមានន័យថាមិនចាំបាច់ពន្យល់ ហេតុ ឬរកលេស លើកតម្កើងខ្លួនឯងទេ"។*

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

មនុស្សយើងមិនអាចជ្រើសរើសកន្លែងកើតបាន ប៉ុន្តែយើង អាចជ្រើសរើសកំណើតខ្លួនយើង ថាយើងចង់ក្លាយទៅជាអ្វី ឬកំណត់ខ្លួនយើងថាខ្លួនជានរណា។

ជោគជ័យ ឬបរាជ័យនឹងគ្មានសំណួរ ឬចម្លើយបញ្ជាក់ តែអ្វីដែលត្រូវគិត គឺតើយើងបានប្រឹងប្រែងហើយ ឬនៅ?

# ថ្ងៃទី១៨ ខែកក្កដា

បណ្ឌិត ចន ស៊ី ម៉ាក្សវែល [ John C. Maxwell ] ពោលថា *"ដើម្បីអភិវឌ្ឍន៍គំនិតវិជ្ជមាន មនុស្សជោគជ័យ តែងសម្លឹងរកមើលមាស ប៉ុន្តែមិនមែនសម្លឹងមើលដីទេ"*។ មនុស្សឆ្លាតមើលឃើញឱកាសក្នុងបញ្ហា។ចំណែកឯមនុស្សឆោតវិញបែរជាមើលឃើញបញ្ហាក្នុងឱកាស។ កម្មករជីកមាសតែងតែមើលឃើញមាសមួយចំនួនតូចក្នុងចំណោមដីជាច្រើន ពីព្រោះគេដឹងថាមាសតិចជាងដី ហើយបើទោះបីជាដីច្រើនជាងមាសយ៉ាងណា ក៏គេនៅតែមើលឃើញមាស។ ចំពោះជីវិតមនុស្សយើងក៏ដូចគ្នាដែរ គឺដូចគ្នាត្រង់ ថាបើយើងសម្លឹងឃើញការប្រឹងប្រែងតែងនាំប្រយោជន៍ យើងក៏នឹងនៅតែប្រឹងប្រែងរហូតដល់ស្លាប់។ នៅក្នុងទំនាក់ទំនងមិត្តភាព ឬស្នេហាក៏ដូចគ្នាដែរ បើយើងពិតជាមានឆន្ទៈចង់សម្លឹងរកមើលសេចក្ដីអាក្រក់ពីក្នុងខ្លួនបុគ្គលណាម្នាក់មែន ខ្ញុំជឿជាក់ថាយើងនឹងអាចរកឃើញដោយងាយ៕

# ថ្ងៃទី១៩ ខែកក្កដា

អស្មិមានះ ៣យ៉ាង

១) កុំគិតថាខ្លួនឯងអន់ថយជាងគេ ពីព្រោះនឹងនាំយើងឲ្យអស់សង្ឃឹម គ្មានការប្រឹងប្រែង។

២) កុំគិតថាខ្លួនឯងអស្ចារ្យជាងគេ ពីព្រោះនឹងនាំយើងឲ្យអំនួត គ្មានការប្រឹងប្រែង។

៣) កុំគិតថាខ្លួនឯង និងអ្នកដទៃដូចគ្នា ព្រោះនឹងនាំឲ្យយើងគ្មានការប្រកួតប្រជែង គ្មានការប្រឹងប្រែង។

ពេលដែលយើងពេញចិត្តចំពោះភាពសាមញ្ញរបស់ខ្លួនឯង ដោយមិនប្រៀបធៀបខ្លួននឹងអ្នកដទៃ ឬប្រកួតប្រជែងនឹងអ្នកដទៃ នោះគ្រប់គ្នានឹងគោរពយើងក្នុងនាមជាយើង៕

# ថ្ងៃទី២០ ខែកក្កដា

ចន កេណ្ណឺឌី [ John F. Kennedy ] ពោលថា "*ចូរអភ័យទោសកំហុសឲ្យសត្រូវរបស់យើង ប៉ុន្តែសូមកុំភ្លេចឈ្មោះរបស់ពួកគេឲ្យសោះ*"។

ការអភ័យទោសកំហុសលើកទីមួយ ឲ្យមនុស្សបោកប្រាស់ គឺជាចិត្តសប្បុរសមួយ តែបើទុកឱកាសឲ្យគេបោកប្រាស់យើងជាលើកទីពីរ គឺជាអំពើឆោតល្ងង់របស់យើងទៅវិញទេ។ ការចងចាំឈ្មោះមនុស្សបោកប្រាស់ គឺអាចឲ្យយើងការពារកុំឲ្យត្រូវគេបោកប្រាស់ម្តងទៀត៕

# ថ្ងៃទី២១ ខែកក្កដា

"អ្នកណាក៏ជាគ្រូរបស់យើង កន្លែងណាក៏ជាសាលារៀនរៀនរបស់យើង ហើយវិនាទីណាក៏ជាម៉ោងរៀនរបស់យើង ឲ្យតែយើងតាំងចិត្តរៀនសូត្រ"។

បើយើងខំសិក្សាយកចំណេះដឹងជ្រៅជ្រះ ដើម្បីតែយកមកធ្វើការងារដល់ខ្លួនទាំងស្រុង ឬក៏យកជាវិជ្ជាបញ្ញាញាណសម្រាប់មើលងាយមើលថោក និងធ្វើជាចៅហ្វាយដល់ជនអវិជ្ជា ឬវណ្ណៈអធន នោះយើងមិនចាំបាច់រៀនខ្ពង់ខ្ពស់ពេកទេ។ ផ្ទុយទៅវិញ យើងគួរតែជួយអប់រំគេ បើយើងឃើញថាគេអវិជ្ជា យើងគួរតែចេះដាក់ទានខ្លះដើម្បីឲ្យគេមានម្ហូបបរិភោគ និងបង្រៀនគេក្នុងការស្លួចត្រីផងដែរ។ ទាំងអស់នេះហើយ ដែលហៅថាបញ្ញាជន និងជាគោលប្រាថ្នានៃការអប់រំពិតប្រាកដ៕

# ថ្ងៃទី២២ ខែកក្កដា

សៀវភៅដែលបានអានចប់ ពេលខ្លះត្រូវហែកចោល ឬក៏ជូនចំពោះមិត្តភក្តិ។ អតីតកាលបើបានជាកន្លងហួស បានសិក្សារៀនសូត្ររួចហើយ ក៏គួរតែដល់ពេលបំភ្លេចចោល។ មនុស្សដែលបាត់ខ្លួន ក៏គួរតែកុំចាំបាច់ទៅស្វែងរក ពីព្រោះនាឡិកាមិនអាចដើរថយក្រោយទេ។

អំបិលមានរសជាតិប្រៃ ចំណែកស្ករមានរសជាតិផ្អែម ឯស្នេហាគឺមានការឈឺចាប់ ចំណែកជីវិតមានភាពលំបាក។ ប៉ុន្តែយើងមិនអាចដឹងថាអំបិលមានរសប្រៃបែបណា ស្ករមានរសជាតិផ្អែមបែបណា ស្នេហាមានការឈឺចាប់បែប និងជីវិតមានភាពលំបាកបែបណានោះទេ លុះត្រាតែយើងសាកល្បងទើបដឹងច្បាស់ ឬលុះត្រាមានការសាកពិសោធន៍ឃើញដោយខ្លួនឯង ទើបយល់បានច្បាស់ថាបែបណាពិតប្រាកដ៕

# ថ្ងៃទី២៣ ខែកក្កដា

*"ប្រសិនបើយើងបន្តចែករំលែកគំនិតល្អ ឲ្យបានជាប់ឥតដាច់គ្រប់គ្រាន់ គឺថ្ងៃណាមួយគំនិតល្អទាំងឡាយ ក៏នឹងរមៀលធ្លាក់ចូលទៅក្នុងខួរក្បាលមនុស្សល្អជាក់ជាពុំខាន"*
។

មនុស្សល្អ មិនប្រាកដថាមានខួរក្បាលល្អ រីឯមនុស្សអាក្រក់អាចមានខួរក្បាលល្អ។ អ៊ីចឹងមនុស្សល្អមានខួរក្បាលល្ងង់នោះនឹងក្លាយទៅជាមនុស្ស១០គត់ ហើយមនុស្សអាក្រក់មានខួរក្បាលល្អនឹងមានគ្រោះភ័យអាក្រក់ដល់សង្គម។

ដាំដើមឈើឲ្យបម្រុងពូជ បម្រុងដី និងបម្រុងអ្នកថែរក្សា តែដាំមនុស្សឲ្យបម្រុងចរិតលក្ខណៈ ពីព្រោះការសាបព្រោះចំណេះដឹងខុស ឬសាបព្រោះចំណេះដឹងដល់មនុស្សមានចរិតលក្ខណៈអាក្រក់ គឺស្មើនឹងសាបព្រោះគ្រោះភ័យដល់សង្គម។

ចិត្តមេត្តាត្រូវដើរទន្ទឹមនឹងប្រាជ្ញា។ មនុស្សល្អប្រៀបដូចជាទៀនមួយដើម ដែលកំពុងមានពន្លឺឆេះសន្ធោសន្ធៅ ហើយដើម្បីរក្សាពន្លឺដល់អ្នកដទៃ គឺខ្លួនឯងត្រូវឆេះជាប់ជានិច្ច៕

# ថ្ងៃទី២៤ ខែកក្កដា

សូក្រាត [ Socrates ] ពោលថា "*សេចក្តីស្លាប់ គឺជាការជាសះស្បើយនូវជំងឺម្យ៉ាងដែលហៅថាជីវិត*"។

ការរស់នៅ គឺជាការពិសោធន៍ តែបើគ្មានការពិសោធន៍លើជីវិតទេ គឺមិនអាចហៅថាជីវិតបានឡើយ។ ដែលហៅថាជីវិត គឺជាការរស់នៅដែលធ្លាប់ជួបនឹងឧបសគ្គ ឬការឈឺចាប់ តែបើគ្មានទេ គឺជីវិតមិនសូវពេញលេញទេ។ ជីវិតពេញលេញ មិនមែនរាប់ពីចំនួនឆ្នាំដែលយើងបានរស់នៅមានអាយុវែង ឬខ្លីទេ តែវាជាការប្រើប្រាស់ជីវិតឲ្យមានប្រយោជន៍ត្រឹមត្រូវ។ មានប្រយោជន៍គឺមានន័យថា យើងបានប្រើជីវិតដើម្បីអ្នកដទៃ ហើយត្រឹមត្រូវគឺមានន័យថា យើងរស់នៅដោយសាងសេចក្តីល្អច្រើន។

ជីវិតមនុស្សយើង បើត្រឹមតែដើម្បីរស់គឺងាយស្រួលទេ តែបើចង់រស់ឲ្យត្រឹមត្រូវ នោះវាទើបពិបាក។ មនុស្សល្អ ដែលបានរស់នៅដោយត្រឹមត្រូវ គឺនៅពេលស្លាប់ទៅនឹង គ្មាននរណាម្នាក់អាចរំខានបានឡើយ។ ពេលខ្លះ សេចក្តី ស្លាប់គួរឲ្យខ្លាច តែការមានជីវិតរស់នៅគឺគួរឲ្យខ្លាចជាង។ បាយបីពេលដែលយើងញ៉ាំ គឺសម្រាប់បន្តជីវិតឲ្យរស់ ហើយបាយក៏មានតួនាទីបន្តការឈឺចាប់របស់យើងដែរ ពី ព្រោះជីវិតពេលខ្លះគឺជាការឈឺចាប់។

ចំពោះស្នេហា យុវវ័យប្រហែលជាធ្លាប់លឺពាក្យមួយឃ្លាថា *"អាពាហ៍ពិពាហ៍ គឺជារណ្តៅកប់ក្តីអាម៉ាស់ទាំងអស់ រីឯសេចក្តីស្លាប់ គឺជាផ្នូរកប់សេចក្តីឈឺចាប់ទាំងឡាយ"*។ នេះមានន័យថា សេចក្តីអាម៉ាស់ក្នុងអតីតកាលអាចកប់ បាន ឬអាចត្រូវលុបលាងបានតាមរយៈចំណងអាពាហ៍ពិ ពាហ៍ តែការឈឺចាប់នៅតែនៅរស់ ហើយមានតែការស្លាប់ ប៉ុណ្ណោះទើបអាចលុបស្នាមឈឺចាប់អតីតកាលបាន។

ជីវិតមានន័យល្អណាស់ ហើយវាមានន័យដោយសារបទពិសោធន៍នៃការឈឺចាប់ និងពុំងាយមាននរណាម្នាក់អាចយល់បានឡើយ។ គ្រប់យ៉ាងដែលគ្មានអ្នកយល់ គឺវាអស្ចារ្យ ហើយពេលដែលគ្រប់គ្នាបានយល់ វានឹងក្លាយទៅជាសាមញ្ញវិញ។ចុងក្រោយបើមិនប្រឹងរស់ដើម្បីខ្លួនឯងក៏ត្រូវប្រឹងរស់ដើម្បីគ្រួសារ តែបើមិនប្រឹងរស់ដើម្បីគ្រួសារក៏ត្រូវប្រឹងរស់ដើម្បីសង្គមជាតិដែរ៕

"Life maybe the the greatest of all human blessings." - Socrates

# ថ្ងៃទី២៥ ខែកក្កដា

"គ្មានដើមរុក្ខជាតិណាដែលមានមែកសាខា អាចចង្អុលវេហាបានដោយគ្មានឬសចាក់ជ្រៅជាប់នឹងដីនោះទេ" ។

សូមឲ្យមនុស្សល្អទាំងអស់ អាចស៊ូទ្រាំនឹងភាពលំបាក ឬអាចឈ្នះលើឧបសគ្គជីវិតទាំងឡាយ។ សូមឲ្យមនុស្សល្អទាំងឡាយក្លាយជាមនុស្សខ្លាំង ទោះបីមេឃរលំ ភ្នំរលាយនៅចំពោះមុខក៏ដោយ ក៏សូមកុំបាក់ស្មារតីក្នុងការប្រយុទ្ធតស៊ូឲ្យសោះ។ មានជីវិត មានសង្ឃឹម។ មានសង្ឃឹមអាចឈ្នះ។ ជ័យជម្នះ គឺការមិនបោះបង់។ ការមិនបោះបង់នឹងឈ្នះដល់ទីបញ្ចប់។ បើមិនទាន់ឈ្នះ នោះមានន័យថាមិនទាន់ដល់ទីបញ្ចប់។ បើមិនទាន់ដល់ទីបញ្ចប់គឺមិនបោះបង់ មិនឈប់ ហើយបើមិនឈប់ មិនបោះបង់ យើងនឹងមិនចាញ់ឡើយ៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី២៦ ខែកក្កដា

*"ភាពសំខាន់បំផុតរបស់មនុស្ស គឺមិនមែនខ្លួន ឬរាងកាយ ឬមិនមែនមានខួរក្បាលឆ្លាតបំផុតទេ ប៉ុន្តែស្ថិតនៅលើឥរិយាបថខាងក្នុងរបស់មនុស្ស"*។

ក្នុងគ្រាមួយ លោក ប្លែស ប៉េស្កាល់ [ Blaise Pascal ] ជាទស្សនវិទូបារាំងដ៏ល្បីល្បាញម្នាក់ ត្រូវបានមនុស្សម្នាក់និយាយទៅកាន់គាត់ថា *"ខ្ញុំនឹងក្លាយជាមនុស្សល្អ និងឆ្លាតពូកែដូចអ្នក ប្រសិនបើខ្ញុំមានខួរក្បាលរបស់អ្នក"*។ បន្ទាប់មក គាត់បានតបវិញថា *"ប្រសិនបើអ្នកចង់មានខួរក្បាលឆ្លាតដូចខ្ញុំ នោះសូមអ្នកធ្វើជាមនុស្សដែលមានឥរិយាបថត្រឹមត្រូវដូចខ្ញុំ មានចិត្តគំនិតត្រឹមត្រូវដូចខ្ញុំ និងធ្វើសកម្មភាពត្រឹមត្រូវដូចខ្ញុំទៅ"*។

ភាពសំខាន់បំផុតរបស់មនុស្ស គឺមិនមែនខ្លួន ឬរាងកាយ មិនមែនខួរក្បាលឆ្លាតបំផុតទេ ប៉ុន្តែស្ថិតនៅលើឥរិយាបថ

ខាងក្នុងរបស់មនុស្ស។ មនុស្សមានមាឌធំ មនុស្សមានសម្រស់ខាងក្រៅស្អាត មនុស្សមានសំឡេងពីរោះ មនុស្សមានសក់ខ្មៅរលោង មានខួរក្បាលឆ្លាតតែបើមានឥរិយាបថខាងក្នុងអន់ នោះនឹងនាំឲ្យគុណភាពជីវិតអន់។ បញ្ហាទាំងឡាយដែលកំពុងប្រឈមមុខដាក់យើង គឺមិនសំខាន់ដូចឥរិយាបថរបស់យើងដែលតបចំពោះបញ្ហានោះទេ ពីព្រោះឥរិយាបថជាអ្នកកំណត់ភាពឈ្នះ ឬចាញ់របស់យើង។

ភាពជាអ្នកឈ្នះ គឺប្រឈមមុខនឹងបញ្ហា និងធ្វើខ្លួនជាចំណែកនៃដំណោះស្រាយ ប៉ុន្តែភាពជាអ្នកចាញ់វិញ គឺគេចចពីបញ្ហា និងធ្វើខ្លួនជាចំណែកនៃបញ្ហា។មនុស្សដែលមានឥរិយបថអវិជ្ជមាន តែងតែស្តីបន្ទោសអ្នកដទៃ ស្តីបន្ទោសមេឃដី ស្តីបន្ទោសនេះ ស្តីបន្ទោស តែមិនដែលស្តីបន្ទោសឲ្យខ្លួនឯងម្តងណាឡើយ។ តើយើងសុខចិត្តស្តីបន្ទោសរន្ធក្តាម? ឬស្តីបន្ទោសដៃរបស់យើងខ្លី? ឬឈប់ស្តីបន្ទោសអ្វីគ្រប់យ៉ាង? តែស្វះស្វែងរកវិធីដោះស្រាយដើម្បីឲ្យទៅដល់ជោគជ័យ។

បុរាណខ្មែរពោលទុកថា "ឆ្អើយស្អុក ឱនដាក់គ្រាប់"។ ផ្ទុយទៅវិញ យើងអាចឆ្អើយបាន តែកុំឆ្អើយដល់មេឃ ឬកុំឆ្អើយខ្ពស់ពេក និងយើងអាចឱនបាន តែកុំឱនទាបពេកអាប់រាសី ព្រមទាំងនិយាយស្តីត្រឹមតែគួរសមទៅបានហើយ។

កែមនុស្សល្ងង់ដោយយើងត្រូវធ្វើខ្លួនជាមនុស្សចេះដឹង តែដឹកនាំមនុស្សចេះដឹង គឺយើងត្រូវចេះធ្វើល្ងង់វិញ។ ធម្មជាតិបានបង្កើតធាតុមួយដើម្បីបង្ក្រាបធាតុមួយទៀត ប្រៀបដូចជាទ្រឹស្តីធម៌អហិង្សារបស់មហាត្មៈ គន្ធី [ Mahatma Gandhi ] ថា "*ចិត្តភ្លើង ឬកំហឹង មិនអាចរំលត់ដោយចិត្តភ្លើងបានទេ ឬរំលត់ដោយកំហឹងបានទេ តែគេត្រូវយកចិត្តទឹកដើម្បីរំលត់ចិត្តភ្លើង ឬយកការអត់ធ្មត់ដើម្បីបង្ក្រាបភាពមានកំហឹង*" ។ បើយើងចង់កែមនុស្សខឹង នោះយើងត្រូវធ្វើខ្លួនជាមនុស្សចិត្តស្ងប់អត់ធ្មត់សិន៕

# ថ្ងៃទី២៧ ខែកក្កដា

ប៊ិនចាមីន ឌីស្រាអ៊ែល [ Benjamin Disraeli ] ពោលថា *"អភិនីហារនៃស្នេហ៍ដំបូង គឺប្រៀបបាននឹងភ្លើងនៃភាពល្ងង់ខ្លៅ របស់មនុស្សស្រីប្រុសទាំងពីរនាក់ដែលមិនងាយនឹងរលត់"*។

ស្នេហាប្រុសស្រី តែងនិមិត្តខ្លួនដំបូងឡើងឲ្យមានសេចក្ដីរំភើបចេញពីបេះដូងដ៏បរិសុទ្ធ តែនឹងក្លាយទៅជាភ្លើងដែលពិបាកពន្លត់ចេញពីក្នុងអារម្មណ៍នៅពេលប្រេះឆា។ ស្នេហាគឺជាកម្លាំងជំរុញផ្លូវចិត្ត និងអារម្មណ៍មួយដែលខ្លាំងក្លា បើភាគីពាក់ព័ន្ធចេះយកវាមកប្រើប្រាស់ដើម្បីជាប្រយោជន៍ល្អ ពីព្រោះមានយុវជនច្រើនណាស់ដែលត្រូវបានស្នេហាជំរុញឲ្យដើរចូលផ្លូវអបាយមុខព្រោះភ្លើងស្នេហា ។ ប៉ុន្តែក៏មានយុវជនជាច្រើនដូចគ្នាដែរ ដែលត្រូវស្នេហាជំរុញឲ្យត្រឡប់ដើរលើផ្លូវត្រូវវិញ។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

បុរសល្អតែងដើររកប្រពន្ធ តែមិនមែនស្វែងរកស្រីស្អាត ឬស្រីកំដរអារម្មណ៍នោះទេ។ រីឯជោគជ័យធំចុងក្រោយរបស់សុភាពនារី គឺមានក្រសែភ្នែកល្អអាចជ្រើសរើសបុរសល្អម្នាក់ដែលពោរពេញទៅដោយទំនួលខុសត្រូវសម្រាប់ជីវិតខ្លួន។

ក្នុងខ្លួនមនុស្សយើង កម្រនឹងមានជាតុព្រះ តែមនុស្សយើងអាចមានជាតុព្រះក្នុងខ្លួន ឬមានជាតុព្រះខ្លះនៅក្នុងខ្លួនទៅបាន លុះត្រាតែទទួលការលត់ដំផ្លូវអារម្មណ៍ ជួបសេចក្ដីឈឺចាប់ និងសិក្សាពីខ្លួនឯងឲ្យបានច្រើន នោះគឺនឹងស្គាល់ពីធម្មជាតិដើមនៃមនុស្ស។ ស្នេហា គឺបានឃើញមនុស្សដែលយើងស្រឡាញ់មានសុភមង្គល ហើយយើងនឹងមានអារម្មណ៍រីករាយ៕

# ថ្ងៃទី២៨ ខែកក្កដា

អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] ពោលថា "ការសិក្សាមិនមែនជាការរៀនសូត្រលើមូលដ្ឋានការពិតនោះទេ តែជាការហ្វឹកហាត់ពីវិធីនៃការគិត"។

ចំណេះដឹងដែលមានសភាពងាប់ក្រឡា គឺនឹងគ្មានភាពរីកចម្រើនទេ តែអ្វីដែលអាចផ្តល់ការអភិវឌ្ឍន៍បាន គឺជំនាញនៃការគិត និងការស្រមើស្រមៃ។ អាញស្តាញលើកឡើងថា "ចំណេះដឹងមានព្រំដែន តែមនោគតិ ឬការគិតស្រមើស្រមៃគ្មានដែនកំណត់ទេ ពីព្រោះចំណេះដឹងអាចត្រឹមតែនាំយើងឲ្យឆ្លងពីកន្លែង "ក" ទៅដល់កន្លែង "ខ" ប៉ុន្តែមនោគតិ ឬការគិតស្រមៃវិញអាចនាំយើងទៅដល់គ្រប់ទីកន្លែងទាំងអស់"៕

# ថ្ងៃទី២៩ ខែកក្កដា

" *ចូរប្រើពេលវេលាសន្តិភាពឲ្យមានប្រសិទ្ធិភាព*" ។ គ្រប់សមរភូមិសង្គ្រាមជីវិតទាំងឡាយ តែងតែបញ្ចប់វិញដោយសន្តិភាពគ្រាន់តែមុន ឬក្រោយប៉ុណ្ណោះ។ ពេលវេលាសន្តិភាពតិចតួចយ៉ាងណាក្តី ត្រូវទាញយកប្រយោជន៍ឲ្យបាន ដោយការខិតខំស្តារស្ថានភាពនៃជីវិត សិក្សាពីអតីតកាល ធ្វើសកម្មភាពបច្ចុប្បន្នកាលរៀបចំអនាគតកាល និងកុំចំណាយពេលសប្បាយភ្លេចខ្លួន និងភ្លេចការឈឺចាប់ ។មានពាក្យមួយឃ្លាពោលថា "ភ្លេចប្រវត្តិសាស្ត្រ គឺប្រវត្តិសាស្ត្រនឹងកើតម្តងទៀតដាន់ដានចាស់។ ចំណែកឯការភ្លេចការឈឺចាប់ នោះសេចក្តីឈឺចាប់នឹងអាចនិមិត្តខ្លួនឡើងម្តងទៀត"។ "The time to repair the roof is when the sun is shining." - John F Kennedy.

# ថ្ងៃទី៣០ ខែកក្កដា

*"ដើមឈើមួយដើម ត្រូវរងនូវសម្ពាធធម្មជាតិ ក្តៅ ត្រជាក់ ខ្យល់ ព្យុះ ភ្លឺ ងងឹត ហើយមនុស្ស ក៏ដូចគ្នាដែរ"។* គេតែងសួរខ្ញុំថា *"ថ្ងៃនេះ បានម្ហូបអ្វី?"* ខ្ញុំតបថា *"បាទ ខ្ញុំមិនដឹងទេ"។* គេសួរទៀតថា *"ម្ហូបដែលបានញ៉ាំ មានរសជាតិឆ្ងាញ់ទេ?"* ខ្ញុំតបថា *"បាទ ខ្ញុំក៏ឥតដឹងដែរ"។* គេប្រហែលជាយល់ថា ខ្ញុំជាមនុស្សចម្លែក តែមិនមែនទេ។ អាហារគ្រាន់តែដើម្បីបន្តជីវិតឲ្យរស់ ហើយរសជាតិបែបណា ខ្ញុំឥតដឹងទេ តែអ្វីដែលខ្ញុំគួរដឹង គឺអាហារដែលត្រូវញ៉ាំត្រូវតែមិនប៉ះពាល់ដល់សុខភាព។ គេសួរខ្ញុំថា *"តើធ្លាប់ឈឺទេ?"* ខ្ញុំតបថា *"ឥតសោះតែម្តង ហើយខ្ញុំក៏ឥតដែលធ្លាប់ប្រើថ្នាំពេទ្យដែរ"។* គេប្រហែលគិតថាខ្ញុំកុហក តែខ្ញុំនិយាយការពិត។ ខ្ញុំជឿលើថាមពលជីវិត ជឿលើថាមពលដួងចិត្ត ជឿលើអំណាចនៃដួងចិត្ត និងជឿលើមនោមយិទ្ធិ [ Will Power ]។

រៀងរាល់យប់ពេញបូរមី ខ្ញុំចូលចិត្តអង្គុយសមាធិក្បែរបង្អួច ស្រូបថាមពលធម្មជាតិ ពន្លឺព្រះច័ន្ទ និងស្រូបខ្យល់ធម្មជាតិ។ ខ្ញុំតែងតែប្រើវិជ្ជាចិត្តសាស្ត្រដើម្បីព្យាបាលជំងឺ។ ហើយចុងក្រោយ ខ្ញុំតែងតែរំលឹកសម្ដីរបស់សូក្រាត និងម៉ុងតេស្គីយ័រ ថា *"ជីវិត គឺជាការហាត់ស្លាប់"*។ *"ហាត់ស្លាប់"* ក្នុងន័យនេះ គឺមិនសូវដូចគ្នានឹងការធ្វើវិបស្សនាកម្មដ្ឋានដែលត្រូវពិសោធលើចិត្ត និងកាយ។ ចំពោះខ្ញុំ ការហាត់ស្លាប់ គឺប្រហែលជាមិនអង្គុយនៅមួយកន្លែងពិសោធលើដង្ហើមចេញចូលទេ តែត្រូវចេញទៅខាងក្រៅ ត្រូវហាត់ទទួលការមើលងាយ ត្រូវហាត់ឈឺចាប់ក្នុងទុក្ខគ្រប់បែបយ៉ាងទាំងចិត្តកាយត្រូវចេះអត់ធ្មត់ត្រូវមានវិន័យលើខ្លួនឯង ត្រូវលត់ដំុចិត្តគំនិត និងអារម្មណ៍...។ល។

ចុងក្រោយ ខ្ញុំក៏យល់ស្របនឹងសម្ដីរបស់ អាល់ប៊ឺត អាញស្តាញ ទាំងស្រុងថា *"គតិបណ្ឌិត គឺជាការណ៍ដែលយើងចេះរស់រៀនពីបទពិសោធន៍ជាក់ស្ដែងក្នុងជីវិតយ៉ាងលំបាក"*។

នៅពេលដែលយើងមិនចេះគ្រប់គ្រងលុយ ឬចំណេះដឹង នោះវាទាំងពីរនឹងក្លាយទៅជាចៅហ្វាយនាយ។ ប៉ុន្តែ ខ្ញុំយល់ថា ការគ្រប់គ្រងអារម្មណ៍ គឺសំខាន់ជាងចំណេះដឹង និងគ្រប់គ្រងលុយ។ អារម្មណ៍ដែលរំភើបនឹងជោគជ័យ អារម្មណ៍ដែលតក់ស្លុតនឹងក្តីទុក្ខ អារម្មណ៍ដែលត្រូវ គេបញ្ចោរបាន អារម្មណ៍ដែលសប្បាយជាច់បង្ហៀរ អារម្មណ៍ដែលខឹងសម្បារ អារម្មណ៍ដែលឈ្លក់វង្វេងនឹងកិត្តិយស អារម្មណ៍ដែលឈ្លក់នឹងចំណេះដឹង អារម្មណ៍ដែលឈ្លក់នឹងសម្រស់ខ្លួនឯង....។ល។ មនុស្សដែលមានអារម្មណ៍ដូចខាងលើច្រើនបំផុត ទី១ គឺយុវជន និងទី២ គឺមនុស្សអាយុគ្រប់វ័យដែលត្រឹមតែចេះ តែមិនដឹង។ ព្រះពុទ្ធ "ត្រាស់ដឹង" តែមិនមែន *"ត្រាស់ចេះ"* ទេ៕

## ទស្សនៈសម្រាប់ខែ

# សីហា

# ថ្ងៃទី០១ ខែសីហា

យកចិត្តទុកដាក់ចំពោះ (ពេលនេះ) អតីតកាលមានន័យថាបច្ចុប្បន្ន បច្ចុប្បន្នមានន័យថាបច្ចុប្បន្ន ហើយអនាគតមានន័យថាបច្ចុប្បន្ន។ ម្សិលមិញក៏ជាថ្ងៃនេះ ថ្ងៃនេះក៏ជាថ្ងៃនេះ ហើយថ្ងៃស្អែកក៏ជាថ្ងៃនេះ។ អ៊ីចឹងត្រូវផ្ចង់ចិត្តគំនិតផ្តោតការយកចិត្តទុកដាក់លើពេលនេះ ថ្ងៃនេះ និងបច្ចុប្បន្ននេះ។ មនុស្សយើងមិនអាចជិះទូកពីរក្នុងពេលតែមួយ តែយើងអាចធ្វើកិច្ចការលើសពីមួយក្នុងពេលយើងជិះទូកមួយ។

សូមកុំឲ្យពេលវេលាកន្លងទៅដោយឥតប្រយោជន៍ ពីព្រោះពេលវេលាជាមាសប្រាក់។ មាសប្រាក់អាចរកបាន និងទិញវត្ថុគ្រប់យ៉ាងបាន តែមាសប្រាក់មិនអាចទិញពេលវេលាបានទេ។ អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] ពោលថា "បុរសម្នាក់ដែលអាចបើកបរកាន់ចង្កូតរថយន្ត

បានផង និងប្រើពេលវេលាដំណាលគ្នាបើបនារីម្នាក់បានផង គឺដោយសារតែគាត់ផ្ចង់យកចិត្តទុកដាក់ចំពោះពេលវេលាបច្ចុប្បន្ន"។

# ថ្ងៃទី០២ ខែសីហា

មហាត្មៈ គន្ធី [ Mahatma Gandhi ] ពោលថា "*ការផ្តួលរំលំរដ្ឋាភិបាលដែលគ្មានសមត្ថភាព ដឹកនាំប្រទេសឲ្យរីកចម្រើនបាន គឺជាកិច្ចការងាយស្រួល ជាងការព្យាបាលជំងឺឆ្កួតរបស់ប្រជាជនឲ្យជាសះស្បើយទៅទៀត*"។

មនុស្សម្នាក់ឆ្កួត គង់តែសង្គមដឹង តែបើសង្គមទាំងមូលឆ្កួតវិញ គឺឥតមានអ្នកណាម្នាក់បានដឹងទេ។ ពេលយើងជាមនុស្សស្មោះត្រង់ សង្គមថាយើងឆ្កួត។ ពេលយើងធ្វើជាមនុស្សត្រឹមត្រូវ សង្គមថាយើងឆ្កួត។ ពេលយើងមិនស៊ីសំណូកពុករលួយ សង្គមថាយើងឆ្កួត ហើយពេលយើងប្រឹងរៀន សង្គមថាយើងគង់តែឆ្កួតនឹងរៀន...។ល។

ប៉ុន្តែចុងក្រោយ សង្គមត្រូវការមនុស្សឆ្កួតដូចរៀបរាប់ខាងលើច្រើននាក់ណាស់ ដើម្បីផ្លាស់ប្តូរសង្គមឆ្កួត។ អ្នករៀនសូត្រចេះដឹង សង្គមពិតជាត្រូវការខ្លាំងណាស់។

ដូច្នេះ យើងជាអ្នកមានចំណេះដឹង មិនឯកាទេ ៕

"Insanity in individuals is rare - but in groups, parties, nations, and epochs, it is the rule."

- Friederich Nietzsche

# ថ្ងៃទី០៣ ខែសីហា

ហ្វ្រីឌ្រិច និហ្សឺ [ Friedrich Nietzsche ] ពោលថា"*ក្នុងលោកនេះ មិនមានការពិតទេ គឺមានត្រឹមតែការទាញន័យបកស្រាយពន្យល់ ទៅតាមទស្សនៈរបស់មនុស្សតែប៉ុណ្ណោះ*"។

ចំពោះមនុស្សជាតិ កើតមកពោរពេញដោយសមត្ថភាព ហើយអាចកាឡៃប្រែល្អទៅជាអាក្រក់ និងអាក្រក់ទៅជាល្អ។ មេធាវីអាចបំភ្លៃល្អឲ្យទៅជាអាក្រក់ និងជាងគំនូរអាចធ្វើសឲ្យទៅជាខ្មៅ ប៉ុន្តែការពិតនៅតែជាការពិត។ ការយល់ឃើញ តែងស្ថិតនៅចន្លោះការពិត និងក្លែងក្លាយ ពីព្រោះពេលដែលមនុស្សមិនដឹងថាពិត ឬក្លែងក្លាយ នោះការយល់ឃើញនឹងលេចរូបរាងឡើង។ មនុស្សមានតម្លៃ ឬគ្មានតម្លៃ មិនស្ថិតលើការនិយាយតាមបែបឡូហ្សិក [ Logic ] ទេ។ ប៉ុន្តែស្ថិតនៅការនិយាយតាមបែបការពិតក្នុងកាលៈទេសៈ

ដែលគួរនិយាយ។ ការនិយាយត្រូវ ឬខុស មិនអាស្រ័យលើចំនួនមនុស្សច្រើនទេ តែវាងអាស្រ័យលើចំណេះដឹង និងការពិត។ ការពិត ឬក្លែងក្លាយរបស់មនុស្ស ក៏មិនស្ថិតនៅជាអមតៈជារៀងរហូតដែរ តែវាស្ថិតនៅលើកាលៈទេសៈជាក់ស្តែងប៉ុណ្ណោះ។ ការពិត តែបើស្ថិតក្នុងកាលៈទេសៈខុស គឺស្មើនឹងមិនពិត។មិនពិតបើស្ថិតក្នុងកាលៈទេសៈត្រូវ គឺស្មើនឹងពិត៕

"There are no facts, only interpretations."

- Friedrich Nietzsche

# ថ្ងៃទី០៤ ខែសីហា

"　　ដៃគូប្រយុទ្ធប្រជែងពិតប្រាកដរបស់យើងគឺខ្លួនយើង ដូច្នេះសូមកុំយកលាមកប្រៀបធៀបជាមួយបាយ　ព្រោះវាឆ្ងាយពីគ្នាដូចមេឃ និងដី"។

មានរឿង ៣យ៉ាងដែលមិនផ្ដល់ភាពចម្រើនដល់មនុស្ស៖

១. អញខ្លាំងជាងគេ គឺអំនួតនិយម។

២. គេ និងអញដូចតែគ្នា គឺគ្មានការប្រកួតប្រជែង។

៣. អញអន់ថយជាងគេ គឺនាំឲ្យខ្លួនបាក់ទឹកចិត្ត។

អស្មិមានៈទាំង ៣នេះផ្ដល់មហន្តរាយដល់មនុស្ស អ៊ីចឹងតើអ្វីទៅហៅថាការប្រកួតប្រជែងពិតប្រាកដ?
វាគឺការរីកចម្រើនជាលំដាប់ពីចំណុច ០ រហូតដល់ ១ ឬពី ១ ដល់ ១០។

ការប្រៀបធៀបខ្លួននិងអ្នកដទៃគឺជាកំហុស តែប្រៀបធៀបខ្លួនឯងពីម្សិលមិញ និងខ្លួនឯងថ្ងៃនេះ គឺជារឿងត្រឹមត្រូវបំផុត ពីព្រោះយើងមិនអាចយកសម្បត្តិដែលរកបានចេញពីញើសលាយឈាម ធៀបជាមួយសម្បត្តិមរតកនោះទេ៕

# ថ្ងៃទី០៥ ខែសីហា

សម្ដេចសង្ឃ ដាឡៃ ឡាម៉ា [ Dalai Lama ] បានពោលថា *"សន្តិភាពពិភពលោកអាចកើតឡើងទៅបាន អាស្រ័យទៅលើសេចក្ដីស្ងប់ក្នុងចិត្ត"*។

យើងតែងតែឆ្ងល់ថា តើកត្តាអ្វីដែលបំផ្លាញសេចក្ដីស្ងប់ក្នុងចិត្តរបស់មនុស្សយើង? តាមពិតមិនមែនជាអាវុធយុទ្ធភណ្ឌ ឬក៏កត្តាគំរាមគំហែងខាងក្រៅមកពីណាទេ ប៉ុន្តែគឺជាភ្លើងកំហឹងរបស់យើងនោះឯង។ មូលហេតុដែលធ្វើឲ្យសេចក្ដីស្រឡាញ់រាប់អានរវាងគ្នានឹងគ្នា និងក្ដីមេត្តាករុណាចំពោះគ្នា មានសារៈសំខាន់ នោះគឺដោយសារតែថាមពលទាំងនោះផ្ដល់ភាពរឹងមាំដល់យើងគ្រប់គ្នា៕

# ថ្ងៃទី០៦ ខែសីហា

លោក ជីម រ៉ូន [ Jim Rohn ] ពោលថា "*ឧបសគ្គចំពោះភាពជាអ្នកដឹកនាំ គឺរឹងប៉ឹង តែមិនចចេស។ ទន់ភ្លន់ តែមិនទន់ជ្រាយ។ ក្លាហាន តែមិនបំពានអ្នកដទៃ។ ពូកែគិត តែមិនមែនបានតែមាត់។ ឱនលំទោន តែមិនលុតក្រាប។ មានមោទកភាព តែមិនអួតអាង។ ចេះកំប្លុកកំប្លែង តែមិនឡិបឡប់*"។ការផ្តល់តម្លៃលើ "អំណាច" ដោយអាស្រ័យលើទ្រព្យសម្បត្តិមនុស្ស ឋានៈមនុស្ស និងអម្បូរមនុស្ស គឺជាវប្បធម៌របស់មនុស្សប្រទេសខ្លះ។ ប៉ុន្តែតថភាព និងប្រវត្តិដើម គឺសម្បត្តិភាគច្រើនកើនដោយសារអំពើពុករលួយខ្លះ កើនដោយសារកាប់ឈើខ្លះ និងកើនដោយការជួញដូរគ្រឿងញៀនខ្លះ។ ចំណែកឋានៈបុណ្យសក្តិបានមកតាមខ្សែស្រលាយ បានមកតាមទឹកប្រាក់ទិញអំណាចបុណ្យស័ក្តិ និងទិញកម្រិតសិក្សាសញ្ញាបត្រ។

មនុស្សពេញលេញ គោរពតម្លៃពិតរបស់មនុស្ស តែមិនមែនគោរពឋានៈមនុស្សទេ ឯមនុស្សលុតក្រាប ដើម្បីប្រយោជន៍ គោរពឋានៈមនុស្ស ជាជាងគោរពភាពជាមនុស្សរបស់មនុស្ស។ ចង់ដឹងមនុស្សល្មោភអំណាចល្អ សូមជន្លឲ្យអំណាចក្នុងដៃគេ នោះនឹងដឹងថាអ្នកដឹកនាំនោះល្អ ឬអាក្រក់។ ចង់ដឹងមនុស្សលោភលន់ នោះសូមយកលុយពិសោធ។ ចង់ដឹងមនុស្សមានការអប់រំ តែខ្វះគុណធម៌ នោះឲ្យអ្នកសុំទានម្នាក់ទៅនិយាយជាមួយគេ។

ព្រះអាទិត្យបាំងមិនជិត ព្រះច័ន្ទបាំងមិនជិត សេចក្តីពិតក៏បាំងមិនជិត ហើយទង្វើល្អ ឬអាក្រក់របស់មនុស្ស ក៏មិនអាចបាំងជិតដូចគ្នា។ ព្រះ យេស៊ូ គ្រីស្ទ [ Jesus Christ ] ពោលថា *"បុគ្គលដែលចេះបន្ទន់ឥរិយាបថ និងសុភាពរាបសា នឹងត្រូវបានគេលើកតម្កើង"*៕

# ថ្ងៃទី០៧ ខែសីហា

ឧត្តគតិលោក អៀវ កើស "យើងត្រូវមានសេចក្ដីស្អាតស្អំជាមូលដ្ឋាន ព្រោះអំពើពុករលួយដែលយើងបានប្រព្រឹត្តក្នុងទីស្ងាត់កំបាំង នោះមកបិទត្រចៀក បិទភ្នែក បិទមាត់យើងហាមឃាត់ចិត្តយើងមិនឲ្យយើងហ៊ានរិះគន់អ្នកប្រព្រឹត្តអំពើពុករលួយ"។ ទោះបីជាគ្មាននរណាម្នាក់ដឹងថា យើងបានធ្វើក៏ដោយ តែយូរនឹងឆាប់គង់តែគេដឹង ដែលនាំឲ្យខូចកិត្តិយស កិត្តិនាមយើងក្នុងអនាគតជាមិនខាន។

ក្នុងទ្រឹស្ដីទំនាញ ៣គូ [ the 3 Pairs of Pulling Forces ] បានលើកបញ្ជាក់ពីមូលហេតុដែលនឹងនាំមនុស្សប្រព្រឹត្តមិនត្រឹមត្រូវ៖

១) ស្រេកឃ្លាន អាហារ និងតណ្ហាក្នុងផ្លូវភេទ [ Appetities and passion ]។

២ ) ចេះតែមានមោទនភាពចំពោះខ្លួនឯង និងចេះតែធ្វើឫក លើសពីសមត្ថភាព និងលទ្ធភាព

[ Pride and pretensions ] ។

៣ ) ចេះតែបម្រុងខ្លួនដើម្បីឯងតែមហិច្ឆិតា

[ Aspiration and ambition ] ។

# ថ្ងៃទី០៨ ខែសីហា

"អ្នកនយោបាយ បើឈ្នះគឺបានទាំងទ្រព្យ បានទាំងអំណាច បានទាំងកិត្តិយស"។ ពាណិជ្ជករ បើឈ្នះគឺបានចំណេញ បានត្រឹមតែលុយកាក់មាសប្រាក់។ អ្នកចម្រៀង បើឈ្នះគឺបានត្រឹមប្រជាប្រិយភាព។ ប្រធានាធិបតីក្របំផុត Jose Mujica បានមានប្រសាសន៍ថា *"បើអ្នកចង់បានមាសប្រាក់ នោះចូរធ្វើជំនួញ ប៉ុន្តែសូមកុំធ្វើនយោបាយ ពីព្រោះនយោបាយ គឺសម្រាប់បម្រើប្រជាជនតែប៉ុណ្ណោះ"*។

ក្នុងសង្គមស្អាតស្អំ អ្នកនយោបាយធ្វើការដើម្បីលុបបំបាត់ភាពក្រីក្រ និងធ្វើការបម្រើប្រជាជន។ ប៉ុន្តែក្នុងសង្គមពុករលួយ ប្រជាជនក្រីក្រប្រឹងប្រែងធ្វើការដើម្បីជួយឲ្យអ្នកមានអំណាចឲ្យកាន់តែមានបានថែមទៀត ជួយមន្ត្រីអាក្រក់ឲ្យកាន់តែបានអំណាច ឬប្រជាជនក្រីក្រត្រូវបង់ពន្ធជូនអ្នកមាន និងអ្នកមានអំណាចជញ្ជក់ឈាមពីអ្នកក្រ។

មន្ត្រីស្អាតស្អំ គឺជាកម្មសិទ្ធិរបស់ប្រជាជន បម្រើរាស្ត្រ គ្មានបក្សពួក តែមានតែច្បាប់ មានសីលធម៌ និងមនុស្សធម៌។

ច្បាប់ សីលធម៌ និងមនុស្សធម៌ គឺបក្សពួករបស់មន្ត្រីល្អ។ ច្បាប់ សីលធម៌ និងមនុស្សធម៌ គឺជាចៅហ្វាយនាយរបស់មន្ត្រីល្អ។ច្បាប់សីលធម៌និងមនុស្សធម៌មានភាពសុក្រឹត្យ។ ច្បាប់អាចដាក់ទោសបានទាំងអ្នកមាន និងអ្នកក្រ ហើយដាក់ទោសបានទាំងអ្នកមានអំណាច និងអ្នកគ្មានអំណាច ។ ចំណែកសីលធម៌ និងមនុស្សធម៌ ប្រើសម្រាប់ជួយអ្នកស្មោះត្រង់ និងជួយអ្នកក្រខ្សត់។ រីឯអ្នកនយោបាយ គឺជាកម្មសិទ្ធិរបស់បក្ស មានភាពលំអៀង ត្រឹមត្រូវ ឬខុសនោះអាស្រ័យលើគោលការណ៍ និងការអនុវត្តន៍យុទ្ធសាស្ត្រជាក់ស្តែងរបស់បក្ស។

មហាត្មៈ គន្ធី [ Mohatma Gandhi ] បាននិយាយដល់អំពើបាប១ក្នុងចំណោម ៧ថា "នយោបាយ ដោយគ្មានគោលការណ៍ ឬ Politics Without Principles" ដែលសំដៅដល់អ្នកនយោបាយដូរធន្ទៈ ដូរគោលការណ៍ដើម្បីអំណាច បុណ្យសក្តិ និងកិត្តិយសខ្លួនឯង និង

អ្នកនយោបាយសុខចិត្តចុះចេញពីអំណាច ឬបោះបង់ដំណែងដើម្បីផលប្រយោជន៍ប្រទេសជាតិ អ្នកដឹកនាំបានលើកឡើងថា *"អ្នកតាំងខ្លួនជាអ្នកដឹកនាំនយោបាយ តែងផ្លាស់ប្តូរគោលការណ៍របស់ពួកគេដើម្បីមុខតំណែង ព្រោះគេយល់ថាតំណែងខ្ពស់ គឺហៅថាអ្នកដឹកនាំ។ ចំណែកអ្នកមានសារជាតិជាអ្នកដឹកនាំនយោបាយបម្រើរាស្ត្រ គឺផ្លាស់ប្តូរតួនាទី ផ្លាស់ប្តូរតំណែងដើម្បីគោលការណ៍ត្រឹមត្រូវ"* ។

មានអំណាច មិនមែនមានន័យថាមានភាពជាអ្នកដឹកនាំនោះទេ តែមានភាពជាអ្នកដឹកនាំ ឬមានភាពជាអ្នកបម្រើប្រជាជន [ Servant - Leadership ] នោះទើបហៅថាមានអំណាចពិតប្រាកដ។ ទស្សនៈអ្នកដឹកនាំជនជាតិជប៉ុនមួយរូបយល់ឃើញថា *"បុគ្គលដែលបានលះបង់ពលីកម្មដើម្បីមហាជនច្រើនប៉ុនណា នោះគេនឹងទទួលបានផលតបស្នងវិញប៉ុណ្ណោះដែរ"*។

អ្នកនយោបាយយល់ថា ដើម្បីធ្វើឲ្យសង្គមរីកចម្រើនបាន លុះត្រាតែដូរក្បាលម៉ាស៊ីនដែលដុះស្លែ។ ចំណែកមន្ត្រីរាជការល្អ បម្រើរាស្ត្រយល់ថា ដូរឬមិនដូរ តែគេនៅតែអាចបម្រើប្រជាជនបានដដែល។

ក្នុងទស្សនវិជ្ជាជីវិតរបស់អ្នកប្រាជ្ញចិន ស៊ូតុង ប៉ ឬ ស៊ូស៊ី [ Su Tung Po ] បានចោទជាសំណួរថា *"តើត្រូវស្មោះព្រះមហាក្សត្រ [ សម័យរាជានិយម ] មុន ឬស្មោះត្រង់ចំពោះប្រជារាស្ត្រមុន? ចម្លើយគឺ ត្រូវស្រឡាញ់ស្មោះត្រង់ចំពោះប្រជារាស្ត្រមុន ព្រោះមហាក្សត្រតែងមានកំហុស តែប្រជារាស្ត្រសាមញ្ញគ្មានកំហុសនោះទេ"* ។

ក្នុងសង្គមអាក្រក់ អ្នកចេះដឹង យកការសិក្សារៀនសូត្រដើម្បីធ្វើជាកាំជណ្តើរដើម្បីស្វែងរកឋានៈ បុណ្យសក្តិ ឬអំណាច និងលាភសក្ការៈ។ ក្នុងប្រវត្តិសាស្ត្រសង្គមបុរាណការផ្លាស់ប្តូរភាគច្រើន សុទ្ធតែបានមកដោយ "ឈាម" របស់អ្នក ស្នេហាជាតិ និងប្រជាជនសាមញ្ញ ធ្វើបដិវត្តិន៍

ផ្លាស់ប្តូររបបរាជានិយមទៅជាប្រជាធិបតេយ្យ ឬសង្គមនិយម ឬផ្លាស់ប្តូររបបនយោបាយ ដូចជាបដិវត្តិន៍នៅរុស្ស៊ី បដិវត្តិន៍នៅចិន សុទ្ធតែបានបូជាឈាមមនុស្សអស់រាប់លាននាក់៕

# ថ្ងៃទី០៩ ខែសីហា

មហាត្មៈ គន្ធី [ Mahatma Gandhi ] ពោលថាថា "*មានចំណេះដឹង តែមិនជ្រាបជាចរិត [ Knowledge Without Character ]*"។ ចរិត គឺជាបែបបទ ឫកពា កិរិយាមារយាទ និងការប្រព្រឹត្តិ។ អ្នកមានចំណេះដឹងតែងតែដុសខាតទម្លាប់អាក្រក់នានាចេញពីខ្លួនគេដោយយោងតាមទ្រឹស្តី និងគោលការណ៍ដែលបានពីការអាន និងការសិក្សា ឬបទពិសោធន៍ ព្រោះគេដឹងថាទម្លាប់មិនល្អ នឹងផ្តល់ផលអវិជ្ជមានដល់ជីវិតរស់នៅ។ សកម្មភាពត្រឹមត្រូវ និងទង្វើល្អ ដុសខាតទម្លាប់អាក្រក់ គឺពិតជាបង្ហាញចេញតាមបែបសម្តែងពិតមែន តែវាជាល្ពានមួយដើម្បីឈានដល់ភាពអចិន្ត្រៃយ៍នៃទម្លាប់។

មហាត្មៈ គន្ធី [ Mohatma Gandhi ] ពោលថា "*ជំនឿក្លាយជាគំនិត, គំនិតនឹងក្លាយជាសម្តី, សម្តីនឹងក្លាយជាទង្វើ, ទង្វើនឹងក្លាយជាទម្លាប់,ទម្លាប់នឹងក្លាយជា*

*ក្លាយជាគុណតម្លៃ ហើយគុណតម្លៃ នឹងបង្កើតបានជាជោគវាសនារបស់បុគ្គលនោះ"*។ យោងតាមសម្ដីរបស់អ្នកនិពន្ធសៀវភៅ "ទម្លាប់ទាំង ៧ សម្រាប់បុគ្គលជោគជ័យ ឬ 7 Habits of Hightly Effective People", លោក Stephen R. Covey ពោលថា "សាបព្រោះគំនិត ប្រមូលកាត់ទង្វើ, សាបព្រោះទង្វើ នឹងប្រមូលកាត់ទម្លាប់, សាបព្រោះទម្លាប់នឹងប្រមូលកាត់ចរិតលក្ខណៈ ហើយសាបព្រោះចរិតលក្ខណៈនឹងប្រមូលកាត់ជោគវាសនា" ។

ចំណែក លី ក្វាន់យូ [ Lee Kuan Yew ] និយាយថា "Culture Is Destiny" វប្បធម៌ គឺជាការសាបព្រោះចំណេះដឹង និងបញ្ញា គឺជនសង្គមមានបញ្ញាទៅបាន លុះត្រាតែទទួលបានការអប់រំប្រកបដោយវិន័យត្រឹមត្រូវ។ គាត់បន្តទៀតថា "ដើម្បីអភិវឌ្ឍន៍សង្ហបុរី គឺត្រូវអភិវឌ្ឍន៍ខួរក្បាលជនសង្ហបុរីជាមុនសិន"។ដូចនេះ ចូរឲ្យការសម្ដែងរបស់យើងក្លាយជាទម្លាប់ និងបង្កើតចរិតលក្ខណៈល្អ ជាមនុស្សពេញលេញក្នុងនាមជាជនសង្គម។

## ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

បើយើងមានសមត្ថភាព និងចរិតលក្ខណៈល្អ ចូរប្រកួតប្រជែងតំណែងជាអ្នកដឹកនាំ ព្រោះបើមនុស្សល្អមិនធ្វើអ្នកដឹកនាំ អ៊ីចឹងមានតែបណ្តោយឲ្យបុគ្គលអាក្រក់ធ្វើជាអ្នកដឹកនាំវិញ [ លទ្ធផល គឺវេទនា និងបំផ្លាញសង្គម ]។ យើងមិនអាចបង្កើតសង្គមល្អមួយសម្រាប់អនាគតប្រទេសជាតិយើង តែយើងអាចរៀបចំយុវជនឲ្យក្លាយជាធនធានសង្គមយ៉ាងល្អបានសម្រាប់អនាគត។

សូមឲ្យការចេះដឹងទាំងឡាយ កើតជាចរិតនៃមនុស្សដែលធ្លាប់អរិដ្ឋាទាំងឡាយ។ ការអប់រំ មិនសំដៅតែលើការចូលសាលាមួយមុខទេ តែវាសំដៅលើបុគ្គលបានរៀនសូត្រពីជីវិតពិត។ យើងមានសញ្ញាបត្រខ្ពស់ពីសាលារយៈពេល៤ឆ្នាំ តែឪពុកម្តាយគ្មានសញ្ញាបត្រពីមហាវិទ្យាល័យ អ៊ីចឹងតើពួកគាត់គ្មានការអប់រំឬ? ទេ! ពួកគាត់មានសញ្ញាបត្រតាមចំនួនឆ្នាំនៃជីវិតរស់នៅរបស់គាត់។

អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] និយាយថា *"គតិបណ្ឌិត មិនមែនបានមកពីសាលារៀនទេ តែទទួលបានមកពីការរស់នៅនៃជីវិតពិត"*៕

# ថ្ងៃទី១០ ខែសីហា

អាប្រាហាម លីនខូលន៍ [ Abraham Lincoln ] ពោលថា *"ពេលដែលខ្ញុំមិនចូលចិត្តនរណាម្នាក់ គឺខ្ញុំត្រូវតែព្យាយាមស្វែងយល់បន្ថែមទៀតពីបុគ្គលនោះ"។*

បើយើងមិនទាន់ស្គាល់នរណាម្នាក់ច្បាស់ទេ នោះក៏មិនគួរវិនិច្ឆ័យថានរណាម្នាក់អាក្រក់ ឬល្អផុតលេខនោះដែរ។ ប៉ុន្តែធម្មជាតិនៃមនុស្ស បើបានដាក់ចិត្តស្អប់នរណាម្នាក់ហើយ នោះយើងនឹងមើលឃើញតែកំហុសរបស់គេ ឬបើស្រឡាញ់នរណាម្នាក់ហើយ នោះនឹងរកសេចក្តីអាក្រក់របស់គេពុំឃើញឡើយ។

បើស្ថិតក្នុងសកម្មភាពជាអ្នកដើរតាមនយោបាយ ឬជាឧបករណ៍នយោបាយវិញ គឺថាបើស្រឡាញ់អ្នកដឹកនាំណាម្នាក់ហើយ ដឹងតែមិនចេះរិះគន់ឬរកចំណុចអាក្រក់នៃអ្នក

ដឹកនាំនោះពុំសូវមាន តែបើស្អប់មេដឹកនាំណាម្នាក់វិញ គឺរិះគន់ដល់អវសាន្ត។ តាមពិតមនុស្សត្រូវការការសង្គ្រោះ តែមិនមែនត្រូវការរុញទម្លាក់ទឹកជ្រោះ។ ដើម្បីជួយមនុស្សល្អ គឺត្រូវតាំងចិត្តធ្វើល្អ៕

# ថ្ងៃទី១១ ខែសីហា

ស៊ុន ជឺ [ Sun Tzu ] ពោលថា"*ចូររក្សាទំនាក់ទំនងជាមួយមិត្តភក្តិរបស់អ្នកឲ្យនៅជិតស្និទ្ធនឹងអ្នកជានិច្ច ហើយនឹងត្រូវរក្សាទំនាក់ទំនងជាមួយសត្រូវរបស់អ្នក ឲ្យកាន់តែជិតស្និទ្ធជាងមិត្តភក្តិរបស់អ្នកទៅទៀត*"។

ទំនាក់ទំនងមិត្តភក្តិ ត្រូវតែរក្សាទុកដើម្បីអាចជួយគ្នាបានទៅវិញទៅមក បង្កើនមិត្តថ្មី រក្សាមិត្តចាស់។ ប៉ុន្តែរក្សាទុកសត្រូវនៅក្បែរខ្លួន គឺងាយស្រួលឲ្យយើងដឹងពីស្ថានភាព ឬអាចស្ទង់ដឹងកម្លាំងពិតសត្រូវ ដើម្បីងាយស្រួលទាញយកប្រយោជន៍ ឬរកយុទ្ធសាស្ត្រដើម្បីកម្ចាត់។

នៅក្នុងសៀវភៅ "ល្បិចទល់មេឃ - មាន ៣ភាគ" បានលើកឡើងថា "បុគ្គលខ្លាំងផ្នែកយុទ្ធសាស្ត្រអាចឲ្យក្បាលដែលបានធ្លាក់ពីលើស្មាសត្រូវនិយាយអរគុណដល់ខ្លួន

ដែលជាអ្នកកាត់ក្បាលសត្រូវ"។ ក្នុងភាសាយុទ្ធសាស្ត្រ ពេលស្តាប់ទៅ ទំនងជាសាហាវ និងអសីលធម៌ ឬ អមនុស្សធម៌ខ្លាំងណាស់។ ប៉ុន្តែគ្រប់យ៉ាងលើលោកសុទ្ធតែមានមុខពីរជានិច្ចដោយអាស្រ័យលើអ្នកប្រើ៕

"Keep your friends close, keep your ememies closer."

# ថ្ងៃទី១២ ខែសីហា

អាល់ប៊ឺត កាមុស [ Albert Camus ] ពោលថា *"សេរីភាពមិនមែនជាអ្វីផ្សេង ក្រៅតែពីឱកាស ដើម្បីឲ្យមនុស្សមានភាពល្អប្រសើរជាងមុនប៉ុណ្ណោះ"*។ អាថ៌កំបាំងនៃសុភមង្គល គឺភាពមានសេរីភាព។ អាថ៌កំបាំងនៃការទទួលបានសេរីភាព គឺសេចក្ដីក្លាហាននៅក្នុងការទាមទារ។ តម្លៃនៃសេរីភាព គឺកើតចេញពីទំនួលខុសត្រូវរបស់ជនក្នុងសង្គម។ មានន័យថា បើមានការគាបសង្កត់នោះទំនួលខុសត្រូវរបស់ជនក្នុងសង្គម គឺត្រូវរើបម្រាស់។ សេរីភាព មិនមែនកើតឡើងដោយតែការចង់ឬមិនចង់ ឬចូលចិត្តឬស្អប់នោះទេ តែវាគឺជាសិទ្ធិដែលយើងគួរធ្វើ។

សេរីភាព គឺមានន័យថាយើងត្រូវបានគេរាំងមិនឲ្យជ្រើសរើសយកជីវិតរស់នៅដែលគ្រប់គ្នាប្រាថ្នាចង់បាន ឬក៏មានន័យមិនខុសគ្នាពីទម្រង់នៃទេសភាពនោះដែរ។

សេរីភាព គឺជាអ្វីដែលយើងត្រូវធ្វើតបជាមួយនឹងទង្វើដែលរដ្ឋាភិបាលបានធ្វើមិនល្អចំពោះយើង។ បើមានការបំបិទសិទ្ធិ គឺយើងត្រូវតបដោយការទាមទារសិទ្ធិ។ បើមានការគាបសង្កត់ គឺយើងត្រូវតបដោយការរើបម្រាស់ ហើយបើមានការប្រើយុទ្ធសាស្រ្តបំបែកសាមគ្គី គឺយើងត្រូវតបដោយការរួបរួមវិញ ៕

# ថ្ងៃទី១៣ ខែសីហា

*"គ្មានបុគ្គលណា គ្មានរដ្ឋាភិបាលណា ឬគ្មានអាទិទេពណា អាចនាំយកសត្វព្រាបនៃសេរីភាពមកឲ្យយើងបានទេ ក្រៅពីខ្លួនយើង"។*

គ្មាននរណាម្នាក់អាចនាំនូវភាពយុត្តិធម៌ និងសន្តិភាពឲ្យដល់យើងបានឡើយ គឺមានតែយើងខ្លួនឯងម្នាក់គត់ដែលអាចធ្វើបាន។ ដើម្បីឲ្យប្រជាជនក្នុងសង្គមមានសេរីភាពទៅបាន ជាដំបូងគេត្រូវមានការអប់រំត្រឹមត្រូវជាមិនសិន ពីព្រោះបើតាម លីក្វាន់ យូ ធ្លាប់បានលើកឡើងថា *"ការអប់រំនឹងធ្វើឲ្យមនុស្សមានសេរីភាព"*។

លោក ម៉ៅ សេទុង [ Mao Tse Tung ] មេដឹកនាំបដិវត្តន៍វប្បធម៌បាននិយាយថា "ពន្យល់ម្តងមិនយល់ នោះគឺត្រូវពន្យល់ពីរដង។ ពន្យល់ពីរដងមិនយល់ នោះគឺត្រូវពន្យល់បីដង។ ពន្យល់បីដងមិនយល់ នោះគឺត្រូវពន្យល់

ប្អូនដង។ មួយរយដង មួយពាន់ដង រហូតដល់អាចយល់បាន"។ ក្នុងរឿងអយុត្តិធម៌ ក៏ការទាមទារក៏អ៊ីចឹងដែរ គឺត្រូវធ្វើរាល់ថ្ងៃ ដូចយើងបរិភោគអាហារអ៊ីចឹង៕

# ថ្ងៃទី១៤ ខែសីហា

ស្ថាបនិកនៃក្រុមហ៊ុន Ford Motor, លោក ហែនរី ហ្វត [ Henry Ford ] ពោលថា *"មនុស្សដែលខុសពិតប្រាកដ គឺជាបុគ្គលដែលខុសហើយ តែមិនព្រមកែ មិនរៀនសូត្រពីកំហុស និងអនុញ្ញាតឲ្យកំហុសនោះកើតឡើងម្តងទៀត"*។ទស្សនវិទូ ស៊ីសឺរ៉ូ [ Cicero ] ពោលថា "មនុស្សកើតមកតែងតែបង្កើតកំហុស ប៉ុន្តែមនុស្សល្ងង់តែងបណ្តាលឲ្យកំហុសនោះកើតឡើងដដែល"។

អច្ឆរិយបុគ្គលស.វទី២០ លោក អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] បានពោលថា *"មនុស្សដែលខ្លាចក្នុងការបង្កើតកំហុស គឺនឹងគ្មានឱកាសបានសាកល្បងនូវអ្វីដែលថ្មីទេ"*។ ការពិត នៅតែជាពិត ហើយរឿងដែលនឹងកើតឡើង គង់តែកើតឡើង គ្រាន់តែមុន ឬក្រោយប៉ុណ្ណោះ។

គតិបណ្ឌិតពិតប្រាកដ មិនមែនបានមកពីការអប់រំនៅសាលា តែកើតចេញពីបទពិសោធន៍ជាក់ស្តែងក្នុងជីវិតពិត ។ កំហុសបង្រៀនមេរៀនជាច្រើនដល់មនុស្ស ទាំងភាពឈឺចាប់ និងភាពរីករាយ ៕

## ថ្ងៃទី១៥ ខែសីហា

មហាត្មៈ គន្ធី [ Mohatma Gandhi ] ពោលថា "*សេរីភាពគ្រប់យ៉ាងនឹងក្លាយជាគ្មានតម្លៃ ប្រសិនបើសេរីភាពនៃការបង្កើតកំហុសរបស់មនុស្ស ត្រូវបានហាមឃាត់*"។

សង្គមដែលគ្មានប្រវត្តិសាស្ត្រឈឺចាប់ នោះនឹងធ្លាក់ក្នុងហាយនភាព។ សង្គមដែលមានប្រវត្តិសាស្ត្រហើយ ប៉ុន្តែមនុស្សក្នុងសង្គមមិនដាក់ចិត្តរៀនសូត្រ ស្វែងយល់ និងវិភាគឲ្យបានល្អិតល្អន់នោះទេ គឺសង្គមនោះមិនធ្លាក់ក្នុងស្ថានភាពហាយនភាពទេ តែគឺត្រូវរលាយបាត់ឈ្មោះតែម្តង។ ការវិភាគប្រវត្តិសាស្ត្រ ត្រូវការចំណេះដឹងសង្គមវិទ្យា និងទស្សនវិជ្ជា បើមិនអើពើចឹងទេ យើងនឹងមិនអាចរៀនមេរៀនប្រវត្តិសាស្ត្របានលំអិតស៊ីជម្រៅទេ៕

# ថ្ងៃទី១៦ ខែសីហា

អារីស្តូត [ Aristotles ] ពោលថា "*អប់រំតែគំនិត តែមិនគិតដល់បេះដូង គឺមិនអាចចាត់ទុកថាការអប់រំល្អនោះទេ តែអាចហៅបានត្រឹមតែជា (ភាពទទេ)* "។

ការឆេវឆាវ ការឆាប់ខឹង ការឆាប់រំភើប ការច្រណែន ការឈ្នានីស ការគុំគួន ការសងសឹក សុទ្ធតែកើតចេញពីបេះដូងដែលមិនមានការហ្វឹកហាត់ពត់លត់ដំឲ្យល្អ។ ចំណេះដឹង និងសមត្ថភាពអាចរកបាន តែទឹកចិត្តបរិសុទ្ធមិនងាយរក ឬអាចរកបានបន្តិចបន្តួចពីមនុស្សមួយចំនួន ឬពីកូនក្មេង។ ការសាបព្រោះចំណេះដឹងខុស បៀបដូចសាបព្រោះគ្រោះភ័យដល់សង្គមទាំងមូលពេញមួយជំនាន់ ៕

# ថ្ងៃទី១៧ ខែសីហា

*"សាបព្រោះចំណេះដឹងខុស និងសាបព្រោះខុសមនុស្ស បៀបដូចសាបព្រោះគ្រោះភ័យដល់សង្គមទាំងមូល"។*

មានសេចក្ដីសុចរិតដោយគ្មានចំណេះដឹង គឺជាភាពទន់ខ្សោយមួយ។ ចំណែកការប្រើចំណេះដឹងដោយគ្មានគោរពគោលការណ៍សុចរិតភាព នោះនឹងនាំមកនូវគ្រោះថ្នាក់ដែលគួរឲ្យខ្លាចញញើតបំផុត។ ចំណេះដឹងចាំបាច់ត្រូវបូករួមជាមួយនឹងគោលការណ៍សុចរិតត្រឹមត្រូវ តែភាពសុច្ចរិតត្រឹមត្រូវមិនចាំបាច់មានគោលការណ៍នោះទេ។ ភាពខ្លាំងក្លានៃជាតិសាសន៍មួយ គឺកើតចេញមកពីសេចក្ដីសុចរិតទៀងត្រង់របស់ជនសង្គមគ្រប់រូប៕

# ថ្ងៃទី១៨ ខែសីហា

*"យើងមិនអាចជ្រើសរើសការចាប់ផ្ដើម ហើយយើងក៏មិនអាចជ្រើសរើសការបញ្ចប់ដូចគ្នាដែរ។ ប៉ុន្តែក្នុងចន្លោះពេលនៃការចាប់ផ្ដើម និងការបញ្ចប់ យើងអាចជ្រើសរើសយកថាយើងជានរណា"*។

យើងមិនមិនអាចធ្វើរឿងគ្រប់យ៉ាង សម្រាប់មនុស្សគ្រប់គ្នានៅគ្រប់ទីកន្លែង។ ប៉ុន្តែយើងអាចជ្រើសរើសធ្វើរឿងមួយចំនួន សម្រាប់មនុស្សមួយចំនួន នៅកន្លែងមួយចំនួនបាន។ យើងមិនអាចផ្លាស់ប្ដូរពិភពលោកទាំងមូលបាន យើងមិនអាចផ្លាស់ប្ដូរអតីតកាលបាន យើងមិនអាចទាយដឹងពីអនាគតបាន ប៉ុន្តែយើងអាចជ្រើសរើសផ្លាស់ប្ដូរខ្លួនយើងបាន និងយើងក៏អាចព្យាករណ៍ថា យើងនឹងក្លាយទៅជានរណាពេលអនាគត៕

We cannot choose our beginnings... we can't choose our end, but the moments in between...we choose who we are.

# ថ្ងៃទី១៩ ខែសីហា

កាលពី៤ឆ្នាំមុន ខ្ញុំបានអានសៀវភៅមួយក្បាល ដែលមានចំណងជើងថា *"លក្ខខណ្ឌរបស់មេដឹកនាំ"* ដែលនិពន្ធដោយជនជាតិជប៉ុន និងបានប្រែសម្រួលជាខេមរភាសា។ សៀវភៅនោះសរសេរពាក្យមួយឃ្លាថា *"បុគ្គលដែលបានលះបង់ខ្លួនដើម្បីសង្គមជាតិច្រើនយ៉ាងណា គឺគេនឹងទទួលបានផលតបស្នងវិញយ៉ាងស័ក្តិសម"*។

លោកប្រធានាធិបតី តេអូឌ័រ រ៉ូសាវែល [ Theodore Rooselvelt ] បានពោលថា *"ទឹកចិត្តស្នេហាជាតិនិយមមានន័យថាសុខចិត្តពលីជីវិតដើម្បីប្រទេសជាតិខ្លួន ប៉ុន្តែមិនមែនសុខចិត្តស្លាប់ខ្លួនដើម្បីមេដឹកនាំណាម្នាក់ ឬរដ្ឋាភិបាលណាមួយនោះទេ"*។ លោក Mark Twain បានលើកឡើងថា *"ចូររក្សាភាពស្មោះត្រង់នឹងជាតិជានិច្ចរៀងទៅ ហើយនឹងរក្សាភក្តីភាពចំពោះរដ្ឋាភិបាលនៅពេលដែលគួរឲ្យភក្តីប៉ុណ្ណោះ"*។

អ្នកប្រាជ្ញចិន ស៊ូសឺ ឬ ស៊ូតុងប៉ [ Su Tungpo ] ក្នុងសម័យរាជានិយម ពោលថា *"រវាងព្រះមហាក្សត្រ និងប្រជារាស្ត្រ គឺត្រូវស្មោះត្រង់ជាមួយប្រជារាស្ត្រមុនព្រះរាជា ព្រោះរាស្ត្រគ្មានកំហុស តែព្រះរាជាមានកំហុស"*។

ជាធម្មជាតិ មនុស្សដែលទម្លាប់ខ្លួននឹងការជេរប្រមាថដើម្បីអប់រំមនុស្ស គឺគេមិនសូវចេះនិយាយពាក្យពីរោះដើម្បីអប់រំមនុស្សទេ។ មនុស្សដែលធ្លាប់ ឬទម្លាប់ផឹកស្រា គឺគេមិនអាចពូកែផឹកទឹកតែនោះទេ។ មនុស្សដែលមានសមត្ថភាពត្រឹមតែពន្លត់ភ្លើងសង្គ្រាម នោះក៏មិនមានន័យថាចេះបង្កើតសន្តិភាពនោះដែរ។

បិតារូបវិទ្យា អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] ពោលថា *"សង្គ្រាមរលត់ តែគ្មានសន្តិភាព"*។ ជាទូទៅពេលសង្គ្រាមចប់ សន្តិភាពត្រូវបែកចេញជាពីរ៖ សន្តិភាពវិជ្ជមាន [ Positive Peace ] និងសន្តិភាពអវិជ្ជមាន [ Negative Peace ]។

លោក ចន ហ្វ៊ីឌីរ៉ល កេណ្ណឌី [ John F. Kennedy ] ពោលទុកថា *"មនុស្សម្នាក់អាចស្លាប់ដើម្បីជាតិរស់ ឬជាតិរលាយ ប៉ុន្តែគំនិតជាតិយម [ Nationalism ]និងទឹកចិត្តស្នេហាជាតិ [ Patriotism ] រស់នៅជានិច្ច"*៕

# ថ្ងៃទី២០ ខែសីហា

*"បញ្ហាពិបាកបំផុត គឺមិនមែនការផ្លាស់ប្តូរសង្គមនោះទេ ប៉ុន្តែគឺជាបញ្ហានៃការផ្លាស់ប្តូរខ្លួនយើង"។*

ប្រឹងប្រែងអភិវឌ្ឍន៍សមត្ថភាពខ្លួនឯងជាមុន នោះសង្គមនឹងអភិវឌ្ឍន៍តាមក្រោយដោយស្វ័យប្រវត្តិ។ ប្រឹងប្រែងដោះស្រាយបញ្ហាលំបាកជាមុន នោះកិច្ចការងាយស្រួលនឹងត្រូវបានដោះស្រាយតាមក្រោយដោយស្វ័យប្រវត្តិ។ ចង់បានសង្គមល្អ គឺខ្លួនយើងត្រូវធ្វើខ្លួនជាមនុស្សល្អជាមុនសិន ហើយចង់បានសង្គមសាមគ្គី គឺយើងត្រូវចេះអភ័យទោសឲ្យគ្នាជាមុនសិន។ បដិវត្តន៍ផ្នត់គំនិតឆ្នាំថ្មី គឺប្រឹងប្រែងរៀន ប្រឹងប្រែងអាន ទម្លាក់ភាពជាអ្នកមានអំនួត ទម្លាក់ភាពជាអ្នកចេះតែម្នាក់ឯង ទម្លាក់ភាពជាអ្នកមានសម្តីបំពាន និងទម្លាក់ភាពជាអ្នកប្រើសម្តីអសុរោះ៕

# ថ្ងៃទី២១ ខែសីហា

*"គ្មាននរណាស្គាល់ប្រទេសមួយយ៉ាងពិតប្រាកដបានទេ លុះត្រាតែគេនោះបានចូលទៅនៅក្នុងគុករបស់ប្រទេសនោះ"*

។ ២៧ឆ្នាំក្នុងគុករបស់ ណែលសិន ម៉ែនដេឡា [ Nelson Mandela, former President of South Africa ] គឺជាការអត់ធន់រង់ចាំយ៉ាងយូរអង្វែងបំផុត ដើម្បីការផ្លាស់ប្តូរ។ គាត់បាននិយាយថា *"គ្មាននរណាស្គាល់ប្រទេសមួយយ៉ាងពិតប្រាកដបានទេ លុះត្រាតែគេនោះបានចូលទៅនៅក្នុងគុករបស់ប្រទេសនោះ។ យើងមិនគួរវាយតម្លៃប្រទេសណាមួយលើវិធីដែលរដ្ឋាភិបាលនៃប្រទេសនោះ បានប្រតិបត្តិចំពោះប្រជាពលរដ្ឋថ្នាក់ខ្ពស់។ ប៉ុន្តែ គួរមើលលើវិធីដែលរដ្ឋាភិបាលប្រតិបត្តិចំពោះប្រជាពលរដ្ឋ ដែលស្ថិតនៅក្នុងស្ថានភាពតូចទាបបំផុត ហើយចំពោះទស្សនៈរបស់ខ្ញុំ រដ្ឋាភិបាលរបស់សហភាពអាហ្វ្រិក បានប្រតិបត្តិចំពោះប្រជាពលរដ្ឋអាហ្វ្រិកដូចគ្នាទៅនឹងការបតិបត្តិចំពោះសត្វធាតុ"*។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] និយាយថា *"ខ្ញុំនិយាយទៅកាន់មនុស្សគ្រប់គ្នាតាមរបៀបដូចគ្នា មិនថាអ្នកនោះគឺជាមនុស្សសំរាម ឬអ្នកនោះជាប្រធានាធិបតីនៃប្រទេសមួយនោះទេ"*។ ទុក្ខវេទនា របស់ប្រជាជនក្រីក្រ ប្រជាជនស្លូតត្រង់ គឺគ្រប់គ្រាន់ឲ្យមនុស្សមួយចំនួនស្រក់ទឹកភ្នែកឆ្អែតចិត្ត ព្រោះអយុត្តិធម៌សង្គម ព្រោះអំពើពុករលួយ ព្រោះការប្រើអំណាចហួសដែនរបស់លោកអ្នកធំ។ ក្នុងនាមជាពាស្ត្រ មានឈាមជ័រតែមួយ សូមផ្តល់ក្តីអាណិតអាសូរ និងជួយសង្គ្រោះតាមលទ្ធភាព ស្របនឹងគោលការណ៍ទ្រឹស្តីបទមួយលើកឡើងថា *"យើងមិនអាចធ្វើរឿងគ្រប់យ៉ាង សម្រាប់មនុស្សគ្រប់គ្នា នៅគ្រប់ទីកន្លែងទាំងអស់ តែយើងអាចធ្វើរឿងមួយចំនួន សម្រាប់មនុស្សមួយចំនួន នៅកន្លែងមួយចំនួនបាន"*។ ដុំថ្មតូចមួយ គឺគង់តែអាចធ្វើឲ្យមានទឹករលកបាន បើយើងតាំងចិត្តគប់វាចូលទៅក្នុងទឹក ហើយចំណែកមនុស្សយើង បើទោះបីជាខ្លួនយើងយល់ថាខ្លួនឯងមិនមានតម្លៃយ៉ាងណាក៏ដោយ តែក៏គង់នៅតែមានប្រយោជន៍៕

# ថ្ងៃទី២២ ខែសីហា

*"មនុស្សដែលចង់ក្លាយខ្លួនជាជនអស្ចារ្យ តែងតែធ្វើឲ្យអ្នកដទៃមានអារម្មណ៍តូចទាបជាងខ្លួន តែបុគ្គលដែលអស្ចារ្យពិតប្រាកដ គឺជាជនដែលតែងតែធ្វើឲ្យអ្នកដទៃ មានអារម្មណ៍ខ្លាំងអស្ចារ្យជាងខ្លួន"*។

ទ្រឹស្តីចិត្តវិទ្យាអះអាងថា *"សរសើរលើកទឹកចិត្តនរណាម្នាក់ម្តង នោះបានត្រឹមតែផ្តល់កម្លាំងចិត្តដល់គេម្តង តែបើសរសើរទឹកចិត្តគេម្តងហើយម្តងទៀត នោះអ្នកដែលយើងសរសើរលើកទឹកចិត្តនឹងក្លាយជាអ្វីដែលយើងតែងតែពោលសរសើរលើកទឹកចិត្ត"*។ ចូរទុកសេចក្តីភ័យខ្លាចក្នុងខ្លួនរបស់យើងចុះ ហើយចូរចែករំលែកនូវកម្លាំងចិត្តរបស់យើងដល់អ្នកដទៃផង ៕

# ថ្ងៃទី២៣ ខែសីហា

*"រូបសម្រស់ខាងក្រៅ គឺជាអ្វីដែលប្រែប្រួលមិនទៀង តែសេចក្តីស្លាប់គឺទៀងណាស់។ សម្បកកាយខាងក្រៅ គឺជាអ្វីដែលគ្រប់គ្នាអាចមើលឃើញនឹងភ្នែកទទេ ប៉ុន្តែចិត្តគំនិតព្រលឹង និងស្មារតី មិនអាចប្រើភ្នែកទាំងគូមើលឃើញបានឡើយ"។*

អ្នកស្រី ហេឡិន ឃែល័រ [ Helen Keller ] បាននិយាយថា "គ្រប់យ៉ាងដែលល្អបំផុត និងស្រស់ស្អាតបំផុតលើលោកយើងនេះ គឺមិនអាចមើលឃើញដោយភ្នែកទទេ ឬត្រឹមប៉ះដោយដៃបានទេបានឡើយ ប៉ុន្តែវាជាអ្វីទាំងឡាយដែលយើងពាល់ត្រូវតាមរយៈអារម្មណ៍ និងបេះដូង"។ ចូរផ្តល់តម្លៃដល់មនុស្សគ្រប់គ្នាឲ្យខ្ពស់ប្រហែលគ្នា បើទោះបីជាអ្នកខ្លះមិនខ្ពង់ខ្ពស់ដូចយើងក៏ដោយ។

លោក អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] បានទូន្មានយើងឲ្យនិយាយទៅកាន់មនុស្សទាំងអស់ក្នុងអាកប្បកិរិយាល្អ និងឲ្យតម្លៃមនុស្សស្មើគ្នា បើទោះពួកគេជានរណាក៏ដោយ ឬអ្នកសុំទានក៏ដោយ ៕

# ថ្ងៃទី២៤ ខែសីហា

*"គំនិតឯកតែមួយ ក៏ប្រហែលជាអាចមានអនុភាពខ្លាំងជាងកម្លាំងមនុស្សរាប់រយនាក់ និងមានអនុភាពខ្លាំងជាងកម្លាំងសត្វរាប់រយក្បាល ហើយក៏មានអនុភាពខ្លាំងជាងម៉ាស៊ីនរាប់រយផងដែរ"*។ បើពេលនេះ យើងមានពេលវេលាច្រើនជាងមួយថ្ងៃ ចូរដាំផ្កា ហើយបើមានពេលវេលាច្រើនជាងជាងមួយឆ្នាំ ចូរដាំដើមឈើ។ ប៉ុន្តែ បើយើងមានពេលវេលាពេញមួយជីវិត ចូរដាំគ្រប់ពូជនៃគំនិត។ មនុស្សដែលរស់នៅខ្លី តែបានដាំគ្រាប់ពូជនៃគំនិតច្រើននឹងរស់នៅជាអមតៈ។ ចំណែកឯ មនុស្សដែលរស់នៅវែងតែឥតបានដាំគ្រាប់ពូជនៃគំនិតអ្វីសោះ នឹងស្លាប់បាត់ឈ្មោះជារៀងរហូត។ មនុស្សអាចស្លាប់គ្រប់ពេលវេលាតែគំនិតនឹងមិនងាយបាត់បង់ឡើយ៕ "One single idea may greater weight than the labor of all men, animals and engines for century." -Ralph Waldo Emerson

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

## ថ្ងៃទី២៥ ខែសីហា

*"បើយើងជាមនុស្សដែលស្រឡាញ់សេរីភាព គឺមានន័យថា យើងស្រឡាញ់អ្នកដទៃ តែបើយើងជាមនុស្សស្រឡាញ់តែអំណាច និងចង់បានអំណាចក្នុងដៃ នោះគឺមានន័យថា យើងស្រឡាញ់តែខ្លួនឯងប៉ុណ្ណោះ"។*

អំណាចធំនៅក្នុងលោក គឺអំណាចនៃក្តីស្រឡាញ់ ពីព្រោះមនុស្សចាប់កំណើតបានដោយសារតែក្តីស្រឡាញ់។ ពេលដែលមនុស្សស្រឡាញ់អំណាច [ Love of Power ] ត្រូវបានអំណាចនៃក្តីស្រឡាញ់ [ Power of Love ] បន្ទន់ចិត្តបានហើយ គឺពិភពលោកទាំងមូលនឹងស្គាល់សន្តិភាពពិតប្រាកដ។

ស្រឡាញ់គ្នា នឹងបង្កើតសាមគ្គីនឹងគ្នាដោយមិនបែកបាក់។ សាមគ្គីគ្នាបាន លុះត្រាតែយើងចេះមើលលើចំណុចស្របគ្នាសិន ដោយមិនមើលលើចំណុចឈ្លោះគ្នា។

## ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

យើងមិនឈ្លោះគ្នា ដោយសារតែយើងស្រឡាញ់គ្នា គិតដល់ប្រយោជន៍អ្នកដទៃជាធំ។ បុគ្គលដែលគិតប្រយោជន៍រួមជាធំ គឺដោយសារតែស្រឡាញ់សន្តិភាពសង្គម។ នេះហើយដែលហៅថា *"សេចក្តីស្រឡាញ់ជាអំណាចធំក្នុងលោក"*។

The love of liberty is the love of others the love of power is the love of ourselves. -William Hazlitt

# ថ្ងៃទី២៦ ខែសីហា

*"ចូរប្រព្រឹត្តទៅលើមនុស្សល្អដោយសេចក្ដីល្អ ហើយក៏ត្រូវប្រព្រឹត្តទៅលើមនុស្សមិនល្អដោយសេចក្ដីល្អផងដែរ។ ធ្វើដូច្នេះ សេចក្ដីល្អក៏នឹងកើតឡើងចំពោះគ្រប់គ្នា។ ចូរស្មោះត្រង់ជាមួយមនុស្សដែលស្មោះត្រង់ ហើយក៏ត្រូវបង្ហាញភាពស្មោះចំពោះមនុស្សដែលមិនស្មោះត្រង់ផងដែរ។ ធ្វើដូច្នេះ សេចក្ដីស្មោះត្រង់នឹងកើតឡើងចំពោះគ្នា"។*

គំនិត និងទង្វើរបស់បុគ្គលបែបណា ក៏នឹងបង្កើតសង្គមមួយបែបនោះ។ សង្គមល្អ ដោយសារមានមនុស្សល្អច្រើន ហើយបើសង្គមអាក្រក់ ក៏ដោយសារមានមនុស្សអាក្រក់ច្រើន។ ជាយុទ្ធសាស្ត្រ មនុស្សល្អ ត្រូវជួយទាញ និងកែប្រែមនុស្សអាក្រក់ឲ្យដើរផ្លូវល្អ។ ប៉ុន្តែ បើប្រឹងទាញមិនបានទេ ដាច់ខាតដកចេញ ពីព្រោះទុកក៏មិនចំណេញ ហើយម្យ៉ាងមានតែបង្កហេតុគ្រោះថ្នាក់ដល់សង្គម។

ឡាំ លីម

ចំពោះមនុស្សអាក្រក់ តែងគិតថា "មនុស្សក្នុងលោក មិនសំខាន់ថានរណាមានហេតុផលល្អ ឬហេតុផលអាក្រក់ទេ តែសំខាន់បើការរស់នៅគ្មានលទ្ធផល នោះពិភពលោកនឹងហៅគេថា *"មនុស្សបោលម្សៀត"*។

Treat those who are good with goodness, and also treat those who are not good with goodness. Thus, goodness is attained. Be honest to those who are honest, and be also honest to those who are not honest. Thus, honesty is attained.

- Lao Tzu

# ថ្ងៃទី២៧ ខែសីហា

*"មនុស្សដែលអស់សង្ឃឹមក្នុងជីវិត គឺនឹងអស់ជីវិត ហើយ មនុស្សដែលអស់ជីវិត ក៏នឹងបាត់បង់អស់គ្រប់យ៉ាងក្នុង ជីវិត"*។

មានជីវិត គឺមានសង្ឃឹម តែបើអស់ជីវិត គឺអស់គ្រប់យ៉ាង។ គ្រប់យ៉ាងមានតម្លៃបំផុតសម្រាប់ជីវិត ហើយក្តីសង្ឃឹម របស់មនុស្ស ក៏មានតម្លៃស្មើជីវិតផងដែរ។ កុំសង្ឃឹម ថាខ្លួននឹងរស់នៅជាអតមៈ តែត្រូវសង្ឃឹមថាតម្លៃជីវិតរបស់ ខ្លួន នឹងមានអ្នកជំនាន់ក្រោយចងចាំជាអតមតៈ។

The man who stopped hoping, stopped living, has nothing. - Great Jewish Quotes, book.

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

## ថ្ងៃទី២៨ ខែសីហា

"សុខចិត្តឲ្យគេគោរពយើង ព្រោះស្រឡាញ់ ប្រសើរជាងឲ្យគេស្រឡាញ់យើងព្រោះខ្លាច"។ អ្នកដទៃគោរពយើងមិនស្មើនឹងយើងគោរពខ្លួនឯង ហើយបើយើងគោរពគេ សូមកុំភ្លេចគោរពខ្លួនឯងឲ្យសោះ។ អ្នកដទៃបន្ទាចយើង មិនអាក្រក់ស្មើនឹងយើងបន្ទាចខ្លួនឯង ហើយបើគេបន្ទាចយើង សូមយើងកុំបន្ទាចខ្លួនឯងឲ្យសោះ៕

Obeying from love is better than to love from fear.

- Great Jewish Quotes, book.

# ថ្ងៃទី២៩ ខែសីហា

លោក ស៊ីវ ខេរ៉ា [ Shiv Kera ] ពោលថា "*ប្រសិនបើយើងជាមនុស្សឆ្លាតច្រើនជាងល្ងង់ ជាមនុស្សល្អច្រើនជាងអាក្រក់ ជាមនុស្សមានសីលធម៌ច្រើនជាងថោកទាប មិនខ្វល់ថាយើងមានសញ្ញាបត្រកម្រិតណាទេ តែយើងនឹងត្រូវបាន គេចាត់ទុកជាបុគ្គលដែលទទួលបានការអប់រំល្អហើយ*"។

មហាត្មៈ គន្ធី បានពោលថា "ចំណេះដឹង ដោយគ្មានជ្រាបចូលជាចរិត ឬ Knowledge Without Character" គឺជាអំពើបាបមួយក្នុងចំណោមអំពើបាបទាំង ៧។ ចំណេះដឹងមិនជ្រាបចូលជាចរិត គឺចង់មានន័យដល់អ្នកមានចំណេះដឹងច្រើន តែបែរជានៅតែនិយាយសម្តីអាក្រក់ និងប្រព្រឹត្តទង្វើអាក្រក់។ គំនិតល្អ នឹងនាំមកនូវសម្តីល្អ។

សម្តីល្អ នឹងនាំមកនូវទង្វើល្អ ហើយទង្វើល្អ នឹងនាំមកនូវលទ្ធផលល្អ។ ប៉ុន្តែ បើគំនិតល្អ សម្តីអាក្រក់ នឹងគ្មានអ្នកស្តាប់តាម។ បើគ្មានអ្នកស្តាប់តាម ក៏គ្មានអ្នកធ្វើតាម។ បើគ្មានអ្នកធ្វើតាម ក៏នឹងគ្មានកើតជាផល៕

"If they have the ability to choose between wisdom and foolishness, between good and bad, between virtuousness and vulgarities, regardless of the academic degrees they have, then they are educated." - Shiv Kera

# ថ្ងៃទី៣០ ខែសីហា

*"ការអាន មិនអាចឲ្យយើងគ្រប់គ្នាក្លាយទៅជាអ្នកដឹកនាំបានពិតមែន ក៏ប៉ុន្តែវាអាចប្រាប់យើងឲ្យដឹងថា តើបុគ្គលប្រភេទណា ដែលយើងគួរដើរតាម។ អ្នកអានទាំងអស់មិនអាចសុទ្ធតែនឹងក្លាយ ទៅជាអ្នកដឹកនាំទេ តែគ្រប់អ្នកដឹកនាំទាំងអស់ សុទ្ធតែជាអ្នកអាន"។*

កុំចាត់ទុកអ្នកដទៃជាមនុស្សល្ងង់ តែត្រូវប្រដៅខ្លួនឯងឲ្យបានល្អ។ ទេពកោសល្យ គឺព្រះជាម្ចាស់ជាអ្នកប្រទានឲ្យយើង ដូច្នេះចូរយើងចេះដាក់ខ្លួន។ កិត្តិនាមល្បីល្បាញគឺអ្នកដទៃជាអ្នកឲ្យ ដូច្នេះចូរយើងចេះថ្លែងអំណរគុណ។ រីឯភាពអំនួតអួតក្អេងក្អាង គឺយើងជាអ្នកបង្កើតឡើងដោយខ្លួនឯង ដូច្នេះចូរយើងចេះប្រុងប្រយ័ត្ន៕

ទស្សនៈសម្រាប់ខែ

# កញ្ញា

# ថ្ងៃទី០១ ខែកញ្ញា

*"សុភមង្គលនៃសង្គមមួយ គឺជាអវសានន្តនៃរដ្ឋាភិបាលមួយ"* ។ បើសង្គមល្អ ក៏មិនចាំបាច់មានរដ្ឋអំណាច តែបើសង្គមមិនល្អ ក៏គួរតែត្រូវមានច្បាប់ និងមានប្រព័ន្ធដឹកនាំរដ្ឋអំណាច។ ច្បាប់ជាអក្សរ តែមនុស្សជាអ្នកអនុវត្ត។ ច្បាប់គឺជាច្បាប់ តែមិនមែននៅលើមាត់។ ច្បាប់ជាអ្នកគ្រប់គ្រងមនុស្ស តែមិនមែនយកមនុស្សមកគ្រប់គ្រងមនុស្សទេ។ តើសង្គមខ្មែរ យកច្បាប់ជាអ្នកគ្រប់គ្រងលើមនុស្ស ឬយកអ្នកមានអំណាចជាអ្នកគ្រប់គ្រងលើមនុស្ស? តើយុវជនគួរធ្វើជាអ្នកចេះ ឬគួរធ្វើជាអ្នកដឹង? អ្នកចេះ គឺអភិរក្សនិយម ហើយអ្នកដឹង គឺជ្រុលនិយម។ អ្នកចេះ គឺស្ងាត់ តែអ្នកដឹងពេលខ្លះគឺត៉វ៉ាទាំងងងឹតងងុល។ ប្រឹងរៀន ប្រឹងអានសន្តិភាពនិយម មិនឈ្លោះគ្នាឯង និងកុំឲ្យគេទិញបានបើទោះបីជាខ្លួនក្រក៏ដោយ៕ *"The happiness of society is the end of government."* - John Adams

# ថ្ងៃទី០២ ខែកញ្ញា

*"យើងត្រូវតែនិយាយពីចិត្តដែលមានសន្តិភាព។ ចិត្តបុគ្គលគ្រប់រូបក្នុងសង្គមមានសន្តិភាព វាក៏នឹងជំរុញឲ្យសង្គមមានសន្តិភាពផងដែរ"*។ មនុស្សកើតចេញពីសង្គម ហើយសង្គមបង្កើតវប្បធម៌ឲ្យមនុស្ស។ មនុស្ស គឺជាកោសិកានៃសង្គម ហើយចិត្តគំនិតបុគ្គលក្នុងសង្គមបែបណា ក៏នឹងបង្ហាញពីចរិតសង្គមនោះបែបនោះដែរ។ អកុសលនៃចិត្តរបស់យើង និងអកុសលចិត្តរបស់អ្នកដទៃ គឺជាមូលហេតុនៃសេចក្ដីទុក្ខសោកទាំងឡាយរបស់ពិភពលោកទាំងមូល។ ពេលណាចិត្តយើងបានប្រែទៅជាបរិសុទ្ធ ខ្សែជីវិតរបស់យើងក៏នឹងបើកចំហសម្រាប់យើងខ្លួនឯងដោយគ្មានទីបំផុត។ បន្ទាប់មក យើងមានសេចក្ដីសប្បាយរីករាយ ហើយយើងក៏នឹងចែករំលែកសុភមង្គលពិតប្រាកដឲ្យដល់អ្នកដទៃទៀតផងដែរ៕ *"We have to talk about liberating minds as well as liberating society."* - Angela Davis

# ថ្ងៃទី០៣ ខែកញ្ញា

"ក្នុងរដូវស្លឹកឈើជ្រុះ ស្លឹកឈើចាស់នឹងលាដើមឈើដែលខ្លួនធ្លាប់អាស្រ័យនៅជាមួយពីមុន។ ការព្រាត់ចាកពីគ្នារវាងស្លឹកឈើ និងដើមឈើ គ្មានសូម្បីតែសំឡេងជូនពរ ហើយក៏គ្មានសូម្បីតែសំឡេងយំអាសូរអាល័យ"។

ការចេះរង់ចាំដើម្បីចាប់ផ្តើមជាថ្មី គឺប្រៀបដូចជាការទទួលយកសេចក្តីស្លាប់ទាំងញញឹមដើម្បីឲ្យឆាប់បានចាប់ជាតិកើតជាថ្មី។ ជីវិត ការរំដោះទុក្ខជីវិត ហើយពេលខ្លះ វាតម្រូវឲ្យយើងចេះរង់ចាំ និងរង់ចាំដោយចិត្តអំណត់តស៊ូ។ ការរង់ចាំ គឺរង់ចាំឲ្យសេចក្តីទុក្ខធ្វើដំណើរឆ្លងកាត់ឲ្យផុតដើម្បីឲ្យសេចក្តីសុខធ្វើដំណើរចូលមកជំនួស។ មហាបុរសណោលសាន់ មែនដេឡា [ Nelson Mandela ] គឺជាគំរូអស្ចារ្យនៃការចេះរង់ចាំថ្ងៃថ្មី ជាថ្ងៃថ្មីដែលជនជាតិស្បែកខ្មៅទាំងឡាយត្រូវទទួលបានសិទ្ធិសេរីភាពស្មើគ្នាដោយគ្មាន

ការរើសអើងទៀតទេ។ ២៧ឆ្នាំក្នុងគុក គឺគ្រាន់តែជាការជ្រុះនូវស្លឹកឈើនៃក្ដីសង្ឃឹមក្នុងទ្រង់ទ្រាយតូចតាចមួយប៉ុណ្ណោះ ដើម្បីលាស់ស្លឹកឈើនៃក្ដីសង្ឃឹមក្នុងទ្រង់ទ្រាយធំមួយខាងមុខ។ ជីវិតយើងក៏ដូចគ្នាដែរ បើទោះបីជាមិនអាចដូចព្រះអាទិត្យ ដែលចាំងពន្លឺនាំផ្លូវមនុស្សសត្វទាំងឡាយ ឬបើទោះបីជាមិនអាចដូចពន្លឺផ្កាយចម្រុះពណ៌ ដែលបំភ្លឺផ្ទៃមេឃានាពេលរាត្រីក៏ដោយ តែយើងអាចធ្វើជាពន្លឺភ្លើងទៀនសម្រាប់បំភ្លឺផ្លូវឲ្យខ្លួនឯង ឬក៏សម្រាប់មនុស្សមួយចំនួនផងដែរ៕

# ថ្ងៃទី០៤ ខែកញ្ញា

លោក ភី. ជេ អាប់ឌុលកាឡាំ [ Abdul Kalam ] ពោលថា *"ដើម្បីអាចធ្វើឲ្យសុបិនក្លាយជាការពិតទៅបាន ដំបូងយើងត្រូវតែមានសុបិនជាមុនសិន"*។

ដើម្បីឲ្យយើងអាចសម្រេចគោលដៅទៅបាន ដំបូងត្រូវបានគោលដៅសិន។ ជីវិតដែលគ្មានគោលដៅ គឺជាជីវិតបរាជ័យ។ សូមសុបិនធ្វើជាដួងចន្ទ តែបើមិនបានធ្វើជាដួងចន្ទទេ យ៉ាងហោចណាស់ ក៏អាចបានក្លាយជាតារាមួយដួងដែរ។ សុបិនមិនមែនជាការពិត តែការពិតទាំងឡាយកើតចេញពីសុបិន។ សុបិនធ្វើឲ្យមនុស្សភ្ញាក់។ សុបិនធ្វើឲ្យអ្នកគេងមិនលក់ ហើយសុបិនពិត តែងដាស់យក្សឲ្យក្រោក៕

"You have to dream before your dreams can come true." - Abdul Kalam

# ថ្ងៃទី០៥ ខែកញ្ញា

ព្រះពុទ្ធជាម្ចាស់ [ Buddha] សម្តែងថា "*ការយល់ត្រូវ នឹងឆ្ពោះទៅរកការនិយាយត្រូវ, ការនិយាយត្រូវ នឹងឆ្ពោះទៅរកការងារត្រូវ, ការងារត្រូវ នឹងឆ្ពោះទៅរកការចិញ្ចឹមជីវិតត្រូវ, ការចិញ្ចឹមជីវិតត្រូវ នឹងឆ្ពោះទៅរកការព្យាយាមត្រូវ, ការព្យាយាមត្រូវ នឹងឆ្ពោះទៅរកការភ្ញាក់រលឹកត្រូវ, ការភ្ញាក់រលឹកត្រូវ នឹងឆ្ពោះទៅរកបញ្ញាត្រូវ, បញ្ញាត្រូវ នឹងឆ្ពោះទៅរកការរំដោះទុក្ខត្រូវ*"។

មនុស្សខ្លះ ក្រុមខ្លះ តែងហារមាត់និយាយពីជនជាតិផ្ទឹព ដែលចូលចិត្តអានសៀវភៅ តែខ្លួនបែរជាប្រឹងតែស្តាប់ប្រើតែត្រចៀក និងមិនសូវអាន។ មនុស្សខ្លះ ក្រុមខ្លះ ហារមាត់និយាយពីសមាធិ និងវិបស្សនាកម្មដ្ឋាន តែខ្លួនឯងបែរជាប្រើសម្តីហិង្សាជេរប្រទេចទៅវិញ។ ទុក្ខខ្លួន មិនអាចរំដោះបានទេ បើយល់ខុស។

ទុក្ខជាតិ ក៏មិនអាចរំដោះបានទេ បើយល់ខុស ហើយទុក្ខសាសនា ក៏មិនអាចរំដោះបានដែរ បើនៅតែយល់ខុស។

ក្នុងនិកាយសាសនា បើអ្នកជាជ្វីព ក៏នឹងក្លាយជាជ្វីពអាក្រក់។ បើជាគ្រីស្ទ ក៏នឹងក្លាយទៅជាគ្រីស្ទអាក្រក់។ បើជាតៅ ក៏នឹងក្លាយទៅជាតៅអាក្រក់។ បើជាហិណ្ឌូ ក៏នឹងក្លាយទៅជាហិណ្ឌូអាក្រក់ ដោយសារគ្រប់យ៉ាងអ្នកយល់ខុស៕

From right understanding proceeds right thought; from right thought proceeds right, speech; from right speech proceeds right, action; from right action proceeds right, livelihood; from right livelihood proceeds right effort; from right effort proceeds right awareness; from right awareness proceeds right concentration; from right concentration proceeds right wisdom; from right, wisdom proceeds right liberation. - Buddha

# ថ្ងៃទី០៦ ខែកញ្ញា

*"អវិជ្ជា គឺជាប្រភពនៃអកុសល។ ចំពោះមនុស្សឆ្លាត ជីវិតគឺជាដំណោះស្រាយ តែចំពោះមនុស្សល្ងង់វិញ ជីវិតគឺជាបញ្ហា"*។

មូលហេតុនៃអវិជ្ជា គឺដោយសារគ្មានឱកាសរៀន ឬមានឱកាសរៀន តែមិនប្រឹងរៀន។ បើមិនចេះ ត្រូវស្តាប់គេអ្នកចេះ តែបើមិនស្តាប់គេអ្នកចេះ ត្រូវប្រឹងអានសៀវភៅ។ ព្រះពុទ្ធបានបង្រៀនពី *"ជីវិត គឺទុក្ខ"*។ សុខចិត្តរស់នៅមួយថ្ងៃ ក្នុងនាមជាអ្នកឃើញការពិតនូវសេចក្តីសុខ និងសេចក្តីទុក្ខនៃជីវិត ប្រសើរជាងរស់នៅ ១០០ឆ្នាំ តែបែរជារស់នៅទាំងវេទនា មិនដឹងទុក្ខ មិនស្គាល់សុខ និងមិនទទួលស្គាល់ធម្មជាតិពិតនៃជីវិត។

### ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

ប៊ីនចាមីន ហ្វ្រង់ឃ្លីន [ Benjamin Franklin ] បានពោលថា *"ជីវិតដែលមានអាយុវែង មិនប្រាកដថាមានតម្លៃគ្រប់គ្រាន់ ហើយជីវិតដែលមានតម្លៃគ្រប់គ្រាន់ មិនប្រាកដថាត្រូវរស់នៅជាអមតៈនោះទេ"*។ ចូរធ្វើជាមនុស្សដែលមានតម្លៃទាំងសម្រាប់ខ្លួនឯង និងសម្រាប់អ្នកដទៃ ៕

*"Ignorance is the roof of al evils. To the wise, life is a solution; to the fool, a problem." "A long life may not be good enough, but a good life is long enough."* - Benjamin Franklin

# ថ្ងៃទី០៧ ខែកញ្ញា

*"បុគ្គលដែលយល់ពីស្ថានភាពរបស់អ្នកដទៃ គឺនឹងមិនវិនិច្ឆ័យផ្តេសផ្តាស តែបុគ្គលដែលចូលចិត្តវិនិច្ឆ័យផ្តេសផ្តាស គឺគេហៅថា (បុគ្គលមិនយល់)"*។ យល់ពីគេ យល់ពីខ្លួនឯង នឹងនាំមកនូវការវាយតម្លៃត្រឹមត្រូវ។ យល់តែពីគេ តែមិនយល់ពីខ្លួនឯង នឹងតែងនាំទុក្ខដល់ខ្លួន។ យល់តែពីខ្លួនឯង តែមិនយល់ពីគេឯង នឹងនាំមកនូវទំនាស់ដល់ខ្លួនឯង។ បុរស "ក" បាននិយាយថា *"ត្រីដែលកំពុងតែហែលទឹក មើលទៅដូចសប្បាយរីករាយខ្លាំងណាស់"*។ បុរស "ខ" បានចំអកថា *"ហេតុអ្វីបានជាលោកដឹងថាត្រីដែលកំពុងហែលទឹកសប្បាយរីករាយ បើលោកមិនមែនជាត្រីផង"*។ បុរស "ក" ក៏ចំអកវិញថា *"ហើយចុះលោកមិនមែនជាខ្ញុំផង ហេតុអ្វីបានជាដឹងថា ខ្ញុំមិនដឹង ឬដឹងថាត្រីដែលកំពុងហែលទឹកនោះរីករាយ?"*៕

# ថ្ងៃទី០៨ ខែកញ្ញា

មនុស្សល្ងង់តែងពូកែវិនិច្ឆ័យគេឯង តែមិនបានប្រដៅខ្លួនឯងឲ្យល្អទេ។ មនុស្សដែលស្គាល់ខ្លួនឯង គឺនឹងមិនវិនិច្ឆ័យសូម្បីតែខ្លួនឯង តែមនុស្សដែលមិនយល់សោះពីជីវិត គឺតែងតែគិតអវិជ្ជមាន បង្កើតមេរោគគំនិតសម្លាប់ខ្លួនឯងជានិច្ច។ មនុស្សវិជ្ជមានគិតដើរទៅមុខជាមួយក្បាល តែមិនមែនជើងទេ បើទោះបីជាឈឺជើង តែគេក៏នឹងប្រើក្បាលព្យាបាលជើងដែរ។ គ្រោះខាងក្រៅ មិនអាចសម្លាប់មនុស្សដូចគំនិតមនុស្សខាងក្នុងនៃខួរក្បាលទេ។ គិតអាក្រក់ពីគេឯង គិតអាក្រក់ខ្លួនឯង នឹងនាំទុក្ខដល់ខ្លួនឯង៕

He who judges others; not understand, and he who understands; not judge.

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី០៩ ខែកញ្ញា

" នារីស្រស់ស្អាតម្នាក់ពិបាកសម្រេចចិត្តជ្រើសរើសយកបុរសម្នាក់ក្នុងចំណោមពីរនាក់ដែលមកស្ដីដណ្ដឹងនាង" ។

បុរស "ក" ជាមនុស្សល្ងង់ខ្លៅ គ្មានគុណធម៌ និងអាក្រក់មើល តែគ្រួសាររបស់គេមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ ចំណែកឯបុរស "ខ" ជាមនុស្សឈ្លាសវៃ មានការចេះដឹង មានគុណធម៌ និងសង្ហា តែគ្រួសាររបស់គេខ្សត់ទ្រព្យធនបំផុត។ ថ្វីត្បិតតែគិតបន្តិចឃើញថាបុរស "ក" មានទ្រព្យធន តែជាតុពិតគេក្រីក្រ ព្រោះទ្រព្យសម្បត្តិទាំងអស់នោះគឺជាកម្មសិទ្ធិរបស់គ្រួសារគេ។ ចំណែកបុរស "ខ" ថ្វីត្បិតតែក្រទ្រព្យធន តែគេមានទ្រព្យផ្ទាល់ខ្លួន ទ្រព្យនោះគឺចំណេះដឹងសមត្ថភាព បូកផ្សំនឹងគុណធម៌។

មនុស្សយើង បើមានទ្រព្យសម្បត្តិដោយមិនបានប្រឹងប្រែងធ្វើការដោយកម្លាំងញើសឈាមខ្លួនឯងទេ នោះទ្រព្យនោះនឹងរលាយសាបសូន្យវិញ បើគ្មានសមត្ថភាពថែរក្សាទ្រព្យឲ្យគង់វង្ស ប្រៀបដូចសម្ដីមហាត្មៈ គន្ធី ថាជាបាបកម្ម "សម្បត្តិមហាសាល ដោយគ្មានពលកម្ម ឬ Wealth Without Work"។បុរាណាចារទុកថា "ចូរគិតអំពីសុភមង្គលជាមុនសិន ទើបរកទ្រព្យធនជាក្រោយ តែបើបណ្ដោយនោះប្រាកដជាទឹកភ្នែកស្រក់លើគំនរទ្រព្យជាមិនខាន"។ ម្ដាយសួរថា៖ "តើកូនស្រីសម្រេចចិត្តជ្រើសយកបុរសណា?" នារីឆ្លើយថា៖ "ម៉ែ! ខ្ញុំអាចហូបបាយនៅផ្ទះបុរស "ក" និងផ្សំដំណេកនៅផ្ទះបុរស "ខ" តើបានទេ?"

# ថ្ងៃទី១០ ខែកញ្ញា

*"បុរសល្អស្វែងរកប្រពន្ធ តែបុរសអាក្រក់ស្វែងរកស្រីសម្រាប់លេងសើច។ នារីឆ្លាត មិនមែនរៀនចប់ថ្នាក់បណ្ឌិត តែល្ងង់លើវិជ្ជារើសស្វាមីនោះទេ ពីព្រោះជោគជ័យដែលធំជាងគេរបស់នារី គឺមានក្រសែភ្នែកល្អអាចជ្រើសរើសបុរសល្អម្នាក់បាន"។*

កំលោះម្នាក់បានសួរទៅឪពុករបស់ខ្លួនថា *"ពុក! តើខ្ញុំអាចស្វែងរកនារីល្អម្នាក់ដែលស័ក្តិសមនឹងខ្ញុំបានដោយរបៀបណា?"* ឪពុកបានឆ្លើយតបថា *"កូនប្រុស សូមកូនបំភ្លេចចោលរឿងកូនចង់ស្វែងរកនារីល្អដែលស័ក្តិសមនឹងកូនទៅ។ ប៉ុន្តែសូមកូនគិតគូថា តើត្រូវធ្វើបែបណាដើម្បីក្លាយខ្លួនជាបុរសល្អម្នាក់"*។

មនុស្សស្រីប្រុសជាច្រើន តែងតែប្រាថ្នាចង់បានមនុស្សល្អមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន តែភ្លេចគិតថាតើខ្លួនយើងបានធ្វើឲ្យខ្លួនឯងមានតម្លៃគ្រប់គ្រាន់ហើយ ឬនៅ។

បុរាណខ្មែរពោលថា *"ឆ្នាំងណាគ្រប់ហ្នឹង ឬនាងរត់រកអ្នកស្រីខាតលក្ខណ៍រត់រកប្រុសកំបាក់អន្សា ជំទាវរត់រកឧញ្ញាស្រីខ្លោចផ្សា រត់រកប្រុសហិចហោច"*។

បុរសល្អស្វែងរកប្រពន្ធ តែបុរសអាក្រក់ស្វែងរកស្រីសម្រាប់លេងសើច។ កិលេសតណ្ហាមនុស្សលោកច្រើន នោះសេចក្តីទុក្ខក៏ច្រើនដែរ។ ភាពខ្លាំងប្រកបដោយភាពទន់ភ្លន់របស់នារី គឺបើឲ្យក្មេងដែលពូកែយំទៅនារីម្នាក់ នោះនាងនឹងធ្វើឲ្យក្មេងញញឹម, បើឲ្យអង្ករមួយកំប៉ុងទៅនារីនោះនាងនឹងបង្កើតបានជាបាយ ហើយបើទុកឲ្យនាងនៅផ្ទះដ៏រញ៉េរញ៉ៃ នោះនាងនឹងធ្វើឲ្យមានរបៀប។

លោកស្រីនាយករដ្ឋមន្ត្រី ម៉ាការ៉េត ថេឆើ [ Margaret Thatcher ] បានពោលថា *"នារីគ្រប់រូបដែលយល់ដឹងពីបញ្ហាស្មុគស្មាញនៃការគ្រប់គ្រងផ្ទះសម្បែង នោះក៏មានន័យថា នាងអាចយល់ដឹងបានពីបញ្ហានៃការដឹកនាំប្រទេសជាតិផងដែរ"*។

# ថ្ងៃទី១១ ខែកញ្ញា

*"សច្ចភាព មិនមែនជាកម្មសិទ្ធិផ្ដាច់មុខរបស់បុគ្គលណាម្នាក់ឡើយ"*។

វិបុលភាពធំបំផុត គឺការពិសោធន៍ឃើញដោយខ្លួនឯងផ្ទាល់នូវសច្ចធម៌។ ជំនឿតែម៉្យាង មិនអាចបញ្ជាក់ពីសេចក្ដីពិតបានទេ។ ប៉ុន្តែ យើងត្រូវពិនិត្យមើលឲ្យឃើញថា តើវាសមហេតុផលដែរ ឬទេ? អាចយកមកប្រតិបត្តិបានដែរ ឬទេ? និងអាចមានផលប្រយោជន៍កើតកុសលដែរ ឬទេ? ចូរកុំអាលជឿនូវអ្វីដែលគេនិយាយប្រាប់ ឬនូវអ្វីដែលគេនិយាយតពីតំណមុនជាច្រើនមក ឬនូវអ្វីដែលជាយោបល់ទូទៅ ឬនូវអ្វីដែលគម្ពីរបានចែងមកថាយ៉ាងនោះ។

សូមកុំព្រមទទួលយកអ្វីដែលគ្រាន់តែសមហេតុផលថាពិត ឬគ្រាន់តែបានឃើញតាមសំបកក្រៅ ឬតាមភាគខ្លះនៃមតិខ្លះ ឬព្រោះទំនាយគួរឲ្យជឿ ឬព្រោះគ្រូអ្នកពោលថាយ៉ាង

នេះមួយ យ៉ាងនោះមួយជាដើម។ ប៉ុន្តែកាលណាអ្នកដឹង ដោយខ្លួនឯងផ្ទាល់ថា គោលការណ៍ទាំងនោះវាជាអកុសល គួរស្តីបន្ទោស ត្រូវបានផ្តន្ទាទោសពីបណ្ឌិត ហើយលុះអ្នក ព្រមយកទៅអនុវត្ត វានាំទៅរកទោស។ គ្រានោះ អ្នកត្រូវ បោះបង់វាចោលឲ្យអស់ទៅ។ កាលណាអ្នកដឹងខ្លួនឯង ផ្ទាល់ថា គោលការណ៍នោះជាកុសល ឥតទោស ត្រូវបាន សរសើរពីបណ្ឌិត។ លុះអ្នកព្រមយកទៅអនុវត្ត វានាំទៅរក សុភមង្គល និងសេចក្តីសុខសប្បាយ នោះចូរអ្នកព្រមទទួល យកទៅប្រតិបត្តិតាមចុះ៕

No monopoly on the truth. The highest authority is one's own experience of truth. - Buddha

# ថ្ងៃទី១២ ខែកញ្ញា

*"ប្រសិនបើយើងព្រមទទួលស្គាល់ថា គ្រប់យ៉ាងតែងតែផ្លាស់ប្តូរជានិច្ច នោះយើងក៏នឹងមិនចាំបាច់ប្រឹងប្រែងប្រកាន់ទុកនូវអ្វីមួយជាអមតៈដែរ។ លើលោកនេះ គ្មានអ្វីដែលថាមិនអាចផ្លាស់ប្តូរ និងសម្រេចទៅបានទេ កាលបើយើងពុំខ្លាចសេចក្តីស្លាប់ហើយនោះ"។*

ពេលខ្លះ ការផ្លាស់ប្តូរជារឿងដែលគួរឲ្យខ្លាច តែអ្នកខ្លាចការផ្លាស់ប្តូរ គឺប្រៀបដូចមនុស្សស្លាប់ ពីព្រោះមនុស្សស្លាប់គឺបាត់បង់គ្រប់យ៉ាង គ្មានគ្រប់យ៉ាង និងចប់គ្រប់យ៉ាង។ ខ្នាតនៃពេលវេលា ដូចជាវិនាទី អាចផ្លាស់ប្តូរទៅជានាទី។ នាទីអាចផ្លាស់ប្តូរទៅជាម៉ោង។ ម៉ោងអាចផ្លាស់ប្តូរទៅជាថ្ងៃ។ ថ្ងៃអាចផ្លាស់ប្តូរទៅជាអាទិត្យ។ អាទិត្យអាចផ្លាស់ប្តូរទៅជាខែ។ ខែអាចផ្លាស់ប្តូរទៅជាឆ្នាំ។ ឆ្នាំអាចផ្លាស់ប្តូរទៅជាទសវត្សរ៍។ ទសវត្សរ៍អាចផ្លាស់ប្តូរទៅជាសតវត្សរ៍។

ទស្សវត្សរ៍អាចផ្លាស់ប្តូរទៅជាសតវត្សរ៍។ ទាំងនេះ គឺចង់មានន័យថា *"ការផ្លាស់ប្តូរដ៏តូចតាច ឬតិចតួចមួយ នោះនឹងបង្កើតឲ្យបង្កើតឲ្យមានការផ្លាស់ប្តូរដ៏ធំមួយ"*៕

If you realize that all things change, there is nothing you will try to hold on to. If you are not afraid of dying, there is nothing you cannot achieve. -Lao Tzu

# ថ្ងៃទី១៣ ខែកញ្ញា

*"ប្រសិនបើយើងកំពុងស្ថិតនៅក្នុងស្ថានភាពអាក្រក់ ក៏សូមកុំបារម្ភ ពីព្រោះវាគង់តែផ្លាស់ប្តូរទេ។ ប្រសិនបើយើងកំពុងតែស្ថិតក្នុងស្ថានភាពល្អ ក៏សូមកុំបារម្ភ ពីព្រោះវាក៏គង់នឹងផ្លាស់ប្តូរដូចគ្នាដែរ"។*

គ្រប់យ៉ាងតែងតែផ្លាស់ប្តូរ តែមានតែការផ្លាស់ប្តូរប៉ុណ្ណោះដែលមិនផ្លាស់ប្តូរ។ គ្រប់យ៉ាងនឹងផ្លាស់ប្តូរទៅជាល្អទាំងអស់នៅទីបញ្ចប់ តែបើវាផ្លាស់ប្តូរមិនទាន់ល្អនៅឡើយទេ គឺគ្រាន់តែមានន័យថា មិនទាន់ដល់ទីបញ្ចប់ប៉ុណ្ណោះ។ ដូច្នេះ ត្រូវប្រឹងប្រែងបន្តទៀត គឺប្រឹងប្រែងរហូតដល់ទីបញ្ចប់ដែលល្អ៕

If you're in a bad situation, don't worry it'll change.

If you're in a good situation, don't worry it'll change.

- John A. Simone, Sr.

# ថ្ងៃទី១៤ ខែកញ្ញា

*"ពេលដែលយើងងងឹត យើងតែងត្រូវការពន្លឺ ហើយពេលអ្នកដទៃងងឹត គេក៏ត្រូវការពន្លឺដូចយើងដែរ"*។

យើងគួរតែរៀនធ្វើជាចង្កៀងបំភ្លឺភាពងងឹត ប្រសើរជាងធ្វើជាភាពងងឹត។ ភាពងងឹត មិនអាចលុបបំបាត់ដោយភាពងងឹតបានទេ តែមានតែពន្លឺប៉ុណ្ណោះ ទើបអាច។ សេចក្តីស្អប់គុំគួន មិនអាចលុបបំបាត់ដោយសេចក្តីស្អប់គុំគួនបានទេ តែមានតែសេចក្តីស្រឡាញ់ប៉ុណ្ណោះ ទើបអាច។ គ្មានមនុស្សខឹងណា ដែលដឹងថាខ្លួនឯងកំពុងខឹងខ្លាំងទេ លុះត្រាតែគេឈប់ខឹង ទើបភ្ញាក់ខ្លួន ហើយគ្មានមនុស្សល្ងង់ណា អាចដឹងថាខ្លួនកំពុងតែល្ងង់ទេ លុះត្រាតែខ្លួនបានចេះដឹង ទើបដឹងថាខ្លួនល្ងង់៕

"Darkness cannot drive out darkness; only light can do that. Hate cannot drive out hate; only love can do that." - Martin Luther King

# ថ្ងៃទី១៥ ខែកញ្ញា

យើងជាអ្នកក្រ រវល់តែគិតដល់កិត្តិយស និងសេចក្ដីល្អ វាពិតជាដាច់ពោះស្លាប់ហើយ។ ប្រាក់ គឺជាព្រះ និងជាកែវមុន្នី។ ពាក្យមួយនិយាយថា *"អ្នកមានលុយតែងល្អ ហើយអ្នកក្រតែងអាក្រក់"*។

បើមានប្រាក់ អ្នកណាក៏គោរពគោតខ្លាចយើង ថាយើងជាមនុស្សល្អ។ ឋានៈជាអ្នកក្រ បើទោះបីជាមានសីលធម៌យ៉ាងណាក្ដី ក៏គង់គេចមិនផុតពីការមើលងាយមើលថោករបស់អ្នកមានប្រាក់ដែរ។ អ្នកមានតែងយល់ថាខ្លួនគេជាមនុស្សល្អប្រសើរ និងគិតថាអ្នកក្រជាខ្ញុំកញ្ជះបាតជើងរបស់គេ។ ពួកនាយទុន និងអ្នកមានអំណាចច្រើនសាងសេចក្ដីសុខលើខ្នងប្រជារាស្ត្រ និងលើអ្នកក្រ ឬនាំគ្នាប្លន់ជាតិខ្ញុំ និងរាស្ត្រខ្ញុំ៕

# ថ្ងៃទី១៦ ខែកញ្ញា

*"មេដឹកនាំល្អ ប្រើខ្លួនដើម្បីជាតិ តែមេដឹកនាំចោលម្សៀត ប្រើជាតិដើម្បីខ្លួន។មេដឹកនាំខ្លះហ៊ានលះបង់ខ្លួនដើម្បីជាតិ តែមេដឹកនាំខ្លះទៀត លក់ជាតិដើម្បីខ្លួន"*។

តើដើម្បីជាតិ ឬដើម្បីខ្លួន? ក្នុងបបូរមាត់ស្នេហាជាតិ ប៉ុន្តែក្នុងគំនិតឈ្លោះតែគ្នា យកឈ្នះយកចាញ់ និងចាត់ទុកភាពអាម៉ាស់បុគ្គល ធំជាងការអាប់អោនកិត្តិយសជាតិមាតុភូមិ។ ទល់ដែនដាច់ខ្សែ ខ្មែរស្មើរដាច់ពូជ សៀមយួនកំហូច លួចប្លន់មិនគិត យកស្រីទាក់ស្នេហ៍ យកប្រាក់ទាក់ចិត្ត ថ្ងៃក្រោយដីពិតខ្មែរនៅប៉ុនណា។

បុគ្គលបំផ្លាញជាតិពិតប្រាកដគឺជាមនុស្សដែលអគតិចំពោះការអប់រំ ហើយបុគ្គលគ្រោះថ្នាក់បំផុតសម្រាប់សង្គម គឺជាមនុស្សដែលអានសៀវភៅតែមួយក្បាល រៀនតែពីគ្រូម្នាក់ ស្តាប់អ្នកនយោបាយតែម្ខាង៕

# ថ្ងៃទី១៧ ខែកញ្ញា

*"លុះត្រាតែពេលណាយើងឈប់លូង់ នោះទើបអ្នកនយោបាយខ្លះនឹងសន្យាថា ឈប់បោកប្រាស់យើងទៀតហើយ។ ប៉ុន្តែ បើយើងនៅតែលូង់ គេគិតថា បោកបានក៏បោកសិនទៅ"*។

ក្នុងទ្រឹស្តីយុទ្ធសាស្ត្របាននិយាយថា *"ដើម្បីឈ្នះ យើងត្រូវចេះរង់ចាំក្នុង ២ដំណាក់កាល"* គឺ៖

ទី១) គឺត្រូវចេះរង់ចាំដល់ពេលសត្រូវទន់ខ្សោយសិន ចាំវាយប្រហារយកឈ្នះ។

ទី២) គឺត្រូវចេះរង់ចាំដល់ពេលខ្លួនយើងខ្លាំងសិន ចាំវាយសង្គ្រប់។

ពេលវេលាកសាងកម្លាំងខ្លួន គឺជាដំណាក់កាលអាទិភាពសំខាន់ទីមួយ។ យុវជនត្រូវខំប្រឹងប្រែងរៀនសូត្រ៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី១៨ ខែកញ្ញា

*"សម្តីរបស់យុវជនទាំងឡាយដែលនិយាយថា ស្រឡាញ់សង្គម ឬចង់ជួយជាតិ នឹងក្លាយទៅជាសំរាមឥតប្រយោជន៍តាមផ្លូវ ឬក៏ក្លាយទៅជាទឹកស្អុយបង្ហូរតាមលូរ បើសម្តីទាំងនោះ នៅតែល្អពីរោះជាងការប្រតិបត្តិជាក់ស្តែង"។*

ទ្រព្យសម្បត្តិពិតប្រាកដរបស់ប្រទេសជាតិមួយ គឺមិនមែនវាស់ដោយមាសប្រាក់នោះទេ តែវាស់កំណត់ដោយការសិក្សាអប់រំរបស់ប្រជាជន គតិបណ្ឌិតរបស់ប្រជាជន និងភាពរឹងប៉ឹងមាំមួនរបស់យុវជន។ យុវជនមានមូលដ្ឋានគ្រឹះរឹងមាំ មានការតាំងចិត្តសិក្សាខ្ពស់ មានឧត្តមគតិស្នេហាជាតិពិត ស្នេហាទឹកដីប្រាកដ មានឆន្ទៈបម្រើប្រជាជន នោះជាតិនឹងរឹងមាំជាមិនខានឡើយ៕

# ថ្ងៃទី១៩ ខែកញ្ញា

ឡៅ ជឺ [ Lao Tzu ] ពោលថា "*ពេលដែលយើងពេញចិត្តចំពោះភាពសាមញ្ញរបស់ខ្លួនឯង ដោយមិនប្រៀបធៀបខ្លួននឹងអ្នកដទៃ ឬប្រកួតប្រជែងនឹងអ្នកដទៃ នោះគ្រប់គ្នានឹងគោរពយើងក្នុងនាមជាយើង*"។

ចំណែក អាឌុល អ៊ីត្លែរ [ Adolf Hitler ] ក៏បានពោលស្រដៀងគ្នាថា "*សូមកុំយកខ្លួនឯងទៅប្រៀបធៀបគ្នាជាមួយអ្នកដទៃឲ្យសោះ ពីព្រោះបើយើងធ្វើដូច្នេះ គឺមានន័យថាយើងកំពុងតែមើលងាយខ្លួនឯងហើយ*"។

ទ្រឹស្តីពុទ្ធនិយម និងទស្សនៈរបស់ ខុង ជឺ បានអប់រំប្រហាក់ប្រហែលគ្នាថា

១. កុំគិតថាខ្លួនឯងអន់ថយជាងគេ ពីព្រោះនឹងនាំយើងឲ្យអស់សង្ឃឹម គ្មានការប្រឹងប្រែង។

២. កុំគិតថាខ្លួនឯងអស្ចារ្យជាងគេ ពីព្រោះនឹងនាំយើងឲ្យអំនួត គ្មានការប្រឹងប្រែង។

៣. កុំគិតថាខ្លួនឯង និងអ្នកដទៃដូចគ្នា ព្រោះនឹងនាំឲ្យយើងគ្មានការប្រកួតប្រជែង គ្មានការប្រឹងប្រែង។

ការប្រកួតប្រជែងពិតប្រាកដ គឺប្រកួតជាមួយខ្លួនឯងពីម្សិលមិញ និងថ្ងៃនេះ។ តើម្សិលមិញ និងថ្ងៃនេះ យើងបានរីកចម្រើនអ្វីខ្លះហើយ។ បុរាណខ្មែរបានផ្តាំថា "*ឈ្នះអ្នកក្រដោយឲ្យទាន ឈ្នះអ្នកមានដោយគោរព ហើយឈ្នះសព្វគ្រប់ គឺឈ្នះលើខ្លួនឯង*"៕

# ថ្ងៃទី២០ ខែកញ្ញា

ទ្រឹស្ដីស្ត្រីនិយម [ Feminism ] លើកឡើងថា *"គ្មានកន្លែងណាដូចផ្ទះយើង ហើយផ្ទះយើងក៏មិនដូចជាផ្ទះយើង ប្រសិនបើមិនមានអ្នកម្ដាយ និងមនុស្សស្រី"*។

សក់វែងរបស់ស្ត្រី បង្ហាញថាស្ត្រីអាចគិតវែងស្មើរតែគ្រប់ជ្រុងជ្រោយ ហើយនេះគឺជាធម្មជាតិស្រី។ ទ្រឹស្ដីមាតាធិតេយ្យនិយមថា *"គ្មានការអភិវឌ្ឍន៍ណា មិនត្រូវការស្ត្រីនោះទេព្រោះគ្រួសារមួយត្រូវការស្ត្រីសហគមន៍មួយត្រូវការស្ត្រី ហើយការអប់រំស្ត្រី គឺអប់រំសហគមន៍ទាំងមូល"*៕

# ថ្ងៃទី២១ ខែកញ្ញា

លោក ជីមី ហែនឌ្រិក [ Jimi Hendrix ] និយាយថា "*ពេលដែលអំណាចនៃសេចក្តីស្រឡាញ់ [ Power of Love ] អាចប្រើដើម្បីបន្ទន់ចិត្តមនុស្សដែលស្រឡាញ់អំណាចបាន [ Love of Power ] គឺពិភពលោកទាំងមូលនឹងស្គាល់សន្តិភាពពិតប្រាកដ*"។ ពេលខ្លះ មនុស្សដែលចង់បានអំណាច អាចថាមានគោលបំណងគាបសង្កត់មនុស្ស ពីព្រោះបើគ្រាន់តែចង់ជួយសង្គ្រោះមនុស្ស មានត្រឹមតែសេចក្តីស្រឡាញ់ និងក្តីអាណិតអាសូរ គឺគ្រប់គ្រាន់ហើយ។

អំណាចមាន ២ប្រភេទគឺ៖

ទី១ ) អំណាចដែលបន្លាចអ្នកដទៃតាមរយៈ ការដាក់ទោសទណ្ឌកម្ម។

ទី២) អំណាចដែលអាណិតប្រណីអ្នកដទៃតាមរយៈ សេចក្តីស្រឡាញ់ ។អំណាចនៃសេចក្តីស្រឡាញ់តែងមានប្រសិទ្ធភាពរាប់ពាន់ដង ព្រមទាំងជាអំណាចដែលមានភាពអចិន្ត្រៃយ៍ជាអតមតៈ ។

Power is of two kinds. One is obtained by the fear of punishment and the other by acts of love. Power based on love is a thousand times more effective and permanent then the one derived from fear of punishment. - Mahatma Gandhi

# ថ្ងៃទី២២ ខែកញ្ញា

ទស្សនវិទូក្រិចបុរាណលើកឡើងថា *"បុគ្គលខ្លះ ប្រឹងប្រែងរកលុយប្រៀបដូចគេអាចរស់នៅបានជាអមតៈអ៊ីចឹង ឯបុគ្គលខ្លះទៀត ចេះតែចាយវាយលុយខ្វះខ្វាយ ប្រៀបដូចជាគេត្រូវស្លាប់ទៅវិញនៅថ្ងៃស្អែកអ៊ីចឹង"*។

បើយើងតែងតែមានបញ្ហារឿងលុយកាក់ជាប្រចាំ នោះក៏សូមចេះរំលឹកដល់ខ្លួនឯងថា "យើងកើតមកមិនបានយកលុយមកជាមួយទេ ហើយពេលយើងស្លាប់ទៅវិញ ក៏នឹងមិនអាចយកលុយទៅជាមួយបានផងដែរ"។ មានលុយច្រើនក៏អាក្រក់ គ្មានលុយសោះក៏អាក្រក់។

ភាពក្រីក្រខាងលុយកាក់ គឺជាប្រភពនៃអំពើអាក្រក់ ឬឧក្រិដ្ឋកម្ម និងចោរកម្មនានា ហើយភាពសម្បូរហូរហៀរខាងលុយកាក់ ក៏អាចជាប្រភពនៃសេចក្ដីលោភលន់ឥតព្រំដែន

អំពើអសីលធម៌ និងទង្វើអាក្រក់នានាផងដែរ។ សម័យបុរាណ មនុស្សប្រើឧបករណ៍ដើម្បីពិសោធន៍លុយក្លែងក្លាយ ឬលុយពិត តែសម័យបច្ចុប្បន្ននេះ គេយកលុយពិសោធន៍មនុស្សថាតើមនុស្សក្លែងក្លាយ ឬមនុស្សពិតវិញ។

នៅលើលោកយើងនេះ មានមនុស្សដែលមានលុយ និងមនុស្សដែលមានសុភមង្គល។ មនុស្សដែលមានលុយច្រើនមិនប្រាកដថាមានសុមង្គល ហើយរីឯមនុស្សដែលមានសុភមង្គល ក៏មិនប្រាកដថាមានលុយច្រើនដែរ។ ដូច្នេះ ចូរយល់ឲ្យច្បាស់ពីតុល្យភាពនៃជីវិតរស់នៅរវាងលុយ និងជីវិត ហើយបើគ្មានលុយ ជីវិតយើងចាំបាច់ត្រូវតែមានទុក្ខមែនទេ៕

There are people who have money and people who are rich. - Coco Chanel

# ថ្ងៃទី២៣ ខែកញ្ញា

មនុស្សណាដែលបានចំណាយពេលវេលាអានច្រើន តែមិនចំណាយពេលគិតច្រើន នោះគឺបានប្រើត្រឹមតែភ្នែកប៉ុណ្ណោះ។ ហើយមនុស្សណាដែលគិតហើយ តែមិនធ្វើនោះគឺបានត្រឹមតែទ្រឹស្តីប៉ុណ្ណោះ។ ហើយមនុស្សណាដែលធ្វើហើយ តែបរាជ័យ នោះគឺបានត្រឹមតែបទពិសោធន៍ប៉ុណ្ណោះ។ ហើយបរាជ័យហើយបរាជ័យទៀត តែមិនចុះចាញ់ នោះទើបហៅថា *"មនុស្សជោគជ័យពិតប្រាកដ"*៕

# ថ្ងៃទី២៤ ខែកញ្ញា

លោក ស៊ីវ ខេរ៉ា [ Shiv Kera ] ពោលថា"*ចូរចងចាំថា អ្នកចាញ់ប្រើវិធីតែមួយ ដើម្បីធ្វើរឿងជាច្រើន ប៉ុន្តែអ្នកឈ្នះឈ្នះវិញ គឺប្រើវិធីជាច្រើន ដើម្បីធ្វើកិច្ចការមួយឲ្យសម្រេច*"។

អ្នកឈ្នះមិនដែលបោះបង់ អ្នកបោះបង់មិនដែលឈ្នះ។ អ្នកជោគជ័យមិនប្តូរគោលដៅ ហើយអ្នកប្តូរគោលដៅ នឹងមិនស្គាល់ភាពជោគជ័យ។ បិតារូបវិទ្យាស.វទី២០ អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] បានក្រាញននៀលនឹងបញ្ហារហូតដល់ចុងបញ្ចប់ទទួលជោគជ័យ ហើយបាននិយាយថា ៖

"*យើងមិនអាចដោះស្រាយបញ្ហាជាច្រើនបាន ក្នុងរបៀបនៃការគិតតែមួយ ឬរបៀបនៃការគិតងាប់ក្រឡាតែម៉្យាងនោះទេ។ ខ្ញុំបានព្យាយាមធ្វើកិច្ចការលំបាកបំផុតចំនួន៩៩លើក ហើយលើកទី១០០ ខ្ញុំក៏បានទទួលជោគជ័យ*"។

មនុស្សបរាជ័យធ្វើកិច្ចការងារទីមួយបរាជ័យ ដោយប្រើវិធីខ្ជិល ឬខ្វះសេចក្តីអំណត់ បន្ទាប់មកគេក៏យកទម្លាប់នៃភាពខ្ជិលច្រអូស ឬខ្វះសេចក្តីអំណត់ទៅធ្វើកិច្ចការងារទីពីរ។ ហើយបន្ទាប់មកទៀត ក៏យកទម្លាប់ខ្ជិលច្រអូសឬខ្វះសេចក្តីអំណត់ទៅធ្វើការងារទីបី ទី៤ ទី៥ ទីប្រាំ..ទីដប់...៕

Remember, winners don't do different things, they do things differently.

# ថ្ងៃទី២៥ ខែកញ្ញា

មហាត្មៈ គន្ធី [ Mahatma Gandhi ] បានថ្លែងថា "បើនឹងយកភ្នែកមួយទៅស៊ីសងនឹងភ្នែកមួយ គឺបានត្រឹមតែធ្វើឲ្យពិភពលោកយើងទាំងមូល នៅសល់ត្រឹមតែមនុស្សខ្វាក់ប៉ុណ្ណោះ"។

១) ធ្វើការផ្លាស់ប្តូរពីជម្លោះ ឲ្យទៅជាការសហការគ្នា។

២) ធ្វើការផ្លាស់ប្តូរពីសត្រូវ ទៅជាមិត្តជិតដ៏ស្និទ្ធនឹងគ្នា។

៣) ធ្វើការផ្លាស់ប្តូរពីបញ្ហា ឲ្យទៅជាដំណោះស្រាយ។

៤) ធ្វើការផ្លាស់ប្តូរពីការលាបពណ៌ ឲ្យទៅជាការទុកចិត្តគ្នា។

៥) ធ្វើការផ្លាស់ប្តូរពីបុគ្គលធិបតេយ្យ ឲ្យទៅជាសមាជិកធិបតេយ្យ។

៦) ធ្វើការផ្លាស់ប្តូរពីការសង្ស័យ ឲ្យទៅជាព័ត៌មានពិត។

៧) ធ្វើការផ្លាស់ប្តូរពីការជេរប្រមាថ ឲ្យទៅជាការអប់រំប្រែកប ដោយសីលធម៌។

៨) ធ្វើការផ្លាស់ប្តូរពីការរើសអើង ឲ្យទៅជាការគោរព ស្រឡាញ់។

៩) ធ្វើការផ្លាស់ប្តូរពីការរំលោភសិទ្ធិ ឲ្យទៅជាការអាណិត អាសូរ។

១០) ធ្វើការផ្លាស់ប្តូរពីការកេងប្រវ័ញ្ច ឲ្យទៅជាការជួយគ្នា ទៅវិញទៅមក។

# ថ្ងៃទី២៦ ខែកញ្ញា

" *ការអានមិនអាចឲ្យយើងគ្រប់គ្នាក្លាយទៅជាអ្នកដឹកនាំបានពិតមែន តែវាអាចប្រាប់យើងឲ្យដឹងថាតើបុគ្គលប្រភេទណាដែលយើងគួរដើរតាម*"។ ទ្រឹស្តីពុទ្ធនិយមបានបង្ហាញថា "អប្បមត្តា សតីមន្តោ ឬប្រែថាអ្នកទាំងឡាយចូរកុំប្រមាថឡើយ"។ កុំចាត់ទុកអ្នកដទៃ ជាមនុស្សល្ងង់ តែត្រូវប្រដៅខ្លួនឯងឲ្យបានល្អ។ ទេពកោសល្យ គឺព្រះជាម្ចាស់ជាអ្នកប្រទានឲ្យយើង ដូច្នេះចូរយើងចេះដាក់ខ្លួន។ កិត្តិនាមល្បីល្បាញ គឺអ្នកដទៃជាអ្នកឲ្យ ដូច្នេះចូរយើងចេះថ្លែងអំណរគុណ។ រីឯភាពអំនួតអួតក្អេងក្អាង គឺយើងជាអ្នកបង្កើតឡើងដោយខ្លួនឯង ដូច្នេះចូរយើងចេះប្រុងប្រយ័ត្ន៕

Reading can't make us all leaders, but it can teach us which leader to follow. Talent is God-given, be humble; fame is man-given, be thankful; conceit is self-given, be careful.

# ថ្ងៃទី២៧ ខែកញ្ញា

*"ខឹង ឬមិនខឹង សុទ្ធតែមិនសំខាន់ តែអ្វីដែលសំខាន់ គឺជាប្រយោជន៍"*។ យើងជាមនុស្សមិនចេះខឹង ឬជាមនុស្សមានមេត្តា តែក៏ត្រូវចេះសម្តែងកំហឹងដែរ បើខឹងទៅមានប្រយោជន៍។ យើងជាមនុស្សឆាប់ខឹង ឬជាមនុស្សឆេវឆាវ តែក៏ត្រូវចេះសម្តែងចិត្តមេត្តា ចិត្តធូន់ដែរ បើចិត្តមេត្តា ចិត្តធូន់នោះមានប្រយោជន៍ក្នុងកាលៈទេសៈនោះ។ ខឹងខុស ខឹងខូច ខឹងខាត តែមិនទាំងអស់ទេ ពីព្រោះអ្នកយុទ្ធសាស្ត្រ អាចប្រើល្បិចខឹងដើម្បីចំណេញក៏ថាបាន។

ទស្សនវិទូក្រិច សូក្រាត [ Socrates ] ពោលថា *"វាជារឿងងាយស្រួលណាស់ ដែលយើងគ្រប់គ្នាអាចមានកំហឹង ប៉ុន្តែវាមិនមែនជារឿងងាយស្រួលប៉ុន្មានទេ ដែលយើងខឹងត្រូវមនុស្ស ខឹងត្រូវកម្រិត ខឹងត្រូវពេល ខឹងត្រូវគោលបំណង ហើយនឹងខឹងត្រូវផ្លូវ"*។

Anybody can become angry - that is easy, but to be angry with the right person and to the right degree and at the right time and for the right purpose, and in the right way - that is not within everybody's power and is not easy. - Aristotle

# ថ្ងៃទី២៨ ខែកញ្ញា

កំហឹង ធ្វើឲ្យមានសេចក្តីឈឺចាប់ដល់ខ្លួនឯងមនុស្សដែលឈឺចាប់ នឹងផ្សាយក្តីក្តៅក្រហាយដល់ជនដទៃ។ អ្នកដែលផ្សាយក្តីក្តៅក្រហាយដល់ជនដទៃ នឹងទទួលបានក្តីសោកស្តាយ និងក្តីក្តៅក្រហាយដល់ជីវិតខ្លួន។ មិនថាជានាទីណាទេ បើយើងទុកកំហឹងក្នុងខ្លួន នោះគឺមានន័យថា យើងបានបោះបង់ចោលសន្តិភាពផ្លូវចិត្តហុកសិបវិនាទី។ មានតែបុគ្គលដែលមានចិត្តបរិសុទ្ធប៉ុណ្ណោះ ទើបអាចផ្សាយក្តីមេត្តាករុណាបាន៕

For every minute you remain angry, you give up sixty seconds of peace of mind.

- Ralph Waldo Emerson

# ថ្ងៃទី២៩ ខែកញ្ញា

*"ពេលយើងឈ្នះ យើងមិនល្អដូចអ្វីដែលអ្នកដទៃនិយាយនោះទេ ហើយពេលយើងចាញ់ យើងក៏មិនអាក្រក់ដូចសម្ដីអ្នកដទៃនិយាយដូចគ្នាដែរ"។*

ពេលឈ្នះមិនរំភើប ពេលចាញ់មិនតក់ស្លុត។ ពេលក្រមិនអស់សង្ឃឹម ពេលមានមិនភ្លើតភ្លើន ហើយបើទោះបីជាមេឃរលំភ្នំរលាយនៅចំពោះមុខ ផែនដីខ្វាត់ខ្វាយគ្មានសល់បំណែក ក៏សូមរក្សាចិត្តឲ្យនឹងថ្កល់ មិនព្រឺមិនព្រួចញញើចញញើមឲ្យសោះ៕

"You're never as good as everyone tells you when you win, and you're never as bad as they say when you lose." - Lou Holtz

# ថ្ងៃទី៣០ ខែកញ្ញា

លោក ម៉ាទីន លូធ័រឃីង [ Martin Luther King ] ពោលថា"*ក្នុងលោកយើងនេះ គ្មានអ្វីដែលគ្រោះថ្នាក់ខ្លាំងបំផុត ជាងមនុស្សស្មោះត្រង់ដោយអវិជ្ជា ឬស្មោះត្រង់ដោយឥតបញ្ញា [ Sincere Ignorance ] ហើយថែមទាំងនៅតែមិនដឹងថាខ្លួនឯងល្ងង់ទៀត*"។

មនុស្សល្ងង់តែងយកបេះដូងដាក់លើអណ្ដាត តែមនុស្សដែលឆ្លាត គេយកអណ្ដាតដាក់លើបេះដូង។ បុរាណខ្មែរតែងប្រដៅឲ្យកូនចៅ "គិត មុនគូរ ឬគិត សិនចាំគូរ"។ អណ្ដាតជាអាទិ៏កន្លង បានសុខទុក្ខផង ក៏ព្រោះអណ្ដាត។ សម្ដីជាឯកលេខជាទោអក្សរជាត្រី។មនុស្សដែលល្ងង់បំផុតតែងប្រើត្រឹមតែអារម្មណ៍មនោសញ្ចេតនាដោយខ្វះការចូលរួមពីខួរក្បាល ហើយមនុស្សដែលឃោរឃៅបំផុត តែងប្រើ

ត្រឹមតែខួរក្បាល ដោយខ្វះការចូលរួមពីអារម្មណ៍មនោសញ្ចេតនា។ តាមកាលៈទេសៈ មនុស្សដែលចេះប្រើខួរក្បាលផង និងចេះប្រើអារម្មណ៍មនោសញ្ចេតនាអាណិតអាសូរផង គឺមិនត្រឹមតែឆ្លាតមានបញ្ញាប៉ុណ្ណោះទេ ហើយថែមទាំងមានចិត្តល្អទៀត ។

សង្គមជាតិត្រូវការមនុស្សមានក្តីអាណិតអាសូរផង និងមានបញ្ញាផង តែបើមានបញ្ញាដោយខ្វះមនោសញ្ចេតនា គឺនឹងក្លាយទៅជាឃោរឃៅដាក់ខ្មែរគ្នាឯង ហើយបើមានមនោសញ្ចេតនាដោយខ្វះបញ្ញា គឺនឹងក្លាយទៅជាឧបករណ៍នយោបាយ ឬត្រូវអ្នកនយោបាយប្រើប្រាស់ដើម្បីមហិច្ឆតានយោបាយ។ បញ្ហាដែលយុវជនខ្មែរត្រូវគិត គឺរឿងនយោបាយ ហើយបញ្ហាដែលយុវជនខ្មែរត្រូវប្រយ័ត្ន គឺអ្នកនយោបាយ ពីព្រោះអ្នកនយោបាយធ្វើឲ្យយុវជនខ្វែងគំនិតគ្នា ស្អប់គ្នា និងលាបពណ៌ដាក់គ្នា [ Label ]។

សង្គមដើរដល់ចំណុចនេះ គឺដោយសារកំហុសអ្នកនយោបាយ។ កំហុសដ៏ធំបំផុត គឺប្រជាជនខ្មែរខ្លាចនយោបាយ។ ថ្ងៃនេះយុវជនស្អប់គ្នា វាយប្រហារគ្នា និងលាបពណ៌ដាក់គ្នា គឺដោយសារកំហុសអ្នកនយោបាយជាន់ខ្ពស់ តែកំហុសធំបំផុត គឺយើងជាយុវជនខ្លួនឯងពេញចិត្តធ្វើជាឧបករណ៍នយោបាយ៕

# ទស្សនៈសម្រាប់ខែ

# តុលា

# ថ្ងៃទី០១ ខែតុលា

សុភាសិតចិនបានលើកឡើងថា *"មនុស្សពីធម្មជាតិកើតមកមានភាពស្រដៀងគ្នា ប៉ុន្តែការអប់រំធ្វើឲ្យមនុស្សគ្រប់គ្នាមានភាពខុសគ្នា"*។

មនុស្សដែលគ្មានការអប់រំ តែងជាប់គុកគំនិត តែមនុស្សដែលមានការអប់រំ គឺតែងមានសេរីភាពខាងគំនិត បើទោះបីជាខ្លួនប្រាណគេនៅក្នុងគុកពិតក៏ដោយ។ រស់នៅក្នុងសង្គមអយុត្តិធម៌ បណ្ឌិតជនជាប់គុកក៏ពិតមែន តែប្រៀបដូចមានសេរីភាព។ ផ្ទុយទៅវិញ ជនអវិជ្ជាគ្មានទោសក៏ពិតមែន តែប្រៀបដូចមានទោស គឺទោសព្រោះគំនិតខាងក្នុង។ ឫសគល់នៃការអប់រំមានជាតិល្វីង តែផ្លែផ្កាតែមានជាតិផ្អែម។

មនុស្សល្ងង់ដោយសារកត្តាពីរ៖

១) គ្មានឱកាសរៀន

២) មានឱកាសរៀន តែមិនប្រឹងប្រែង។

បើចង់បានភោគផលសម្រាប់រយៈពេលមួយឆ្នាំ ចូរដាំស្រូវ។ បើចង់បានភោគផលសម្រាប់រយៈពេលមួយទស្សវត្សរ៍ ចូរដាំដើមឈើ ហើយបើចង់បានភោគផលសម្រាប់រយៈពេញមួយជីវិត ចូរដាំមនុស្ស៕

# ថ្ងៃទី០២ ខែតុលា

"បើមានឆន្ទៈចង់ជួយជាតិ តែគ្មានសមត្ថភាព តើមានប្រយោជន៍អ្វី"។ បើមានសមត្ថភាព តែគ្មានសីលធម៌ និងគ្មានចិត្តមេត្តា តើមានអ្វីកើតឡើង? មានឆន្ទៈ ហើយថែមទាំងមានសមត្ថភាពទៀត នោះទើបកើតប្រយោជន៍។ មានសមត្ថភាពពិត ហើយមានសីលធម៌ និងចិត្តមេត្តាដោយឈរលើភាពត្រឹមត្រូវនិយម នោះគឺទើបអាចសង្គ្រោះមនុស្សបាន។ ជាយុវជនគួរខិតខំប្រឹងប្រែងរៀនសូត្រ៕

# ថ្ងៃទី០៣ ខែតុលា

ដល់ទីណាក៏ដោយ ក៏ត្រូវតែមានសេចក្តីសុខនៅជាមួយមិត្តភក្តិ ក៏ត្រូវតែមានសេចក្តីសុខ។ នៅជាមួយគូស្នេហ៍ ក៏ត្រូវតែមានសេចក្តីសុខ។ នៅជាមួយគ្រួសារ ក៏ត្រូវតែមានសេចក្តីសុខ ហើយនៅម្នាក់ឯង ក៏ត្រូវតែមានសេចក្តីសុខ ពីព្រោះពេលវេលានៃសេចក្តីសុខ មានត្រឹមតែម្តងប៉ុណ្ណោះគឺ ពេលនេះ និងបច្ចុប្បន្ននេះ។ វាមិនអាចទេដែលគ្រប់គ្នាថា *"សេចក្តីសុខនៅគ្រប់ទីកន្លែង តែតាមពិតសេចក្តីសុខតែងស្ថិតនៅក្នុងខ្លួនយើងមួយកន្លែងគត់"* ។ វាមិនអាចទេដែលគ្រប់គ្នាថា "សង្គមរញ៉េរញ៉ៃ តែតាមពិតយើងម្នាក់គត់ដែលធ្វើឲ្យជីវិតខ្លួនឯងរញ៉េរញ៉ៃ។ ហើយវាក៏មិនអាចទេដែលគ្រប់គ្នាស្វែងរកសេចក្តីសុខពីអ្នកដទៃ តែតាមពិតយើងត្រូវព្យាយាមស្វែងសេចក្តីសុខក្នុងពីខ្លួនយើង ៕

# ថ្ងៃទី០៤ ខែតុលា

ហេតុអ្វី អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] លៀនអណ្តាតចេញមកក្រៅ? ក្នុងយុគសម័យនោះ មិនថាគាត់ធ្វើអ្វី ឬទៅណាមកណា គឺតែងមានអ្នកកាសែតតាមហូរហែរហូត។ ដោយការធុញទ្រាន់ចំពោះអ្នកយកព័ត៌មានដែលតាមថតរូប ទើបគាត់លៀនអណ្តាតដាក់អ្នកថតរូប។ ក៏ប៉ុន្តែ ការលៀនអណ្តាតរបស់គាត់ ក៏ត្រឡប់ក្លាយទៅជារូបបែបទំនៀមទម្លាប់មួយ ដែលនរណាមានអារម្មណ៍ធុញទ្រាន់ ឬជាមនុស្សចូលចិត្តលេងបែបសប្បាយ ក៏តែងលៀនអណ្តាត។ ជីវិតប្រៀបដូចនឹងការជិះកង់ គឺយើងត្រូវរក្សាលំនឹង។

សមីការជីវិតរបស់អាល់ប៊ឺត អាញស្តាញ [ Albert Einstein] គឺ៖ "បើ A ជាបុគ្គលជោគជ័យក្នុងជីវិត, នោះ A ស្មើឲ្យ x បូក y បូក z ។ តាង x គឺជាការងារ, តាង y គឺជាការលេង

កម្សាន្ត , និងតាង z គឺជាការមិននិយាយច្រើនឥតប្រយោជន៍"។ ការក្លាយជាបុគ្គលជោគជ័យ គឺត្រូវមានកត្តាបីខាងលើ។ មានការប្រកបការងារផង [ x ] ហើយនិងមានការលេងកម្សាន្តផង [ y ] ពីព្រោះវាជារឿងធម្មតានៃជីវិតមនុស្សពីធម្មជាតិ។

យើងមិនមែនជាមនុស្សម៉ាស៊ីនដែលត្រូវតែគិតពីការងារគ្រប់វេលានោះទេ។ ចំណែកការនិយាយស្ដី [ z ] គឺជាការប្រសើរត្រូវនិយាយឲ្យតិច ធ្វើឲ្យច្រើន ហើយធ្វើល្អប្រសើរជាងនិយាយល្អ។ បុគ្គលដែលកាន់តែជោគជ័យគេដឹងកាន់តែច្បាស់ថា ការនិយាយឲ្យតិច និងធ្វើឲ្យច្រើនជារឿងប្រពៃ និងមានប្រយោជន៍។ លោក Jim Rohn ពោលថា "បើពេលរៀន គឺត្រូវរៀន, បើពេលធ្វើការគឺត្រូវធ្វើការ, ហើយបើពេលលេង គឺត្រូវលេង តែសូមកុំច្របល់គ្នាក្នុងពេលតែមួយឲ្យសោះ"៕

"Life must be lived as play." - Plato

# ថ្ងៃទី០៥ ខែតុលា

*" ជោគជ័យមិនមែនជាគន្លឹះទៅរកសុភមង្គលតែសុភមង្គលគឺជាគន្លឹះទៅរកភាពជោគជ័យ។ យើងនឹងទទួលបានជោគជ័យ ប្រសិនបើយើងស្រឡាញ់អ្វី ដែលយើងកំពុងធ្វើ និងធ្វើអ្វីដែលយើងស្រឡាញ់"។*

ជោគជ័យ គឺត្រូវធ្វើអ្វីដែលយើងស្រឡាញ់ និងស្រឡាញ់ពេញចិត្តអ្វីដែលយើងធ្វើ។ ជីវិតដែលគ្មានការងារធ្វើ ឬស្ថិតក្នុងនិកម្មភាព គឺនៅពេលយើងកើត និងពេលយើងចាស់ជិតស្លាប់។ ក៏ប៉ុន្តែក្រៅពីនោះ មនុស្សយើងនៅជាមួយការងាររហូតស្ទើពេញមួយជីវិត។ មនុស្សម្នាក់អាចទទួលបានប្រាក់ចំណូលខ្ពស់ពីការងារមួយដែលខ្លួនមិនស្រឡាញ់ តែខ្លួនឥតទទួលបានសុភមង្គលទាល់តែសោះពីការងារនោះ។ អ៊ីចឹងគឺមានន័យថា មិនស្រឡាញ់ចូលចិត្តការងារដែលខ្លួនកំពុងធ្វើ ប្រៀបដូចធ្លាក់នរកទាំងរស់៕

# ថ្ងៃទី០៦ ខែតុលា

ការជួយសង្គ្រោះមនុស្សពិតប្រាកដ ការជួយសង្គ្រោះមនុស្សពិតប្រាកដ គឺជាការជួយឲ្យពួកគេចេះជួយខ្លួនឯង។ ពេលខ្លះ ចូរយើងកុំព្យាយាមធ្វើជាមនុស្សខ្លាំងដើម្បីឲ្យពួកគេពឹងផ្អែកបានរហូតឲ្យសោះ។ អំណោយអាចឲ្យមនុស្សរស់បានមួយថ្ងៃ តែភាពមានការងារនឹងជួយឲ្យមនុស្សរស់បានមួយជីវិត។ អំណោយគឺសម្រាប់ជនពិការ និងជនរងគ្រោះ តែមិនមែនសម្រាប់មនុស្សគ្រប់គ្នាទូទៅនោះទេ។ បុគ្គលថ្លៃថ្នូរត្រូវការការងារ មិនមែនត្រូវការអំណោយដើម្បរស់ទេ៕

# ថ្ងៃទី០៧ ខែតុលា

វិល្លៀម ស្ហេកស្ពៀរ [ William Shakespeare ] ពោលថា *"មនុស្សល្ងង់តែងគិតថាខ្លួនឯងឆ្លាត តែមនុស្សឆ្លាត បែរជាគិតថាខ្លួនឯងនៅល្ងង់"*។

ទស្សនវិទូក្រិច សូក្រាត [ Socrates ] ពោលថា "ខ្ញុំមិនដឹងគ្រប់យ៉ាងទាំងអស់ តែខ្ញុំដឹងត្រឹមតែម្យ៉ាងគត់ គឺខ្ញុំមិនចេះអ្វីទាំងអស់"។ មនុស្សល្ងង់រៀនពីអ្នកចេះ អ្នកចេះរៀនពីមនុស្សគ្រប់ប្រភេទ តែបណ្ឌិតរៀនពីអ្វីគ្រប់យ៉ាង។ ចំណីដល់មាត់មិនចេះស៊ី វិជ្ជាដល់ត្រចៀកមិនចេះទទួល។ ចង់ចេះឲ្យប្រឹងរៀន ចង់មានឲ្យប្រឹងរក ចង់ស្រណុកឲ្យស្រវារកវិជ្ជា ចង់វេទនាឲ្យខ្ជិលច្រអូស។

កាន់តែរៀន កាន់តែរស់ ហើយអ្នកដែលឈប់រៀន គឺមានន័យថាឈប់រស់ដែរ។ មានឱកាសរៀន សូមប្រឹងប្រែងរៀន ពីព្រោះមានអ្នកខ្លះគ្មានឱកាសរៀនទេ។

នឹកឃើញជីវិតពិតខ្ញុំ ពេលវ័យត្រូវចូលមហាវិទ្យាល័យ តែបែរជាមិនអាច និងត្រូវទទួលបន្ទុកគ្រួសារពេញស្មាទៅវិញ ។ រយៈពេល ៨ ឬ៩ឆ្នាំ មិនមែនជាពេលលេងសើចទេសម្រាប់ខ្ញុំ ពីព្រោះខ្ញុំត្រូវបោះបង់យុវភាព បោះបង់ការសិក្សាបន្ត [ តម្លៃឱកាសដែលត្រូវតែធ្វើការ ឬហៅថា Opportunity Cost ] បោះបង់ការសប្បាយ និងត្រូវធ្វើការរហូតរហូតដល់ចប់បន្ទុកទើបអាចបន្តមហាវិទ្យាល័យបាន។ មិត្តខ្ញុំដល់ខែ តែងទូរស័ព្ទទៅអ្នកផ្ទះយកថវិការៀន តែខ្ញុំជិតដល់ខែ ម៉ែទូរស័ព្ទសួរថា "បើកប្រាក់ខែហើយ ឬនៅ?" នេះហើយ ដែលគេហៅថាជីវិត៕

# ថ្ងៃទី០៨ ខែតុលា

*"យើងមិនអាចធ្វើរឿងគ្រប់យ៉ាង សម្រាប់មនុស្សគ្រប់គ្នា នៅគ្រប់ទីកន្លែងទាំងអស់ តែយើងអាចធ្វើរឿងមួយចំនួន សម្រាប់មនុស្សមួយចំនួន នៅកន្លែងមួយចំនួនបាន"។* ដុំថ្មតូចមួយដុំ គឺគង់តែអាចធ្វើឲ្យមានទឹករលកបាន បើយើងតាំងចិត្តគប់វាចូលទៅក្នុងទឹក។ ចំណែកមនុស្សយើង បើទោះបីជាខ្លួនយើងយល់ថា ខ្លួនឯងមិនមានតម្លៃយ៉ាងណាក៏ដោយ តែក៏គង់នៅតែមានប្រយោជន៍។

គេថា "កុំឲ្យយកពងមាន់ទៅជល់នឹងថ្ម"។ ការពិត ថ្វីត្បិតតែពងមាន់បែកមែន ពេលដែលជល់នឹងថ្ម តែយ៉ាងហោចណាស់គង់អាចធ្វើឲ្យថ្មប្រលាក់ខ្លះដែរ។ លះបង់ខ្លួនដើម្បីអនាគតខ្លួន លះបង់អនាគតខ្លួន ដើម្បីអនាគតគ្រួសារខ្លួន លះបង់គ្រួសារខ្លួន ដើម្បីស្រុកភូមិខ្លួន ហើយលះបង់ស្រុកភូមិខ្លួន ដើម្បីសង្គមជាតិខ្លួន។

ពេលខ្លះមនុស្សខ្លះអ្នកដឹកនាំខ្លះអាចបរាជ័យលើគ្រប់យ៉ាង ពីព្រោះការលះបង់គ្រប់យ៉ាងដើម្បីបុព្វហេតុជាតិតែម្យ៉ាង ហើយជាតិនឹងរស់រហូត។ មាតាតូច គឺម្តាយ តែមាតាធំ គឺជាតិ។ ដូច្នេះ បើកូនទាំងឡាយស្រឡាញ់ម្តាយធំ ចូរកូនចូលរួមធ្វើនយោបាយសង្គ្រោះម្តាយផង៕

We can't do everything for everyone everywhere, but we can do something for someone somewhere.

- Richard L. Evans

# ថ្ងៃទី០៩ ខែតុលា

យុទ្ធសាស្ត្រ [ Strategy ] និងសិល្បៈ [ Tactics ]

១. មានយុទ្ធសាស្ត្រខ្លាំង និងសិល្បៈអស្ចារ្យ នោះនឹងធ្វើឲ្យយើងរីកចម្រើនយ៉ាងឆាប់រហ័ស។

២. មានយុទ្ធសាស្ត្រខ្សោយ តែមានសិល្បៈខ្លាំង នោះនឹងធ្វើឲ្យយើងបរាជ័យយ៉ាងលឿនបំផុត។

៣. មានសិល្បៈខ្សោយ តែមានយុទ្ធសាស្ត្រខ្លាំងអស្ចារ្យ នោះក៏អាចធ្វើឲ្យយើងសម្រេចជោគជ័យសមរម្យ ទោះមិនអស្ចារ្យ តែក៏មិនអន់។

៤. មានសិល្បៈខ្សោយ ហើយមានយុទ្ធសាស្ត្រខ្សោយទៀត នោះសន្សឹមៗនឹងធ្វើឲ្យយើងឆ្ពោះទៅរកបរាជ័យដោយល្បឿនដ៏យឺត។

ម៉ៅ សេទុង [ Mao Tse Tung ] ពោលថា "*យើងអាចធ្វើឲ្យសត្រូវដើរផ្លូវខុសបានដោយថ្វីដៃរបស់យើង*"។

ស៊ុន ជឺ ពោលថា "*យកឈ្នះដោយល្បិចកល ត្រូវរៀបចំអន្ទាក់ឲ្យសត្រូវដើរចូល ហើយប្រើកម្លាំងវាយសង្គ្រប់យកឈ្នះតែម្តង*"។ ការប្រើយុទ្ធសាស្ត្រ មិននិយាយពីសីលធម៌ ឬគុណធម៌ តែសំខាន់គឺការសម្រេចប្រយោជន៍ធំ ពីព្រោះក្នុងសង្គមខ្លះ អ្នកចាញ់ គឺជាចោរ និងអ្នកឈ្នះ គឺជាស្តេច។ ស្តេច ឬចោរ គ្មាននរណាខ្វល់នឹងយើងទេ តែសំខាន់គឺយើងឈ្នះ មានកិត្តិយស។ ចូរយើងរៀនកសាងតម្លៃឲ្យខ្លួនឯង៕

# ថ្ងៃទី១០ ខែតុលា

បុរាណខ្មែរពោលថា"*ស្រុកកើតសង្គ្រាម ត្រូវការអ្នកក្លាហាន ស្រុកសាន្តត្រាន ត្រូវការអ្នកចេះដឹង*"។ជំនាន់នេះ គឺជាសម័យអន្តរកាលទំនាស់មួយ រវាងប្រជាជនចាស់ អ្នកតស៊ូសម័យសង្គ្រាមពីមុន និងយុវជនជំនាន់ថ្មីដែលមានទ្រឹស្តីអប់រំសែសម័យទំនើប។ ទស្សនៈអ្នកក្លាហានយល់ថា "*យុវជនអត់បានជួយតស៊ូ អ៊ីចឹងដល់មានសន្តិភាព ហេតុអ្វីស្រួលៗត្រូវផ្ទេរអំណាច?*"

យុវជនសម័យសន្តិភាពស្រាប់យល់ឃើញថា "មានតែអ្នកចេះដឹងទេ ទើបអាចកសាងសង្គមមួយរីក ចម្រើនបាន ពីព្រោះអ្នកក្លាហានបានត្រឹមតែពន្លត់ភ្លើងសង្គ្រាម ប៉ុណ្ណោះ"។

តើអ្នកក្លាហាន [ អ្នកតស៊ូរំដោះជាតិខ្មែរសម័យសង្គ្រាម ] និងអ្នកចេះដឹង [ យុវជនសម័យសន្តិភាព ] អាចស្រុះស្រួលដោយងាយស្រួលទេ? ហើយ តើយុវជនគួរដោះស្រាយបញ្ហានេះដោយរបៀបណា?

ជាទស្សនៈខ្ញុំ បើមិនទាន់អាចធ្វើបាន សូមត្រឹមតែត្រៀមខ្លួនទៅបានហើយ ពីព្រោះគ្មានអ្វីមួយ ឬគ្មាននរណាម្នាក់អតមៈទេ។ យើងគ្រាន់តែត្រូវចាំថា *"យើងមិនអាចក្លាយទៅជាយុវជនខ្លាំងក្នុងថ្ងៃនេះ តែយើងអាចប្រឹងប្រែងរៀនសូត្រចាប់ពីថ្ងៃនេះតទៅ ដើម្បីត្រៀមខ្លួនជួយសង្គមជាតិឲ្យខ្លាំងនាពេលអនាគត"*៕

# ថ្ងៃទី១១ ខែតុលា

*" ត្រូវចេះមានទឹកចិត្តមើលឃើញដល់ទុក្ខលំបាកមនុស្សក្រខ្សត់ មុនពេលគេអង្វរសុំទាន ឬមុនពេលគេបង្ខំចិត្តធ្វើជាចោរប្លន់"*។

មនុស្សល្អនឹងជួយអ្នកមានទុក្ខតាមសំណើសុំជំនួយ ប៉ុន្តែមនុស្សហួសពីល្អ គឺនឹងផ្តល់ជំនួយដោយមិនចាំបាច់មានសំណើសុំជួយ។ គ្រប់គ្នានិយាយថា *"កុំឲ្យត្រីទៅនរណាម្នាក់ តែត្រូវបង្រៀនគេឲ្យចេះស្ទូចត្រីដោយខ្លួនឯង"* ។

ប៉ុន្តែខ្ញុំយល់ថា *"ត្រូវតែឲ្យត្រីទៅគេ ហើយបន្ទាប់ទើបបង្រៀនគេឲ្យចេះស្ទូចត្រីតាមក្រោយទៀតផង"*។ នេះហើយ គឺជារបៀបជួយឲ្យដល់ត្រើយ៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី១២ ខែតុលា

*"ធ្លាប់បានព្យាយាម ធ្លាប់បានទទួលបរាជ័យ តែទោះជាយ៉ាងណា ក៏នៅតែព្យាយាមម្តងទៀត ហើយក៏បានបរាជ័យម្តងទៀត ក៏ប៉ុន្តែគឺត្រូវបរាជ័យឲ្យល្អជាងមុន"។*

ថ្ងៃដែលយើងព្យាយាម គឺជាថ្ងៃដែលយើងហាត់។ ថ្ងៃដែលយើងបរាជ័យ គឺជាថ្ងៃដែលយើងយំ។ ថ្ងៃដែលយើងតាំងចិត្តសាកល្បងម្តងទៀត គឺជាថ្ងៃដែលយើងមានសង្ឃឹមឡើងវិញ។ ថ្ងៃដែលបរាជ័យស្ថិតនៅជាមួយយើងទៀត គឺជាថ្ងៃដែលយើងទទួលមេរៀន និងភាពរឹងមាំ។ ថ្ងៃបន្ទាប់យើងបរាជ័យល្អជាងមុន ហើយចុងក្រោយស្នាមញញឹមក៏មានលើផ្ទៃមុខយើង ពោរពេញដោយមោទកភាព។

បើមិនស្គាល់លុយពិត តែសូមឲ្យស្គាល់លុយក្លែងក្លាយ បើមិនស្គាល់មនុស្សល្អ តែសូមឲ្យស្គាល់មនុស្សអាក្រក់ ហើយ

បើមិនស្គាល់មាគ៌ាទៅកាន់ជោគជ័យ តែក៏សូមឲ្យស្គាល់មាគ៌ាទៅកាន់បរាជ័យ គឺគ្រប់គ្រាន់ដើម្បីឲ្យយើងអាចជ្រើសរើសយកជម្រើសមួយបានហើយ។

"បរាជ័យឲ្យល្អជាងមុន" គឺចង់សំដៅថា បរាជ័យនោះនឹងប្រាកដជាអាចនាំយើងឲ្យទៅដល់ជ័យជម្នះ ហើយដើម្បីអាចទៅដល់ភាពជាអ្នកឈ្នះបាន លុះត្រាតែយើងបានរៀនពីបទពិសោធន៍ចាញ់។ បរាជ័យដែលមិនល្អ គឺជាបរាជ័យដែលយើងបោះបង់ឱកាសរៀនពីភាពបរាជ័យ ឬគ្មានបានទាញមេរៀនអ្វីសោះដើម្បីសិក្សាស្វែងយល់។

ទ្រឹស្តីវិទ្យាសាស្ត្រជោគជ័យបុគ្គលបានលើកឡើងថា "បើចង់ជោគជ័យកាន់តែខ្លាំង គឺសូមបង្កើនចំនួនបរាជ័យឲ្យកាន់តែកើនឡើងទ្វេដង"។ ប្រឌិតករឬអ្នកបង្កើតអំពូលភ្លើង ថូម៉ាស់ អេឌីសិន [ Thomas A. Edison ] បានបរាជ័យជាងមួយពាន់ដងក្នុងការងារបង្កើតអំពូលភ្លើង តែ

គាត់មិនបោះបង់ ហើយបានរៀនមេរៀនល្អៗជាច្រើនពីបរាជ័យនោះ និងរហូតចុងក្រោយ គាត់ក្លាយជាអ្នកឈ្នះលើបំណងប្រាថ្នា និងការព្យាយាមរបស់ខ្លួន៕

*"Ever tried. Ever failed. No matter. Try again. Fail again. Fail better. "* Samuel Beckett

# ថ្ងៃទី១៣ ខែតុលា

*"សូមកុំចំណាយពេលវេលាដែលកំពុងមាន ទៅគិតឥតប្រយោជន៍លើពេលវេលាដែលធ្លាប់មានពីមុនឲ្យសោះ។ សូមយើងចេះថែរក្សាគ្រប់យ៉ាងដែលកំពុងតែមាន ប្រសើរជាងទៅគិតលើអ្វីម្យ៉ាងដែលធ្លាប់មាន"។*

យើងយល់ថាលុយសំខាន់ តែពេលវេលាសំខាន់ជាងលុយទៅទៀត ពីព្រោះលុយអាចរកបាន តែពេលវេលាបើកន្លងទៅហើយ គឺមិនអាចត្រឡប់ថយក្រោយវិញបានទេ។ យើងថាពេលវេលាមានតម្លៃ តែសុខភាពមានតម្លៃជាងពេលវេលាទៅទៀត ពីព្រោះបើសុខភាពខ្សោយ គឺគ្រប់យ៉ាងក៏ខ្សោយដែរ។ បើមានត្រឹមតែពេលវេលាច្រើន បូកនឹងសុខភាពខ្សោយ គឺស្មើនឹងសូន្យ ហើយបើមានសុខភាពល្អបូកនឹងខ្សោយរបៀបចាត់ចែងពេលវេលា ក៏ស្មើនឹងសូន្យដែរ។

មនុស្សមានប្រយោជន៍ ឬគ្មានប្រយោជន៍ គឺជាបុគ្គលដែលចេះប្រើពេលវេលាឲ្យមានប្រយោជន៍ ឬគ្មានប្រយោជន៍នោះឯង។ ចូរយើងចេះប្រើពេលនេះ ឲ្យមានប្រយោជន៍ ហើយត្រូវចាំថាអតីតកាលបានកន្លងហួសហើយ ចំណែកអនាគតក៏ពុំទាន់កើត តែមានតែពេលនេះប៉ុណ្ណោះដែលសំខាន់ជាងគេបំផុតក្នុងជីវិតមនុស្សយើង។ ម្យ៉ាងវិញទៀត ម្សិលមិញគឺជាថ្ងៃនេះ ថ្ងៃនេះគឺជាថ្ងៃនេះ ហើយអនាគតក៏ជាថ្ងៃនេះដែរ គឺថាឲ្យតែយើងចេះរៀបចំថ្ងៃនេះឲ្យល្អបំផុត នោះអតីតកាលក៏នឹងល្អ ហើយក៏មានន័យថាបានរៀបចំអនាគតឲ្យបានល្អដូចគ្នាដែរ៕

No more wasting time thinking about wasted time.

# ថ្ងៃទី១៤ ខែតុលា

*"បើមនុស្សប្រុសប្រើកម្លាំងដើម្បីឈ្នះមនុស្សស្រី គឺគ្មាននរណាគេសរសើរទេ តែបើចាញ់មនុស្សស្រីវិញ ក៏មិនដឹងយកមុខទៅទុកទីណាដែរ"*។

ចំណែកជីវិតវិញ ទទួលបានជោគជ័យដោយមិនបានប្រឹងប្រែង នោះក៏គ្មាននរណាសរសើរ តែបើប្រឹងប្រែងហើយនៅតែមិនទទួលជោគជ័យទៀត ក៏អាចនិយាយបានថាមិនដឹងយកមុខទៅទុកទីណា ឬក៏អាចថាគ្មាននរណាគេសើចចំអកឲ្យដែរ។ គ្មានកន្លែងណាមួយអាចឲ្យយើងឈប់សម្រាកបានស្រួលទេ ពីព្រោះរៀនក៏ពិបាក ដោយត្រូវប្រឹងធ្វើការឲ្យគេក៏ពិបាក ដោយសារត្រូវប្រឹង ទៅបួសជាសង្ឃក៏ពិបាក ដោយសារត្រូវប្រឹង និងធ្វើមន្ត្រីរាជការក៏ពិបាកដោយសារត្រូវប្រឹង។

ប៉ុន្តែសេចក្តីស្លាប់ បើទៅដល់ទីនោះហើយ មិនថាអ្នករៀនសូត្រ មិនថាអ្នកធ្វើការឲ្យគេ មិនថាមន្ត្រី មិនថាអ្នកបួស និងមិនថាមនុស្សល្ងង់ ឬមនុស្សឆ្លាតទេ សុទ្ធតែប្រាកដជាបានសម្រាកមែនទែនហើយ។ កុំបារម្ភ ពីព្រោះកាលណាសេចក្តីស្លាប់មកដល់ នោះយើងនឹងបានសម្រាកហើយ។

រឿងដែលពិបាករកបំផុតក្នុងជីវិត គឺបុព្វហេតុនៃជីវិត ពីព្រោះបុព្វហេតុនៃជីវិតឥតមាននរណាម្នាក់អាចប្រាប់យើងបាន ក្រៅពីយើងរកឃើញវាដោយខ្លួនឯង។ ថ្ងៃណាមួយ ឬពេលនេះ យើងអស់សង្ឃឹម យើងបោះបង់ខ្លួនឯងចោល តែទោះបីជាយ៉ាងណាក៏កុំភ្លេច *"ប្រឹងប្រែង"*។ បើមិនចង់ប្រឹងដើម្បីខ្លួនឯង ក៏គួរតែប្រឹងដើម្បីគ្រួសារ តែបើមិនចង់ប្រឹងដើម្បីគ្រួសារទេ ក៏គួរតែប្រឹងដើម្បីសង្គមជាតិ៕

# ថ្ងៃទី១៥ ខែតុលា

ល្បិច និងយុទ្ធសាស្ត្រ

ឪពុកនិយាយទៅកាន់កូនប្រុសថា៖ កូនប្រុស ពុកនឹងជ្រើសរើសគូអនាគតឲ្យកូន។

កូនប្រុសតប៖ ទេ ខ្ញុំមិនយល់ព្រមទេ!

ឪពុកបន្តថា៖ នារីម្នាក់នោះ គឺជាកូនស្រីរបស់ ប៊ីល ហ្គេត។

កូនប្រុសតប៖ បាទ បើអ៊ីចឹងមែន ខ្ញុំយល់ព្រម។

ឪពុកបានទៅជួប ប៊ីល ហ្គេត រួចនិយា៖ ខ្ញុំចង់បានកូនស្រីរបស់លោករៀបការជាមួយកូនប្រុសខ្ញុំ។

ប៊ីល ហ្គេតតប៖ ទេ ខ្ញុំមិនយល់ព្រមទេ!

ឪពុកបន្ត៖ កូនប្រុសរបស់ខ្ញុំ គឺជានាយកប្រតិបត្តិនៃធនាគារពិភពលោក world bank។

ក្រោយបន្តិច ប៊ីល ហ្គេតតប៖ បាទ បើអ៊ីចឹងមែន ខ្ញុំយល់ព្រម។

ឪពុកបានទៅជួបប្រធានធានាគារពិភពលោក world bank រួចនិយាយថា៖ ខ្ញុំចង់ឲ្យលោកតែង តាំងកូនប្រុសខ្ញុំជានាយកប្រតិបត្តិនៃធានាគារពិភពលោក world bank។

ប្រធានធានាគារ world bank តប៖ ទេ ខ្ញុំមិនអាចធ្វើបែបហ្នឹងបានទេ!

ក្រោយមកឪពុកនិយាយទៀតថា៖ កូនប្រុសរបស់ខ្ញុំគឺជាកូនប្រសាររបស់ ប៊ីល ហ្គេត។

បន្តិចក្រោយមក ប្រធានធានាគារ world bank តប៖ បាទ បើអ៊ីចឹងមែន ខ្ញុំយល់ព្រម។

# ថ្ងៃទី១៦ ខែតុលា

*"សុខពិត គឺសេចក្តីស្ងប់ ហើយពុំមានសុខណា ស្មើស្ងប់ទេ"*

ពុំមានសេចក្តីសុខអស្ចារ្យណា ដែលអ្នកដទៃផ្តល់ឲ្យយើង ស្មើដល់សេចក្តីសុខដែលយើង រកបានក្នុងខ្លួនយើងនោទេ ។ ពុំមានសេចក្តីសុខណា ដែលយើងរកបានក្នុងខ្លួនយើង ស្មើដល់សេចក្តីស្ងប់ដែលមានក្នុងចិត្តយើងនោះទេ។

ឈប់គិតរឿងជាប់ជំពាក់មួយរយៈសិន យកដៃចាប់កាន់សៀវភៅ ឧទ្ទិសខ្លួនលើចំណេះដឹង ដើម្បីដោះស្រាយបញ្ហាសង្គមពេលនេះ ក៏ដូចជាសម្រាប់១០ ឬ២០ឆ្នាំក្រោយ។ តម្លៃពិតរបស់ជីវិត គឺកសាងស្នាដៃសម្រាប់អនុជនជំនាន់ក្រោយ។ ចូររៀនកសាងតម្លៃខ្លួនឯង ហើយហ្វឹកហាត់ចិត្តកាយជាមនុស្សមានតម្លៃ។

ចូរធ្វើជាមនុស្សមានតម្លៃ និងធ្វើជាមនុស្សជោគជ័យ តែបើយើងត្រូវជ្រើសមួយក្នុងចំណោមពីរ គឺចូរធ្វើជាមនុស្សមានតម្លៃ ប្រសើរជាងធ្វើជាមនុស្សជោគជ័យ ពីព្រោះបើធ្វើជាមនុស្សមានតម្លៃតែម្យ៉ាង យើងនឹងមានគ្រប់យ៉ាង ៕

*"There is no path to happiness: happiness is the path."* - Buddha

# ថ្ងៃទី១៧ ខែតុលា

## ដូចម្ដេចដែលហៅថា មនុស្សគម្រក់?

ខុង ជឺ [ Confucius ] ពោលថា "ការចូលចិត្តមួលបង្កាច់អំពើល្អរបស់អ្នកដទៃឲ្យទៅជាអាក្រក់ ឈ្លក់វង្វេងនឹងវោហារសាស្ត្រដែលប្រើក្នុងផ្លូវខុសរបស់ខ្លួន មានគំនិតអាក្រក់ និយាយត្រឡប់ត្រឡិន និយាយបាតដៃជាខ្នងដៃ ហើយនៅអួតថាខ្លួនឯងឆ្លាតជាងគេ ឃើញអ្នកដទៃធ្វើខុស ខ្លួនឯងសប្បាយចិត្ត និងមិនប្រឹងប្រែងសិក្សារៀនសូត្រឲ្យជ្រៅជ្រះ បែរជាទៅដៀលត្មះថា អ្នកដទៃគ្មានការចេះដឹង។

គឺអ្វីទាំងនេះហើយ ដែលជាវិធីរបស់មនុស្សគម្រក់"។ មនុស្សឆ្លាតកើតមកមិនមែនដើម្បីមាក់ងាយមនុស្សល្ងង់ទេ តែដើម្បីជួយបង្រៀនមនុស្សល្ងង់ ហើយមនុស្សល្អកើតមកក៏មិនមែនដើម្បីមាក់ងាយមនុស្សអាក្រក់ដែរ តែដើម្បីជួយសង្គ្រោះមនុស្សអាក្រក់។

ពេលខ្លះ សូមកុំធ្វើជាអ្នករិះគន់បញ្ហាតែម្យ៉ាងគត់ តែត្រូវធ្វើជាអ្នករិះគន់ និងធ្វើជាអ្នកដោះស្រាយបញ្ហាផងដែរ៕

# ថ្ងៃទី១៨ ខែតុលា

សួរសុខ សួរទុក្ខ តើនរណាខ្លះដែលចូលចិត្តសួរនាំមិត្តភក្តិ ឬមនុស្សជុំវិញខ្លួនថា "តើសុខសប្បាយទេ?, ការងារ ឬការងារសិក្សាយ៉ាងណាដែរ? សុខភាពល្អទេ?...។ល"សូមធ្វើជាមនុស្សដែលចេះយកចិត្តទុកដាក់ ចំពោះមនុស្សដូចគ្នាដោយមិនប្រកាន់និកាយសាសនា និន្នាការនយោបាយ អ្នកមានឬអ្នកក្រ។ គ្រប់គ្នា មិនថាមនុស្សខ្សោយ ឬមនុស្សខ្លាំង អ្នកឆ្លាត ឬមិនឆ្លាត អ្នកដឹកនាំ បណ្ឌិតជន ឬមិនថានរណាទេ គឺត្រូវការការយកចិត្តទុកដាក់ ពីព្រោះយើងជាមនុស្សដូចគ្នា។ ពាក្យលើកទឹកចិត្តមនុស្សបាក់ទឹកចិត្តមួយម៉ាត់នឹងមានឥទ្ធិពលវិជ្ជមានជាងពាក្យសរសើរមនុស្សជោគជ័យមួយរយម៉ាត់៕

# ថ្ងៃទី១៩ ខែតុលា

បណ្ឌិត កែម ឡី មានប្រសាសន៍ថា *"អ្នកដឹកនាំល្អ គឺជាអ្នកដែលរៀបចំអ្នកបន្តវេនបានច្រើន ទាន់ពេលវេលា និងល្អជាងខ្លួនជានិច្ច"*។

ខ្ញុំយល់ថា *"យើងមិនអាចមានយុវជនខ្លាំងក្នុងថ្ងៃនេះ តែយើងអាចរៀបចំបណ្តុះបណ្តាលយុវជនថ្ងៃនេះ ឲ្យខ្លាំងសម្រាប់ថ្ងៃស្អែក"*។ ខ្ញុំខ្លួនឯង ថ្វីត្បិតតែជាអ្នកចូលចិត្តអានតែតាមពិត មានសៀវភៅ១០០០ក្បាល មិនស្មើនឹងមានគ្រូល្អនៅពីក្រោយម្នាក់ទេ។ពេលខ្លះមានអ្នកខ្លះសើចចំអកថា ល្ងង់ធ្វើចេះ ល្ងង់គង់វិនាស អានច្រើនឡប់។ សង្គមដែលមិនចេះហុចដៃជួយ ហើយចាំតែហារមាត់ស្តីបន្ទោស និងរិះគន់ គឺមិនត្រឹមត្រូវតាមគោលការណ៍ដាំបណ្តុះមនុស្សទេ។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

អ្នកណាក៏ជាគ្រូយើង កន្លែងណាក៏ជាសាលារៀនយើង ហើយវិនាទីណាក៏ជាម៉ោងរៀនរបស់យើង ឲ្យតែយើងតាំងចិត្តរៀនសូត្រ។

ទោះបីជាយ៉ាងក៏ដោយ ក្នុងនាមជាយុវជន សូមកុំរង់ចាំមេឃភ្លៀង តែត្រូវចេះរកទឹក និងរកប្រភពទឹក មកចាក់បំពេញចំណេះដឹងដោយខ្លួនឯង។ ចូរយើងក្រឡេកឲ្យខ្ពស់សម្លឹងមើលទៅឆ្ងាយ ប៉ុន្តែត្រូវទុកជើងទាំងពីរឲ្យមាំនៅលើដី។ ចូរយើងធ្វើអ្វីដែលអាចធ្វើបាន ដោយប្រើអ្វីដែលយើងមាន នៅទីកន្លែងដែលយើងរស់នៅ ហើយវាអាចបរាជ័យ ប៉ុន្តែអាក្រក់ជាងបរាជ័យទៅទៀត នោះគឺមិនហ៊ានសាកល្បង៕

# ថ្ងៃទី២០ ខែតុលា

*"យើងតែងនាំគ្នានិយាយថា មនុស្សដែលមានចំណេះដឹងតិចតួច ឬចេះមិនប្រាកដ គឺជារឿងគ្រោះថ្នាក់ខ្លាំងបំផុត តែបើទោះបីជាយ៉ាងណា ក៏វាមានគ្រោះថ្នាក់មិនបានពាក់កណ្ដាលមនុស្សដែលអវិជ្ជាដែរ"*។

មនុស្សពីរប្រភេទដែលគ្រោះថ្នាក់ខ្លាំងបំផុតសម្រាប់សង្គមជាតិ។

ប្រភេទទី១ គឺមនុស្សអាក្រក់ដែលមានចំណេះដឹងខ្ពស់ ឬចំណេះដឹងដោយគ្មានជ្រាបចូលជាចរិត ឬ "Knowledge Without Character"។ ការសាបព្រោះចំណេះដឹងខុស ឬសាបព្រោះខុសមនុស្សល្អ គឺប្រៀបដូចជាសាបព្រោះគ្រោះកាចដល់សង្គមទាំងមូល។

ប្រភេទទី២ គឺមនុស្សមានមនោសញ្ចេតនាដែលអវិជ្ជា ឬចិត្តល្អតែល្ងង់ ឬ "Sincere Ignorance"។

មនុស្សគ្រោះថ្នាក់ប្រភេទទី២ ភាគច្រើនតែងចាញ់បោកទៅរួមដៃជាមួយមនុស្សគ្រោះថ្នាក់ប្រភេទទីមួយ។ មនុស្សល្ងង់ជឿលង់លើសាសនា អាចបង្កើតឲ្យមានភេរវកម្ម។ មនុស្សល្ងង់កាន់អំណាចក្នុងដៃ អាចសង្កត់សង្កិនផ្តាច់ការ។ មនុស្សល្ងង់ប្រើប្រាស់សិទ្ធិសេរីភាពជ្រុល អាចបង្កើតភាពវឹកវរ និងភាពអនាធិបតេយ្យ។ មនុស្សល្ងង់មានលុយបង្កើតភាពមិនស្កប់ស្កល់ លោភលន់ និងពុករលួយ ហើយមនុស្សល្ងង់រស់ក្នុងភាពក្រីក្រអាចប្រព្រឹត្តិឧក្រិដ្ឋកម្មនានា។

ផ្ទុយទៅវិញ មនុស្សមានចំណេះជឿសាសនា មនុស្សមានចំណេះកាន់អំណាច មនុស្សមានចំណេះប្រើសេរីភាព មនុស្សមានចំណេះស្ថិតក្នុងភាពក្រីក្រ គឺជាប្រភពនៃសេចក្តីរុងរឿង សេចក្តីប្រឹងប្រែងដោយគុណធម៌ ដោយសីលធម៌ និងដោយសេចក្តីស្រឡាញ់។ អវិជ្ជាតែម្យ៉ាង គឺជាប្រភពនៃអកុសលគ្រប់យ៉ាង។ នៅក្នុងសង្គមខ្មែរក៏ប្រហែលជាមានមនុស្សគ្រោះថ្នាក់ ២ប្រភេទសម្រាប់សង្គមដែរ៖

១. មានបញ្ញាវន្តដែលគ្មានមនសិការជាតិយម

[ Unconscientious Intellectual ]

## ២. ជនអវិជ្ជាដែលមានមនសិការ

[ Conscientious Ignorant ]។

បើនិយាយក្នុងន័យនយោបាយ យើងត្រូវប្រុងប្រយ័ត្នចំពោះបញ្ញាវ័ន្តដែលគ្មានមសិការ និងជនអវិជ្ជាដែលមានមនសិការ ដោយសារចំណេះដឹងដែលគ្មានមនសិការជាតិនិយមមកបម្រើសង្គម គឺគេប្រឹងនឹងបូមប្រយោជន៍ពីសង្គមតាមវិធីពុករលួយ ឬអសីលធម៌ផ្សេងៗ ហើយបុគ្គលដែលមានមនសិការចង់ជួយសង្គមដោយអវិជ្ជា គឺនឹងត្រូវបានអ្នកនយោបាយបោកប្រើឲ្យបង្កចលាចលដល់សង្គមជាក់ជាពុំខាន ៕

# ថ្ងៃទី២១ ខែតុលា

ទ្រឹស្តីមួយបានលើកឡើងថា "*អ្នកដឹកនាំណាដែលធ្វើឲ្យសត្រូវទុកចិត្តចំពោះខ្លួន អ្នកដឹកនាំនោះនឹងអាច ថែរក្សាការពារប្រទេសជាតិឲ្យមានសន្តិភាពបាន*"។ អ្នកដឹកនាំដែលធ្វើឲ្យសត្រូវសង្ស័យ ឬធ្វើឲ្យសត្រូវមិនទុកចិត្ត គឺត្រូវបានគេដកតំណែង និងចាប់ដាក់គុកនយោបាយអស់រយៈពេលជាង១០ឆ្នាំ។ ផ្ទុយទៅវិញ អ្នកដឹកនាំដែលបានធ្វើឲ្យសត្រូវទុកចិត្ត បែរជាធ្វើឲ្យប្រជាពលរដ្ឋអស់ទំនុកចិត្តនៅពេលខ្លះទៅវិញ។

ព្រះពុទ្ធសម្តែងថា "*ក្នុងលោកយើងនេះមានវត្ថុ ៣យ៉ាងដែលមិនអាចបិទបាំងជិតបានគឺ ទីមួយគឺព្រះអាទិត្យ, ទីពីរគឺព្រះចន្ទ និងទីបីគឺការពិត ឬសច្ចភាព*"។ ស្របនឹងប្រធានាធិបតីអាមេរិក អាប្រាហាម លីនខុល [ Abraham Lincoln ] បានលើកឡើងថា "*អ្នកអាចបោកប្រាស់ប្រជាជន*

*ទាំងអស់បានក្នុងពេលខ្លះ អ្នកអាចបោកប្រាស់ប្រជាជនខ្លះបានគ្រប់ពេល តែអ្នកមិនអាចបោកប្រាស់ប្រជាជនទាំងអស់បានគ្រប់ពេលទាំងអស់នោះទេ"។*

ខ្ញុំបានលើកឡើងពីទស្សនៈរបស់គណៈប្រធានរដ្ឋសម័យកម្ពុជាប្រជាធិបតេយ្យ ដែលថា "អ្នកនយោបាយបណ្តោយខ្លួនឲ្យដួចប្រជាជនសាមញ្ញពុំបានទេ ពីព្រោះអ្នកនយោបាយត្រូវទទួលខុសត្រូវលើវាសនាជាតិ" ក៏មានអ្នករិះគន់ដែរ។

មានពេលមួយនោះ ខ្ញុំបានសរសេរព្រះរាជបន្ទូលរបស់សម្តេច នរោត្តម សីហនុ ដែលថា "មនុស្សគ្រប់រូប គ្មាននរណាម្នាក់ដែលគ្មានកំហុសទេ រួមទាំងខ្ញុំផងដែរ។ ប៉ុន្តែអ្វីដែលចង់ឃើញបំផុតនោះគឺ ប្រទេសរបស់ខ្ញុំមានសុខសន្តិភាពប្រជារាស្ត្ររបស់ខ្ញុំចេះស្រឡាញ់ និងរួបរួមគ្នា"។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

បើស្ទង់មើលទៅលើលក្ខណៈ ចិត្តសាស្ត្រសង្គមមនុស្សខ្មែរ គឺថាអ្នកមួយចំនួនហាក់បីដូចជាមានការស្អប់ស្រឡាញ់ ឬខឹងសម្បាលើប្រវត្តិសាស្ត្រតាមនិន្នាការនយោបាយរៀងខ្លួន និងប្រកាន់ត្រូវ ប្រកាន់ខុសរៀងខ្លួន មិនថាមនុស្សជំនាន់សាធារណៈរដ្ឋ មនុស្សជំនាន់កម្ពុជាប្រជាធិបតេយ្យ មនុស្សជំនាន់រដ្ឋកម្ពុជា ឬតមកសម័យកាលក្រោយទៀត និងយុវជនសព្វថ្ងៃផងដែរ។ រឿងស្អប់ស្រឡាញ់ប្រវត្តិសាស្ត្រនេះ បានកើតឡើងផងដែរ ទៅលើប្រជាជនមួយចំនួនដែលរស់នៅឯនាយសមុទ្រ ឬដែលពេលខ្លះបង្រៀនអ្នកជំនាន់ក្រោយឲ្យមានទំនោរ ឬនិន្នាការស្អប់ស្រឡាញ់អ្នកនយោបាយ និងប្រវត្តិសាស្ត្ររបស់ជាតិខ្លួន។

វាជារឿងគ្រោះថ្នាក់បំផុត! ពេលដែលមនុស្សឥតយល់បញ្ហាតែហ៊ានវិនិច្ឆ័យ ហើយគ្រោះថ្នាក់ធំបំផុតនៅពេលយុវជន និងជនសង្គម យកសៀវភៅប្រវត្តិសាស្ត្រតែមួយក្បាលមកអាន ហើយវិនិច្ឆ័យដោយខ្វះប្រភពគ្រប់ជ្រុងជ្រោយ ឬមើលមិនសព្វ។

វាមិនមែនជាទស្សនវិជ្ជាត្រឹមត្រូវ ឬមាគ៌ាត្រឹមត្រូវទេ ដែលគ្រប់គ្នាសើចយំ ឬចំអកឡកឡឺយឲ្យប្រវត្តិសាស្ត្រ បង្កើតនិន្នាការស្អប់ស្រឡាញ់ ដែលធ្វើឲ្យបាត់បង់ការឈឺចាប់ជាតិ មិនបានរៀនពីអតីតកាល និងរកឯកភាពជាតិមិនឃើញ ឈ្លោះគ្នា ជេរគ្នា វាយប្រហារគ្នាជាដើម។ រឿងមួយទៀតដែលកាន់តែគ្រោះថ្នាក់ នោះគឺយុវជនមិនប្រឹងរៀន។ គេថា មនុស្សក្នុងសង្គមមានរឿងពីរយ៉ាងត្រូវដឹងគុណ៖ ទីមួយគឺម្តាយ និងទីពីរគឺជាតិ៕

# ថ្ងៃទី២២ ខែតុលា

មហាត្មៈ គន្ធី [ Mahatma Gandhi ] ពោលថា "*មនុស្សទន់ខ្សោយមិនចេះអភ័យទោសឲ្យអ្នកដទៃទេ ពីព្រោះការចេះអភ័យទោសឲ្យអ្នកដទៃ គឺជាលក្ខណៈសម្បត្តិរបស់មនុស្សខ្លាំង*"។

មិនថាយើងជាមនុស្សល្អ ឬអាក្រក់ទេ វាអាចងាយស្រួលដែលត្រូវអភ័យទោសឲ្យអ្នកដទៃ ប៉ុន្តែវាប្រហែលពិបាកដែលត្រូវបំភ្លេចទង្វើគ្រប់យ៉ាងរបស់គេដែលបានធ្វើចំពោះយើង។ អ្នកប្រាជ្ញម្នាក់និយាយថា "លើលោកនេះ មនុស្សទាំងអស់សុទ្ធតែជាបងនិងប្អូននឹងគ្នា អ៊ីចឹងវាមានន័យថាយើងមិនត្រូវឈ្លោះប្រកែកគ្នានោះទេ"៕

# ថ្ងៃទី២៣ ខែតុលា

ខុង ជឺ [ Confucius ] ពោលថា "ចូរអ្នកតបនឹងអំពើល្អដោយអំពើល្អ ប៉ុន្តែចូរតបនឹងអំពើអាក្រក់ដោយយុត្តិធម៌" ។ ខ្ញុំមិនដឹងថា "យុត្តិធម៌" មានន័យបែបណា ឬមាន ឬមិនមានពិតទេ តែខ្ញុំគ្រាន់តែដឹងថា លើលោកយើងនេះ គឺគ្មាននិយាម ឬស្តង់ដារយុត្តិធម៌ទេ ពីព្រោះថាបើមនុស្សព្រមទទួលយក "ភាពអយុត្តិធម៌"ដោយពេញចិត្ត គឺភាពអយុត្តិធម៌នោះ ក៏បានក្លាយជាយុត្តិធម៌ដោយស្វ័យប្រវត្តិ។

សង្គមនេះ និងសង្គមពិភពលោកទាំងមូលហាក់បីដូចជាដណ្តើមគ្នារស់ បើយើងមិនរត់ឲ្យលឿន គេនឹងជាន់យើងស្លាប់។អ្នកខ្លាំងគឺរស់អ្នកខ្សោយគឺស្លាប់។អ្នកខ្លះជោគជ័យលើសេចក្តីទុក្ខនៃអ្នកដទៃ ឬជោគជ័យដោយអំពើទុច្ចរិត ឬជោគជ័យដោយអំពើថោកទាប តែសង្គមទាំងមូលបែរជាឥតសួរនាំ និងផ្ទុយទៅវិញសង្គមបែរជានាំគ្នាអបអរសាទរ

បើទោះបីជាជោគជ័យដោយវិធីណាក៏ដោយ។ នេះគឺមានន័យថា សង្គមគេមិនខ្វល់ថាយើងជានរណាទេ ឬយើងជាមនុស្សល្អបែបណា មានគុណធម៌ ឬសីលធម៌បែបណាទេ តែបើយើងបរាជ័យ គឺយើងថោកទាប ឬបរាជ័យ គឺជាចោរ៕

# ថ្ងៃទី២៤ ខែតុលា

ហ្សង់ហ្សាក់ រ៉ូសូ [ Jean Jacques Rousseau ] ពោលថា " *យើងគ្រប់គ្នាតែងតែព្យាយាមស្វែងរកហេតុនៃអំពើអាក្រក់ និងអកុសលក្នុងលោកខាងក្រៅ តែតាមពិតទៅ ហេតុអកុសល និងអំពើអាក្រក់ទាំងឡាយ កំពុងតែស្ថិតនៅខាងក្នុងខ្លួនយើង*"។

មនុស្សដែលខំប្រព្រឹត្តសេចក្ដីល្អ នឹងទទួលបានលិខិតឆ្លងដែនមួយទៅកាន់ឋានសួគ៌នៃជីវិត។ បើមើលពីទីជិត ជីវិតដែលប្រព្រឹត្តិអាក្រក់សាងបាប ហាក់បីដូចជាមានសេចក្ដីសុខណាស់ក្នុងពេលបច្ចុប្បន្ន។ ប៉ុន្តែ ពេលដែលមើលពីទីឆ្ងាយវិញ វាគឺជាទុក្ខទោស សេចក្ដីសោកស្ដាយ និងខ្លួនតែងតែប្រឆាំងនឹងខ្លួនឯងជានិច្ច។

ក្នុងទ្រឹស្ដីសាសនា ព្រះពិតជាមានអត្ថិភាពក្នុងលោកយើងមែន។ ប៉ុន្តែតាមពិត ព្រះគឺជាមនុស្ស មនុស្សគឺជាយើង ហើយយើងគឺជាព្រះ។

យើងគឺជាព្រះក្នុងខ្លួនមនុស្ស និងព្រះក្នុងខ្លួនយើង។ អកុសលដែលមានក្នុងខ្លួនយើង នឹងប្រឆាំងនឹងយើងជានិច្ច។ សង្គមអាក្រក់ ពីព្រោះមានមនុស្សអាក្រក់ច្រើន និងមានមនុស្សអាត្មានិយមច្រើន។ សង្គមល្អ ត្រូវតែចាប់ផ្តើមពីមនុស្សល្អ។ មនុស្សល្អ ត្រូវការផ្តល់ការអប់រំល្អ។

ការអប់រំល្អ ត្រូវការការអប់រំដែលមិនមែនមានត្រឹមតែចំណេះដឹង និងជំនាញប៉ុណ្ណោះទេ តែត្រូវអប់រំចរិតលក្ខណៈមនុស្សក្នុងសង្គម និងអប់រំសីលធម៌មនុស្ស។ មនុស្សដែលមានការអប់រំខ្ពស់ តែគ្មានចរិតជាមនុស្សខ្ពង់ខ្ពស់ គ្មានសីលធម៌ខ្ពស់ គ្មានគុណធម៌ខ្ពស់ គ្មានមនុស្សធម៌ខ្ពស់ គឺមិនអាចយកប្រើការបាន ឬបម្រើសង្គមបានទេ។ ការសាបព្រោះចំណេះដឹងគឺជាការណ៍ល្អ តែបើសាបព្រោះចំណេះដឹងមិនចំមនុស្សល្អ គឺស្មើនឹងសាបព្រោះគ្រោះកាចអាក្រក់ដល់សង្គមទាំងមូល។

លី ក្វាន់យូ ពោលថា "វប្បធម៌យ៉ាងណា ផ្លែផ្កាសង្គមបែប នោះ"។ សូមកុំខ្លាចផលអាក្រក់នៅថ្ងៃស្អែក តែត្រូវប្រឹង សាងហេតុល្អនៅថ្ងៃនេះ, សូមកុំបារម្ភខ្លាចឈឺចាប់ តែសូម ឲ្យតែថ្ងៃនេះប្រឹងសាងសុខឲ្យខ្លួនឯង និងអ្នកដទៃផង, សូមកុំភ័យថាអតីតកាលនឹងបណ្ដាលឲ្យយើងមាន វិប្បដិសារៈ តែត្រូវប្រឹងថ្ងៃនេះឲ្យល្អបំផុត។ អតីតកាល គឺថ្ងៃនេះ ថ្ងៃនេះគឺថ្ងៃនេះ ហើយអនាគតកាលគឺនៅតែ ថ្ងៃនេះ៕

You seek the cause of evil, and it is only in yourself.

-Jean Jacques Rousseau.

# ថ្ងៃទី២៥ ខែតុលា

មហាត្មៈ គន្ធី "គោលការណ៍នៃភាពជាអ្នកដឹកនាំអហិង្សា ៥យ៉ាងបិតាឯករាជ្យឥណ្ឌា មហាត្មៈ គន្ធី [ Mahatma Gandhi ] ពោលថា "អ្នកទន់ខ្សោយ មិនចេះអភ័យទោសឲ្យអ្នកដទៃទេ ពីព្រោះការចេះអភ័យទោសឲ្យអ្នកដទៃ គឺជាគុណលក្ខណៈនៃមនុស្សខ្លាំង"។

មហាត្មៈគន្ធីបានដើរតាមគោលការណ៍នៃភាពជាអ្នកដឹកនាំ ៥យ៉ាងរបស់ព្រះយេស៊ូវ៖

១. ចូរស្រឡាញ់សត្រូវរបស់អ្នក។

២. ចូរកុំខឹងគុំគួននឹងសត្រូវ ឬបងប្អូនរបស់អ្នក។

៣. ចូរកុំសងសឹកនឹងមនុស្សទុច្ចរិតឡើយ។

៤. ចូរកុំត្រេកត្រអាលនឹងកាមតណ្ហាឡើយ។

៥. ចូរកុំប្រើពាក្យស្បថសច្ចាឲ្យសោះ បើ "មែន គឺមែន"តែបើ "ទេ គឺទេ"។

គោលការណ៍ទាំង ៥ខាងលើ មានចែងក្នុងគម្ពីរគ្រីស្ទសាសនាត្រង់ម៉ាថាយ ជំពូក៥ ចាប់ពីខ២២ ដល់ ខ៤។

អ្នកនយោបាយខ្មែរខ្លះក្នុងបរិបទខ្មែរ បានដើរតាមគោលការណ៍មនោគមវិជ្ជាផ្ទុយពីអ្នកដឹកនាំឥណ្ឌា៖

១. ស្អប់ និងជេរប្រទេចអ្នកណាដែលយល់មិនដូចគំនិតខ្លួន។

២. ខឹងគុំគួនជេរប្រទេចអ្នកណាដែលយល់មិនដូចគំនិតខ្លួន។

៣. ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី។

៤. អបាយមុខ ស្រី ស្រា ល្បែង។ ៥. ប្រជាភិថុតិ ស្បថស្បែឲ្យតែបានអំណាច។

អ្នកនយោបាយខ្មែរ បើបានយករាស្ត្រខ្មែរជាប្រជារាស្ត្ររបស់ខ្លួន និងចង់ជួយសង្គ្រោះជាតិខ្មែរ គួរតែបង្រៀនប្រជាជនឲ្យចេះគោរពស្រឡាញ់ខ្មែរគ្នាឯង មានសីលធម៌គ្រប់គ្នា និងកុំឈ្លោះ ប្រកែកគ្នា តែមិនមែនបង្រៀនឲ្យស្អប់ខ្មែរ

និងយកខ្មែរជាសត្រូវ ឬប្រើពាក្យជេរប្រទេចបញ្ឆេះកំហឹងនោះទេ។

លក្ខណៈចរិតបែបសុភាពរាបសារ មហាត្មៈ គន្ធី ត្រូវបានគេហៅថាជា "សាសនិកនៃអហិង្សា ឬអ្នកសន្តិភាពនិយម ឬ Religion of Nonviolence"។ បិតាឯករាជ្យឥណ្ឌាម្នាក់នេះបានទទូចអង្វរឲ្យមនុស្សចេះស្រឡាញ់គ្នា ចេះសាមគ្គីគ្នា និងកុំមានគំនុំសងសឹកដល់គ្នាថា "បើនឹងយកភ្នែកទៅស៊ីសងនឹងភ្នែក គឺបានត្រឹមតែធ្វើឲ្យពិភពលោកយើងទាំងមូលនៅសល់ត្រឹមតែមនុស្សខ្វាក់ប៉ុណ្ណោះ"។ ជាមួយគ្នាផងដែរ មិនខុសពីគំនិតរបស់លោកនាយរដ្ឋមន្ត្រីអង់គ្លេស វីនស្តុន ឆើឈីល [ Winston Churchill ] ដែលនិយាយថា "មេរៀនជីវិតដ៏អស្ចារ្យពិតប្រាកដរបស់មនុស្សយើង គឺការដែលយើងត្រូវតែដឹងខ្លួនថា ពេលខ្លះមនុស្សល្ងង់ ក៏អាចគិតត្រូវ និយាយត្រូវ និងធ្វើត្រូវម្តងម្កាលដែរ"។

# ថ្ងៃទី២៦ ខែតុលា

ពេល "ឡើង"ត្រូវប្រុងកម្លាំង តែពេល "ចុះ" ត្រូវប្រុងស្មារតី ។ ការឡើងលើឆាកជីវិត ត្រូវការឲ្យយើងប្រឹងប្រែងដោយអត់ធ្មត់ តែពេលធ្លាក់សង្វៀនជីវិត ត្រូវការឲ្យយើងពង្រឹងស្មារតីជានិច្ច។

ពេលខ្លះ បើមានអារម្មណ៍ថា "ធ្ងន់" សូមទម្លាក់ចុះ ហើយទម្លាក់វត្ថុអ្វីចេញពីដៃ មិនស្មើទម្លាក់សេចក្តីតានតឹង ឬការឈឺចាប់ចេញពីចិត្ត។ អ្នកប្រាជ្ញចិន ឡៅ ជឺ [ Lao Tzu ] ធ្លាប់បានពោលទុកថា "បើចង់ដើរឲ្យបានឆ្ងាយ កុំបីឡើយជាប់ជំពាក់ច្រើន"។ ឬមានន័យថា ឲ្យចេះទម្លាក់របស់ខ្លះចោលខ្លះ។ សាកល្បងដកដង្ហើមចេញ ដកដង្ហើមចូល ហើយត្រូវគិតថា បើទោះបីជាចេញ ឬចូល ក៏សុទ្ធតែជាដង្ហើម។ ចំណែកជីវិត ទុក្ខខ្លះ សុខខ្លះ ក៏ជាជីវិត។ ក្នុងជីវិតតែងមានសុខខ្លះ ទុក្ខខ្លះ ហើយទទួលយកបានខ្លះ មិនអាចទទួលយកបានខ្លះ គឺគ្រប់យ៉ាងគ្មានលើស និងគ្មានខ្វះ៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី២៧ ខែតុលា

"ល្អបំផុតក៏ចិត្ត អាក្រក់បំផុតក៏ចិត្ត និងទុកចិត្តមិនបានក៏ចិត្ត។ ដើម្បីបានកម្លាំងចិត្ត ចូរយើងព្យាយាមធ្វើល្អ និងធ្វើជាមនុស្សល្អ ប្រសើរជាងព្យាយាមតាមស្វែងរកមនុស្សល្អ"។បើស្រឡាញ់ខ្លួនឯងក៏សូមចេះអភ័យទោសឲ្យទោសឲ្យគេ បើទោះបីជាគេមិនភ្ញាក់ខ្លួនក៏ដោយ ពីព្រោះមិនមែនដើម្បីគេ តែដើម្បីយើងខ្លួនឯង។ កាន់តែស្រឡាញ់គឺកាន់តែស្អប់ កាន់តែខឹង គឺកាន់តែឈឺចាប់ ហើយបើកាន់តែឈឺចាប់ នោះភ្លើងនៃសេចក្តីទុក្ខ ក៏កាន់តែឆេះខ្លាំងក្នុងខ្លួនខ្លាំងដែរ៕

# ថ្ងៃទី២៨ ខែតុលា

*"ទ្រឹស្តីមិនអាចឈ្នះមនុស្សល្ងង់បាន តែអាចឈ្នះមនុស្ស ដែលមិនចង់ល្ងង់ ឬចង់ចេះ និងមិនត្រឹមតែប៉ុណ្ណោះ អាចឈ្នះលើមនុស្ស ដែលចង់មានសហសន្តិភាពជាមួយគ្នា [ Co-Consistence ]"។*

ទ្រឹស្តីពុទ្ធនិយមបានលើកឡើងថា *"អកុសល មិនអាចឈ្នះអកុសលបានទេ ហើយអវិជ្ជា ក៏មិនអាចឈ្នះអវិជ្ជាបានដែរ គឺមានតែកុសលទេ ដែលអាចឈ្នះអកុសល"*។

មហាត្មៈ គន្ធី [ Mahatma Gandhi ] អះអាងថា "ចិត្តភ្លើងមិនអាចរំលត់ដោយចិត្តភ្លើងបានទេ តែត្រូវរំលត់ដោយចិត្តទឹក។ បើយកភ្នែកទៅសងសឹកនឹងភ្នែក នោះបានត្រឹមតែបន្សល់ទុកមនុស្សខ្វាក់ប៉ុណ្ណោះ"។

ក្នុងសង្គមខ្មែរសម័យមហារុងរឿង ប្រជាជនមានសាមគ្គី ចេះយោគយល់គ្នា មានទ្រឹស្តីដឹកនាំត្រឹមត្រូវ ស្របគ្នា និង ចេះសាមគ្គីគ្នា។ បើកាលណាមនុស្សមានឆន្ទៈចង់ធ្វើកិច្ចការងារដើម្បីជាតិ នោះនឹងមានវិធីដើម្បីសាងសាមគ្គីជាតិតែមួយ។ បុគ្គលឆ្លាតម្នាក់បានសួរបុរសល្ងង់ម្នាក់ថា "*តើត្រូវធ្វើបែបណាដើម្បីឲ្យខ្មែរចេះសាមគ្គី និងអាចទទួលបានសាមគគ្គីភាព ព្រោះខ្មែរយើងនិយាយតែពីរឿងសាមគ្គី តែគ្មានសាមគ្គីភាពសោះ*"?

បុរសល្ងង់តបដោយស្ទាក់ស្ទើរថា "*ខ្ញុំមិនដឹងថាត្រូវធ្វើបែបណានោះទេ តែខ្ញុំដឹងបន្តិចបន្តួចថា ដើម្បីឲ្យខ្មែរយើងបានសាមគ្គី នោះគឺត្រូវយកគំនិតខ្ញុំ បូកគំនិតលោក និង បូកបញ្ចូលគំនិតមនុស្សទាំងអស់ ព្រមទាំងដកគំនិតឈ្នះចាញ់ចេញ ដកគំនិតឈ្លោះប្រកែកគ្នាចេញ នោះសាមគ្គីនឹងកើតឡើង*"។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

យុវជនវង្វេងផ្លូវ មិនយល់គំនិតអ្នកដឹកនាំ យកអ្នកនយោបាយធ្វើជាអ្នកដឹកនាំរបស់ខ្លួន តែមិនយកអ្នកនយោបាយដើម្បីបម្រើខ្លួន។ ចុងក្រោយយើងស្អប់ប្រវត្តិសាស្ត្រ ចងគំនុំនឹងប្រវត្តិសាស្ត្រដែលកន្លងហួស បង្រៀនកូនឲ្យស្អប់ប្រវត្តិសាស្ត្រ ឃើញខុសក៏ខុស ឬឃើញត្រូវក៏ខុស និងប្រើគំនិតដឹកនាំប្រឆាំងគ្នាដាច់ខាត។

ពេលខ្លះយើងយល់ថា វាជាកំហុសអ្នកនយោបាយដែលគ្មានគោលការណ៍ តែបើនិយាយមួយបែបទៀត គឺអ្នកនយោបាយប្រៀបដូចជាតួឡាន តែប្រជាជនប្រៀបដូចជាអ្នកបើកបរ ព្រោះរថយន្តមិនអាចទៅមុខបានទេ បើគ្មានអ្នកបើកបរ។ អ្នកនយោបាយប្រៀបដូចជាទូក ប្រជាជនប្រៀបដូចទឹក ហើយទឹកអាចបណ្តែតទូកបាន នោះក៏អាចពន្លិចទូកបានដែរ៕

# ថ្ងៃទី២៩ ខែតុលា

*សម្តេចនរោត្តម សីហនុ ទ្រង់មានព្រះរាជបន្ទូលថា "មនុស្សគ្រប់រូបគ្មាននរណាម្នាក់ដែលគ្មានកំហុសនោះទេ រួមទាំងរូបខ្ញុំ។ ប៉ុន្តែអ្វីដែលចង់ឃើញបំផុតនោះគឺ ប្រទេសរបស់ខ្ញុំមានសុខសន្តិភាព ប្រជារាស្ត្ររបស់ខ្ញុំចេះស្រឡាញ់ និងរួបរួមគ្នាជាផ្លុងមួយ"។*

ចង្កឹះមួយបាច់ កាច់មិនបាក់។ សាមគ្គីរស់ បែកបាក់សាមគ្គីស្លាប់។ ទីណាមានសាមគ្គីភាព ទីនោះមានភាពរឹងមាំ។ ត្រូវមើលលើចំណុចស្របគ្នា ហើយត្រូវដោះស្រាយចំណុចផ្ទុយគ្នា តែកុំប្រឆាំងឈ្លោះគ្នា។ អាឌុល អ៊ីត្លែរ [ Adolf Hilter ] និយាយថា "ដើម្បីឈ្លានពានលើប្រទេសណាមួយ ដាដំបូងអ្នកត្រូវរកវិធីធ្វើឲ្យប្រជាជនក្នុងប្រទេសនោះក្លាយជាមនុស្ស ដែលមិនចេះទទួលខុសត្រូវចំពោះប្រទេសដែលខ្លួនរស់នៅ"។

មហាត្មៈ គន្ធី បានបង្រៀនមនុស្សឲ្យស្គាល់តួនាទីខ្លួនឯង ក្នុងនាមជាប្រជាជនក្នុងប្រទេសមួយ។ ទំនួលខុសត្រូវដែល មហាត្មៈ គន្ធី បាននិយាយគឺ៖ ទំនួលខុសត្រូវចំពោះខ្លួនឯង ទំនួលខុសត្រូវចំពោះគ្រួសារ និងទំនួលខុសត្រូវចំពោះ សង្គម៕

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី៣០ ខែតុលា

ចច អូវែល [ George Orwell ] បានលើកឡើងថា "មនុស្ស ដែលអាចគ្រប់គ្រងអតីតកាលបានល្អ គឺប្រៀបបាននឹង អាចគ្រប់គ្រងអនាគតកាលបានល្អ ហើយអ្នកដែលអាច គ្រប់គ្រងបច្ចុប្បន្នបានល្អ ក៏នឹងអាចបង្កើតអតីតកាលល្អ ដូចគ្នាដែរ"។

ថ្ងៃម្សិលមិញ គឺជាអតីតកាលនៃថ្ងៃនេះ។ ថ្ងៃនេះ គឺជា អតីតកាលនៃថ្ងៃស្អែក ហើយថ្ងៃស្អែក គឺជាអនាគតកាល នៃថ្ងៃនេះ។ ម្សិលមិញគឺជាថ្ងៃនេះ។ ថ្ងៃនេះ គឺជាថ្ងៃនេះ ហើយថ្ងៃស្អែកគឺជាថ្ងៃនេះ ឲ្យតែគ្រប់គ្រងថ្ងៃនេះឲ្យបានល្អ បំផុត នោះអតីតកាល និងអនាគតកាល នឹងល្អជានិច្ចដូចគ្នា ពីព្រោះគ្រប់គ្រងថ្ងៃនេះឲ្យល្អ គឺមានន័យបានបង្កើត អតីតកាលល្អ ហើយក៏មានន័យថា កំពុងបានរៀបចំ អនាគតកាលយ៉ាងល្អប្រសើរដែរ។

បើមើលពីទីជិត ជីវិតគឺប្រៀបដូចជាសោកនាដកម្មដ៏រន្ធត់ និងអយុត្តិធម៌មួយ តែកាលណាបានសម្លឹងត្រឡប់ទៅក្រោយយ៉ាងឆ្ងាយ និងសម្លឹងទៅអនាគតខាងមុខវែងអន្លាយ គឺហាក់បីដូចជាសុខនាដកម្ម ឬសេចក្ដីសុខម្យ៉ាងដែលបំពេញន័យឲ្យជីវិត។ ដូច្នេះ ចូររៀបចំថ្ងៃនេះឲ្យល្អ៕

"Who controls the past controls the future. Who controls the present controls the past."

- George Orwell

# ទស្សនៈសម្រាប់ខែ

# វិច្ឆិកា

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី០១ ខែវិច្ឆិកា

"ខ្ញុំអាចស្លាប់ដើម្បីអ្នក តែខ្ញុំមិនធ្វើអ៊ីចឹងទេ ហើយក៏គ្មានថ្ងៃធ្វើបែបហ្នឹងដែរ...ខ្ញុំសុខចិត្តរស់នៅដើម្បីអ្នកវិញ"។ នៅក្នុងទ្រឹស្តីសាសនា គ្មានសាសនាបង្រៀនមនុស្សថាស្លាប់ហើយ គឺនឹងសូន្យបាត់ឈឹង ឬលែងកើតវិញទេ ពីព្រោះព្រះចង់ឲ្យមនុស្ស ចេះឲ្យតម្លៃលើបច្ចុប្បន្នភាព ជឿលើការកសាងអំពើល្អ និងសន្សំទង្វើល្អ។ ការស្លាប់ មិនមែនទៅព្រឹកហើយត្រឡប់មកវិញពេលល្ងាចនោះទេ។

និយមន័យនៃជីវិត គឺការរស់នៅនឹងបច្ចុប្បន្ន ពីព្រោះបច្ចុប្បន្នគឺជាអំណោយមួយ ឬ Present is a present។ បើស្រឡាញ់ សូមបង្ហាញក្តីស្រឡាញ់ និងចាប់ផ្តើមផ្តល់ភាពកក់ក្តៅដល់គ្នា តែកុំបង្កើតក្តីក្តៅក្រហាយ ពីព្រោះជីវិតខ្លីណាស់ក្នុងការរស់នៅ៕

"I could die for you. But I couldn't, and wouldn't, live for you." - Ayn Rand

# ថ្ងៃទី០២ ខែវិច្ឆិកា

"អាពាហ៍ពិពាហ៍ គឺជារណ្តៅកប់ក្តីអាម៉ាស់ទាំងអស់ ចំណែកឯសេចក្តីស្លាប់ គឺជាផ្នូរកប់សេចក្តីឈឺចាប់ទាំងឡាយ"។ ស្នេហ៍ទីមួយ អ្នកជាមនុស្សស្មោះត្រង់។ អ្នកត្រូវបានគេបោះបង់ចោលដោយហេតុផលមួយចំនួន។ តែចុងក្រោយ ដោយក្តីស្រឡាញ់ អ្នកក៏យល់ព្រមតាមហេតុផលជាលេសទាំងឡាយរបស់គេ ពីព្រោះមនុស្សចង់បែកតែងមានហេតុផលច្រើន។ អ្នកឈឺចាប់ តែអ្នកនៅតែរឹងមាំជានិច្ច។ អ្នកឈឺចាប់ខ្លាំងណាស់ តែអ្នកយំមិនចេញទេ។

ស្នេហ៍ទីពីរ អ្នកនៅតែជឿជាក់ថា ក្នុងលោក មនុស្សទាំងអស់មិនដូចគ្នាទេ ហើយអ្នកក៏បង្កើតសេចក្តីស្នេហាថ្មីមួយទៀត។ តែចុងក្រោយ គេក្បត់អ្នកព្រោះកត្តញ្ញូ។ អ្នកស្រឡាញ់គេណាស់ តែអ្នកលើកទឹកចិត្តឲ្យគេរៀបការ ហើយគេក៏ភ្លេចអ្នកយ៉ាងលឿនមុនពេលរៀបការ។

មួយឆ្នាំជាង គេបែកបាក់គ្រួសារ ហើយគេក៏វិលត្រឡប់មករកអ្នកវិញ។ អ្នកជាមនុស្សស្មោះត្រង់ ពោរពេញដោយក្ដីអាណិត។ អ្នកបានលើកទឹកចិត្តគេកំឡុងពេលគេមានបញ្ហា ហើយភ្លើងស្នេហ៍កើតឡើងម្ដងទៀតរវាងអ្នកនិងគេ។

អ្នកជឿជាក់យ៉ាងខ្លាំងថា គេនឹងក្លាយទៅជារបស់អ្នកមួយរយភាគរយ(១០០%)។ តែចុងក្រោយ គេក៏បង្កើតស្នេហាថ្មី និងចាកចេញពីអ្នកជាលើកទីពីរ។ ទីបំផុត អ្នកនៅតែជាអ្នកចង្អុលផ្លូវឲ្យគេដើរ ព្រមទាំងជូនពរគេដោយទឹកមុខញញឹម ឥតបង្ហាញទុក្ខព្រួយ។ អ្នករស់នៅពោរពេញដោយក្ដីឈឺចាប់ ឥតនិយាយចេញ។

ស្នេហ៍ទីបី អ្នកថ្មីបានផ្ដល់ក្ដីសង្ឃឹមឲ្យអ្នក។ អ្នកសប្បាយចិត្ត រំភើបស្ទើរស្រក់ទឹកភ្នែក។ ពេលខ្លះ ទឹកភ្នែកអ្នកស្រក់ទាំងញញឹម ពីព្រោះសប្បាយចិត្ត។ គេសន្យាជាមួយអ្នកថា

គេនឹងនៅក្បែរអ្នកអស់មួយជីវិត មិនថាមានរឿងអ្វីកើតឡើងក៏ដោយ។ អ្នកក៏ប្រៀបដូចជាបុប្ផាដែលត្រូវសន្សើមរស់ឡើងវិញ។ ទីបំផុត គ្រប់យ៉ាងប្រែប្រួល ដោយគេប្រាប់ហេតុផលដ៏សមរម្យម្យ៉ាងថា អ្នកនិងគេមិនសាកសម្បនឹងគ្នាទេ។ គេបានសុំទោសអ្នក តែអ្នកទប់ទឹកភ្នែកមិនបាន អ្នកក៏ស្រក់ទឹកភ្នែកជាមួយពាក្យយល់ព្រម ព្រមទាំងជូនពរគេទាំងឈឺចាប់។

ទីបំផុត អ្នកនៅតែរក្សាតម្លៃជាមនុស្សស្មោះត្រង់ម្នាក់ បើទោះបីជាអ្នកត្រូវឈឺចាប់ដោយសារគេ គ្រប់គ្នាបោះបង់អ្នកចោលក៏ដោយ។ អ្នកក៏ក្លាយជាមនុស្សរឹងមាំនិងរៀនសូត្រពីមេរៀនជីវិតបានយ៉ាងច្រើន។ ពេលវេលាចុងក្រោយ អ្នកចង់ប្រើជីវិតរស់នៅឲ្យមានតម្លៃបំផុត។ បទពិសោធន៍របស់អ្នកបានជួយមនុស្សជាច្រើនឲ្យរឹងមាំ និងបន្តដំណើរទៅមុខ។

យុវវ័យឆ្លាត ត្រូវយល់ច្បាស់ពីស្នេហា ហើយត្រូវចាំថា មិនសំខាន់ថាមានមនុស្សប៉ុន្មាននាក់មករកអ្នកទេ ប៉ុន្តែអ្វីដែលសំខាន់តើមនុស្សណាម្នាក់ណា ដែលអ្នកនឹងជ្រើសរើសយក។ អ្នកនឹងជួបអ្នកមាន អ្នកក្រ អ្នកល្អ អ្នកអាក្រក់ និងមនុស្សគ្រប់ប្រភេទ តែតាមពិតមិនសំខាន់ដល់មនុស្សមួយប្រភេទ ដែលជាប្រភេទមនុស្សដូចអ្នកទេ។ បើគេមិនស្រឡាញ់អ្នកគឺជាអ្នក បើគេមិនមានលក្ខណៈសម្បត្តិដូចអ្នក សូមកុំទទួលយកឲ្យសោះ៕

# ថ្ងៃទី០៣ ខែវិច្ឆិកា

អាល់បឺត អាញស្តាញ [ Albert Einstein ] និយាយថា *"ក្តីស្រឡាញ់ទៅលើកិច្ចការដែលខ្លួនធ្វើ បានបង្រៀនអ្វីៗឲ្យយើងចេះលើសពីតួនាទីដែលត្រូវធ្វើទៅទៀត"*។

យើងមិនគួរបង្រៀនយុវជនឲ្យប្រឹងប្រែងរកភាពជោគជ័យក្នុងជីវិតទាំងងងឹតងងុលនោះឡើយ។ អ្វីដែលសំខាន់បំផុតគឺការមានក្តីសុខនឹងការងារ មានក្តីសុខជាមួយនឹងលទ្ធផលដែលកើតឡើង មានក្តីសុខនឹងការបានចេះដឹង និងមានក្តីសុខនឹងការបំពេញប្រយោជន៍ដល់សង្គម នោះគឺជាជោគជ័យពិតប្រាកដ។ បើចង់បានក្តីសុខនឹងការងារ យើងត្រូវផ្សារភ្ជាប់ជីវិតទៅនឹងគោលដៅ កុំផ្សារភ្ជាប់នឹងមនុស្ស។ ទីបញ្ចប់ កុំធ្វើខ្លួនសម្រាប់តែជោគជ័យ តែត្រូវធ្វើខ្លួនឲ្យទៅជាមនុស្សមានតម្លៃជាអតមៈ៕

# ថ្ងៃទី០៤ ខែវិច្ឆិកា

លោកគ្រូវិបស្សនាកម្មដ្ឋាន ហ្គោឥនកា បានមានប្រសាសន៍ថា *"ជាជាងផ្លាស់ជំនឿរបស់មនុស្សពីសាសនាមួយទៅសាសនាមួយទៀត យើងគួរសាកល្បងផ្លាស់ប្តូរមនុស្សពីទុក្ខសោក ទៅរកសុភមង្គល ពីការជាប់ចំណង ទៅរកការរួចរំដោះ និងពីភាពកាចសាហាវឃោរឃៅ ទៅរកភាពមេត្តាករុណាវិញ"*។

ចូរខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយជម្លោះ និងភាពតានតឹងរវាងនិកាយសាសនានានា ពីព្រោះនៅពេលមានកំហឹង និងមានសេចក្តីស្អប់ខ្ពើមនៅក្នុងចិត្ត យើងចាប់ផ្តើមមានទុក្ខដោយមិនចំពោះថាគេនោះ គឺជាគ្រិស្តសាសនិក ហិណ្ឌូ ព្រះពុទ្ធ មូស្លីម ឬនិកាយសាសនាណា ឬជាអ្នកទស្សនវិជ្ជាណាមួយឡើយ។ បំណងប្រាថ្នារបស់ព្រះ និងជាច្បាប់ធម្មជាតិគឺ *"អ្នកដែលមានមេត្តា និងករុណានៅក្នុងចិត្តដ៏បរិសុទ្ធ នឹងទទួលបទពិសោធន៍នៃឋានសួគ៌នៅក្នុងខ្លួន"*៕

# ថ្ងៃទី០៥ ខែវិច្ឆិកា

*បរមគ្រូ ខុង ជឺ ពោលថា "មនុស្សពាលចេះតែគ្រលាស់អណ្ដាតមួយមុខប៉ុណ្ណោះ ហើយណែនាំគ្នាទៅបង្កកម្មអកុសល ដោយក្នុងចិត្តគ្មានបំណងល្អបរិសុទ្ធចំពោះអ្វីមួយឡើយ។ ក៏ប៉ុន្តែ វិញ្ញូជនវិភាគក្នុងន័យស្ថាបនា ផ្ដល់កម្លាំងចិត្តចំពោះគ្នាទៅតាមភាពត្រឹមត្រូវពេញលេញ ដោយគោលបំណងល្អដល់គ្នា"។*

សូមប្រយ័ត្នលើចំណេះដឹងខ្លួនឯងផង ក្រែងលំដើរលើមាគ៌ាខុសដោយឥតដឹងសតិ។ ពេលខ្លះ សង្គមពុលដោយសារតែអ្នក តែអ្នកឥតដឹងខ្លួនទេ ពីព្រោះអ្នកអំនួតខ្លួនឯងជ្រុលពេក។ ឥតសង្គ្រាម តែគ្មានសន្តិភាព ពីព្រោះអ្នកប្រើហេតុផលតក្កសាស្ត្រ ឬ Logic ពន្យល់មនុស្សឲ្យយល់គ្រប់គ្នា តែតក្កសាស្ត្ររបស់អ្នកទំនងចាកឆ្ងាយពីសេចក្ដីពិត ឬសច្ចភាព៕

# ថ្ងៃទី០៦ ខែវិច្ឆិកា

*"សូមកុំស្វែងសុវត្ថិភាព តែត្រូវរកកាលានុវត្តភាព ឬឱកាស ពីព្រោះទូកដែលចតតែក្នុងផែ ពិតជាមានសុវត្ថិភាពមែន ប៉ុន្តែទីបំផុតបាតក្រោមនឹងផុយពុកនៅថ្ងៃណាមួយជាក់ជាពុំខាន"។*

បុរាណខ្មែរពោលថា "ចាប់ប្រវាអុំ ត្រូវសម្លឹងត្រើយ"។ គឺមានន័យថាត្រូវចេះសម្លឹងមើលទៅគោលដៅ តែមិនមែនមើលឧសគ្គទេ។ មនុស្សដែលចូលចិត្តមើលបញ្ហា គឺតែងតែធ្វើជាចំណែកនៃបញ្ហា តែមនុស្សដែលចង់សម្រេចបំណងតែងជាចំណែកនៃដំណោះស្រាយ។ ជាធម្មតា ជីវិតគឺជាសោកនាដកម្ម បើយើងសម្លឹងមើលពីទីជិត តែតាមពិតជីវិតគឺជាសុខនាដកម្ម បើយើងចេះសម្លឹងមើលទៅទីឆ្ងាយ ៕ Seek opportunity, not security. A boat in a harbor is safe, but in time its bottom will rot out.

- H. Jackson Brown.

# ថ្ងៃទី០៧ ខែវិច្ឆិកា

អាល់ប៊ឺត អាស្តាញ [ Albert Einstein ] ពោលថា *"ការខ្លាចស្លាប់ គឺជាសេចក្តីខ្លាចដែលឥតប្រយោជន៍បំផុត ក្នុងបណ្តាសេចក្តីខ្លាចទាំងពួង"*។

អាឌុល អ៊ីត្លែរ [ Adolf Hitler ] បានបញ្ជាឲ្យភ្នាក់ងារសម្ងាត់របស់អាល្លឺម៉ង់តាមសម្លាប់ អាល់ប៊ឺត អាញស្តាញ និងបានដាក់ថ្លៃក្បាលរបស់គាត់ជាទឹកប្រាក់ក្នុងចំនួនដ៏ច្រើនមហាសាល រហូតអាញស្តាញពោលថា *"ខ្ញុំមិនដែលដឹងខ្លួនពីមុនមកឡើយថា ខ្លួនឯងមានតម្លៃសន្ធឹកសន្ធាប់ដល់ថ្នាក់នេះ"* ភរិយារបស់គាត់ព្យាយាមប្រាប់ឲ្យគាត់ឈប់និយាយប្រឆាំងនឹងពួកណាស៊ី តែអាញស្តាញបដិសេធដោយប្រាប់ថា *"បើខ្ញុំបិទមាត់ស្ងៀម នោះខ្ញុំក៏មិនមែនអាញស្តាញដែរ"*។

## ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

នៅថ្ងៃចុងក្រោយរបស់សូក្រាត សិស្សម្នាក់បានសួរគាត់ថា "តើលោកគ្រូខ្លាចស្លាប់ទេ?" សូក្រាត តបថា "តើហេតុអ្វីខ្ញុំត្រូវខ្លាចនូវអ្វីដែលខ្ញុំមិនដឹងនោះ?" លក្ខណៈចិត្តសាស្ត្រសាស្ត្ររបស់សត្វមនុស្ស គឺខ្លាចនូវអ្វីគ្រប់យ៉ាងដែលខ្លួនមិនដឹង ដូចជាអ្នកខ្លះខ្លាចខ្សែគោពេលយប់ងងឹត ដោយសារគេយល់ថាខ្សែគោ គឺជាពស់។ មនុស្សយើងបើមិនចេះដឹងពីរបៀបនៃការរស់នៅផង តើហេតុអ្វីចាំឆ្ងល់ពីរឿងស្លាប់ឬខ្លាចស្លាប់។ ពេលខ្លះ ខ្ញុំយល់ថាការឈឺចាប់ទាំងឡាយក្នុងពេលមានជីវិតរស់នៅ គឺគួរឲ្យខ្លាច និងវេទនាជាងសេចក្តីស្លាប់ទៅទៀត។ ជុំបាយ សម្រាប់បន្តជីវិត ហើយជុំបាយក៏បន្តការឈឺចាប់ដែរ៕

# ថ្ងៃទី០៨ ខែវិច្ឆិកា

*"មនុស្សដែលពូកែ ហើយដែលមានទឹកចិត្តល្អទៀត គឺគេនឹងព្យាយាមចែករំលែកចំណេះដឹង និងបទពិសោធន៍ដល់អ្នកដទៃ ឲ្យដូចជាគេត្រូវស្លាប់ទៅវិញនៅថ្ងៃស្អែកអ៊ីចឹង"។*

មនុស្សឆ្លាតខាងទាញប្រយោជន៍ពីអ្នកដទៃ គេនឹងប្រឹងប្រែងទាញប្រយោជន៍ពីអ្នកដទៃ ឲ្យដូចជាគេនឹងស្លាប់ទៅវិញដោយយកអ្វីៗទាំងអស់ទៅជាមួយផងអ៊ីចឹង។ ចូរចងចាំពាក្យជាភាសាអង់គ្លេសមួយឃ្លាថា "Smartest is not enough, but kindness" ឬមានន័យថា "ឆ្លាតតែម៉្យាងគត់គឺឥតទាន់គ្រប់គ្រាន់នៅឡើយទេ តែត្រូវមានចិត្តល្អផងដែរទើបកាន់តែល្អប្រសើរឡើង"៕

# ថ្ងៃទី០៩ ខែវិច្ឆិកា

*"លើលោកយើងនេះ គ្មានអ្វីដែលគួរឲ្យស្អប់ ឬគ្មានអ្វីដែលគួរឲ្យស្រឡាញ់ទេ បើយើងបានសិក្សាស្វែងយល់ពីឫសគល់គ្រប់យ៉ាងពីដំបូង"* ។

ធម្មជាតិរបស់មនុស្ស គឺល្អស្រាប់ពីធម្មជាតិ តែហេតុអ្វីក៏មនុស្សក្លាយទៅជាអាក្រក់ នៅពេលរស់នៅក្នុងសង្គម? យើងមិនគួរដាក់ទោសឧក្រិដ្ឋជនទាំងស្រុង ដោយមិនបានសិក្សាពីសង្គមថា តើមូលហេតុអ្វីទើបបានជាមានឧក្រិដ្ឋកម្ម [ សិក្សាពីឧក្រិដ្ឋវិទ្យា ឬ Criminology ]។ យើងមិនអាចអសីលធម៌ទៅដេរម៉ែឪដែលបោះបង់កូនចោល ដោយមិនបានសិក្សាពីមូលហេតុនៃការធ្លាក់ចុះនៃសីលធម៌សង្គម ឬគុណធម៌មនុស្ស ឬបញ្ហាសង្គមនានាទេ។ មនុស្សគ្មានសីលធម៌ ឬគ្មានគុណធម៌ ព្រោះស្ថានភាពសង្គម

[ សិក្សាពីសង្គមវិជ្ជា ឬ Sociology ] គឺសង្គមត្រូវបង្កស្ថានភាពអំណោយផលដល់មនុស្សទាំងនោះ ឲ្យមានឱកាសសារភាពកំហុស កែប្រែកំហុស និងបង្កើតជីវិតថ្មីល្អជាងមុន ។

សម្ដេចសង្ឃដាឡៃ ឡាម៉ា [ 14th Dalai Lama ] មានសង្ឃដីកាថា *"សង្គមមិនត្រូវស្អប់អ្នកដែលធ្លាប់ប្រព្រឹត្តខុស និងអ្នកដែលជាឧក្រិដ្ឋជនឡើយ ពីព្រោះពួកគេក៏ជាមនុស្សម្នាក់ដែលជាសមាជិកមួយរបស់សង្គមដូចយើងដែរ ។ ពួកគេក៏អាចផ្លាស់ប្ដូរបានដូចយើងដែរ តែរឿងសំខាន់ត្រូវនាំក្ដីសង្ឃឹម និងការប្រឹងប្រែងមកឲ្យពួកគេអាចកសាងជីវិតថ្មីរបស់ខ្លួនបាន"*។

"Nothing can be loved or hated unless it is first understood." - Leonardo da

# ថ្ងៃទី១០ ខែវិច្ឆិកា

*"ពិភពលោកយើង ត្រូវការបុគ្គលដែលតស៊ូដើម្បីភាពត្រឹមត្រូវ តស៊ូដើម្បីយុត្តិធម៌សង្គម តស៊ូដើម្បីមនុស្សធម៌ តស៊ូដើម្បីគុណធម៌ និងតស៊ូដើម្បីសីលធម៌ ច្រើនជាងអ្នកតស៊ូដើម្បីភាពជោគជ័យតែម្យ៉ាង"។* បិតារូបវិទ្យាស.វទី២០ អាល់ប៊ឺត អាញស្តាញ [ Albert Einstein ] អះអាងថា *"ជីវិតដែលមានន័យ គឺជាជីវិតដែលរស់នៅដើម្បីគ្នាទៅវិញទៅមកនិងមិនអាត្មានិយម។ចូរធ្វើជាមនុស្សដែលមានតម្លៃប្រសើរថ្លៃថ្លាជាងធ្វើជាមនុស្សជោគជ័យ"*។

បើយើងចង់រកជោគជ័យ ចូរនៅក្បែរ និងសេពគប់បុគ្គលវិជ្ជមាន ឬបុគ្គលជោគជ័យ តែបើយើងចង់រកអត្ថន័យឲ្យជីវិត ចូរកុំទៅណាឆ្ងាយពីក្រុមមនុស្សអវិជ្ជមាន ឬមនុស្សបរាជ័យ ឬមនុស្សអស់សង្ឃឹម និងមនុស្សបាក់ទឹកចិត្ត។ ក្នុងន័យនេះ គឺចង់មានន័យថា ឲ្យយើងចេះ

ចំណាយពេលវេលាយកអាសាចំពោះមនុស្សគ្មានទីពឹងខ្លះផង ឲ្យតម្លៃដល់ពួកគេផង ដោយសារពួកគេក៏ជាមនុស្សដែលមានធម្មជាតិដូចយើងដែរ តែគ្រាន់តែអ្នកខ្លះមិនមានឱកាសរស់នៅល្អតាំងពីដំបូងដូចយើងប៉ុណ្ណោះ។

អ្នកម្តាយ តេរេសា [ Mother Teresa ] បានពោលថា " យើងត្រូវចេះធ្វើជាមនុស្សដែលប្រព្រឹត្តរឿងធម្មតាជាមួយនឹងក្តីស្រឡាញ់អស្ចារ្យ។ ចេះបរិច្ចាគរបស់តិចតួចជាមួយនឹងក្តីស្រឡាញ់អស្ចារ្យ"។ ពេលខ្លះភាពក្រីក្រពិតប្រាកដ គឺមិនមែនក្រដោយខ្វះទ្រព្យសម្បត្តិ ឬក្រដោយខ្វះផ្ទះសម្បែងរស់នៅនោះទេ តែក្រដែលមានអំណាចធំជាងគេបំផុត គឺមនុស្សក្រក្តីស្រឡាញ់នឹងគ្នា។ នេះមានន័យថា បើស្រឡាញ់យើងនឹងចេះចែករំលែក បើស្រឡាញ់យើងនឹងចេះផ្តល់ការយកចិត្តទុកដាក់ ហើយបើស្រឡាញ់ យើងនឹងចេះផ្តល់តម្លៃដល់គ្នា៕

# ថ្ងៃទី១១ ខែវិច្ឆិកា

*"ដើម្បីសម្រេចបានសមិទ្ធិផលអស្ចារ្យ គឺយើងមិនគ្រាន់តែធ្វើការងារអស្ចារ្យ ឬមិនគ្រាន់តែមានក្តីសុបិនអស្ចារ្យ ឬក៏មិនគ្រាន់តែរៀបចំផែនការអស្ចារ្យប៉ុណ្ណោះទេ តែត្រូវបូកផ្សំនឹងការជឿជាក់ដ៏អស្ចារ្យលើខ្លួនឯងផងដែរ"*។

បើទោះបីជាអ្នកដទៃភ្លេចយើង តែយើងត្រូវតែចងចាំខ្លួនឯង។ បើទោះបីជាអ្នកដទៃអស់សង្ឃឹមចំពោះយើង តែត្រូវតែមានសង្ឃឹមចំពោះខ្លួនឯង។ បើទោះបីជាអ្នកដទៃស្អប់យើង តែយើងត្រូវតែស្រឡាញ់ខ្លួនឯង។បើទោះបីជាអ្នកដទៃបោះបង់យើង តែយើងមិនត្រូវបោះបង់ខ្លួនឯងដាច់ខាត។ បើទោះបីជាអ្នកដទៃអស់ជំនឿចិត្តចំពោះយើង តែយើងត្រូវតែជឿលើខ្លួនឯងជានិច្ច។ និយាយដោយខ្លី ខ្លឹមស្រួលស្តាប់ និងអាចស្តាប់បានងាយយល់គឺថា *"យើងភ្លេចអ្វី ភ្លេចបាន ឬយើងអាចភ្លេចគ្រប់យ៉ាងក្នុងលោកនេះបាន*

តែសូមកុំភ្លេចខ្លួន ហើយត្រូវចងចាំថាពេលក្រកុំអស់សង្ឃឹម ហើយពេលមានកុំភ្លើតភ្លើន ឬសប្បាយដាច់បង្ហៀរឲ្យ សោះ"៕

# ថ្ងៃទី១២ ខែវិច្ឆិកា

ការគ្រប់គ្រងយុទ្ធសាស្ត្រ [ Strategic Management ]

មានឆន្ទៈ តែមិនធ្វើ គឺស្មើនឹងបរាជ័យ។ ធ្វើហើយ តែមិនបានល្អ ធ្វើដោយមិនមានយុទ្ធសាស្ត្រ ធ្វើដោយខ្វះឧបាយកលខ្វះសិល្បៈព្រមទាំងធ្វើដោយគ្មានគោលការណ៍ច្បាស់លាស់ នោះគឺស្មើនឹងបរាជ័យដូចគ្នា។ ជោគជ័យនឹងធ្វើឲ្យយើងក្លាយជាស្តេច តែបើបរាជ័យវិញ យើងនឹងកើតជាចោរ ហើយមនុស្សទាំងពីរសុទ្ធត្រូវបានគេទទួលស្គាល់ដូចគ្នា៕

# ថ្ងៃទី១៣ ខែវិច្ឆិកា

"ដួងច័ន្ទមួយដួង អាចបំភ្លឺផែនពសុធាទាំងមូលបាន តែដួងតារារាប់លានដួង មិនអាចបំភ្លឺមេឃានាពេលរាត្រីបាន"។

ម្ដាយតែម្នាក់អាចចិញ្ចឹមបីបាច់ថែរក្សាកូនដប់ ឬម្ភៃនាក់ តែកូនដប់ម្ភៃនាក់ បែរជាមិនអាចចិញ្ចឹមម្ដាយតែម្នាក់បាន។ ក្នុងក្រមរដ្ឋប្បវេណី [ Civil Law ] ខ្មែរចែងថា "ម្ដាយឪពុកមានកាព្វកិច្ច (ត្រូវតែ និងដាច់ខាត) ចិញ្ចឹមបីបាច់ថែរក្សាកូន"។

ចំណែកកូនមានករណីកិច្ច (ចិញ្ចឹមក៏បាន ឬមិនចិញ្ចឹមក៏បាន) ថែរក្សាម្ដាយពេលគាត់ចាស់ទៅ។ ពេលដែលមិនមានច្បាប់ហានិភ័យសង្គម [ Security Law ] ដូចនៅប្រទេសគេឬមានច្បាប់ហានិភ័យសង្គមតែមិនទាន់អនុវត្តន៍ នោះបង្កបញ្ហាទុក្ខលំបាកដល់ជនចាស់ជរាជានិច្ច៕

# ថ្ងៃទី១៤ ខែវិច្ឆិកា

"កូតនៅហោរ ចោរនៅជាង" វិធីសាស្ត្រល្អបំផុតដើម្បីឲ្យយើងទស្សទាយអនាគតខាងមុខបាន គឺយើងត្រូវចេះបង្កើតអនាគតឡើងឲ្យបានឡើងដោយខ្លួនឯង។ អ្នកនិពន្ធសៀវភៅ "As A Man Thinketh" លោក ជេម អាឡិន [ James Allen ] បានពោលថា *"អ្នកដែលស្វែងរកដោយការអត់ធ្មត់ និងមានការប្រឹងប្រែងមិនចេះចប់មិនចេះហើយ ទើបជាអ្នកអាចរកបាននូវកំណប់ទ្រព្យនៃចំណេះដឹង"*។

គុកនិងសោរ គឺចោរជាអ្នកបង្កើត ហើយឱសថល្អធើតកើតចេញពីរោគ ឬកើតចេញពីគ្រូពេទ្យ។ ដូច្នេះព្រហ្មលិខិត ឬកម្មវាសនា ក៏ស្ថិតនៅក្នុងដៃយើង ហើយយើងខ្លួនឯងគឺជាអ្នកបង្កើតវាឡើងមកដោយខ្លួនឯង។ ខ្ញុំចាំសម្ដីមួយឃ្លារបស់ប្រធានាធិបតីអាមេរិកថា *"ខ្ញុំជាមនុស្ស*

*ដែលជឿលើពេជ្រសំណាងជាខ្លាំង គឺថាបើខ្ញុំប្រឹងប្រែងកាន់តែខ្លាំង នោះខ្ញុំក៏នឹងក្លាយទៅជាមនុស្សដែលមានសំណាងកាន់តែខ្លាំងផងដែរ"។*

ក្នុងភាសាខ្មែរ ពាក្យថា "សំណាង" ប្រែថាការកសាង ឬបង្កើត ហើយសំណាងល្អ ក៏កើតចេញពីការកសាងល្អផងដែរ។មួយវិញទៀតពេលខ្លះការកសាងល្អក៏អាចទទួលលទ្ធផលបរាជ័យ៕

# ថ្ងៃទី១៥ ខែវិច្ឆិកា

បណ្ឌិត កែម ឡី៖ "ជំងឺបាក់ស្បាតសង្គម"ជំងឺបាក់ស្បាតរបស់ប្រជាពលរដ្ឋ ដែលជាកត្តាជំរុញឲ្យមនុស្សនៅក្នុងសង្គមខ្មែរបែរជាមិនខ្វល់ពីរឿងសង្គម និងរឿងអ្នកដទៃ។ អ្នកនយោបាយទុច្ចរិតកន្លងមក បានបណ្ដុះនូវវប្បធម៌នយោបាយហិង្សា ល្បិចកល ឧបាយកលអាក្រក់ និងតែងតែរកវិធីសម្លាប់គ្នាទៅវិញទៅមក ដើម្បីគ្រប់គ្រងអំណាចរដ្ឋ។ កត្តានេះហើយដែលជំរុញឲ្យប្រជាពលរដ្ឋខ្លួនឯងអសកម្ម និងមិនចូលរួមពេញលេញក្នុងគ្រប់ទិដ្ឋភាពសង្គម។

ពាក្យទាំងនោះរួមមាន *"នៅមិននៅកុំយកដំរីភ្នៅត្បៀតខ្លៀក។ បើមិននិយាយ គេមិនថាខ្លួនគរទេ។ ត្រីកំភ្លាញងាប់ព្រោះមាត់។ ធ្វើគរ ធ្វើថ្លង់ទៅរស់បានយូរ។ ពងមាន់កុំជល់ជាមួយថ្ម។ កុំព្យាយាមទូលភ្នំម្នាក់ឯង។*

ឡាំ លីម

កុំឈឺក្បាលក្នុងរឿងអ្នកដទៃ។ កុំចេះជាងមេ ទុកឲ្យមេជាអ្នកសម្រេច។ កុំចង់ល្បីម្នាក់ឯង។ សាច់មិនបានស៊ី កុំយកឆ្អឹងព្យួរក...។ល។"

# ថ្ងៃទី១៦ ខែវិច្ឆិកា

"ដុំថ្ម ឬគ្រួសតូចមួយដុំ ក៏អាចបង្កើតឲ្យមានទឹករលកបានដែរ"។ អ្នកម្ដាយ ថេរ៉េសា [ Mother Teresa ] ពោលថា "ខ្ញុំម្នាក់ឯងមិនអាចផ្លាស់ប្ដូរពិភពលោកបានទេ ប៉ុន្តែខ្ញុំអាចគប់ដុំថ្មកាត់ទឹកដើម្បីបង្កើតរលកអង្កាញ់ៗជាច្រើនបាន" ។ ចំណែកឃ្លាមួយទៀតពោលថា "កុំរង់ចាំអ្នកដឹកនាំ ចូរធ្វើវាតែម្នាក់ឯងក៏បាន ដោយចាប់ផ្ដើមពីមនុស្សម្នាក់ទៅម្នាក់ទៀត"។

យើងនឹងត្រូវគេរិះគន់ថា "គ្មានភាពជាអ្នកដឹកនាំ រហូតដល់យើងព្យាយាមធ្វើអ្វីមួយបានសម្រេច នោះយើងនឹងក្លាយជាអ្នកដឹកនាំ"។

ត្រូវចាំថា បើយើងមិនអាចធ្វើរឿងធំដុំបានទេ តែយើងគួរធ្វើអ្វីតាមលទ្ធភាពដែលយើងអាចធ្វើបាន ចំពោះមនុស្សមួយចំនួន និងនៅកន្លែងមួយចំនួន៕

You will be criticized no leadership skill until you can achieve it, then you are called leader.

# ថ្ងៃទី១៧ ខែវិច្ឆិកា

## ទស្សនវិជ្ជាជីវិតអ្នកប្រាជ្ញចិន ស៊ូ តុងប៉

អាណិតតាំងចិត្តឲ្យមានសេចក្តីក្លាហាន សម្រេចកិច្ចការតាមស្ថានភាព និងតាមលទ្ធភាព រស់នៅមិនទាមទារជីវិតអមតៈ ស្លាប់ទៅមិនទាមទារការចងចាំពីនរណាម្នាក់។ ពេលរស់សូមឲ្យជាមនុស្សយល់ដឹង ពេលស្លាប់ សូមឲ្យស្លាប់ដោយមានន័យ។ អ្នកខ្លះរៀនសូត្រជ្រៅជ្រះហាមាត់ឡើងសច្ចធម៌ៗ ប៉ុន្តែគេទុកការរៀនសូត្រជាកាំជណ្តើរដើម្បីស្វែងរកឋានៈ បុណ្យសក្តិ។ នៅពេលមានឋានៈបុណ្យសក្តិហើយ គេចាប់ផ្តើមស្វែងរកទ្រព្យសម្បត្តិ។ នេះបានន័យថា អ្នកទាំងនោះជាអ្នករៀនសូត្រជ្រៅជ្រះ ប៉ុន្តែគំនិតរបស់គេមិនមែនបម្រើប្រជារាស្ត្រ ឬជាតិទេ គឺដើម្បីស្វែងរកលាភសក្ការៈតែប៉ុណ្ណោះ៕

# ថ្ងៃទី១៨ ខែវិច្ឆិកា

បំផ្លាញធម្មជាតិ៖ ធម្មជាតិបំផ្លាញយើងវិញ តែបើយើងស្រឡាញ់ធម្មជាតិ ធម្មជាតិស្រឡាញ់យើងវិញ។ អ្នកមានអំណាចបំផ្លាញព្រៃឈើ តែធម្មជាតិជាអ្នកបង្កវេទនាដល់រាស្ត្រ។

ច្បាប់សាសនា៖ មិនចាំបាច់មានទង្វើ ត្រឹមតែគិត (ចិត្ត) អាក្រក់ ក៏ព្រះជាម្ចាស់ដាក់ទោសបាន។

ច្បាប់មនុស្ស៖ ច្បាប់លើអញ កើតឡើងព្រោះបាតុភូតសង្គម។ ពេលមានអញ អាចអវត្តមានច្បាប់បានព្រោះច្បាប់បង្កើតដោយអញ។

# ថ្ងៃទី១៩ ខែវិច្ឆិកា

បណ្ឌិត កែម ឡី "តើធ្វើយ៉ាងណាបានឡើងឋានៈខ្ពស់ឆាប់ក្នុងនាមជាមន្ត្រីរដ្ឋាភិបាល?" មានមន្ត្រីម្នាក់បានប្រាប់ខ្ញុំថា "ខ្ញុំមិនអាចឡើងឋានៈខ្ពស់បានទេ ពីព្រោះខ្ញុំចេះតែជំនាញបច្ចេកទេស តែមិនចេះនយោបាយ និងសេដ្ឋកិច្ច"។ តើអ្វីទៅជាជំនាញនយោបាយ និងសេដ្ឋកិច្ចរបស់មន្ត្រី? ចម្លើយគឺ៖

១. ចេះជំនាញសេដ្ឋកិច្ច គឺចេះពុករលួយ ចេះធ្វើជំនួញក្នុងរដ្ឋាភិបាល ចេះសូកលុយមេ ចេះសុំបុងសាំង ចេះសុំចុះបេសកម្មតាមខេត្ត ចេះមកចុចវត្តមានព្រឹកនិងល្ងាច ចេះឲ្យលុយមេពេលបើកប្រាក់លាភការ។ល។

២. ចេះជំនាញនយោបាយ គឺចេះលុតក្រាប ចេះភូតភរ ចេះប៉ែងជើងគ្នាឯង ចេះដើរតាមមេ ចេះហៃរហម ចេះលើកជើង ចេះមានល្បិចកល់លើគ្នាឯង ចេះមានឧបាយកល់អាក្រក់ដើម្បីឲ្យគ្នាឯងធ្លាក់ពីតំណែង រួចយកតំណែងគ្នាឯង។ល។

 

# ថ្ងៃទី២០ ខែវិច្ឆិកា

*"បើគ្មាននរណាម្នាក់ប្រាប់យើងទេ តែចូរប្រាប់ខ្លួនឯងថា ជីវិតរបស់យើង គឺពោរពេញដោយភាពស្រស់ថ្លា"*។

ច្បាប់នៃការស្រូបទាញ [ the Law of Attraction ] គឺបើយើងគិតល្អ នោះយើងនឹងទាញរឿងល្អចូលមកក្នុងជីវិតយើង។ ដូច្នេះចូរប្រាប់ខ្លួនឯងថា *"មនុស្សជាច្រើនស្រឡាញ់រាប់អានយើង។ មនុស្សជាច្រើនកំពុងត្រូវការយើង"*។ ជីវិតយើងត្រូវរស់នៅដើម្បីបុព្វហេតុ ឬហេតុផលណាមួយ។ យើងជាមនុស្សអស្ចារ្យជាងអ្វីដែលយើងគិតចំពោះខ្លួនឯង។ យើងជាមនុស្សកើតមកដើម្បីតែតែភាពជោគជ័យ។ បើយើងធ្លាប់បានសិក្សាពីច្បាប់នៃការស្រូបទាញ នោះយើងនឹងដឹងថាចក្រវាល ឬ Universe អាចផ្តល់ភាពវិជ្ជមានក្នុងជីវិតយើង ប្រសិនបើអ្នកគិតបែបវិជ្ជមានជានិច្ច៕

# ថ្ងៃទី២១ ខែវិច្ឆិកា

*"ជីវិតមនុស្ស គឺត្រូវបានបែងចែកជា ៣ដំណាក់កាល"* គឺ៖

១. ដំណាក់កាលអតីតកាល។

២. ដំណាក់កាលបច្ចុប្បន្ន។

៣. ដំណាក់កាលអនាគត។

ចូរយើងនាំគ្នារៀនសូត្រពីមេរៀនអតីតកាល ដើម្បីបង្កើតប្រយោជន៍បច្ចុប្បន្ន ហើយរស់នៅប្រឹងប្រែងក្នុងពេលបច្ចុប្បន្ន ដើម្បីឲ្យមានជីវិតល្អប្រសើរនាពេលអនាគត។ ទំនាយអនាគត គឺថាគ្រប់យ៉ាងនៅក្នុងលោកនឹងកើតឡើងយ៉ាងពិតប្រាកដនៅពេលអនាគតខាងមុខ។

បច្ចុប្បន្នប្រឹងរៀន អនាគតនឹងបានការចេះដឹង។ បច្ចុប្បន្នប្រឹងរក អនាគតនឹងឃើញការមានបាន និងបច្ចុប្បន្នចេះ "ឲ្យ" អនាគតនឹង "ទទួល" បាន៕

 

# ថ្ងៃទី២២ ខែវិច្ឆិកា

*"ការអប់រំមានរសជាតិល្វីងក្នុងពេលនេះ តែផ្លែផ្កានៃការអប់រំ គឺមានរសជាតិផ្អែមនៅពេលក្រោយ"*។

ការអប់រំ គឺជាលិខិតឆ្លងដែនសម្រាប់ចម្លងមនុស្សឲ្យទៅដល់អនាគតរុងរឿង ហើយថ្ងៃស្អែក គឺជាកម្មសិទ្ធិរបស់បុគ្គលទាំងឡាយណាដែលចេះត្រៀមខ្លួនរៀបចំនៅថ្ងៃនេះ។ គោលដៅចម្បងមហិមានៃការអប់រំ គឺមិនមែនរៀនត្រឹមតែចំណេះដឹងទ្រឹស្តីប៉ុណ្ណោះទេ តែត្រូវដឹងពីចំណេះធ្វើផងដែរ។ ការអត់ធ្មត់ខ្ពស់បំផុត គឺជាលទ្ធផលដែលកើតចេញពីការអប់រំជ្រៅជ្រះបំផុត។ ការអប់រំត្រឹមត្រូវ គឺបណ្តុះទាំងបញ្ញាមនុស្ស និងលត់ដំទាំងបេះដូងមនុស្សផងដែរ៕

# ថ្ងៃទី២៣ ខែវិច្ឆិកា

*"សូមកុំឲ្យភាពភ័យខ្លាចចូលក្នុងខ្លួនយើងបានឲ្យសោះ តែត្រូវជំនះយកសេចក្ដីក្លាហានដាក់ខ្លួនវិញ"*។

សូមកុំឲ្យគំនិតអវិជ្ជមានចូលក្នុងខ្លួនយើងបានឲ្យសោះ តែត្រូវជម្នះយកគំនិតវិជ្ជមានដាក់ខ្លួន។ សូមកុំរក្សាភាពខ្ជិលច្រអូសទុកក្នុងខ្លួនយើងឲ្យសោះ តែត្រូវលាងជម្រះដំនួសដោយភាពឧស្សាហ៍ព្យាយាម ហើយសូមកុំសុខចិត្តទទួលយក *"ភាពគ្មានអ្វីម៉្យាង"* តែត្រូវជម្នះយក *"គ្រប់យ៉ាង"* ដែលជាក្ដីប្រាថ្នាចង់បានរបស់យើង។

លោក ណាប៉ូលេអុង ហ៊ីល [ Napoleon Hill ] ពោលថា *"ចំណង់ គឺជាចំណុចចាប់ផ្ដើមនៃគ្រប់សមិទ្ធិផល"*៕

# ថ្ងៃទី២៤ ខែវិច្ឆិកា

*"យើងត្រូវតែរៀនធ្វើកិច្ចការងារណាដែលយើងគិតថា ខ្លួនឯងមិនអាចធ្វើបាន ពីព្រោះដោយសារតែយើងមិនចេះ ទើបយើងត្រូវចេះគិតវិជ្ជមាន ដោយត្រូវរៀនសាកល្បង"។*

យើងមិនអាចក្លាយជាចុងភៅដ៏ពូកែបាន ដោយត្រឹមតែយើងអានសៀវភៅវិជ្ជាធ្វើម្ហូបនោះទេ។ យើងមិនអាចក្លាយជាអ្នកអ្នកនេសាទដ៏ពូកែបាន ដោយត្រឹមតែអង្គុយអានសៀវភៅនេសាទនោះទេ ហើយយើងក៏នឹងមិនអាចក្លាយជាមនុស្សពូកែ ឬមនុស្សល្អបាន ដោយត្រឹមតែយើងអង្គុយអានពីទ្រឹស្តីមនុស្សពូកែ ឬអានពីសិក្ខាបទមនុស្សល្អដែរ។ ប៉ុន្តែចូរធ្វើជាមនុស្សអស្ចារ្យ ដោយចាប់ផ្តើមពីការធ្វើអំពើល្អពីឥលូវនេះតែម្តងទៅ៕

# ថ្ងៃទី២៥ ខែវិច្ឆិកា

## ទ្រឹស្តីភាពជាអ្នកដឹកនាំ

"អ្នកដឹកនាំអស្ចារ្យ គឺជាអ្នកបង្កើតអ្នកដឹកនាំបន្តវេន តែមិនមែនបង្កើតអ្នកដើរតាម។ ភាពជាអ្នកដឹកនាំ គឺកើតចេញពីសកម្មភាពធ្វើ តែមិនមែនកើតចេញពីអំណាចនោះទេ"។ ពេលមនុស្សមានត្រឹមតែជំនាញការងារ ប៉ុន្តែខ្វះភាពជាអ្នកដឹកនាំ នោះនឹងនាំឲ្យមានគំរូអាក្រក់តាមរយៈសកម្មភាព ឬប្រៀបដូចជាបុគ្គលមានកម្រិតភាពឆ្លាតលើការសិក្សាខ្ពស់ [ High IQ level ] តែមានកម្រិតនៃការយល់ដឹងផ្លូវអារម្មណ៍ទាប [ Low EQ level ]។ តាមការស្រាវជ្រាវបានឲ្យដឹងថា មនុស្សដែលមានកម្រិតភាពឆ្លាតខ្ពស់ ឬ High IQ level មានភាពជោគជ័យទាបជាងមនុស្សដែលមានកម្រិតនៃការយល់ដឹងផ្លូវអារម្មណ៍ខ្ពស់ ឬ High EQ level ប៉ុន្តែបើមានកម្រិតភាពឆ្លាតខ្ពស់ទាំងពីរនោះ ប្រៀបដូចជាខ្លាដុះស្លាប៕

# ថ្ងៃទី២៦ ខែវិច្ឆិកា

ពាក្យ៣ ម៉ាត់យ៉ាងខ្លីដែលមនុស្សយើងគួររៀនពីជីវិតគឺ *"បន្តដំណើរ - ជីវិត - ទៅមុខ"*។

ជីវិតគឺជាដំណើរ បើទោះបីជាយើងគ្មានគោលដៅពិតប្រាកដថាទៅណា ក៏នៅតែទៅដល់។ ដំណើរចាប់កំណើត ដំណើរកើតជាទារកទារិកា ដំណើរធំពេញវ័យ ដំណើរចាស់ ដំណើរជរា ដំណើរស្លាប់ និងដំណើរនាមនិងរូបបែកខ្ញែកពីគ្នា....ហើយចុងក្រោយគឺស្លាប់។

ជីវិតមិនមែនអមតៈ តែវាអាចអមតៈទៅបាន លុះត្រាតែយើងអាចបន្សល់ស្នាដៃដល់មនុស្សជាតិជំនាន់ក្រោយ។ មហាត្មៈ គន្ធី គ្មានជីវិតរស់នៅបន្ត តែមិនមែនស្លាប់ទេ។ អាល់ប៊ឺត អាញស្តាញ គ្មានជីវិតរស់នៅបន្ត តែមិនមែនស្លាប់ទេ។ អាប្រាហាម លីនខុន គ្មានជីវិតរស់នៅបន្ត តែមិនមែនស្លាប់ទេ។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

ព្រះបាទជ័យវរ្ម័នទី៧ គ្មានជីវិតរស់នៅបន្ត តែមិនមែនស្លាប់ទេ។ល។

ជីវិតដែលអស្ចារ្យ គឺជាជីវិតដែលចេះប្រើប្រាស់ចន្លោះពេលវេលារវាងការរស់នៅ និងការស្លាប់អស់ជីវិតឲ្យមានប្រយោជន៍សម្រាប់ជីវិតមនុស្សជំនាន់បន្ត។ ចូរយើងរៀនរស់ឲ្យដូចស្លាប់ ហើយរៀនស្លាប់ឲ្យដូចរស់ គឺមានន័យប្រឹងប្រែងដើម្បីជីវិត ឲ្យដូចយើងនឹងគ្មានថ្ងៃស្លាប់ ហើយយកសេចក្តីស្លាប់ទៅដោះដូរនឹងការប្រឹងប្រែង ធ្វើអ្វីម៉្យាងក្នុងពេលមានជីវិត។ លើលោកយើងនេះ គ្មាននរណាម្នាក់ស្លាប់ដោយសារការប្រឹងប្រែងទេ តែមនុស្សដែលខ្ជិលប្រឹងទៅវិញទេដែលរស់នៅវេទនា។ ការមិនចេះអត់ធ្មត់តស៊ូនឹងភាពលំបាកវេទនា គឺជាបុព្វហេតុនាំជីវិតឲ្យវេទនា។

"In three words I can sum up everything I've learned about life: it goes on." - Robert Fros

# ថ្ងៃទី២៧ ខែវិច្ឆិកា

"*ចំណេះ*" គឺជាផ្លូវទៅរកការពិសោធន៍។ "*ការដឹង*" ដោយពិសោធន៍ផ្ទាល់នឹងធ្វើឲ្យមនុស្សស្គាល់ព្រះ។ មនុស្សដែលមានសេចក្តីស្រឡាញ់ក្នុងចិត្ត គឺជា"*ព្រះ*"។

អ្នកសារព័ត៌មានម្នាក់ បានសម្ភាសន៍អ្នកម្តាយតេរេសា [ Mother Teresa ] ថា "តើសេចក្តីស្រឡាញ់ពិតមានអត្ថន័យបែបណា?" អ្នកម្តាយតេរេសាឆ្លើយតបទាំងទឹកមុខញញឹមថា "*សេចក្តីស្រឡាញ់ គឺមានន័យថាការចេះឲ្យដោយលះបង់។ ព្រះ (ព្រះយេហ៊ូវ៉ា) ដែលគង់នៅស្ថានសួគ៌ស្រឡាញ់ពិភពលោក។ ព្រះអង្គទ្រង់បានបញ្ជូនបុត្រាតែមួយគត់របស់ទ្រង់ឲ្យមកកាន់ពិភពលោក។ លោកយេស៊ូស្រឡាញ់ពិភពលោកយើងខ្លាំង លោកយេស៊ូស្រឡាញ់យើងខ្លាំង ហើយលោកយេស៊ូក៏ស្រឡាញ់ខ្ញុំខ្លាំង។ ដូច្នេះហើយ ទើបលោកយេស៊ូលះបង់ឈាម លះបង់ជីវិត*

*ដើម្បីសង្គ្រោះពិភពលោក សង្គ្រោះយើង និងសង្គ្រោះខ្ញុំ តាមរយៈសេចក្តីស្រឡាញ់នេះ។ សេចក្តីស្រឡាញ់ គឺជាការលះបង់រហូតដល់អាចឈឺចាប់ ឬរហូតដល់អាចស្លាប់។ ស្រឡាញ់គឺលះបង់"។*

អ្នកម្តាយតេរេសាបានសួរអ្នកសារព័ត៌មានវិញថា "តើអ្នកកាន់សាសនាអ្វី?" មុននឹងអ្នកសារព័ត៌មានឆ្លើយតបនូវសំនួរ គឺអ្នកសារព័ត៌មានបានបង្ហាញឥរិយាថបដោយបង្ហាញក្តីគោរព សេចក្តីស្រឡាញ់ ការឲ្យតម្លៃ និងចិត្តមេត្តាករុណា។ រួចបន្ទាប់មកតបថា *"ខ្ញុំជាមនុស្សមិនជឿលើសាសនា [ Atheist ] ទេ"។* អ្នកម្តាយតេរេសាក៏ញញឹមដោយក្តីស្រឡាញ់ រួចនិយាយថា *"សូមមេត្តាកុំនិយាយថាអ្នកជាមនុស្សមិនជឿលើសាសនា ពីព្រោះពាក្យពេជន៍ ឬសម្តីរបស់អ្នក គឺបង្ហាញថាអ្នកមានជំនឿលើសាសនាដោយសារទីណាមានសេចក្តីស្រឡាញ់ ទីនោះតែងមានព្រះជាម្ចាស់ ហើយព្រះជាម្ចាស់គឺជាសេចក្តីស្រឡាញ់។ អ្នកបាន*

បុគ្គលដែលពាក់ស្លាក ជាអ្នកមានជំនឿលើសាសនាណាមួយ តែគ្មានសេចក្តីស្រឡាញ់លើមនុស្សទាំងឡាយ គឺជាអំពើបាបមួយយ៉ាងធ្ងន់ធ្ងរ ឬសាសនាដោយគ្មានពលីកម្ម [ Religion Without Sacrifice ]៕

In knowing one knows God; in love one BECOMES God. Knowledge is the spiritual discipline; love is the fulfillment.

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

# ថ្ងៃទី២៨ ខែវិច្ឆិកា

*"មនុស្សដែលស្រឡាញ់ផ្កា គង់មិនកាច់ផ្កា។ មនុស្សដែលសម្រេចចិត្តកាច់ផ្កា នឹងធ្វើឲ្យផ្កាស្វិតស្រពោនស្លាប់។ ពេលដែលផ្កាស្វិតស្រពោនស្លាប់ ក៏នឹងធ្វើឲ្យយើងបាត់បង់ផ្កាដែលខ្លួនធ្លាប់ស្រឡាញ់។ សេចក្តីស្រឡាញ់ពិត គឺមិនមែនជាកម្មសិទ្ធិ តែវាជាការពេញចិត្តឃើញមនុស្សដែលយើងស្រឡាញ់រស់នៅមានសេចក្តីសុខ"។*

សេចក្តីស្រឡាញ់គ្មានហេតុផល ពីព្រោះរឿងហេតុផលជាបញ្ហាខួរក្បាល។ ស្រឡាញ់មនុស្សម្នាក់គ្មានហេតុផល តែបើការស្រឡាញ់មានហេតុផល គឺហេតុផលព្រោះស្រឡាញ់ប៉ុណ្ណោះ។ សេចក្តីស្រឡាញ់គ្មានចំណង់ចង់ឈ្នះចាញ់ ពីព្រោះរឿងឈ្នះចាញ់ គឺជាចរិតលក្ខណៈរបស់មនុស្សអាត្មានិយម។

សេចក្តីស្រឡាញ់បែបអាត្មានិយមអាចបន្តដំណើរទៅមុខបាន តែមិនបានយូរអង្វែង។ ស្រឡាញ់ព្រោះមាន ស្រឡាញ់ព្រោះស្អាត ស្រឡាញ់ព្រោះឆ្លាត ឬស្រឡាញ់ព្រោះ. . . . ព្រោះ. . . ព្រោះ. . . តែបើថ្ងៃណាមួយឈប់មាន ឈប់ស្អាត ឈប់ឆ្លាត នឹងឈប់ស្រឡាញ់ ពីព្រោះនេះក៏ជាហេតុផលព្រោះ... ព្រោះ...ព្រោះ...ដែរ៕

សេចក្តីស្រឡាញ់គឺជាគោលដៅ ជីវិតគឺជាដំណើរទៅរកគោលដៅ ហើយគោលដៅ គឺស្រឡាញ់។ ចុងក្រោយបើយើងរស់នៅដើម្បីខ្លួនឯង គឺរស់នៅបានដោយសារសេចក្តីស្រឡាញ់របស់អ្នកដទៃ តែបើចង់រស់នៅដើម្បីអ្នកដទៃ គឺត្រូវហ៊ានលះបង់ខ្លួនឯង។

រស់នៅដោយគ្មានមនោសញ្ចេតនាស្នេហាប្រុសស្រី គឺជាការឈឺចាប់ម្នាក់ឯង តែបើរស់នៅដោយគ្មានមនោសញ្ចេតនាចំពោះសង្គមជាតិ គឺជាការអស់ផ្ទះសម្បែងស្លាប់ទាំងអស់គ្នា។ នេះហើយបានជាគេនិយាយថា "*ស្នេហា គឺជាការលះបង់*"។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

តែលះបង់ដើម្បីស្នេហាប្រុសស្រី ឬស្នេហាជាតិ គឺជាជម្រើសប៉ុណ្ណោះ៕

If you love a flower, don't pick it up. Because if you pick it up it dies and it ceases to be what you love. So if you love a flower, let it be. Love is not about possession. Love is about appreciation. - Osho

# ថ្ងៃទី២៩ ខែវិច្ឆិកា

*"ជីវិតមនុស្សយើងគ្មានអ្វីទាំងអស់ ក្រៅតែពីប្រឹងប្រកួតប្រជែងដណ្តើមធ្វើជាអ្នកខ្លាំង ជាជាងធ្វើជាជនរងគ្រោះ"*។

ក្នុងសង្គមខ្លះ មនុស្សមិនខ្វល់ថាតើយើងមានប្រវត្តិអាក្រក់ ឬល្អបែបណាទេ តែបើយើងជោគជ័យ ឬមានទ្រព្យសម្បត្តិច្រើន គឺហៅថាជាមនុស្សពេញលក្ខណៈ តែបើយើងចាញ់ក៏ក្លាយជាជនរងគ្រោះ ឬជាមនុស្សគ្មានតម្លៃ ហើយទទួលរងនូវការប្រមាថមើលងាយ។ រឿងនេះ គឺជារឿងពិតមួយដែលជូរចត់បន្តិច។ ជៀសវាងយើងត្រូវចាញ់សង្គម ឬត្រូវទទួលការមើលងាយ ដូច្នេះចូរប្រឹងឲ្យឈ្នះខ្លួនឯង និងព្យាយាមសាងតម្លៃឲ្យខ្លួនឯង៕

*"Life is nothing but a competition to be the criminal rather than the victim."* - Bertrand Russell

# ថ្ងៃទី៣០ ខែវិច្ឆិកា

*"សច្ចភាពគ្មាននៅកន្លែងណាទាំងអស់ ឬគ្មាននរណាម្នាក់ធ្លាប់បានឃើញនូវសច្ចភាពទេ តែបើយើងនិយាយថាខ្លួនយើងឃើញនូវសច្ចភាព គឺថាការពិតក៏នឹងប្រែក្លាយទៅជាក្លែងក្លាយ"។*

ទ្រឹស្តីពុទ្ធនិយមបានបង្ហាញថា សច្ចភាពគឺមានសម្រាប់តែបុគ្គលម្នាក់ៗនិងរៀងៗខ្លួនប៉ុណ្ណោះ។ សច្ចភាព មិនអាចត្រូវនិយាយចេញមកប្រាប់ដល់អ្នកដទៃបានយល់ ឬឲ្យស្គាល់បានទេ តែលុះត្រាតែបុគ្គលខ្លួនឯងពិសោធន៍ដោយខ្លួនឯងផ្ទាល់។ ទ្រឹស្តីព្រហ្មណ៍សាសនាបានបញ្ជាក់ទៀតថា សច្ចភាពគឺប្រៀបដូចជាស្គរ និងខ្សាច់ដែលគ្មានបុគ្គលណាម្នាក់អាចមើលនឹងភ្នែកទទេយល់បានឡើយ។ ម្យ៉ាងសច្ចភាពនេះ មានតែមួយគត់ តែក្រុមបុគ្គលនិយមតែងនាំគ្នាបង្កើតសច្ចភាពក្លែងក្លាយរាប់មិនអស់។

ក្នុងគម្ពីរ តៅ តេ ជីង របស់ឡៅ ជឺ បានសរសេរបើក នូវមាតិកាទំព័រដំបូងបំផុតនៃសៀវភៅថា តៅដែលអាច និយាយចេញមកបាន មិនមែនជាតៅពិតប្រាកដទេ ឬតៅ ដែលអាចពន្យល់ឲ្យគ្រប់គ្នាយល់បាន ក៏ត្រឹមតែជាតៅក្លែង ក្លែងក្លាយប៉ុណ្ណោះ។ លទ្ធិតៅ គឺជាលទ្ធិធម្មជាតិ ឬជាច្បាប់ ធម្មជាតិដែលប្រកាន់យកធាតុសំខាន់ពីរ គឺជាតុយិន និងយ៉ាង ដែលមានន័យដល់ជាតុញី និងជាតុឈ្មោល។

មនុស្សជ្រុលនិយម ឬបុគ្គលអ្នកស្មោះត្រង់ តែមានជាប់នូវ នាំងអវិជ្ជាក្នុងខ្លួន [ Sincere Ignorance ] តែងប្រកាន់ ខ្ជាប់ថាគំនិតអញត្រូវ គំនិតឯងថោកទាប។ ក្រុមអញល្អ ក្រុមឯងអាក្រក់។ អញជេរពីរោះ តែឯងនិយាយពីរោះ មានសីលធម៌ គឺជាសម្ដីដែលមានមនោថោកទាប។ សង្គម ដែលសាបព្រោះនូវមនោគមន៍វិជ្ជាដល់មនុស្សឥតមានមូល ដ្ឋានថ្លឹង ឬបន្សុទ្ធចំណេះដឹង គឺមុន ឬក្រោយនឹងក្លាយទៅ ជាសង្គមកម្ពុជាប្រជាធិបតេយ្យ ឬសង្គមបដិវត្តន៍វប្បធម៌ របស់ចិន។

"There is nothing true anywhere, the true is nowhere to be seen; If you say you see the true, this seeing is not the true one." - Abraham Lincoln

# ទស្សនៈសម្រាប់ខែ

# ធ្នូ

# ថ្ងៃទី០១ ខែធ្នូ

"ភាពជាអ្នកស្គាល់រឿងដែលត្រឹមត្រូវ មិនល្អប្រពៃជាងភាពជាអ្នកធ្វើរឿងត្រឹមត្រូវនោះទេ។ មនុស្សដែលប្រឹងធ្វើរឿងល្អប្រសើរជាងមនុស្សនិយាយល្អ។ និយាយល្អនូវពាក្យមានប្រយោជន៍ ប្រសើរជាងពាក្យដេរបញ្ចោរ"។

ភាពអកុសលរបស់បុគ្គលអ្នកល្ងង់ គឺច្រឡំចំពោះខ្លួនឯងថាចេះ។ ភាពអកុសលរបស់បុគ្គលអ្នកចេះ គឺច្រឡំចំពោះខ្លួនឯងថាដឹង។ ភាពអកុសលរបស់បុគ្គលអ្នកដឹង គឺមិនចេះប្រឹងទប់អំនួតខ្លួនឯង។ បុរាណខ្មែរតែងពោលថា "កុំចេះ ជាងដឹង"។

ក្នុងសង្គមខ្មែរមានមនុស្សពីរក្រុម៖ ទីមួយគឺក្រុមអ្នកចេះដែលតែងចូលចិត្តអភិរក្សនិយម។ ទីពីរគឺក្រុមអ្នកដឹងដែលតែងចូលចិត្តភាពជ្រុលនិយម។ រវាងភាពជាអ្នកដឹង និងភាពជាអ្នកចេះ តែងមានចន្លោះមួយដែល ឲ្យយើងអាចធ្វើ

ទាំងជាអ្នកចេះ និងទាំងជាអ្នកដឹង ឬអ្នកមានចំណេះដឹង ដោយតាមរយៈភាពជាអ្នកយល់កាលៈទេសៈ ឬយល់ស្ថានភាពជាក់ស្តែងក្នុងស្ថានភាពណាមួយ។ នេះមានន័យថា "កុំធ្វើជាមនុស្សក្លាហានរហូតដល់ជួបគ្រោះថ្នាក់ តែក៏កុំកំសាកអាត្មានិយមរហូតរត់យករួចខ្លួននូវគ្រប់គ្រោះថ្នាក់"

៕ "Knowing what's right doesn't mean much unless you do what's right." - Theodore Roosevelt

# ថ្ងៃទី០២ ខែធ្នូ

*តើមាននរណាម្នាក់ដឹងច្បាស់ទេថា "ជីវិតលំបាកប៉ុនណា ប៉ុន្តែវារឹតតែលំបាកខ្លាំង បើយើងមិនប្រឹង"*។ គ្រប់គ្នាតែងយល់ថា *"ការញុំាអាហារ ធ្វើឲ្យមនុស្សបន្តជីវិតរស់នៅ តែខ្ញុំយល់ថាពេលខ្លះ អាហារ គឺដើម្បីឲ្យមានជីវិតបន្តការឈឺចាប់ទៅវិញទេ"*។ គោលបំណង និងបុព្វហេតុនៃការរស់នៅ គឺសំខាន់ខ្លាំងបំផុតសម្រាប់ជីវិត។ គោលបំណងនៃជីវិត គឺរស់នៅដើម្បីធ្វើជាមនុស្សល្អមានតម្លៃ ហើយបុព្វហេតុនៃជីវិតរបស់មនុស្សមានតម្លៃ គឺដើម្បីជួយអ្នកដទៃឲ្យក្លាយទៅជាមនុស្សល្អដែរ។

កែវភ្នែករបស់មនុស្សល្អ តែងតែសម្លឹងរកមើលចំណុចល្អរបស់អ្នកដទៃ។ អាប្រាហាម លីនខុន ពោលថា *"បើយើងតាំងចិត្តមាំថា នឹងស្វែងរកសេចក្តីអាក្រក់ពីក្នុងខ្លួនបុគ្គល*

*ដទៃ គឺថាយើងនឹងអាចរកឃើញសេចក្ដីអាក្រក់នោះភ្លាម"* ។

បបូរមាត់របស់មនុស្សល្អ តែងតែវាចាពោលពាក្យពីរោះមានន័យទៅកាន់អ្នកដទៃដោយសុទ្ធចិត្ត។ បុរាណខ្មែរពោលថា *"ខ្លៅរវៃងស្អប់ប្រាជ្ញ នាអ្នកខ្លួនខ្លាច រវៃងធ្វើហ៊ាន ខ្សត់ខ្សោយស្ទុតទ្រុឌ រវៃងធ្វើជាមាន អ្នកឥតសន្តាន រវៃងមើលងាយគេ"*។ អច្ឆរិយបុគ្គល អាល់ប៊ឺត អាញស្តាញ ក៏បានពោលស្រដៀងគ្នាដែរថា *"មនុស្ស ដែលឈ្លោះប្រកែកជាមួយបណ្ឌិតជន គឺហៅថាបុគ្គលពាល"*៕

# ថ្ងៃទី០៣ ខែធ្នូ

អារីស្តូត [ Aristotle ] ពោលថា *"សូមកុំកំសាក រហូតដល់រត់គេចពីគ្រប់គ្រោះថ្នាក់ តែក៏សូមកុំក្លាហាន រហូតដល់ធ្វើឲ្យយើងជួបគ្រោះថ្នាក់ដែរ"*។

មនុស្សក្លាហានតែខ្វះប្រាជ្ញា គឺប្រៀបដូចសត្វខ្លារត់ចូលចំការមីន តែមនុស្សមានប្រាជ្ញាហើយខ្វះភាពហានក្លាវិញ គឺប្រៀបដូចទៀនគ្មានបញ្ឆេះ។ ដូច្នេះ កាលៈទាសៈ គឺសំខាន់ខ្លាំងបំផុតចំពោះគ្រប់ការងារ ឬមានន័យម៉្យាងទៀតថា កាលៈទេសៈដាក់ស្តែងរបស់ស៊ីម៉ាអ៊ីសម័យសាមកុក គឺខុសគ្នាពីកាលៈទេសៈរបស់យើង។

ភាពក្លាហាន និងកំសាកសុទ្ធតែមានប្រយោជន៍ដូចគ្នា បើត្រូវកាលៈទេសៈ។ ក្នុងទ្រឹស្តីយុទ្ធសាស្ត្រថា "ត្រូវចេះសម្តែង ឬបើចិត្តកំពុងតែពុះកញ្ជ្រោលក្លាហាន គឺត្រូវចេះ

សម្តែងធ្វើកំសាក ហើយបើចិត្តកំពុងតែកំសាក ក៏ត្រូវចេះបង្ហាញថាក្លាហានដែរ។ អ្វីដែលសំខាន់ គឺប្រយោជន៍ជាធំ" ៕

# ថ្ងៃទី០៤ ខែធ្នូ

"ប្រជាធិបតេយ្យ មានន័យថាអំណាចទាំងអស់ប្រមូលផ្តុំភាគច្រើន ទៅលើក្រុមមនុស្សដែលមិនបានសិក្សាខ្ពង់ខ្ពស់ តែអភិជនាធិបតេយ្យគឺមានន័យថាអំណាចទាំងអស់ ស្ថិតក្នុងកណ្តាប់ដៃក្រុមអភិជនឈ្លាសវៃគំនិតអាក្រក់" ។ ប្រជាធិបតេយ្យ គឺជាផលិតផលរបស់ប្រទេសសាមីនីមួយៗផ្ទាល់ដោយមិន ថតចម្លងទាំងស្រុងពីប្រទេសដទៃ។ ប្រជាធិបតេយ្យពេកក៏នឹងបង្កឲ្យមានភាពអាណាធិបតេយ្យគ្មានសណ្តាប់ធ្នាប់។ ប្រទេសដែលមានប្រជាជនភាគច្រើនខ្វះការអប់រំ គឺត្រូវការអ្នកដឹកនាំដែលស្មោះត្រង់ តែប្រទេសដែលមានមេដឹកនាំឈ្លាសវៃគំនិតអាក្រក់ គឺជាទុក្ខរបស់ប្រជារាស្ត្រ។

របបសង្គមបែបណាក៏ដោយ គឺត្រូវការយុត្តិធម៌សង្គមជាសំខាន់ ហើយបើសង្គមបាត់យុត្តិធម៌ មនុស្សល្អពិបាករស់នៅ តែបើសង្គមល្អ មនុស្សអាក្រក់ក៏ពិបាករស់ដែរ។ ថ្វីត្បិតតែយុត្តិធម៌ គ្មាននិយាម ឬមិនមានម៉ែត្រវាស់ពីស្តង់ដា តែយ៉ាងហោចណាស់ ក៏គួរតែធ្វើយ៉ាងណាឲ្យប្រជាជនភាគច្រើនអាចទទួលយកបាន៕

*"Democracy means government by the uneducated, while aristocracy means government by the badly educated."*- G.K Chesterton

# ថ្ងៃទី០៥ ខែធ្នូ

*"ទីណាមានអំណាចនៃគតិបណ្ឌិត គឺទីនោះគ្មានឡើយនូវទំនាស់រវាងគំនិត និងអារម្មណ៍មនោសញ្ចេតនា"។*

អាល់ប៊ឺត អាញស្តាញ ធ្លាប់បានអះអាងរួចហើយថា "គតិបណ្ឌិត មិនមែនជាផលិតផលដែលបានមកពីសាលារៀននោះទេ តែបានមកពីបទពិសោធន៍ជីវិតជាក់ស្តែង"។ មនុស្សដែលមានគតិបណ្ឌិត [ man of wisdom ] គឺខុសគ្នាពីមនុស្សដែលមានចំណេះដឹង [ man of knowledge ] ។ ចំណេះដឹង គឺមិនមែនជាអំណាចដូចយើងគ្រប់គ្នាគិតទេ តែចំណេះដឹងគ្រាន់តែជាព័ត៌មានដែលមានក្នុងខួរក្បាលមនុស្សប៉ុណ្ណោះ។

ចំណេះដឹងនឹងក្លាយទៅជាអំណាចទៅបាន លុះត្រាតែមាន លក្ខខណ្ឌ ២យ៉ាង៖

ទី១. ត្រូវយកមកអនុវត្តន៍ជាក់ស្តែង ទើបក្លាយទៅជា អំណាច តែបើមិនអនុវត្តន៍ជាក់ស្តែងទេ គឺហៅថាទ្រឹស្តី និយម ឬជាព័ត៌មានប៉ុណ្ណោះ។

ទី២. អនុវត្តន៍ហើយ ត្រូវទទួលលទ្ធផលល្អផង តែបើគ្មាន លទ្ធផលល្អទេ គឺហៅថាចំណេះឥតបានការណ៍។

បើតាមទស្សនៈម៉ៅ សេទុង គឺចំណេះដឹងដែលអនុវត្តន៍ឥត បានការណ៍ ដាច់ខាតត្រូវបោះបង់ចោលភ្លាម។ ជាទូទៅ បេះដូងតែងមានហេតុផលរបស់បេះដូងដែលខួរក្បាលមិន អាចពាល់ត្រូវ តែមនុស្សដែលប្រើបេះដូងដោយត្រឹមត្រូវ បំផុតបាន លុះត្រាតែមានការយល់ដឹងតាមគំនិតគិតក្នុងខួរ ក្បាលសិន។ មនុស្សដែលមានគតិបណ្ឌិត ប្រៀបដូចជាខ្លា ដុះស្លាប ពីព្រោះគេដឹងថាពេលណាប្រើអារម្មណ៍និងពេល ណាប្រើគំនិត តែបើមិនអាចបែងចែកកាលៈទេសៈទាំងពីរ

នេះឲ្យដាច់ពីគ្នាបានទេ មនុស្សនឹងក្លាយទៅជាទាសករនៃអារម្មណ៍។ អ្នកប្រយុទ្ធប្រើអារម្មណ៍ តែងស្លាប់ក្នុងសមរភូមិ។អ្នកនយោបាយប្រើអារម្មណ៍តែងទទួលការស្អប់ខ្ពើមពីប្រជាជន។ ស្នេហាដែលប្រើអារម្មណ៍ គឺមុន ឬក្រោយក៏គង់មានតែការបែកបាក់គ្នា៕

*"Where wisdom reigns, there is no conflict between thinking and feeling."* - Carl Jung

# ថ្ងៃទី០៦ ខែធ្នូ

*"តម្លៃនៃជីវិត គឺជាទីបញ្ចប់នៃគ្រប់យ៉ាង"*

មនុស្សមិនសំខាន់ថាចាស់ ឬក៏ក្មេងទេ តែសំខាន់ការយល់ដឹងតិច ឬច្រើន។ មនុស្សមិនសំខាន់ថាការយល់ដឹងតិច ឬច្រើនទេ តែសំខាន់ គឺបទពិសោធន៍ជាក់ស្តែងក្នុងជីវិតច្រើន។ មនុស្សមិនសំខាន់ថាបទពិសោធន៍ជាក់ស្តែងក្នុងជីវិតតិច ឬច្រើនទេ តែសំខាន់ គឺតម្លៃដែលយើងបានកសាងឡើងក្នុងពេលមានជីវិតរស់នៅ។ តម្លៃនៃជីវិត គឺជាទីបញ្ចប់នៃគ្រប់យ៉ាង។

ខុង ជឺ បង្រៀនឲ្យយើងចាស់ទុំមុនអាយុ ឬមានន័យថាភាពចាស់ ឬក្មេងខ្ចីមិនមើលលើអាយុទេ តែមើលលើចរិតលក្ខណៈចាស់ទុំ។ អាល់ប៊ឺត អាញស្តាញ បង្រៀនយើងថាគតិបណ្ឌិតមានតម្លៃជាងចំណេះដឹង ហើយគតិតបណ្ឌិតមិនមែនជាផលិតផលបានមកពីសាលារៀនទេ

តែបានមកពីបទពិសោធន៍ជីវិតជាក់ស្តែង។ ចុងក្រោយ ធ្វើជាមនុស្សមានតម្លៃប្រសើរជាងត្រឹមតែធ្វើជាមនុស្សជោគជ័យ៕

## ថ្ងៃទី០៧ ខែធ្នូ

"ការចាប់ផ្តើមឡើងនៃសេចក្តីស្នេហា គឺជាការរលត់ទៅនៃគតិបណ្ឌិត"។

ដូច្នេះហើយ ទើបមនុស្សជាច្រើនតែងនិយាយថា "ស្នេហាគឺតែងធ្វើឲ្យមនុស្សខ្វាក់"។ សូម្បីតែទស្សនវិទូក៏មានស្នេហាមិនសមប្រកបដែរ។ នេះដោយសារស្នេហាគឺជាមេរៀនដោយពុំចាំបាច់មានគ្រូ ហើយម្យ៉ាងទស្សនវិទូពូកែតែខាងប្រើខួរក្បាលគិតប៉ុណ្ណោះ តែបើនិយាយពីបេះដូងរបស់ទស្សនវិទូ គឺមិនមែនជាអ្នកមនោសញ្ចេតនានិយមទេ។

ពេលខ្លះ គ្រប់យ៉ាងនឹងកើតឡើង តែគ្រាន់តែវាត្រូវការពេលវេលាខ្លះប៉ុណ្ណោះ។ គ្រប់យ៉ាង ត្រូវការពេលវេលារបស់វាតាមច្បាប់ធម្មជាតិ។ ទឹកល្អក់ត្រូវការពេលវេលាដើម្បីឲ្យថ្លាដូចដើម។ ចំពោះស្នេហាឈឺចាប់ ក៏ត្រូវការពេលវេលាដើម្បីឲ្យជាសះស្បើយវិញដែរ។ បើយើងស្រឡាញ់មនុស្សដែលខូចចិត្ត គឺយើងចាំបាច់ត្រូវប្រើចិត្តនិងពេលវេលា ដើម្បីដើរចូលទៅក្នុងបេះដូងរបស់គេបន្តិចម្តងៗដែរ ទើបសម្រេច៕

# ថ្ងៃទី០៨ ខែធ្នូ

*"រឿងនយោបាយ មិនជាប់ពាក់ព័ន្ធនឹងរឿងសីលធម៌ ឬ អសីលធម៌ទេ តែសំខាន់គឺអំណាច"*។

ទ្រឹស្តីនយោបាយបែបនេះ គឺដើម្បីឲ្យមេដឹកនាំប្រឹងធ្វើគ្រប់បែបយ៉ាងក្នុងការដណ្តើមអំណាច យកមកជួយសង្គមឲ្យខានតែបាន។ ប៉ុន្តែ បើមេដឹកនាំប្រឹងយកអំណាចដើម្បីបង្កើនឥទ្ធិពលខ្លួនឯង ឬដើម្បីតែបក្សខ្លួន ឬក្រុមខ្លួនឯង នោះគឺជាការខុសទាំងស្រុង។ អំណាចបែបអាត្មានិយមបែបនេះ[PowerCorrupt]គឺប្រៀបដូចជាប្រសាសន៍លោកគង់ ប៊ុនឈឿនថា *"អំណាចនិងលាមក បើគណនាក្លិនមិនខុសគ្នាដូចភ្លើម្រាក់ បើឲ្យអំណាចជ្រុលទាញទាក់នោះស្អុយជាងធ្លាក់លាមកទៀត"*។

លោកយេស៊ូគ្រិស្តបានរកឃើញច្បាប់ធម្មជាតិមួយ គឺច្បាប់នៃក្តីស្រឡាញ់ ឬ Law of Love ។ បើមេដឹកនាំស្រឡាញ់

សង្គមមែន គឺពេលខ្លះមិនចាំបាច់មានអំណាចធំពេកទេ ពីព្រោះប្រើត្រឹមតែក្ដីស្រឡាញ់ គឺល្មមគ្រប់គ្រាន់ហើយ។ ទស្សនៈនេះ ដូចអ្វីដែលលោក ឆាលី ឆាព្លីន ឬសាក់ឡូ [ Charlie Chaplin ] ធ្លាប់បានអះអាងស្រដៀងគ្នាដែរថា *"ពេលខ្លះ មេដឹកនាំដែលចង់បានអំណាច អាចថាមានគោលបំណងដើម្បីធ្វើបាបគាបសង្កត់ប្រជាជន ពីព្រោះបើគ្រាន់តែចង់ជួយសង្គ្រោះប្រជាជន មានត្រឹមតែសេចក្ដីស្រឡាញ់ និងចិត្តអាណិតអាសូរ គឺគ្រប់គ្រាន់ហើយ"*។

ខ្ញុំនៅចាំប្រសាសន៍របស់អ្នកនិពន្ធចម្រៀងអាមេរិកម្នាក់, លោក ជីមី ហែនឌ្រិក [ Jimi Hendrix ] លើកឡើងថា *"ពេលដែលអំណាចនៃសេចក្ដីស្រឡាញ់ [ Power of Love] អាចប្រើដើម្បីបន្ទន់ចិត្តមនុស្សដែលស្រឡាញ់អំណាចបានហើយ [ Love of Power ] គឺពិភពលោកទាំងមូលនឹងស្គាល់សន្តិភាពពិតប្រាកដ"*។

សូមឲ្យយុវជនគិតរឿងសិក្សាអប់រំជាធំ ដោយទោះបីជាយ៉ាងណាក៏ដោយ ក៏សូមកុំរស់នៅក្នុងភាពស្អប់ស្រឡាញ់ពេលនេះ ឬពេលអនាគត ដោយលុបចេញនូវទស្សនៈ "ទឹកឡើង ត្រីស៊ីស្រមោច ទឹកហោច ស្រមោចស៊ីត្រី" ចេញពីសង្គមខ្មែរ។ ឈ្នះចាញ់ គឺជារឿងមុនក្រោយ ឬម្តងម្នាក់ប៉ុណ្ណោះ ហើយក៏ពុំគួរបង្ហាញឥរិយបថឱដងដែរ៕

Politics have no relation to morals. - Niccolo Machiavelli

# ថ្ងៃទី០៩ ខែធ្នូ

រឿងនយោបាយ និងរឿងសាសនា តែងបំបែកប្រជាជនឈាមតែមួយឲ្យបែកសាមគ្គីគ្នា។ អ៊ីត្លែរយល់ថា ដើម្បីលេបយកប្រទេសមួយ គឺគេត្រូវធ្វើឲ្យប្រជាពលរដ្ឋក្នុងសង្គមមួយលែងស្គាល់តួនាទីខ្លួនឯងក្នុងនាមជាជនសង្គម។

ចន អាដាមយល់ថា ដើម្បីលេបយកប្រទេសមួយ គេត្រូវប្រើវិធីពីរយ៉ាង៖

១). តាមរយៈការធ្វើសង្គ្រាម។

២).តាមរយៈការបង្កើតបំណុលឬធ្វើយ៉ាងណាឲ្យមេដឹកនាំឬប្រជាជនជំពាក់បំណុលកាន់តែច្រើន។

ទ្រឹស្តីដឹកនាំរដ្ឋរបស់ ប្លាតុង លើកទឹកចិត្តឲ្យអ្នកចេះដឹង ជាពិសេសក្រុមទស្សនវិទូចូលរួមក្នុងជីវភាពនយោបាយ ពីព្រោះប្លាតុង យល់ថាមានតែក្រុមអ្នកចេះដឹងប្រកបដោយសីលធម៌ និងគុណធម៌ប៉ុណ្ណោះ ទើបអាចធ្វើឲ្យសង្គមជាតិ

មានភាពសុខសាន្តពិតប្រាកដបាន។ ត្រង់ចំណុចនេះ ប្លាតុង សំដៅដល់ "ក្រុមអ្នកចេះដឹង ឬទស្សនវិទូ ដែលមានគុណធម៌ និងសីលធម៌" គឺមានន័យថា ក្នុងសង្គមមួយ មិនខ្វះទេមនុស្សមានសមត្ថភាព ឬមនុស្សមានចំណេះដឹង តែបើសមត្ថភាព និងចំណេះដឹងទាំងនោះឃ្លាតចាកពីគោលការណ៍សីលធម៌ គឺជារឿងអពមង្គលរបស់ប្រជាជន។

ហេតុអ្វីបញ្ញវន្តនៅតែខ្វែងគំនិតគ្នារឿងនយោបាយ? នៅក្នុងទ្រឹស្តីចិត្តវិទ្យានយោបាយបានអះអាងថា *"មនុស្សពីធម្មជាតិ នៅពេលដែលខ្លួនរស់នៅសុខស្រួល ហើយ ឬគ្រួសារខ្លួនសុខស្រួលហើយ ពួកគេតែងតែខ្លាចនូវការផ្លាស់ប្តូរគ្រប់បែបយ៉ាង ពីព្រោះការផ្លាស់ប្តូរតែងមករំខាននូវសេចក្តីសុខរបស់ក្រុមខ្លួន ឬធ្វើឲ្យខាតបង់ប្រយោជន៍របស់ខ្លួន"*។ ត្រង់ចំណុចនេះ ក្រុមមនុស្សដែលចង់បានការផ្លាស់ប្តូរ គឺក្រុមអ្នកស៊ីអត់ស៊ីឃ្លានក្រុមអ្នកទទួលរងនូវអយុត្តិធម៌ និងក្រុមអ្នកវណ្ណៈអធន។

មានបញ្ញាវន្តម្នាក់និយាយមកកាន់ខ្ញុំថា *"មួយជីវិតខ្ញុំ គ្មានជនបរទេសណាហ៊ានមើលងាយខ្ញុំទេ"*។ ខ្ញុំតបថា *"វាជាការពិត ដោយសារឋានៈសង្គមរបស់លោកខ្ពស់ ដូច្នេះគ្មាននរណាមើលងាយលោកទេ តែលោកគួរតែមើលទៅកាន់ប្រជាជនក្រីក្រ និងប្រជាកសិករជាង ៨៥ភាគរយក្នុងប្រទេសវិញ"*។ ជំងឺនិយាយការពារ និងជំងឺអាត្មានិយមនឹងធ្វើឲ្យសង្គមទាំងមូលគ្មានការពិត ហើយថែមទាំងនាំទុក្ខដល់អ្នកជំនាន់ក្រោយថែមទៀត។ ដូច្នេះហើយ ទើបលីក្វាន់ យូ អះអាងថា *"វប្បធម៌សង្គមបែបណា វាសនាជាតិក៏នឹងក្លាយទៅជាបែបនោះដែរ"*៕

# ថ្ងៃទី១០ ខែធ្នូ

អាញស្តាញ [ Albert Einstein ] ពោលថា *"អ្នកដែលនិយាយថាការគិតមិនលំបាក គឺអ្នកនោះពុំដែលធ្លាប់បានគិតទេ"*។

មនុស្សមិនចេះអក្សរ មិនអាចអានអត្ថបទច្បាប់បាន។ អ្នកអាចអានអត្ថបទច្បាប់បាន មិនប្រាកដថាអាចយល់បាន។ អ្នកអាចយល់បាន មិនប្រាកដថាអាចវិភាគបកស្រាយបាន។ អ្នកអាចវិភាគបកស្រាយបាន មិនប្រាកដថាបកស្រាយបានត្រឹមត្រូវ។ គ្រប់យ៉ាងត្រូវតែឆ្លងកាត់ការគិតយ៉ាងស៊ីជម្រៅ។ ដើម្បីអាចគិតបានស៊ីជម្រៅ គឺត្រូវប្រើថាមពលច្រើន។ កាលបើប្រើថាមពលគិតច្រើន គឺតែងមានការលំបាក។ អាល់ប៊ឺត អាញស្តាញ ត្រូវបានពន្យារពេលទទួលពានរង្វាន់ណូបែលដោយសារកត្តាពីរគឺ

១ ) . គណៈកម្មការគ្មានសមត្ថភាពអាចយល់បានពីគំនិត

និងទ្រឹស្តីដែលអាញស្តាញបានរកឃើញ។

២). ដោយសារទ្រឹស្តីរបស់អាញស្តាញពេលនោះ មិនទាន់អាចយកមកអនុវត្តន៍ជាក់ស្តែងបាននៅឡើយ។

ដូចគ្នាដែរ អត្ថបទបែបទ្រឹស្តីទស្សនវិជ្ជា តែងមានគំនិតបង្កប់ជ្រៅដែលមនុស្សធម្មតា ឬមនុស្សខ្វះការព្យាយាមអានមិនងាយអាចអានយល់បានស្រួល ដោយប្រើពេលត្រឹមតែមួយដងនោះទេ។

នយោបាយតែងមានទីផ្សាររបស់នយោបាយ ដូចជាទីផ្សារនយោបាយរបស់គណបក្ស "ក" គឺបានរំដោះប្រទេសឲ្យរួចផុតពីសង្គ្រាម សុខសន្តិភាព និងការអភិវឌ្ឍន៍។ ទីផ្សារនយោបាយរបស់គណបក្ស "ខ" គឺអន្តោប្រវេសន៍ខុសច្បាប់របស់ប្រទេសជិតខាង អំពើពុករលួយ ការកាប់ព្រៃឈើបក្សពួកនិយម និងអយុត្តិធម៌សង្គមរបស់មេដឹកនាំកាន់អំណាច។ ទីផ្សារនយោបាយរបស់បក្ស "គ" គឺការសេរីរើនិយម [ Rebel ] និងការផ្លាស់ប្តូរការគិតរបស់ពលរដ្ឋ...

គឺថាអ្នកនយោបាយ សុទ្ធតែស្ទង់មើលចិត្តសាស្ត្រនយោបាយរបស់ពលរដ្ឋ ហើយបន្ទាប់មកកំណត់ទីផ្សារគោលដៅថាតើពលរដ្ឋប្រភេទណាដែលជាអតិថជនរបស់ខ្លួន។

ដូចគ្នាដែរ អត្ថបទដែលខ្ញុំព្យាយាមចែករំលែក ក៏មានទីផ្សារដែរ។ ហើយមនុស្សដែលប្រឹងអាន ឬព្យាយាមអានអត្ថបទមួយចំនួនរបស់ខ្ញុំ គឺជាយុវជនដែលចង់ធំដឹងក្តីមុនអាយុ។ បើកាលណាមនុស្សចេះគិតហើយ នោះការគិតរបស់គេនឹងក្លាយទៅជាចាស់ទុំ។ បន្ទាប់ពីការគិតចាស់ទុំ គឺពេលនោះហើយ ដែលគេនឹងក្លាយទៅជាមនុស្សចាស់ដោយស្វ័យប្រវត្តិ បើទោះបីអាយុនៅក្មេងក៏ដោយ។

មានលោកគ្រូប៉ុន្មាននាក់ចង់ទិញអត្ថបទរបស់ខ្ញុំ ហើយក៏មានបងប្អូនខ្លះចង់ទិញសៀវភៅរបស់ខ្ញុំ តែខ្ញុំបានជម្រាបពួកគាត់ថា *"អត្ថបទ និងសៀវភៅរបស់ខ្ញុំគ្មានតម្លៃសោះសូម្បីតែមួយរយរៀល"*។

មូលហេតុដែលខ្ញុំនិយាយបែបនេះ គឺដោយសារវាពិតជាគ្មានតម្លៃមែន សូម្បីតែលុយ ១ដុល្លា ក៏ទិញមិនបាន ឬ១០ ឬ១០០ដុល្លារក៏នៅតែទិញមិនបាន។ ផ្ទុយទៅវិញ តម្លៃរបស់វាគឺស្ថិតនៅលើមនុស្សដែលបានអាន និងចង់ចេះដឹងជាអ្នកឲ្យតម្លៃវាដោយខ្លួនឯង។

សូមឲ្យការខិតខំរៀនសូត្រ ស្ថិតនៅក្នុងបេះដូងយុវជនខ្មែររៀងរហូត។ សូមឲ្យបញ្ហាស្នេហា និងមនោសញ្ចេតនាទាំងឡាយ ជៀសឆ្ងាយពីការគំនិតយុវជនខ្មែរបណ្តោះអាសន្ន។ សូមឲ្យក្តីស្រឡាញ់ មេត្តាករុណាស្ថិតក្នុងបេះដូងមនុស្សគ្រប់គ្នា។ មានតែចំណេះដឹងរបស់ខួរក្បាលប៉ុណ្ណោះ ដែលអាចឲ្យយុវជនខ្មែរ ទប់ទល់នឹងយុទ្ធសាស្ត្រគ្រជាក់របស់សត្រូវខាងក្រៅបាន៕

"Thinking is hard work; that's why so few do it."

-Albert Einstein

# ថ្ងៃទី១១ ខែធ្នូ

*"ការមានឆន្ទៈ និងការមានបញ្ញា គឺមានលក្ខណៈតែមួយដូចគ្នា ពីព្រោះបើមនុស្សមានឆន្ទៈចង់ធ្វើអ្វីមួយ នោះគេក៏នឹងប្រើបញ្ញា ដើម្បីរកវិធីធ្វើរឿងនោះឲ្យបានសម្រេចខានតែបាន"។*

យើងពុំគួរសួរខ្លួនឯងថា តើយើងនឹងអាចក្លាយទៅជានេះ ឬអាចក្លាយទៅជានោះតាមបំណងដែរឬទេ? តែយើងគួរសួរខ្លួនឯងថា យើងពិតជា "ចង់" បានមែនដែរឬទេ? បើយើងចង់ខ្លាំង ឬមានចំណង់ពុះកញ្ជ្រោល [ Burning desire ]តើមានអ្វីដែលអាចរារាំងយើងបាន។ មនុស្សអាក្រក់ធ្វើរឿងអាក្រក់បាន ដោយសារតែឆន្ទៈ ហើយមនុស្សល្អ ធ្វើរឿងល្អបានក៏ដោយសារឆន្ទៈ ដែលយើងហៅថាសុឆន្ទៈ [ good will ]។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

យើងប្រហែលជាមិនភ្លេចប្រសាសន៍របស់អ្នកទាមទារសិទ្ធិសេរីភាពជាតិអាមេរិកគឺ លោក ម៉ាទីន លូធើឃីង ជូនៀ [ Martin Luther King Jr. ] ដែលថា *"បើយើងមិនអាចហោះហើរបានទេ នោះក៏ចូររត់, តែបើយើងមិនអាចរត់បានទេនោះក៏ចូរដើរ, តែបើយើងមិនអាចដើរបានទេនោះក៏ចូរលូន ហើយគ្រប់យ៉ាងដែលយើងធ្វើ គឺត្រូវតែឈានទៅមុខជានិច្ច"*៕

"Will and intellect are one and the same thing."

- Baruch Spinoza

# ថ្ងៃទី១២ ខែធ្នូ

*"មនុស្សមានចំណេះដឹង និងមនុស្សដែលមានគតិបណ្ឌិត"*

មនុស្សដែលមានចំនេះដឹង ឬ the man of knowledge គេតែងយល់ថាខ្លួនអស្ចារ្យណាស់ ដែលមានចំនេះដឹងលើសគេលើសឯង តែគេភ្លេចថា បើចាត់ថ្នាក់ ចំនេះដឹងរបស់មនុស្ស គឺគ្រាន់តែព័ត៌មានប៉ុណ្ណោះ។

មនុស្សដែលមានគតិបណ្ឌិត ឬ the man of wisdom គេតែងយល់ថាខ្លួននៅមានចំនុចខ្លះត្រូវរៀនបន្ថែមពីជីវិត ឬត្រូវការការពិសោធន៍ថែមទៀតដើម្បីឲ្យគេអាចស្វែងយល់បន្ថែមពីអត្ថិភាពរបស់ខ្លួននៅលើផែនដីនេះ។

មនុស្សដែលមានចំនេះដឹង នឹងអាចអានយល់ត្រឹមតែអត្ថបទទីមួយ តែប្រហែលជានឹងឆាប់យល់ ឬយល់នៅពេល

ក្រោយនូវអត្ថន័យនៃអត្ថបទទីពីរ។ អ្វីដែលខ្ញុំចង់មានន័យគឺថាមនុស្សដែលមានចំនេះដឹងត្រូវរៀនទប់អំនួតអួតក្អេងក្អាង ឬកុំប្រើអារម្មណ៍មនោសញ្ចេតនានិយមជ្រុល ពីព្រោះបើពុំដូច្នោះទេ យើងមិនអាចឈានដល់កម្រិតទីពីរបានឡើយ។

មនុស្សដែលមានចំនេះដឹង ឬ the man of knowledge និងមនុស្សដែលមានគតិបណ្ឌិត ឬ the man of wisdom គឺជាអត្ថបទដែលខ្ញុំរកឃើញ នៅក្នុងសៀវភៅទស្សនវិជ្ជាឥណ្ឌា ដែលមានប្រមាណ ១០០ទំព័រជាង៕

# ថ្ងៃទី១៣ ខែធ្នូ

*"បើយើងបាននិយាយប្រៀបធៀប រវាងភាពល្អ និងភាពអាក្រក់ នៃគំនិតណាមួយប្រាប់ដល់នរណាម្នាក់រួចហើយនោះយើងក៏ពុំចាំបាច់ផ្តល់ដំបូន្មានដល់គេទៀតដែរ"* ។

ការពិតមនុស្សឆ្លាតខ្លះ ប្រហែលជាពុំត្រូវការការប្រឹក្សា ឬដំបូន្មានអ្វីទេ តែគេអាចត្រូវការ ការស្តាប់ដោយយកចិត្តទុកដាក់របស់យើងប៉ុណ្ណោះ។ ពេលគេកំពុងនិយាយនៅពីមុខយើង សូមយើងកុំប្រើត្រចៀកស្តាប់ តែត្រូវប្រើភ្នែកស្តាប់វិញទើបមានក្រមសីលធម៌ជាង។

បណ្ឌិតដែលមានទំនោរនិយម ឬមាននិន្នាការនិយម តែងនិយាយបញ្ចុះបញ្ចូលឲ្យជឿ ឬឲ្យត្រូវតែជឿ តែអ្នកកណ្តាលនិយម [ Centrist ] ប្រឹងនិយាយឲ្យបុគ្គលអ្នកស្តាប់ថ្លឹងថ្លែង។ ចុងក្រោយ មិនថាជាអ្នកនិយាយឲ្យគេជឿ

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

ឬមិនថាអ្នកនិយាយឲ្យគេថ្លឹង ឬមិនថាអ្នកនិយាយរិះគន់គេទេ គឺដាច់ខាតត្រូវតែមានសិល្បៈ៕

If you can tell the difference between good advice and bad advice, you don't need advice.

# ថ្ងៃទី១៤ ខែធ្នូ

ទ្រឹស្តីពុទ្ធនិយមលើកឡើងថា *"ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់។ បុគ្គលឲ្យសុខទៅគេ រមែងបានសុខមកវិញ ហើយបុគ្គលឲ្យទុក្ខទៅគេ ក៏រមែងនឹងបានទុក្ខត្រឡប់មកខ្លួនឯងវិញដែរ"*។

ទ្រឹស្តីវិទ្យាសាស្ត្ររបស់រូបវិទូ អ៊ីសាក់ ញូវតុន [ Isaac Newton ] បានអះអាងថា *"រាល់គ្រប់កម្លាំងចលករ តែងមានកម្លាំងតបស្នងដែលមានទំហំប៉ុនគ្នា ប៉ុន្តែស្ថិតក្នុងទិសដៅផ្ទុយគ្នា"* ។

 

នេះមានន័យថា បើយើងឲ្យទុក្ខ ឬសុខទៅបុគ្គល "ក"ហើយបន្ទាប់មកយើងនឹងទទួលបានសុខ ឬទុក្ខទាំងនោះមកវិញពីបុគ្គល "ខ"។

ចំពោះទស្សនៈរបស់សូក្រាត, ឡៅ ជឺ, ខុង ជឺ, លោកយេស៊ូ និងអ្នកប្រាជ្ញក្នុងសាសនាធំៗ ឬមិនថាទស្សនវិទូណាទេ សុទ្ធតែបានអះអាងដូចៗគ្នាថា "កុំធ្វើនូវទង្វើណា ដែលយើងមិនចង់ឲ្យអ្នកដទៃធ្វើមកលើយើងវិញ"។

ចំពោះធម្មជាតិ គឺតែងតែស្រឡាញ់មនុស្សជានិច្ច តែបើយើងប្រព្រឹត្តទង្វើមិនល្អចំពោះធម្មជាតិ នោះធម្មជាតិក៏នឹងបំផ្លាញយើងវិញដែរ។ ឧទាហរណ៍ បើយើងកាប់បំផ្លាញព្រៃឈើ បន្ទាប់ពីអស់ឈើ តើជីវិតមនុស្សជាតិ នឹងមានបញ្ហាអ្វីកើតឡើង។ ចូរធ្វើជាមនុស្សល្អចំពោះខ្លួនឯង ចំពោះសាសនា ចំពោះធម្មជាតិ ហើយរបៀបនៃការក្លាយទៅជាមនុស្សល្អ គឺមានសារសំខាន់ខ្លាំងជាងសេចក្តីលោភលន់ទាំងឡាយ។

នៅក្នុងសង្គមស៊ីវិល័យ ឬក្នុងប្រទេសរីកចម្រើនខ្លាំង គេលែងបង្រៀនមនុស្សឲ្យចង់បានភាពជោគជ័យទៀតហើយ តែគេបង្រៀនមនុស្សឲ្យធ្វើជាមនុស្សមានតម្លៃវិញ។ ប៉ុន្តែក្នុងសង្គមដែលមានសេដ្ឋកិច្ចខ្សោយ ឬប្រទេសកំពុងអភិវឌ្ឍន៍ កត្តាសេដ្ឋកិច្ចគឺចាំបាច់បំផុតសម្រាប់ការរស់នៅ។ នេះហើយ ដែលគេតែងលើកឡើងថា បើក្រពះទទេមិនអាចក្លាយជាមនុស្សល្អបាន១០០%ទេ គឺវាប្រាកដជាមានទង្វើមិនល្អខ្លះកើតឡើងហើយ៕

## ថ្ងៃទី១៥ ខែធ្នូ

*"សិល្បៈនៃការរស់ និងសីល្បៈនៃការស្លាប់"*

ពេលគេង គឺគេង ហើយពេលគិត គឺគិត។ ពេលថ្ងៃ គឺគិត ហើយពេលយប់ គឺគេង។ បើចង់គេងលក់ស្រួលនៅពេលយប់ ឬ deep sleep លុះត្រាតែយើងបានប្រព្រឹត្តរឿងល្អនៅពេលថ្ងៃ។

បើចង់ស្លាប់ស្រួល ឬស្លាប់ដោយសិល្បៈ ឬ art of dying លុះត្រាតែយើងចេះសិល្បៈនៃការរស់នៅ ឬ art of living ឬចេះវិធីរស់នៅល្អ។ ការចេះរស់នៅល្អបច្ចុប្បន្ន គឺប្រៀបដូចជារៀបក្បួនស្លាប់ឲ្យល្អនៅពេលអនាគត។

សិល្បៈនៃការស្លាប់ក្នុងទ្រឹស្តីពុទ្ធសាសនា គឺត្រូវចេះធ្វើសមាធិ ឬធ្វើចិត្តឲ្យស្ងប់។ ដើម្បីចិត្តស្ងប់ទៅបាន លុះត្រា

យើងមានសីល។ សីល គឺមានន័យថាកុំប្រព្រឹត្តទង្វើអាក្រក់នានាដែលនាំឲ្យចិត្តល្អក់កករ ឬចិត្តប្រឆាំងនឹងខ្លួនឯង។ ក្នុងទ្រឹស្តីទស្សនវិជ្ជា សិល្បៈនៃការស្លាប់ គឺត្រូវស្គាល់ខ្លួនឯងឲ្យច្បាស់ ហើយបន្ទាប់មកស្គាល់ធម្មជាតិ។ គ្មានទស្សនវិទូណាម្នាក់ខ្លាចស្លាប់ទេ។ ការស្លាប់ប្រៀបដូចជាការដេកលក់៕

# ថ្ងៃទី១៦ ខែធ្នូ

*"តើពាក្យថា សច្ចភាព និងសេចក្តីពិត ខុសគ្នាត្រង់ណា?"*

គេសួរខ្ញុំថា "តើពាក្យថា សច្ចភាព និងសេចក្តីពិត ខុសគ្នាត្រង់ណា?" ខ្ញុំតបថា *"សច្ចភាព ជាពាក្យដែលប្រើក្នុងទ្រឹស្តីព្រះពុទ្ធសាសនា ហើយសេចក្តីពិត គឺជាពាក្យដែលប្រើក្នុងគម្ពីរគ្រីស្ទសាសនា និងគម្ពីរសាសនាជាភាសាខ្មែរដទៃទៀត"*។

គេសួរទៀតថា *"តើ សច្ចភាព និងសេចក្តីពិត មានន័យបែបណាវិញ?"* ខ្ញុំតបថា *"សច្ចភាព ឬសេចក្តីពិត ឬជាភាសាអង់គ្លេសថា* Truth *គឺមានន័យថាផែនដីវិលជុំវិញព្រះអាទិត្យ"*។ អ្នករកឃើញច្បាប់ទំនាញផែនដី ឬ The Law of Gravity គឺអ៊ីសាក់ ញូវតុន។ មានញូវតុនក្តី ឬគ្មានញូវតុនក្តី គ្រប់មនុស្សដែលដើរផុតស្ពានគឺត្រូវតែធ្លាក់ចុះទៅខាងក្រោម។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

អ្នករកឃើញច្បាប់នៃសេចក្តីស្រឡាញ់ ឬ The Law of Love គឺលោកយេស៊ូ។ មានលោកយេស៊ូក្តី ឬគ្មានលោកយេស៊ូក្តី ធម្មជាតិនៅតែស្រឡាញ់មនុស្សជានិច្ច។ ព្រះពុទ្ធរកឃើញច្បាប់កម្មផល និងច្បាប់ធម្មជាតិជាច្រើនទៀត។ មានព្រះពុទ្ធក្តី ឬគ្មានព្រះពុទ្ធក្តី គឺមនុស្សធ្វើល្អ បានផលល្អ និងធ្វើអាក្រក់ បានផលអាក្រក់។ កាលីឡេ រកឃើញថាមិនមែនព្រះអាទិត្យទេដែលវិលជុំវិញផែនដី តែផែនដីទៅវិញទេដែលវិញជុំវិញព្រះអាទិត្យ។ មានកាលីឡេក្តី ឬគ្មានកាលីឡេ ក្តី ក៏ផែនដីនៅតែវិលជុំវិញព្រះអាទិត្យ។

ផឹកទឹកឲ្យស្គាល់ប្រភព ជ្រកម្លប់ឲ្យស្គាល់អ្នកដាំ។ បើគ្មានបុគ្គលត្រាស់ដឹង [ Enlightenments ] ទាំងនោះទេម្ល៉េះសមយើងក៏ប្រហែលជាមិនមានថ្ងៃនេះដែរ។ នេះហើយដែលគេកំណត់ថា *"យើងរស់នៅបានមកដល់សព្វថ្ងៃ គឺពុំមែនដោយសារតែដុំបាយទេ តែដោយសារប្រវត្តិសាស្ត្រពីអតីតកាល"*៕

# ថ្ងៃទី១៧ ខែធ្នូ

ឡៅ ជឺ [ Lao Tzu ] ពោលថា "*ជីវិត គឺជាគូនឹងសេចក្ដីស្លាប់ ហើយការស្លាប់ គឺជាការចាប់ផ្ដើមនៃជីវិត។ យើងមានកំណើតមកពីទីកន្លែងដែលយើងមិនស្គាល់ ហើយយើងក៏នឹងត្រឡប់ទៅកន្លែងដែលយើងមិនស្គាល់វិញ។ បើដូច្នេះ តើហេតុអ្វីត្រូវបារម្ភច្រើនអំពីជីវិតធ្វើអ្វី*" ?

បើមិនចង់ស្លាប់ លុះត្រាតែកុំកើត តែបើកើតហើយ មិនថាជាមនុស្ស ឬមិនថាជាសត្វទេ គឺនឹងត្រូវស្លាប់ទៅវិញជាពុំខាន។ សូក្រាត មិនរត់ចេញពីគុក តែសុខចិត្តស្លាប់ដើម្បីសេចក្ដីពិតសង្គ្រោះមនុស្ស។ ព្រះវិស្ណុ សុខចិត្តចុះចាប់កំណើតជាអវតាផ្សេងៗ ដើម្បីបង្រៀនមនុស្សលោកឲ្យប្រព្រឹត្តសេចក្ដីល្អ។ព្រះយេហ៊ូវ៉ា បានបញ្ជូនលោកយេស៊ូក្នុងនាមទ្រង់ដើម្បីបង្រៀនសេចក្ដីពិតដល់មនុស្សលោក។ ព្រះពុទ្ធលះបង់ផ្លូវលោកីយរកផ្លូវត្រាស់ដឹងដើម្បីបង្រៀន

មនុស្សលោកឲ្យធ្វើល្អ។

សាសនាក្នុងលោក និងលទ្ធិទាំងឡាយបង្រៀនថា "ពេលមនុស្សស្លាប់ទៅ នឹងមិនសូន្យទេ"។ តើមនុស្សណាខ្លះដែលតែងតែជឿថាខ្លួនឯងជាមនុស្សល្អឥតខ្ចោះ? មនុស្សពេញលេញ មិនល្អឥតខ្ចោះទេ តែមនុស្សដែលយល់ថាខ្លួនឯងល្អឥតខ្ចោះ គឺជាប្រភេទមនុស្សមិនពេញលេញ ហើយមិនពេញលេញ គឺដោយសារតែពាក្យភូតកុហកថាខ្លួនល្អទាំងអស់។ ចូររស់នៅឲ្យស្រួល កុំតក់ក្រហល់ពេក។ ជីវិតគឺល្អទេ តែយើងទៅវិញទេដែលបំផ្លាញភាពល្អរបស់ជីវិត៕

"Life is the companion of death; death is the beginning of life. We arrive here from the unknown and go back to where we came from. Why should we be concerned?" - Lao Tzu

# ថ្ងៃទី១៨ ខែធ្នូ

មហាត្មៈ គន្ធី បាននិយាយថា "អ្នកដែលនិយាយថា សាសនាមិនជាប់ពាក់ព័ន្ធគ្នាជាមួយនយោបាយ គឺដោយសារគេពុំទាន់យល់ច្បាស់ពីខ្លឹមពិតប្រាកដនៃសាសនាទេ" ។

នៅត្រង់ចំណុចនេះ លោកយល់ថា ដើម្បីឲ្យសង្គមមួយរួចផុតពីការគាបសង្កត់ [ Freedom ] ដាច់ខាតជនក្នុងសង្គមទាំងអស់ត្រូវតែរួចរដោះពីកិលេសតណ្ហា [ Liberty ] និងភាពបុគ្គលនិយមសិនដោយយកប្រយោជន៍ធំជាមួយ។

មហាត្មៈ គន្ធី ជឿថាសេចក្តីស្រឡាញ់នឹងមិនបង្កឲ្យមានភាពហិង្សា [ Himsa ] ទេ ហើយមានតែអហិង្សា [ Ahimsa] មួយគត់ដែលអាចឈ្នះលើគ្រប់យ៉ាងក្នុងលោកបាន។

មហាត្មៈ គន្ធី បានកំណត់ថាមូលហេតុនៃអំពើហិង្សាតែងកើតឡើងដោយសារ បាបកម្មសង្គម ៧យ៉ាង

[ 7 Deadly Sins ] គឺ៖

១. ទ្រព្យសម្បត្តិមហាសាល ដោយគ្មានពលកម្ម ឬ Wealth Without Work,

២. សប្បាយដាច់បង្ហៀរ ដោយគ្មានសម្បជញ្ញៈ ឬ Pleasure Without Conscience,

៣. វិទ្យាសាស្ត្រ ដោយគ្មានគិតដល់មនុស្សជាតិ ឬ Science Without Humanity,

៤. សេដ្ឋកិច្ច ដោយគ្មានគិតពីសីលធម៌ ឬ Economic Without Morality,

៥. ចំនេះដឹង ដោយគ្មានជ្រាបចូលជាចរិត ឬ Knowledge Without Character,

៦. សាសនា ដោយគ្មានពលីកម្ម ឬ Religion Without Sacrifice,

៧. នយោបាយ ដោយគ្មានគោលការណ៍ ឬ Politic Without Principle ។

តើទស្សនៈមហាត្មៈ គន្ធី ទទួលឥទ្ធិពលពីបុគ្គលណាខ្លះ ? មហាត្មៈ គន្ធី បានអានសៀវភៅសាសនាជាច្រើនដូចជា

គម្ពីរកូរ៉ាន់, គម្ពីរគ្រីស្ទសាសនា, គម្ពីរព្រហ្មញ្ញសាសនា, គម្ពីរព្រះពុទ្ធសាសនា។ បុគ្គលដែលជះឥទ្ធិពលដល់ជីវិតរបស់គន្ធីមានដូចជា ទស្សនវិទូឥណ្ឌា Patanjaili, Vivekanada, Bhagavad Gita, Leo Tolstoy, Jhon Ruskin, Plato, Socrates...។

តើបុគ្គលណាខ្លះ ដែលទទួលឥណ្ឌពលទស្សនវិជ្ជាអហិង្សាពីមហាត្មៈ គន្ធី? យើងដឹងហើយថា សច្ចភាពរបស់គន្ធីគឺជាអហិង្សា ឬការមិនសហការនឹងសកម្មភាពហិង្សា។ បុគ្គលដែលបានរៀនសូត្រពីគន្ធីមានដូចជា Nelson Mandela, Martin Luther King Jr. ព្រមទាំងសាស្ត្រាចារ្យជាច្រើនទៀត ក្នុងនោះមានលោក ជីន សាប [ Gene Sharp ] នៃវិទ្យាស្ថានអាល់ប៊ឺត អាញស្តាញ ក៏បានយកគោលការណ៍របស់គន្ធីមកនិពន្ធសៀវភៅមួយដែលមានចំណងជើងថា "ពីរបបផ្តាច់ការទៅប្រជាធិបតេយ្យ ឬ From Dictatorship To Democracy" ផងដែរ៕

# ថ្ងៃទី១៩ ខែធ្នូ

*"លះបង់មនុស្សម្នាក់ ដើម្បីប្រយោជន៍គ្រួសារ លះបង់គ្រួសារ ដើម្បីប្រយោជន៍ភូមិស្រុក ហើយលះបង់ភូមិស្រុក ដើម្បីប្រយោជន៍សង្គមជាតិ។ ប៉ុន្តែគួរតែលះបង់ពិភពលោកទាំងមូលដើម្បីខ្លួនឯង"*។ បុគ្គលម្នាក់ គឺជាកោសិកានៃគ្រួសារ ហើយគ្រួសារមួយ គឺជាកោសិកានៃសង្គម។ បើចង់ឲ្យសង្គមរីកចម្រើន ត្រូវ បង្កើនជីវភាពគ្រួសារ, បើចង់ឲ្យគ្រួសាររីកចម្រើន គឺបុគ្គលម្នាក់ៗក្នុងគ្រួសារត្រូវចេះប្រឹងប្រែង។ ការលះបង់របស់យុវជន គឺមិនឲ្យកាន់កាំភ្លើងធ្វើសង្គ្រាម ក្នុងសមរភូមិទេ តែគឺត្រឹមតែប្រឹងរៀនឲ្យពេញទាំងចំណេះដឹងនិងគុណធម៌ ក៏ល្មមអាចហៅថា ការលះបង់បានហើយ៕

*"Always sacrifice a person for the sake of the family, a family for a village, a village for the state, but for the self-sacrifice the whole world."*

- Chanakya Neeti.

# ថ្ងៃទី២០ ខែធ្នូ

*"អ្នកវប្បធម៌ត្រូវជួយជាតិបែបណា?"*

អត្ថបទវិចារណកថារបស់លោក លី ធាមតេង ដែលមានចំណងជើងថា "អ្នកវប្បធម៌ត្រូវជួយជាតិបែបណា?"សូមអានអត្ថបទទាំងស្រុង៖ "វេលានេះ ប្រទេសជាតិកំពុងមានមហន្តរាយ អ្នកវប្បធម៌ទាំងអស់ រួមទាំងអ្នកនិពន្ធ កវី អ្នកអក្សរសាស្ត្រនេះផង ត្រូវឈមមុខប្រឆាំងតទល់ពេញទំហឹង ដើម្បីជួយយឹតយោងប្រទេសជាតិ។ តើយើងអ្នកនិពន្ធ កវី និង អ្នកអក្សរសាស្ត្រ ប្រឆាំងដោយមធ្យោបាយណា? [...] យើងអ្នកនិពន្ធ កវី អ្នកអក្សរសាស្ត្រព្រមជាមួយអ្នកវប្បធម៌ទាំងអស់ មិនមែនប្រឆាំងដោយកម្លាំងកាយ កម្លាំងអាវុធ ពុះពារដូចយុទ្ធជនក្នុងសមរភូមិទេ គឺយើងត្រូវប្រឆាំងតាមផ្លូវប្រាជ្ញា តាមមធ្យោបាយចិត្តសាស្ត្រ តាមការដាស់តឿនសតិអារម្មណ៍ជនរួមជាតិយើងឲ្យរឹងប៉ឹងស្មារតី ស្ម័គ្រសាមគ្គីពួតកម្លាំងដូចខ្លួនតែ

ទើបរើខ្លួន ឬបម្រះខ្លួន វិលទាន់ពេលប្រយុទ្ធប្រកួតប្រជែង នឹងសត្រូវគ្រប់ទិសស្របនឹងយុទ្ធជនបាន "។

អ្វីដែលខ្ញុំយល់ស្របនឹងលោក លី ជាមតេង ខ្លាំងបំផុត គឺ ប្រយោគដែលលោកលើកបានឡើងថា "ការតស៊ូរបស់ខ្មែរ ដែលមានចង្វាក់ស្របគ្នាល្អឥតខ្ចោះគឺថា អ្នកច្បាំងនឹង អាវុធក៏ខំ អ្នកច្បាំងនឹងកិច្ចការក៏ខំ អ្នកច្បាំងនឹងផ្លូវចិត្តផ្លូវ អប់រំក៏ ខំព្រមគ្នា ទើបប្រទេសជាតិឆ្លងផុត ឬគេចផុតពី គ្រោះមហន្តរាយបាន "។ បើមើលពីសង្គមខ្មែរបច្ចុប្បន្ន ខ្ញុំបានឃើញថា ខ្មែរមួយចំនួនតូចកំពុងតែមានគំនិតមើល បំណាំ ឬអំនួតពីរឿងជួយសង្គមតិច ឬជួយសង្គមច្រើន គិតតិច ឬគិតច្រើន..។ល។ មនុស្សដែលយល់បែបនេះ មិនមែនជាមនុស្សអាក្រក់ទេ តែជាមនុស្សដែលខ្សោយ ចំណេះដឹងចិត្តសាស្ត្រសង្គម ឬមនុស្សដែលមិនយល់ពី ស្ថានភាពមនុស្សដទៃ។

លោក សុទ្ធ ប៉ូលីន យល់ឃើញថា "លក្ខណៈនៃមនុស្សអសមត្ថភាពមាន ៣ប្រភេទគឺ៖

មនុស្សអសមត្ថភាពក្នុងនយោបាយ, មនុស្សអសមត្ថភាពក្នុងផ្លូវភេទ និងមនុស្សអសមត្ថភាពក្នុងជីវិត"។ បើតាមមហាត្មៈ គន្ធ [ Mahatma Gandhi ] យល់ថាសង្គមមួយអាចរីកចម្រើនទៅបាន លុះត្រាតែមនុស្សក្នុងសង្គមស្គាល់តួនាទីខ្លួនឯងក្នុងសង្គមសិន។

តួនាទី១៖ គឺកាតព្វកិច្ចចំពោះខ្លួនឯង ដោយត្រូវធ្វើយ៉ាងណាឲ្យជីវិតខ្លួនល្អប្រសើរ កុំធ្លាក់អន្លង់អបាយមុខ ស្រី ឬប្រុស ស្រា ល្បែង។ បុរាណខ្មែរក៏បានផ្ដាំទុកដែរថា "ខូចនឹងប្រុស អស់ព្រហ្មចារីយ ហើយខូចនឹងស្រី គង់ខ្លីវិជ្ជា"។

តួនាទី២៖ គឺកាតព្វកិច្ចចំពោះគ្រួសារ និងតួនាទី៣៖ គឺកាតព្វកិច្ចចំពោះសង្គមជាតិ។

អសមត្ថភាពក្នុងជីវិតរបស់យុវជនក្នុងជីវិតយុវវ័យ គឺកំពុងតែសម្លាប់ទាំងខ្លួនឯង និងសម្លាប់ទាំងអនុជនជំនាន់ក្រោយ។ សម្លាប់ខ្លួនឯង គឺមានន័យថាជីវិត នឹងរស់នៅក្នុងមនោសញ្ចេតនានិយមដោយភ្លេចគិតប្រឹងប្រែងរៀន ឬរៀនមិនចូលដោយសារតែជំងឺស្នេហា ឬជំងឺសង្គមនានា។ សម្លាប់អនុជនជំនាន់ក្រោយ គឺមានន័យថា *"មនុស្សក្នុងជំនាន់យើងរស់បានមិនមែនដោយសារតែដុំបាយទេ តែដោយសារការតស៊ូប្តូរផ្តាច់របស់បុព្វបុរសក្នុងប្រវត្តិសាស្ត្រពីមុន"*។ ពេលនេះ យើងក្នុងជំនាន់នេះ គឺមានតួនាទីបង្កើតប្រវត្តិសាស្ត្រថ្មីសម្រាប់អ្នកជំនាន់ក្រោយ ហើយបើយើងមិនប្រឹងពេលនេះ តើអ្នកជំនាន់ក្រោយនឹងមានសល់អ្វីខ្លះ៕

# ថ្ងៃទី២១ ខែធ្នូ

*"យើងអាចរស់នៅមានជីវិតមកដល់សព្វថ្ងៃនេះ គឺមិនមែនដោយសារជុំបាយទេ តែដោយសារប្រវត្តិសាស្ត្រ"។*

ជីវិតមនុស្សស្លាប់ ឬរស់ព្រោះតែជុំបាយ តែមាតុភូមិស្លាប់រស់ព្រោះតែនយោបាយ។ ផឹកទឹកឲ្យស្គាល់ប្រភព ជ្រកម្លប់ឲ្យស្គាល់អ្នកដាំ ហើយបើគ្មានប្រវត្តិសាស្ត្រពលីកម្ម ឬការតស៊ូរបស់បុព្វបុរសស្នេហាជាតិទេ គឺគ្មានថ្ងៃនេះដែរ។

យុវជន គួរតែជៀសវាងចម្រៀង ឬសិល្បៈណាដែលអសីលធម៌ដូចជា "អោបប្ដីនឹកសង្សារចាស់"....។ល។ ខ្ញុំចាំប្រសាសន៍របស់អ្នកនិពន្ធដើងចាស់ម្នាក់ថា "អ្នកនិពន្ធជួយជាតិតាមរយៈសំណេរបណ្ដុះស្មារតីជាតិនិយម និងស្នេហា។ "ខ្ញុំស្ដាប់ចម្រៀងបែបនេះ ២ឆ្នាំហើយ ពេលស្ដាប់កាន់តែយូរ ខ្ញុំក៏ស្រមៃឃើញការឈឺចាប់ជាតិជាច្រើនដូចជា

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

ការព្រាត់ប្រាស់ ការតស៊ូ នឿយហត់ លះបង់ឈាមស្រស់ សាច់ស្រស់ តាំងពីសម័យបារាំង និងចុងក្រោយរហូតដល់ទស្សវត្សរ៍១៩៩០៕

## ថ្ងៃទី២២ ខែធ្នូ

*"អ្នកណាដែលអាចគ្រប់គ្រងប្រព័ន្ធព័ត៌មានបាន គឺប្រៀបដូចជាអាចគ្រប់គ្រងប្រព័ន្ធគំនិត របស់មនុស្សបានដូចគ្នាដែរ"*។

តម្រាពិជ័យ ស៊ុន ជឺ [ Sun Tzu ] អះអាងថា *"ស្គាល់គេស្គាល់ខ្លួនឯង ច្បាំងមួយរយដង ឈ្នះមួយរយដង តែបើស្គាល់គេ ឥតស្គាល់ខ្លួនឯង ឬស្គាល់ខ្លួនឯង ឥតស្គាល់គេឯង ច្បាំងអាចឈ្នះអាចចាញ់"*។ របៀបរបស់ ស៊ុន ជឺ ដើម្បីស្គាល់ពីសត្រូវ គឺត្រូវប្រើចារជន ៥ប្រភេទ៖ ១) ចារជនតំបន់ [ Local spies ], ២) ចារជនរនុកក្នុង [ Inward spies ],

៣) ចារជនមុខពីរ [ Converted spies ], ៤) ចារជនពលី [ Doomed spies ] និង៥) ចារជនរួចជីវិត [ Surviving spies ]។

ក្រោយពីការដួលរលំនៃប្លុកកុម្មុយនីស្ត និងក្រោយពីសង្គ្រាមត្រជាក់បានបញ្ចប់ ពិភពលោកក៏បានបន្តដំណើរផ្លាស់ប្តូរមកសម័យកាលថ្មីមួយទៀត ដែលអ្នកប្រវត្តិសាស្ត្របានហៅថា *"បដិវត្តន៍បច្ចេកវិទ្យា ឬ បដិវត្តន៍ឌីជីថល [ Digital Revolution ]"*។

ដូច្នេះ ព័ត៌មានបានក្លាយជាអាវុធយកឈ្នះលើគូប្រកួតមិនថាលើផ្នែកនយោបាយ ពាណិជ្ជកម្ម សិក្សាធិការ..។ល។ កាលជំនាន់មហាត្មៈ គន្ធី ក៏បានយកប្រព័ន្ធព័ត៌មានជាធាតុអាស្រ័យដើម្បីទាមទារឯករាជ្យពីអង់គ្លេសដែរ៕

*"Whoever controls the media, controls the mind."*

- Jim Morris

# ថ្ងៃទី២៣ ខែធ្នូ

អាល់បឺត អាញស្តាញ [ Albert Einstein ] និយាយថា *"គតិបណ្ឌិត គឺមិនមែនជាផលិតផលដែលបានមកពីសាលារៀនទេ តែគឺជាអ្វីដែលទទួលបានពីការរស់នៅក្នុងជីវិតជាក់ស្តែង"*។

ដោយសារតែខ្ញុំមានរឿងជីវិតផ្ទាល់ខ្លួន ដូច្នេះ ខ្ញុំមិនចំណាយវេលាអានពីរឿងជីវិតអ្នកដទៃទេ។ មនុស្សដែលទទួលបានការអប់រំផ្លូវការនៅសាសារៀន គឺជាមនុស្សដែលមានចំណេះដឹង ឬជា the man of knowledge តែមនុស្សដែលរៀនពីបទពិសោធន៍ជាក់ស្តែងក្នុងជីវិត គឺជាមនុស្សដែលមានគតិបណ្ឌិត ឬជា the man of wisdom។ បើសិនជាអាច យើងគួរតែប្រឹងប្រែងយកទាំងពីរ គឺទាំងបទពិសោធន៍ជាក់ស្តែងក្នុងជីវិត និងការអប់រំផ្លូវការនៅសាលារៀន៕

# ថ្ងៃទី២៤ ខែធ្នូ

*"សេចក្តីក្លាហាន មិនមែនជាគុណធម៌ធម្មតាទេ តែវាគឺជាចំណុចចាប់ផ្តើមនៃការកកើតឡើង នៃគុណធម៌ទាំងឡាយផ្សេងទៀត"។*

បើមាននេះ គឺដោយសារមាននោះ, បើកើតនេះ ក៏ដោយសារកើតនោះ, បើមានមួយ ក៏គង់នឹងមានពីរ, ហើយដំណើររាប់រយគីឡូ តែងចាប់ផ្តើមចេញពីមួយជំហាន។ មេដឹកនាំកំសាកម្នាក់ នឹងបង្កើតកូនទាហានកំសាកញ៉ីរាប់រយនាក់ តែបើមេដឹកនាំក្លាហានម្នាក់ គង់នឹងលុបបំបាត់ភាពភ័យដល់មនុស្សរាប់រយនាក់។

គ្រាមួយ នៃលសិន មិនដេឡា [ Nelson Mandela ] បានធ្វើដំណើរតាមយន្តហោះដើម្បីឃោសនាស្វែងរកសម្លេងធ្នោតគាំទ្រពីប្រជាជនតាមតំបន់។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

ក្នុងកំឡុងពេលយន្តកំពុងតែហោះហើរ ក៏កើតមានបញ្ហាមួយ។ អ្នកបើកបរយន្តហោះជូនដំណឹងមកលោក និងសហការីថា *"សូមប្រកាសអាសន្ន ពេលនេះយន្តហោះប្រហែលអាចនឹងធ្លាក់ក្នុងពេលប៉ុន្មាននាទីចុងក្រោយ"* ។ បន្ទាប់មក នៃលសិន មិនដៃឡា នៅស្ងៀមដោយរក្សាទឹកមុខធម្មតា និងធ្វើដូចមិនដឹងមិនលឺអ្វីទាំងអស់ ហើយសកម្មភាពរបស់គាត់ធ្វើជាអានកាសែតធម្មតា គ្មានភ័យខ្លាចបន្តិចសោះ។ ចុងក្រោយ យន្តហោះបានចុះចតដោយសុវត្ថិភាព។ អ្នកបើកបរ និងសហការី សប្បាយចិត្តខ្លាំងហើយក៏បានសួរ នៃលសិន មិនដៃឡា ថា "តើលោកប្រធានមិនភ័យខ្លាចទេ"។ គាត់តបថា *"ខ្ញុំភ័យខ្លាំងណាស់ ហើយភ័យខ្លាំងជាងអ្នកទាំងអស់គ្នាទៀតផង តែខំសម្តែងធ្វើជាធម្មតា ដូចជាគ្មានរឿងអ្វីកើតឡើងបន្តិចសោះ"*៕

Courage is not simply one of the virtues, but the form of every virtue at the testing point.

- C. S. Lewis

# ថ្ងៃទី២៥ ខែធ្នូ

*"សូមកុំបោះបង់សេចក្តីពិត បើទោះបីយើងត្រូវបានក្រុមភាគច្រើនថា យើងជាមនុស្សល្ងង់ក៏ដោយ តែភាពល្ងង់របស់យើង គឺជាសេចក្តីពិត"*។

ប្រហែលជាក្នុងចន្លោះអាយុ ៧០ឆ្នាំ ឬ៧៥ឆ្នាំ កាលីឡេ [ Galileo ] បានរកឃើញថា *"ការពិត មិនមែនព្រះអាទិត្យទេ ដែលវិលជុំវិញផែនដី តែផែនដីទៅវិញទេ ដែលវិលជុំវិញព្រះអាទិត្យ"*។ ក្រោយមក កាលីឡេ ក៏ត្រូវបានសម្តេចប៉ាប [ Pope ] អញ្ជើញឲ្យចូលឆ្លើយបំភ្លឺពាក់ព័ន្ធនឹងការរកឃើញរបស់គាត់ ដែលកំពុងតែប្រឆាំងនឹងគម្ពីរដែលព្រះជាម្ចាស់បានចែងមកពីឋានសួគ៌។ សម្តេចប៉ាបបាននិយាយថា អ្នកកំពុងតែប្រព្រឹត្តបទឧក្រិដ្ឋមួយយ៉ាងធ្ងន់ធ្ងរ ដោយសារក្នុងខគម្ពីរបានចែងថាព្រះអាទិត្យវិលជុំវិញផែនដី ហើយយើងទុកជម្រើសពីរឲ្យអ្នក៖

១) អ្នកត្រូវផ្លាស់ប្តូរគំនិតឲ្យស្របតាមគម្ពីរដែលមកពីព្រះជាម្ចាស់ និង២) យើងនឹងដាក់ទោសប្រហារជីវិតអ្នក"។ កាលីឡេ ក៏បានតបថា *"លោកម្ចាស់ មិនជាបញ្ហាអ្វីទេ ហើយខ្ញុំអាចស្របតាមសម្តីដែលលោកចង់បាន ដោយសុខចិត្តដូរគំនិតរបស់ខ្ញុំតាមលោក*"។

ចុងក្រោយ កាលីឡេ បានកែប្រែសំនេរតាមសម្តីរបស់សម្តេចប៉ាបដោយសរសេរក្នុងសៀវភៅថា *"ដោយយោងទៅតាមព្រះគម្ពីរ, ដោយយោងតាមសម្តីសាមញ្ញរបស់សម្តេចប៉ាប និងដោយយោងទៅតាមគំនិតមនុស្សសាមញ្ញ គឺព្រះអាទិត្យវិលជុំវិញផែនដី*"។ ប៉ុន្តែ កាលីឡេ បានបញ្ជាក់ខាងក្រោមទំព័រនៃសៀវភៅថា "សច្ចភាព ឬសេចក្តីពិត គឺផ្ទុយនឹងព្រះគម្ពីរ, ផ្ទុយនឹងសម្តីរបស់សម្តេចប៉ាប និងផ្ទុយពីគំនិតរបស់មនុស្សសាមញ្ញ។ ម្យ៉ាងទៀត ខ្ញុំគ្មានសមត្ថភាពបញ្ចុះបញ្ចូលផែនដី និងព្រះអាទិត្យឲ្យធ្វើតាម (ខ)គម្ពីរបានឡើយ ពីព្រោះថាផែនដី និងព្រះអាទិត្យ មិនមែនជាគ្រីស្ទសាសនិកទេ"។

ក្នុងលោកយើងនេះ គ្មានអ្វីដែលត្រឹមត្រូវរហូតទេ ឬក៏គ្មានអ្វីដែលខុសរហូតទេ តែវាអាស្រ័យលើពេលវេលា និងការយល់ដឹងរបស់មនុស្ស។ គ្រប់សាសនាទាំងអស់ មានចំណុចខ្លះត្រឹមត្រូវ ឬជាគោលការណ៍ឥតប្រែប្រួល តែក៏មានខ្លះទៀតគង់ផ្លាស់ប្តូរតាមពេលវេលាដែរ។ ដូច្នេះពុំគួរជ្រុលនិយមពេកឡើយ ហើយគួរតែចេះគោរពឲ្យតម្លៃដល់អ្នកដទៃផងដែរ។ ព្រះជាម្ចាស់ គឺជាសេចក្តីស្រឡាញ់ ហើយសេចក្តីស្រឡាញ់ ក៏ជាព្រះជាម្ចាស់ដែរ។ ដូច្នេះការស្រឡាញ់ គឺជាអ្វីគ្រប់យ៉ាង៕

"The truth is just the opposite. I cannot help it. I cannot convince the earth and the sun to follow the Bible. They are not Christian." - Galileo

# ថ្ងៃទី២៦ ខែធ្នូ

បើគេអញ្ជើញ សាសនិកក្នុងនិកាយសាសនាទាំងអស់មកឲ្យជជែកគ្នាក្នុងបន្ទប់មួយ ពីគោលការណ៍ជំនឿសាសនារបស់ខ្លួន គេនឹងឃើញមានសកម្មភាពនៃការឈ្លោះប្រកែកគ្នា ឬឈានដល់អំពើហិង្សានៃសាសនិកទាំងនោះជាក់ជាពុំខាន។ ប៉ុន្តែ បើគេយកព្រះពុទ្ធ ព្រះយេស៊ូ ព្រះអាឡាស់ ព្រះវិស្ណុមកជជែកគ្នានៅក្នុងបន្ទប់មួយពីគោលការណ៍ជំនឿ គេនឹងមិនឃើញមានការឈ្លោះប្រកែក ពាក្យសម្ដីគ្នារបស់មេសាសនានីមួយៗឡើយ។

សច្ចភាព គឺជាអ្វី? គម្ពីរព្រាហ្មណ៍ចែងថា "សច្ចភាពគឺមានតែមួយទេ តែមេដឹកនាំនិកាយសាសនានានា បានឲ្យឈ្មោះសច្ចភាពផ្សេងៗគ្នា"។ សច្ចភាពរបស់ព្រះពុទ្ធសាសនា គឺព្រះនិព្វាន, សច្ចភាពរបស់គ្រីស្ទសាសនា គឺសេចក្ដីស្រឡាញ់ ឬបានទៅរស់នៅសួនអេដេន, ហើយ

អ្នកវិទ្យាសាស្ត្រហៅសច្ចភាពថាសម្បជញ្ញៈ ឬសេចក្តីដឹងខ្លួន ឬការមិនភ្លេចខ្លួន ឬការប្រុងប្រយ័ត្នជានិច្ច ឬការត្រិះរិះរំពឹងដឹងខ្លួនជាដរាប [ Consciousness ]។ មហាត្មៈ គន្ធី [ Mahatma Gandhi ] បានលើកឡើងថា "សាសនាទាំងអស់មានគោលដៅតែមួយដូចគ្នា តែគ្រាន់តែប្រើប្រាស់មាគ៌ាខុសគ្នាតែប៉ុណ្ណោះ"។

ហេតុអ្វីខ្មែរយើងមានទំនាស់គ្នាពីរឿងសាសនា? ទស្សនៈមួយបានលើកឡើងថា *"ព្រះគឺជាសេចក្តីស្រឡាញ់ ឬ GOD is love"* ហើយក៏មានន័យដូចគ្នាដែរថា *"សេចក្តីស្រឡាញ់គឺជាព្រះ ឬ LOVE is god"*។ សម្តេចសង្ឃដាឡៃ ឡាម៉ា បានមានសង្ឃដីកាថា "សាសនានៃភាពសាមញ្ញ គឺមិនចាំបាច់មានព្រះវិហារ ឬមិនចាំបាច់គិតដល់ទស្សនវិជ្ជានាំឲ្យស្មុគស្មាញ។ ប៉ុន្តែយើងគ្រាន់តែយកខួរក្បាលរបស់យើង និងបេះដូងរបស់យើងមកធ្វើជាព្រះវិហារ ហើយទស្សនវិជ្ជារបស់យើង គឺចិត្ត

សប្បុរសធម៌"។ ផ្ទុយពីសេចក្តីស្រឡាញ់ មានសាសនិក និកាយសាសនាខ្លះ បានប្រឹងប្រែងសូត្រធម៌ដាក់ទំនាយមនុស្ស ឬប្រឹងអធិដ្ឋានទៅព្រះជាម្ចាស់ដាក់ទំនាយឲ្យសត្រូវរបស់ខ្លួនឆាប់រលាយចេញពីផែនដីនេះ។

ទ្រឹស្តីសាសនា ឬក៏ខ្លឹមនៃការបង្រៀននៃសាសនាក្នុងលោកទាំងអស់ គឺតែងប្រោសសណ្តោសប្រណីដល់មនុស្សលោកទាំងល្អ និងទាំងអាក្រក់ ឬបើអាក្រក់ក៏ប្រោសឲ្យរកមាគ៌ាត្រឹមត្រូវវិញ។ ការស្ថិតក្នុងភាពល្ងង់ខ្លៅ តែងឲ្យទុក្ខទោសចំពោះមនុស្សគ្រប់រូបទាំងអស់ តែការពង្រីកបញ្ញា តែងផ្តល់សេចក្តីល្អដល់មនុស្សគ្រប់រូបទាំងអស់។ ពេលយើងគ្មានរនាំងអវិជ្ជា ឬភាពគ្មានបុគ្គលនិយម យើងនឹងក្លាយទៅជាគ្រីស្ទានល្អ ជាអ្នកជ្វីស ជាមូស្លីមល្អ ជាហិណ្ឌូល្អ និងពុទ្ធសាសនិកល្អ។ តែផ្ទុយទៅវិញ ពេលយើងមានរនាំងអវិជ្ជា ឬភាពជាបុគ្គលនិយម យើងនឹងត្រូវតែប្រែក្លាយទៅជាមនុស្សលោកមិនល្អ ជាគ្រីស្ទានមិនល្អ ជាជ្វីសមិនល្អ ជាមូស្លីមមិនល្អ ជាហិណ្ឌូមិនល្អ ជាពុទ្ធសាសនិកមិនល្អ។

របៀបធ្វើខ្លួនឲ្យទៅជាមនុស្សលោកល្អនេះ គឺពិតជាមានសារៈសំខាន់បំផុត ៕

# ថ្ងៃទី២៧ ខែធ្នូ

ព្រាហ្មណ៍ឥណ្ឌា [ Indian Brahmin ] ពោលថា *"មនុស្សយើងពុំគួរស្មោះត្រង់ពេកទេ ពីព្រោះដើមឈើត្រង់ពេក តែងត្រូវគេកាប់មុន ហើយមនុស្សស្មោះត្រង់ពេក ក៏គង់នឹងត្រូវបានគេកម្ចាត់ចោលមុនដែរ"។*

ថ្ងៃមួយឡៅ ជឺ [ Lao Tzu ] និងសិស្ស [ Disciples ] របស់គាត់បានដើរចូលក្នុងព្រៃ ហើយក៏បានជួបនឹងជាងឈើជាច្រើនកំពុងកាប់ឈើ។ ឡៅ ជឺ បានឃើញដើមឈើមួយមិនត្រូវបានគេកាប់។ បន្ទាប់មកគាត់ក៏ឲ្យសិស្សទៅសួរថា "តើហេតុអ្វីបានជាអ្នកកាប់ឈើមិនកាប់ដើមឈើមួយដើមនោះ"?

អ្នកកាប់ឈើតបថា "ដើមឈើនេះគ្មានប្រយោជន៍ទេ ដោយសារមែករបស់វាប្រសេចប្រសាចពេកហើយម៉្យាងវាមិនត្រង់ត្រង់ល្អទេ"។ ក្រោយមកឡៅ ជឺ ពោលទៅកាន់សិស្សរបស់គាត់ថា "ចូរធ្វើខ្លួនឲ្យដូចជាដើមឈើមួយដើមនេះ ពីព្រោះអ្នកនឹងអាចរស់នៅបានយូរអង្វែង និងអាចសាងប្រយោជន៍យូរអង្វែង បានដោយសារតែអ្នកចេះធ្វើល្ងង់ខ្លះ ឬសម្តែងធ្វើជាមនុស្សគ្មានតម្លៃខ្លះ។ បើអ្នកប្រឹងបង្ហាញថាខ្លួនឆ្លាតពេក ឬមានតម្លៃពេក នោះអ្នកនឹងត្រូវគេប្រើប្រាស់ឥតពេលសម្រាក ឬបើត្រឹមត្រូវពេក អ្នកនឹងត្រូវបានមនុស្សអាក្រក់ធ្វើទុកបុកម្នេញមុនគេ"។

ទ្រឹស្តីខាងលើ គឺជាទ្រឹស្តីបែបយុទ្ធសាស្ត្រ។ ពេលខ្លះមនុស្សយើងត្រូវដឹងថា ពេលណាត្រូវធ្វើចេះ ឬពេលណាត្រូវចេះធ្វើល្ងង់,ពេលណាត្រូវធ្វើល្អពេលណាត្រូវធ្វើអាក្រក់, ពេលណាត្រូវស្មោះត្រង់ ឬពេលណាត្រូវក្រឡិចក្រឡុច ...។ល។ ហើយអ្វីដែលសំខាន់ គឺប្រយោជន៍នៃទង្វើដែល

យើងសម្តែង។ ក្នុងរឿងសាមកុក មានស៊ីម៉ាអ៊ី ម្នាក់ដែលពូកែលាក់សមត្ថភាព៕

"A person should not be too honest. Straight trees are cut first and honest people are screwed first."- Chanakya

# ថ្ងៃទី២៨ ខែធ្នូ

ឡៅ ជឺ [ Lao Tzu ] ពោលថា "អ្នកដំណើរល្អ តែងដើរទៅគ្រប់ទីកន្លែងដោយគ្មានគម្រោងដាក់លាក់ ហើយក៏មិនមានចិត្តចង់ទៅដល់គោលដៅដែរ"។ ជីវិត គឺជាកំណើតមិនពេញលេញ។ មិនពេញលេញដោយសារ មនុស្សកើតមកដោយមិនគ្រប់លក្ខណៈ។ មិនគ្រប់លក្ខណៈមានន័យថា បន្ទាប់ពីកើត គឺយើងត្រូវបន្តដំណើរឲ្យពេញលេញ ឬឲ្យចប់សព្វគ្រប់ ដូចជាត្រូវត្រូវចាស់ ជរា ព្យាធិ និងត្រូវធ្វើកិច្ចការផ្សេងៗដើម្បីឲ្យពេញលេញជាជីវិតរហូតដល់ស្លាប់។

ការរស់នៅក្នុងជីវិត ពេលខ្លះយើងពុំគួរប្រញាប់ពេកទេ ដោយសារគ្រប់យ៉ាងត្រូវការ ពេលវេលាតាមច្បាប់ធម្មជាតិ ពីព្រោះបើប្រញាប់ពេក ដំណើរជីវិតក៏ឆាប់ទៅដល់ ហើយបើឆាប់ទៅដល់ ប្រៀបដូចជាទៅដល់គោលដៅស្លាប់អ៊ីចឹង ។

ពីចំណុចជីវិតមកដល់ចំណុចស្លាប់ គឺជារង្វង់ពេញលេញមួយរបស់ជីវិត៕

*"A good traveler has no fixed plans, and is not intent on arriving."* - Lao Tzu

# ថ្ងៃទី២៩ ខែធ្នូ

ឡៅ ជឺ [ LaoTzu ] ពោលថា *"បុគ្គលដែលគ្មានជំនឿទុកចិត្តលើអ្នកដទៃ ក៏គង់នឹងមិនអាចស្វែងរកភាពស្មោះត្រង់ពីក្នុងខ្លួនអ្នកដទៃបានឡើយ"*។

គ្រប់យ៉ាងដែលមាន គឺដោយសារយើងមើលឃើញ ហើយសំឡេងដែលដែលយើងឮ គឺដោយសារយើងស្ដាប់។ ដូចគ្នាដែរ បើយើងដាក់ចិត្តប្រឹងស្វែងរកសេចក្ដីអាក្រក់ពីក្នុងខ្លួនអ្នកដទៃ យើងក៏នឹងរកឃើញភាពអាក្រក់នោះជាពុំខាន។

ប្រតិទិនទស្សនៈ៣៦៥ថ្ងៃ

ក្នុងជីវិត ពេលខ្លះ យើងសុខចិត្តទុកចិត្តមនុស្សដែលមិនស្មោះត្រង់ពីព្រោះភាពស្មោះត្រង់គឺជាតម្លៃពិតរបស់យើង។ ឡៅ ជឺ ជឿថា គ្រប់យ៉ាងក្នុងលោកកើតឡើងដោយធាតុពីរគឺធាតុយិន [ Yin ] និងធាតុយ៉ាង [ Yang ]។ តើយើងនឹងក្លាយទៅជាមនុស្សស្មោះត្រង់ម្តេចបាន បើគ្មានមនុស្សក្បត់ ហើយយើងនឹងក្លាយទៅជាមនុស្សល្អម្តេចបាន បើគ្មានមនុស្សអាក្រក់៕

*"He who has no faith in others shall find no faith in them."* - Lao Tzu

# ថ្ងៃទី៣០ ខែធ្នូ

ចច អូវែល [ George Orwell ] ពោលថា *"ប្រជាជនដែលបោះឆ្នោតឲ្យអ្នកនយោបាយពុករលួយ មិនហៅថាជនរងគ្រោះទេ តែប្រជាជននឹងត្រូវរងគ្រោះ ដោយសារក្រុមអ្នកនយោបាយដែលសមគំនិតក្នុងបទទុច្ចរិត"*។

ក្នុងស្ថានភាពសង្គមខ្លះ បានបង្ហាញថាអ្នកនយោបាយមានពីរប្រភេទគឺ៖ ១) អ្នកសមគំនិតចូលរួមក្នុងបទទុច្ចរិតជាមួយអ្នកនយោបាយពុករលួយ។ ២) អ្នកនយោបាយថ្លៃថ្នូរដែលជៀលប្រជាជនថាគ្មានតម្លៃ។ អ្នកនយោបាយឲ្យនិយមន័យនយោបាយថា *"ជាសិល្បៈសម្រេចគោលដៅ"* ដោយមិនសំខាន់ថាប្រើវិធីស្មោគគ្រោកបែបណាក៏ដោយ។ នយោបាយមិនមែនជាការស្អប់ ឬការស្រឡាញ់ មិនមែនជាការសងសឹក ឬចងគុំនំ តែវាគឺជាការដោះស្រាយបញ្ហាឲ្យប្រជាជន។ ភាសានយោបាយត្រូវបានអ្នកនយោបាយប្រឹងនិយាយឲ្យដូចការពិត តែការពិតគឺបោកប្រាស់៕

The people that elect corrupt politicians...are not victims...but accomplices. - George Orwell

# ចំណាងជើងសៀវភៅផ្សេងៗដែលខ្ញុំបានអាន

I. ចំណងជើងជាភាសាខ្មែរ

១. ភាពជាអ្នកដឹកនាំ 5 កម្រិត

២. ឪពុកអ្នកមានបង្រៀនធុរជន ត្រៀមខ្លួនធ្វើជាម្ចាស់ធុរកិច្ច

៣. អំណាចនៃអនុសម្បជញ្ញៈ

៤. រនាំងមនុស្សល្ងង់

៥. អ៊ែកគីល វីរបុរសកម្លាំងទេព

៦. I Am Malala

៧. ចរន្តប្រាក់ប្អូនផ្ទែក

៨. សិល្បៈចងមិត្ត បន្ទន់ចិត្តអ្នកដទៃ

៩. តើអ្នកដឹងអ្វីខ្លះ? ភាគ៣

១០. តើអ្នកដឹងអ្វីខ្លះ? ភាគ២

១១. តើអ្នកដឹងអ្វីខ្លះ? ភាគ១

១២. និទានប្រាជ្ញា (រួមភាគ)

១៣. និទានវិញ្ញាណទិព្វ ១&២

១៤. ស្វែងរកចំណុចខ្លាំង

១៥. ច្បាប់អមតៈ 21 មាត្រាសម្រាប់អ្នកដឹកនាំ

១៦. ច្បាប់ចិត្តវិញ្ញាញ 7 ប្រការ ដើម្បីសម្រេចជោគជ័យ

១៧. ត្រឹមតែពូកែមិនគ្រប់គ្រាន់ទេ

១៨. វិធីចៀសវាង 199 ស្ថានការណ៍ ធ្វើឲ្យខាតពេលវេលា

១៩. ការគិត

២០. ធ្វើឲ្យសុបិនក្លាយជាការពិត

២១. អ្នកឡឹកឹបានធ្វើសេដ្ឋី

២២. ដឹមេជិក( The Magic )

២៣. មាគ៌ាបុគ្គលឆ្នើម

២៤. វិធីសាស្ត្រនៃការសម្រេចចិត្ត

២៥. មេរៀនប្រវត្តិសាស្ត្រ នៃភាពចម្រើនរុងរឿង និងរលំរលាយជាតិ

២៦. អភិវឌ្ឍសិល្បៈដឹកនាំក្នុងខ្លួនអ្នក

២៧. យកឈ្នះក្តីទុក្ខ សាងជីវិតស្រស់បំព្រង

២៨. បុរសមកពីឋានព្រះអង្គារ

២៩. ហ្សង់ហ្សាក់ រូស្សូ
៣០. ចំណាត់ការលើអំណាច
៣១. ប្រជុំស្នាដៃឯករបស់សេកស្ពៀរ
៣២. ស្វែងយល់អំពីជំងឺទឹកនោមផ្អែម
៣៣. សំនួនវោហារក្នុងពិភពយុទ្ធគុនចិន
៣៤. វិធីបដិសេធយ៉ាងឆ្លាតវៃ
៣៥. ខុង ជឺ
៣៦. ចោទឆ្លើយចំណោះដឹងអំពីជីវិត
៣៧. គតិបណ្ឌិត ភាពជាអ្នកដឹកនាំ
៣៨. ចោទ-ឆ្លើយ បញ្ហាដួងចិត្ត
៣៩. យុទ្ធវាទការប្រើវោហាជាអាវុធ
៤០. វិធីនិយាយក្នុងចំណោមមហាជន
៤១. សិល្បៈតម្រង់ផ្លូវ ចៅហ្វាយនាយ
៤២. ដឹផៅវ័រ
៤៣. ប្រជុំរឿងជាតក ភាគ១
៤៤. ប្រជុំរឿងជាតក ភាគ២

៤៥. ចោទឆ្លើយ បញ្ហាផ្លូវលោក

៤៦. តម្រាពិជ័យសង្គ្រាម ស៊ុនជឺ

៤៧. កុំចុះចាញ់ខ្លួនឯង នោះអ្នកនឹងមិនចាញ់អ្នកដទៃ

៤៨. ចិត្តសាស្ត្រសាងស្នេហ៍

៤៩. ជឺ ស៊ីក្រេត

៥០. ពិភពរឿងប្លែក ភាគ១

៥១. ពិភពរឿងប្លែក ភាគ២

៥២. មាគ៌ាមហាសេដ្ឋី

៥៣. យល់ឧបាយ ឆ្ងាយអន្ទាក់

៥៤. គិតជ្រៅ ផ្លូវឈ្នះ

៥៥. ៣៦៥ ថេរដីការបស់សម្តេច ដាឡៃឡាម៉ា

៥៦. និទានវិញ្ញាណទិព្វ ភាគ២

៥៧. និទានវិញ្ញាណទិព្វ ភាគ១

៥៨. វាចាមាសពីសេតវិមាន

៥៩. គតិរួមលោក

៦០. ១០០វិធី បំផុសសក្តានុពលមនុស្ស

៦១.	បណ្ដាំកញ្ជ្រោងចាស់

៦២.	បុគ្គលខ្លាំង

៦៣.	ចិត្តវិទ្យាវ័យជំទង់

៦៤.	រយពាន់និទាន

៦៥.	រៀនឲ្យចេះ ប្រើចំណេះ ឲ្យមានប្រយោជន៍

៦៦.	សិល្ប៍វិធីក្នុងការនិយាយ

៦៧.	ចិត្តវិទ្យា ភាពវៃឆ្លាត គំនិតច្នៃប្រឌិត

៦៨.	លោកខាងលិច លោកខាងកើត លោកសកល

៦៩.	អាញស្ដាញ ប្រវត្តិនិងបញ្ញាញាណ

៧០.	អ្នកល្ងង់ អ្នកឆ្លាត អ្នកមានគតិបណ្ឌិត

៧១.	សុភាសិតជោគជ័យ

៧២.	សិល្បៈប្រើបណ្ឌិត

៧៣.	យុទ្ធសាស្ត្រទម្លុះគោលដៅ

៧៤.	និទានរៀនគិត

៧៥.	ប្រាជ្ញាជីវិត ភាគ១

៧៦.	ប្រាជ្ញាជីវិត ភាគ២

៧៧. សម្តីមាសអ្នកដឹកនាំ

៧៨. ចិត្តសាស្រ្តទំនាក់ទំនង

៧៩. គិតឲ្យដូចជើងឯក

៨០. អំណាចសុបិន

៨១. ពង្រីកបញ្ញា

៨២ អ្នកដឹកនាំល្អ

៨៣. ប្រជុំពុទ្ធភាសិត

៨៤. អ្នកអាចឈ្នះ

៨៥. ប្រភពគំនិតផលិតបញ្ញា

៨៦. រឿងនិទានមានប្រាជ្ញា

៨៧. ចាប់គិតផ្តើមមាន

៨៨. ភាពជាអ្នកដឹកនាំ

៨៩. ឈ្នះការរិះគន់

៩០. ផ្លាស់ប្តូរជីវិត

៩១. រស់ដោយកិត្តិយស

៩២. បិតាស្ថាបនិកសិង្ហបុរី លីក្វាន់ យូ

៩៣. អ្នកដឹកនាំក្នុងខ្លួន

៩៤. រស់ដោយប្រាជ្ញា ភាគ១ ដល់ ភាគ៥

៩៥. និទានបែបកំប្លែង

៩៦. អំណាចដួងចិត្ត

៩៧. អំណាចក្នុងខ្លួនមនុស្ស

៩៨. ខ្លឹមសម្ដី

៩៩. ក្លាហាន

## II. ចំណងជើងជាភាសាអង់គ្លេស


1. Anne Rooney, ( 2006 ). Einstein in His Own Words

2. Alice Calaprice, ( 2011 ). The Ultimate Quotable Einstein

3. Thomas J. Mcfarlane, Wes Nisker, ( 2002 ). Einstein and Buddha: The Parallel Sayingsulysses Press, Seastone ( 2002 )

4. Albert Einstein, ( 1998 ). Ideas and Opinions

5. Anne E. Schraff, ( 2008 ). Albert Einstein

6. Don Miguel Ruiz, ( 1997 ). The Four Agreements:

A Practical Guide To Personal Freedom

7. Don Miguel Ruiz, ( 1999 ). The Mastery Of Love: A Practical Guide To The Art Of Relationship

8. Don Miguel Ruiz, ( 2013 ). The Five Levels Of Attachment

9. John C. Maxwell, ( 2009 ). How Successful People Thi nk: Change Your Thinking, Change Your Lifecenter Street

10. John C. Maxwell, ( 2011 ). The 360 [Degree Symbol] Leader: Developing Your Influence from Anywhere In The Organization

11. John C. Maxwell, ( 2008 ). Developing The Leaders Around You

12. John C. Maxwell, ( 2007 ). The 21 Irrefutable Laws Of Leadership

13. Carol Dweck, ( 2007 ). Mindset: The New Psychology Of Success

14. Napoleon Hill, ( 1996 ). Grow Rich: With Peace Of Mind

15. Napoleon Hill, ( 1997 ). Napoleon Hill's Keys To Success: The 17 Principles Of Personal Achievement

16. Napoleon Hill, ( 1937 ). Think And Grow Rich

17. Niccolo Machiavelli, ( 1532 ). The Prince

18. Rhonda Byrne, ( 2012 ). The Magic

19. Rhonda Byrne, ( 2010 ). The Power

20. Rhonda Byrne, (2006). The Secret

21. Robert T. Kiyosaki, (2004). Rich Dad Poor Dad For Teens: The Secrets About Money

22. Robert T. Kiyosaki, (1998). Rich Dad's Cashflow Quadrant: Guide To Financial Freedom

23. Ed Voerman And Fons Trompenaars, (2009). Servant Leadership Across Cultures: Harnessing The Strength Of The World's Most Powerful Leadership Philosophy

24. Leslie Pockell, Adrienne Avila, (2007). The 100 Greatest Leadership Principles Of All Time

25. Susan Cain, (2013). Quiet: The Power of Introverts In A World That Can't Stop Talking

26. Lance B. Kurke, (2004). The Wisdom of Alexander The Great: Enduring Leadership Lessons From The Man Who Created An Empire

27. Sean Covey, (1998). The 7 Habits of Highly Effective Teen

28. Stephen Covey , ( 1989 ). The 7 Habits of Highly Effective People

29. Sidney Walter Finkelstein ( 2014 ). 7 Bad Habits of Uns uccessful People ( Insights From Great Business Minds )

30. Thomas Cleary, ( 2001 ). Wentzu: Understanding The Mysteries

31. Theodora Lau, ( 2009 ). Bestloved Chinese Proverbs

32. Tzu Sun, Von Clausewitz General Carl, Machiavelli Nic colo, Jomini Baron De, ( 2013 ). The Complete Art of War

33. Wilson, ( 2009 ). The Wisdom of Confucius

34. Sheila Melvin, ( 2007 ). The Little Red Book of China Business

35. Ben Dupre, ( 2008 ). 50 Philosophy Ideas You Really Need To Know

36. S. E. Frost, (1962). Basic Teachings of the Great Philosophers

37. Jitendra Nath Mohanty, (2000). Classical Indian Philosophy

38. P. J. Abdul Kalam, (2002). The Guiding Light: A Selection Of Quotations

39. C. Bhaktivedanta Swami Prabhupada, (1968). Bhagavadgita As It Is

40. Anant Pai, (2009). Chanakya

41. Pavan Varma, (2013). Chanakya's New Manifesto To Resolve The Crisis Within India

42. Radhakrishnan Pillai, (2015). Chanakya In You

43. Chaturvedi, B K, (2013). Chanakya Neeti

44. Anne E. Schraff, (2008). Mahatma Gandhi

45. Margaret Chatterjee, (1983). Gandhi□s Religious Thought

46. Anne M. Todd, Martin E. Marty, (2004). Mohandas Gandhi (Spiritual Leaders And Thinkers)

47. Erik Homburger, (1993). Gandhi's Truth: On The Origins of Militant Nonviolence

48. Mahatma Gandhi, Krishna Kripalani, (2013). Gandhi All Men Are Brothers

49. Mahatma Gandhi, (1929). The Story of My Experiments With Truth

50. Glyn Richards, (1995). The Philosophy of Gandhi: A Study Of His Basic Ideas

51. S. Lal, (2015). 50 Magnificent Indians Of The 20Th Century

52. Leo Tolstoy, (1997). A Calendar of Wisdom

53. Osho, (2012). Fear: Understanding And Accepting The Insecurities Of Life

54. Osho, (2004). Freedom: The Courage To Be Yourself

55. Osho, (2015). First In The Morning: 365 Uplifting Moments To Start The Day Consciously

56. Osho, (2004). Intelligence: The Creative Response To Now

57. Osho, (2001). Intuition: Knowing Beyond Logic

58. Osho, (2012). Learning To Silence The Mind: Wellness Through Meditation

59. Osho, (1978). Path of Love: Understanding That Nothing Is Perfect In Life

60. Osho, (2003). The ABC of Enlightenment: A Spiritual Dictionary

61. Osho, (2010). The Book of Secrets: 112 Meditations To Discover The Mystery Within

62. Osho, (2009). The Mustard Seed: The Revolutionary Teachings of Jesus

63. Osho, (2012). Why Is Love So Painful?

64. Tom Butler-Bowdon, (2017). 50 Philosophy Classics: Your shortcut to the most important ideas on being, truth, and meaning (50 Classics)

65. Tom Butler-Bowdon, (2003). 50 Self-Help Classics: 50 Inspirational Books to Transform Your Life from Timeless Sages to Contemporary Gurus (50 Classics)

66. Tom Butler-Bowdon, (2017). 50 Success Classics, Second Edition: Your shortcut to the most important ideas on motivation, achievement, and prosperity (The 50 Classics)

67. William Shakespeare, Jane Armstrong, (1999). The Arden Dictionary of Shakespeare Quotations

68. Robert Andrews, (2004). The New Penguin Dictionary of Modern Quotations

69. Dean Lebaron, Romesh Vaitilingam, (2001). The Ultimate Book of Investment Quotations

70. Andy Zupko, Andy Zubko, (1996). Treasury of Spiritual Wisdom: A Collection of 10,000 Inspirational Quotations

71. Bruce Adamson, ( 2004 ). The Best Things Ever Said In The Dark The Wisest, Wittiest, Most Provocative Quotations From The Movies

72. Buckner F. Melton Jr., ( 2005 ). The Quotable Founding Fathers: A Treasury of 2,500 Wise And Witty Quotations From The Men And Women Who Created America

73. C.C. Gaither, Alma E Cavazos, ( 2003 ). A Dictionary of Quotations On Astronomy, Mathematics And Physics

74. C.C. Gaither, Alma E Cavazos, ( 1996 ). Statistically Speaking: A Dictionary of Quotations

75. C.R.S. Marsden, ( 1988 ). The Dictionary of Outrageous Quotations

76. Catherine Frank, ( 2000 ). Quotations For All Occasions

77. Charles E. Lathrop, ( 2004 ). The Ultimate Source For Quotations On Espionage & Intelligence

78. Dave English, ( 2003 ). The Air Up There More Great Quotations On Flight

79. David B. Frost, Compiled By David B. Frost, (2013). John F. Kennedy In Quotations: A Topical Dictionary, With Sources

80. David Grambs, Ellen S. Levinethe, (2014). Describer's Dictionary: A Treasury of Terms & Literary Quotations

81. David Grambs, (1995). The Describer's Dictionary: A Treasury of Terms & Literary Quotations

82. Don Currie, (2005). Government Chambers Dictionary of Quotations

83. Dr. Norman Vincent Peale, (1993). Positive Thinking Every Day: An Inspiration For Each Day Of The Year

84. Gary Saul Morson, (2011). The Words of Others From Quotations To Culture

85. GeOffrey Parrinder, (2001). The Routledge Dictionary of Religious And Spiritual Quotations

86. Isaac Asimov, Jason A. Shulman, (1990). Isaac Asimov's Book of Science And Nature Quotations

87. James H. Hutson, James H. Hutson, (2005). The Founders On Religion: A Book of Quotations

88. Jeanette Beerin, (2014). Their Own Words Practices of Quotation In Early Medieval History Writing

89. Jeffrey Gitomer, (2004). Little Red Book of Selling: 12.5 Principles of Sales Greatness

90. Johnnie L. Roberts, (2016). The Big Book of Business Quotations Over 1,400 Of The Smartest Things Ever Said About Making Money

91. Jonathan Schell, (2003). The Unconquerable World Power, Nonviolence, And The Will of The People

92. Katherine Karvelas, (1998). Winning With Teamwork Quotations To Inspire The Power Of Teamwork

93. Krieger, Richard Alan, (2002). Civilization's Quotations Life's Ideal

94. Lewis D. Eigen, Jonathan P. Siegel, (1991). The Manager's Book of Quotations

95. Lisa Congdon, ( 2014 ). Whatever You Are, Be A Good One: 100 Inspirational Quotations

96. Mardy Grothe Neverisms, ( 2011 ). A Quotation Lover's Gui de To Things You Should Never Do, Never Say, Or Never Forget

97. Melanie Axellute, ( 2001 ). Quotation Index To Children's Literature

98. Morton Wagman, ( 200 ). Historical Dictionary of Quotations In Cognitive Science

99. Oon Seng Tan, Ee Ling Low, David Hung, ( 2017 ). Lee Kua n Yew's Educational Legacy The Challenges Of Success

100 . Richard A. Branyon, ( 1994 ). Latin Phrases & Quotations

101. Richard A. Branyon, ( 1995 ). Treasury of French Love Poems, Quotations And Proverbs

102. Richard Langworth, (2008). Churchill By Himself: The Definitive Collection Of Quotations

103. Richard Newman, (1998). African American Quotation

104. Robert Bircher, (1998). 101 Reasons Not To Do Anything: A Collection Of Cynical And Defeatist Quotations

105. Ronald Reagan, (2011). Ronald Reagan In Quotations: A Topical Dictionary, With Sources, Of The Presidential Years

106. Katherine Karvelas, (1998). Commitment To Excellence: Quotations That Lift The Spirit Toward Excellence

107. Katherine Karvelas, (1998). The Best of Success Quotations To Illuminate The Journey Of Success

108. Katherine Karvelas, (1998). The Essence of Attitude Quotations For Igniting Positive Attitudes

109. Katherine Karvelas, (1998). The Magic of Motivation Quotations To Empower Your Drive On The Road To Success

110. Tad Tuleja, (1992). Quirky Quotations: More Than 500 Fascinating, Quotable Comments And The Stories Behind

111. The Saint Quotations For All Occasion (2000)

112. Mark Twain, (1998). The Wit And Wisdom Of Mark Twain: A Book Of Quotations

113 . Martin H. Manser, Rosalind Fergusson, David Pickering, (2007). The Facts On File Dictionary of Proverbs

114. David C. Gross, David C., (1997). Gross Dictionary of 1000 Jewish Proverbs

115. Palihawadana, Mahinda Carter, John Ross, (1998). The Dhammapada: The Sayings of The Buddha

116. Gerhard Gschwandtner, (2007). Great Thoughts To Sell By Quotes To Motivate You To Success

117. Uncle John's Colossal Collection of Quotable Quotes (2004)

118 . Peggyanderson, Michaelmckee, (1997). Great Quotes From Great Leaders (Great Quotes Series)

119. Thomas J. Vilord, (2004). 1001 Motivational Quotes For Success

120. Gerald Lieberman, (1987). 3,500 Good Quotes For Speakers

121. K. Kruse, (2014). 365 Best Inspirational Quotes: Daily Motivation For Your Best Year Ever

122. Frederick Apthorp Paley, (1881). A Collection of Smart Say ings And Anecdotes Translated From Greek Prose Writers

123 . John Simpson And Jennifer Speake, (2009). A Dictionary of Proverbs

124 . Nicholas Rescher, (2015). A Journey Through Philosophy In 101 Anecdotes

125 . Binnie Tate Wilkin, (2014). A Life In Storytelling Ane cdotes, Stories To Tell, Stories With Movement And Dance, Suggestions For Educators

126 . Bob Phillips, ( 1993 ). A Stupendous Collection of Quo tes, Quips, Epigrams, Witticisms, And Humorous Comments. For Personal Enjoyment And Ready Reference

127. W. Clouston, ( 2007 ). Book of Wise Sayings ( Selected Largely From Eastern Sources )

128. Abhi Sharma, ( 2013 ). The Great Book of Best Quotes Of All Time

129. Change Your Life Publishing, ( 2014 ). Achieve Your Full Potential 1800 Inspirational Quotes That Will Change Your Life

130. Alex Pattakos, Stephen R. Covey, ( 2008 ). Prisoners of Our Thoughts

131. Allen Klein, ( 2001 ). Lift Your Spirits Quote Book

132 . Edward Podsiadlik Iii, ( 2014 ). Anecdotes And Afterthoughts Literature As A Teacher's Curriculum

133. Anonymous, ( 2005 ). Frankly My Dear: The Ultimate Movie Quote

134. Barbara Ann Kipfer, ( 2001 ). 8,789 Words of Wisdom Workman

135. Clifton Fadiman And Andre Bernard, ( 2000 ). Bartlett's Book of Anecdotes

136 . Dale Lumpa, ( 2004 ). Great Quotes For Great Educators

137. Daniel B. Baker, ( 2001 ). Power Quotes Visible

138. David Brucethe Kindest People Who Do Good Deeds Volume 3, 250 Anecdotes ( 2007 )

139 . David Galef, Jun Hashimoto, ( 2012. Japanese Proverbs Wit And Wisdom

140. Dr. Gary Westfahl, Arthur C. Clarke, ( 2005 ). Science Fic tion Quotations From The Inner Mind To The Outer Limits

141. English Proverbs And Sayings ( 1987 )

142. Editions Didier Millet, ( 2012 ). Facts, Figures, Quotes And Anecdotes On Singapore

143. Gomes, Helio, (1996). Quality Quotes

144. Noah Benshea, (1993). Great Jewish Quotes Five Thousand Years of Truth And Humor From The Bible To George Burns

145. Gerhard Gschwandtner, (2007). Great Thoughts To Sell By Quotes To Motivate You To Success

146. Joe Tichio, (2013). Greatest Inspirational Quotes: 365 Days To More Happiness, Success, And Motivation

147. David C. Gross, (1997). Dictionary of 1000 Jewish Proverbs

148. Jerome Agel, (1987). Pearls of Wisdom A Harvest Of Quotations From All Ages

149. John Cook, (1997). The Book of Positive Quotations

150. Jon R. Stone, (2006). Routledge Book of World Proverbs

151. Joseph Solman, (1990). Mozartiana Two Centuries of Notes, Quotes, & Anecdotes

152. Kerry Patterson, Joseph Grenny, Ron Mcmillan, Al Switzler, Stephen R. Covey, (2002). Crucial Conversations Tools For Talking When Stakes Are High

153. Kids Book of Wisdom Quotes From The African American Tradition (1997)

154. Kuan Yew Lee, (2013). The Wit And Wisdom Of Lee Kuan Yew

155. Laozi, Moss Roberts, Laozi, (2001). Dao De Jing: The Book of The Way

156. Mcgrath, James, (2017). The Little Book Of Big Management Wisdom 90 Important Quotes And How To Use Them In Business

157. Narcissism Book of Quotes

158. Paul E. Miller, Phyllis Coledai, (1998). 365 Days of Spiritual Growth

159. John Moore, (2003). Quotations For Martial Artists Hun dreds Of Inspirational Quotes To Motivate And Enlighten The Modern Warrior

160. Diogenes The Cynic, (2012). Sayings And Anecdotes, With Other Popular Moralists

161. Stephen Arnott, (2007). Peculiar Proverbs Weird Words of Wisdom From Around The World

162. Stephen Spector, (2015). May I Quote You On That A Guide To Grammar And Usage

163. Atticus Aristotle, (2012). Success And Happiness Quotes To Motivate Inspire & Live By

164. Tatyana Eckstrand, (2009). The Librarian's Book of Quotes

165. The Art Of Communicating 500 Quotes On How To Communicate With Others (2012)

166. William Martin, (2004). The Best Liberal Quotes Ever: Why The Left Is Right

167. Alan Ken Thomas, (2011). The Business Wisdom of Steve Jobs 250 Quotes From The Innovator Who Changed The World

168. The Change Your Life Quote Book Gramercy (2000)

169. The Complete Idiot's Guide To Great Quotes For All Occasions (2008)

170. The Facts On File Dictionary of Proverbs Checkmark Books (2002)

171 . The Speaker's Sourcebook Quotes, Stories And Anecdotes (1988)

172. Thomas E. Kelly, (1995). Wisdom of One The Ultimate Existentialist Quote Book

173 . Tram Nguyen, (2008). Language Is A Place Of Struggle Great Quotes By People Of Color

174. Winning Words Classic Quotes From The World Of Sports (2008)

175. Wisdom Inspirational Quotes And Quips About The World's Most Celebrated Beverage Tuttle (2009)

176. Wise Words And Quotes Tyndale House Publishers, Inc. (2000)

177. Andrews Mcmeel, (2001). Words of Wisdom Quotes by His Holiness The Dalai Lama

178. Dalai Lama and Victor Chan, (2005). The Wisdom Of Forgiveness: Intimate Conversations And Journeys

179. Hanh, Thich Nhat, (2004). True Love: A Practice for Awakening The Heart

នៅមានសៀវភៅភាសាជាផ្សេងទៀតដែលខ្ញុំពុំបានរៀបរាប់ជូន រួមមានទាំងសៀវភៅបែបទស្សនវិជ្ជា សាសនា នយោបាយ និងច្បាប់ ព្រមទាំងកម្រងពាក្យសម្ដីចេញពី Brilliant Quotes ។ សូមបញ្ជាក់ជូនថា រាល់គំនិតទាំងឡាយដែលមានក្នុងសៀវភៅនេះ គឺជាការដកស្រង់ចេញពីទស្សនៈក្នុងសៀវភៅដែលប្រែសម្រួលជាខេមរភាសាខ្លះ និងភាគច្រើនគឺចេញពីសៀវភៅបរទេស (កម្រងពាក្យសម្ដី - Quote Book)។ សូមឧទ្ទិសគំនិតទាំងអស់ដែលមានក្នុងសៀវភៅនេះដល់លោកអ្នកនិពន្ធខ្មែរទាំងអស់ ទាំងអ្នកចងក្រង រៀបរៀង ប្រែសម្រួល៕

# សៀវភៅ “ប្រតិទិនទស្សនៈ ៣៦៥ថ្ងៃ” នេះ ចែកជូនដោយឥតគិតថ្លៃដល់យុវជនខ្មែរ

**ប្រធានាធិបតីអាមេរិក ចន កេណ្ណឌី [ John F. Kenndy ] និយាយថា**
**“ចូរយើងកុំបន់ស្រន់សុំជីវិតដែលងាយស្រួល**
**តែត្រូវបន់ស្រន់សុំឲ្យខ្លួនឯងក្លាយទៅជាមនុស្សខ្លាំងៗ”**

ទស្សនវិទូចិន ខុង ជឺ [ Confucius ] បានឲ្យនិយមន័យ “មនុស្សខ្លាំង គឺសំដៅដល់បុគ្គលដែលមានគំនិតចាស់ទុំខណៈដែលខ្លួនមានអាយុនៅក្មេងនៅឡើយ។” បញ្ហាជីវិតកើតឡើងលើគ្រប់មនុស្សទាំងអស់ មានមនុស្សខ្លះព្រមទទួលបញ្ហា សុខខ្លះ ទុក្ខខ្លះ ដោះស្រាយបានខ្លះ ដោះស្រាយមិនបានខ្លះ វាជាច្បាប់ធម្មជាតិ។ ដូច្នេះ គួរតែទទួលស្គាល់នូវការផ្លាស់ប្តូររាល់បាតុភូត និងរឿងរ៉ាវជីវិតក្នុងធម្មជាតិ។

មនុស្សខ្លាំង មិនចាំបាច់មានអាវុធអស្ចារ្យ។ មនុស្សខ្លាំង មិនចាំបាច់មានមាឌធំ។ មនុស្សខ្លាំង សុខចិត្តស្រក់ឈាម តែមិនស្រក់ទឹកភ្នែក សុខចិត្តហត់នឿយកាយ តែមិនហត់នឿយចិត្ត។ មនុស្សខ្លាំងនឹងស់នៅក្នុងសភាពខ្លាំងខាងក្នុងចិត្ត មានឆន្ទៈខ្លាំង មិនងាយចុះចាញ់ ទោះបីមេឃរលំភ្នំរលាយចំពោះមុខ ក៏នៅតែមិនព្រឺព្រួចឡើយ។ ជោគជ័យ គ្មានអ្វីគួរឲ្យរីករាយ បើមិនបានជួបឧបសគ្គខ្លះ។ បរាជ័យ ក៏គ្មានអ្វីគួរឲ្យខ្លាច បើយើងនៅតែអាចក្រោកឈរបាន។ ឧបសគ្គតូច ឬធំ ការប្រឹងប្រែងតិច ឬច្រើន បើទោះបីគ្មាននរណាម្នាក់ឃើញតម្លៃ នោះក៏កុំអាក់អន់ស្រពោនចិត្តឡើយ ពីព្រោះមនុស្សខ្លាំងប្រៀបដូចនឹងផ្កាមួយទង បើទោះបីជាគ្មានអ្នកណានិយាយថាក្រអូប តែវាក៏នៅតែក្រអូបក្នុងសភាពធម្មជាតិរបស់ផ្កាជានិច្ច។

គ្រប់យ៉ាងនឹងទៅជាល្អទាំងអស់នៅទីចុងបញ្ចប់ តែបើមិនទាន់ល្អនៅឡើយទេ គឺគ្រាន់តែមានន័យថាមិនទាន់ដល់ទីបញ្ចប់។ សូមឲ្យការប្រឹងប្រែងស្ថិតក្នុងដួងចិត្តមនុស្សទាំងឡាយក្នុងសង្គមខ្មែរ៕

“Do not pray for easy lives. Pray to be stronger men.” – John F. Kennedy

© រក្សាសិទ្ធិគ្រប់បែបយ៉ាង ® ២០១៧